# ព្រះត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៧៤

បាលីប្រែ ៨៩ - ៩០ - ៩១

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# អភិធម្មបិដក

## និង

## បរមត្ថទីបនី អដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## យមកៈ

## តតិយភាគ ~ ចតុត្ថភាគ ~ បញ្ចមភាគ

## ៧៤

## បាលីប្រែ ៨៩~៩០~៩១

*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៧៤
# អភិធម្មបិដក ទាលីប្រែ -៨៩
# យមក តតិយភាគ

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## អនុសយយមកៈ
## អនុស័យ ៧ គឺ

*កាមរាគានុស័យ ១ បដិឃានុស័យ ១ មានានុស័យ ១ ទិដ្ឋានុស័យ ១ វិចិកិច្ឆានុស័យ ១ ភវរាគានុស័យ ១ អវិជ្ជានុស័យ ១ ។*

*[ ១ ] ( សួរ ) កាមរាគានុស័យ ដេកសម្ងំនៅ ( គឺកើត ) ក្នុងទីណា ។ ( ឆ្លើយ ) កាមរាគានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរនុ៎ះ ( គឺសុខ-វេទនា ១ ឧបេក្ខាវេទនា ១ ) ក្នុងកាមធាតុ ។ បដិឃានុស័យ ដេកសម្ងំនៅ ក្នុងទីណា ។ បដិឃានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានុ៎ះ ។ មានានុស័យ ដេកសម្ងំនៅ ក្នុងទីណា ។ មានានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរនុ៎ះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ ។ ទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទីណា ។ ទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងពួកធម៌ ដែលរាប់បញ្ចូល ក្នុងសក្កាយទាំងអស់នុ៎ះ ។ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីណា ។ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងពួកធម៌ ដែលរាប់បញ្ចូលក្នុងសក្កាយទាំងអស់នុ៎ះ ។ ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា ។ ភវរាគានុស័យ*

ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនុ៎ះ ។ អវិជ្ជានុស័យ ដេកសម្ងំនៅក្នុងទីណា ។ អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងពួកធម៌ ដែលរាប់បញ្ចូលក្នុងសក្កាយទាំងអស់នុ៎ះ ។

## អនុសយវារៈ

[ ២ ] កាមរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ( គឺកើតមាន ) បដិឃានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត បដិឃានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ កាមរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ កាមរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ មានានុស័យរបស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត មានានុស័យរបស់បុគ្គលណា ដេកសម្ងំនៅ កាមរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ មានានុស័យ របស់អនាគាមិបុគ្គល ដេកសម្ងំនៅ ឯកាមរាគានុស័យ របស់អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅទេ មានានុស័យរបស់បុគ្គល ៣ ពួក ( គឺបុថុជ្ជន ១ សោតាបន្នបុគ្គល ១ សកទាគាមិបុគ្គល ១ ) ដេកសម្ងំនៅ ទាំងកាមរាគានុស័យក៏ដេកសម្ងំនៅដែរ ។ កាមរាគានុស័យរបស់បុគ្គលណា ដេកសម្ងំនៅ ទិដ្ឋានុស័យរបស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ កាមរាគានុស័យរបស់បុគ្គលពីរពួក ( គឺសោតាបន្នបុគ្គល ១ សកទាគាមិបុគ្គល ១ ) ដេកសម្ងំនៅ ឯទិដ្ឋានុស័យរបស់បុគ្គលពីរពួកនោះ មិនដេកសម្ងំនៅទេ កាមរាគានុស័យរបស់បុថុជ្ជន ដេកសម្ងំនៅ ទាំងទិដ្ឋានុស័យ ក៏ដេកសម្ងំនៅដែរ ។ មួយ

យ៉ាងទៀត ទិដ្ឋានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ កាមរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ កាមរាគានុស័យរបស់បុគ្គលណា ដេកសម្ងំនៅ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ កាមរាគានុស័យ របស់បុគ្គលពីរពួក ដេកសម្ងំនៅ ឯវិចិកិច្ឆានុស័យ របស់បុគ្គលពីរពួកនោះ មិនដេកសម្ងំនៅទេ កាមរាគានុស័យ របស់បុថុជ្ជន ដេកសម្ងំនៅ ទាំងវិចិកិច្ឆានុស័យ ក៏ដេកសម្ងំនៅដែរ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ កាមរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ កាមរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ភវរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ភវរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ កាមរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ ភវរាគានុស័យ របស់អនាគាមិបុគ្គល ដេកសម្ងំនៅ ឯកាមរាគានុស័យ របស់អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅទេ ភវរាគានុស័យ របស់បុគ្គល ៣ ពួក ដេកសម្ងំនៅ ទាំងកាមរាគានុស័យ ក៏ដេកសម្ងំនៅដែរ ។ កាមរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ កាមរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អវិជ្ជានុស័យ របស់អនាគាមិបុគ្គល ដេកសម្ងំនៅ ឯកាមរាគានុស័យ របស់អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅទេ អវិជ្ជានុស័យ របស់បុគ្គល ៣ ពួក ដេកសម្ងំនៅ ទាំងកាមរាគានុស័យ ក៏ដេក

សម្ងំនៅដែរ ។

[ ៣ ] បដិឃានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ មានានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត មានានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ បដិឃានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ មានានុស័យ របស់អនាគាមិបុគ្គល ដេកសម្ងំនៅ ឯបដិឃានុស័យ របស់អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅទេ មានានុស័យ របស់បុគ្គល ៣ ពួក ដេកសម្ងំនៅ ទាំងបដិឃានុស័យ ក៏ដេកសម្ងំនៅដែរ បដិឃានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ទិដ្ឋានុស័យ ។បេ។ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ បដិឃានុស័យ របស់បុគ្គលពីរពួក ដេកសម្ងំនៅ ឯវិចិកិច្ឆានុស័យ របស់បុគ្គលពីរពួកនោះ មិនដេកសម្ងំនៅទេ បដិឃានុស័យ របស់បុថុជ្ជន ដេកសម្ងំនៅ ទាំងវិចិកិច្ឆានុស័យ ក៏ដេកសម្ងំនៅដែរ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ បដិឃានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ បដិឃានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ភវរាគានុស័យ ។បេ។ អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ បដិឃានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អវិជ្ជានុស័យ របស់អនាគាមិបុគ្គល ដេកសម្ងំនៅ ឯបដិឃានុស័យ របស់អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅទេ អវិជ្ជានុស័យ របស់បុគ្គល ៣ ពួក ដេកសម្ងំនៅ ទាំងបដិឃានុស័យ ក៏ដេកសម្ងំនៅដែរ ។

[ ៤ ] មានានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ទិដ្ឋានុស័យ ។បេ។ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ មានានុស័យ របស់បុគ្គល ៣ ពួក ដេកសម្ងំនៅ ឯវិចិកិច្ឆានុស័យ របស់បុគ្គល ៣ ពួកនោះ មិនដេកសម្ងំនៅទេ មានានុស័យ របស់បុថុជ្ជន ដេកសម្ងំនៅ ទាំងវិចិកិច្ឆា-នុស័យ ក៏ដេកសម្ងំនៅដែរ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ មានានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មានានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ភវរាគានុស័យ ។បេ។ អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ មានានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។

[ ៥ ] ទិដ្ឋានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត វិចិកិច្ឆា-នុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ទិដ្ឋានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ ទិដ្ឋានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ភវរា-គានុស័យ ។បេ។ អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ទិដ្ឋានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អវិជ្ជានុស័យ របស់បុគ្គល ៣ ពួក ដេកសម្ងំនៅ ឯទិដ្ឋានុស័យ របស់បុគ្គល ៣ ពួកនោះ មិនដេកសម្ងំនៅទេ អវិជ្ជានុស័យ របស់បុថុជ្ជន ដេកសម្ងំនៅ ទាំងទិដ្ឋានុស័យ ក៏ដេកសម្ងំនៅ

ដែរ ។

[ ៦ ] វិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ កវរាគានុស័យ ។បេ។ អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អវិជ្ជានុស័យ របស់បុគ្គល ៣ ពួក ដេកសម្ងំនៅ តែវិចិកិច្ឆានុស័យ របស់បុគ្គល ៣ ពួកនោះ មិនដេកសម្ងំនៅទេ អវិជ្ជានុស័យ របស់បុថុជ្ជន ដេកសម្ងំនៅ ទាំងវិចិកិច្ឆានុស័យ ក៏ដេកសម្ងំនៅដែរ ។

[ ៧ ] កវរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ កវរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។

[ ៨ ] កាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ មានានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត មានានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ កាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ មានានុស័យ របស់អនាគាមិបុគ្គល ដេកសម្ងំនៅ តែកាមរាគានុស័យ និងបដិឃានុស័យ របស់អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅទេ មានានុស័យ របស់បុគ្គល ៣ ពួក ដេកសម្ងំនៅ ទាំងកាមរាគានុស័យ និងបដិឃានុស័យ ក៏ដេកសម្ងំនៅ

ដែរ ។ កាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ទិដ្ឋានុស័យ ។បេ។ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ កាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលពីរពួក ដេកសម្ងំនៅ តែ វិចិកិច្ឆានុស័យ របស់បុគ្គលពីរពួកនោះ មិនដេកសម្ងំនៅទេ កាមរាគានុស័យ និងបដិឃានុស័យ របស់បុថុជ្ជន ដេកសម្ងំនៅ ទាំងវិចិកិច្ឆានុស័យ ក៏ដេក សម្ងំនៅដែរ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំ នៅ កាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរ ឬ ។ អើ ។ កាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលណា ដេកសម្ងំ នៅ ភវរាគានុស័យ ។បេ។ អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរ ឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ កាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អវិជ្ជានុស័យ របស់អនាគាមិបុគ្គល ដេកសម្ងំនៅ តែកាមរាគានុស័យ និង បដិឃានុស័យ របស់អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅទេ អវិជ្ជានុស័យ របស់បុគ្គល ៣ ពួក ដេកសម្ងំនៅ ទាំងកាមរាគានុស័យ និងបដិឃានុស័យ ក៏ដេកសម្ងំនៅដែរ ។

[ ៩ ] កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ របស់បុគ្គល ណា ដេកសម្ងំនៅ ទិដ្ឋានុស័យ ។បេ។ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេក សម្ងំនៅដែរឬ ។ កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ របស់ បុគ្គលពីរពួក ដេកសម្ងំនៅ តែវិចិកិច្ឆានុស័យ របស់បុគ្គលពីរពួកនោះ មិន

ដេកសម្ងំនៅទេ កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ របស់បុថុជ្ជន ដេកសម្ងំនៅ ទាំងវិចិកិច្ឆានុស័យ ក៏ដេកសម្ងំនៅដែរ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ភវរាគានុស័យ ។បេ។ អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អវិជ្ជានុស័យ និងមានានុស័យ របស់អនាគាមិបុគ្គល ដេកសម្ងំនៅ តែកាមរាគានុស័យ និងបដិឃានុស័យ របស់អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅទេ អវិជ្ជានុស័យ របស់បុគ្គល ៣ ពួក ដេកសម្ងំនៅ ទាំងកាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ ក៏ដេកសម្ងំនៅដែរ ។

[ ១០ ] កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ភវរាគានុស័យ ។បេ។ អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។

អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ កាម-
រាគានុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ របស់បុគ្គលនោះ
ដេកសម្ងំនៅដែរឬ ។ អវិជ្ជានុស័យ និងមានានុស័យ របស់អនាគាមិបុគ្គល
ដេកសម្ងំនៅ តែកាមរាគានុស័យ បដិឃានុស័យ និងទិដ្ឋានុស័យ របស់
អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅទេ អវិជ្ជានុស័យ កាមរាគានុស័យ
បដិឃានុស័យ និងមានានុស័យ របស់បុគ្គលពីរពួក ដេកសម្ងំនៅ តែទិដ្ឋា-
នុស័យ របស់បុគ្គលពីរពួកនោះ មិនដេកសម្ងំនៅទេ អវិជ្ជានុស័យ របស់
បុថុជ្ជន ដេកសម្ងំនៅ ទាំងកាមរាគានុស័យ បដិឃានុស័យ មានានុស័យ
និងទិដ្ឋានុស័យ ក៏ដេកសម្ងំនៅដែរ ។

[ ១១ ] កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ
និងវិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ភវរាគានុស័យ ។បេ។
អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត
អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ កាមរាគានុស័យ បដិឃានុស័យ
មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំ
នៅដែរឬ ។ អវិជ្ជានុស័យ និងមានានុស័យ របស់អនាគាមិបុគ្គល ដេកសម្ងំ
នៅ តែកាមរាគានុស័យ បដិឃានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់
អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅទេ អវិជ្ជានុស័យ កាមរាគានុស័យ
បដិឃានុស័យ និងមានានុស័យ របស់បុគ្គលពីរពួក ដេកសម្ងំនៅ តែទិដ្ឋា-
នុស័យ និងវិចិកិច្ឆានុស័យ របស់បុគ្គលពីរពួកនោះ មិនដេកសម្ងំនៅទេ

អវិជ្ជានុស័យ របស់បុថុជ្ជន ដេកសម្ងំនៅ ទាំងកាមរាគានុស័យ បដិឃា-
នុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក៏ដេកសម្ងំនៅដែរ ។

[ ១២ ] កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ
វិចិកិច្ឆានុស័យ និងភវរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ អវិជ្ជា-
នុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត
អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ កាមរាគានុស័យ បដិឃានុស័យ
មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យ របស់បុគ្គល
នោះ ដេកសម្ងំនៅដែរឬ ។ អវិជ្ជានុស័យ មានានុស័យ និងភវរាគានុស័យ
របស់អនាគាមិបុគ្គល ដេកសម្ងំនៅ តែកាមរាគានុស័យ បដិឃានុស័យ ទិដ្ឋា-
នុស័យ និងវិចិកិច្ឆានុស័យ របស់អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅទេ
អវិជ្ជានុស័យ កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងភវរាគា-
នុស័យ របស់បុគ្គលពីរពួក ដេកសម្ងំនៅ តែទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ
របស់បុគ្គលពីរពួកនោះ មិនដេកសម្ងំនៅទេ អវិជ្ជានុស័យ របស់បុថុជ្ជន ដេក
សម្ងំនៅ ទាំងកាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ
វិចិកិច្ឆានុស័យ និងភវរាគានុស័យ ក៏ដេកសម្ងំនៅដែរ ។

[ ១៣ ] កាមរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា បដិឃានុស័យ
ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត បដិឃានុស័យ
ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។
មិនមែនទេ ។ កាមរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា មានានុស័យ ដេក

សម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត មានានុស័យ ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មានានុស័យ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុទុំះ តែកាមរាគានុស័យ មិនដេកសម្ងំនៅ ក្នុងទីនោះទេ មានានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរទុំះ ក្នុងកាមធាតុ ទាំងកាមរាគានុស័យ ក៏ដេកសម្ងំនៅដែរ ។ កាមរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា ទិដ្ឋានុស័យ ។បេ។ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនាទុំះ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែកាមរាគានុស័យ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរទុំះ ក្នុងកាមធាតុ ទាំងកាមរាគានុស័យ ក៏ដេកសម្ងំនៅដែរ ។ កាមរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ កាមរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនាទុំះ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែកាមរាគានុស័យ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងវេទនា

ពីរនុ៎ះ ក្នុងកាមធាតុ ទាំងកាមរាគានុស័យ ក៏ដេកសម្ងំនៅដែរ ។

[ ១៤ ] បដិឃានុស័យ ដេកសម្ងំនៅ ក្នុងទីណា មានានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត មានានុស័យ ដេកសម្ងំនៅ ក្នុងទីណា បដិឃានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ បដិឃានុស័យ ដេកសម្ងំនៅ ក្នុងទីណា ទិដ្ឋានុស័យ ។បេ។ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីណា បដិឃានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរនុ៎ះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានុ៎ះ ទាំងបដិឃានុស័យ ក៏ដេកសម្ងំនៅដែរ ។ បដិឃានុស័យ ដេកសម្ងំនៅ ក្នុងទីណា ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា បដិឃានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ បដិឃានុស័យ ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីណា បដិឃានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរនុ៎ះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានុ៎ះ ទាំងបដិឃានុស័យ ក៏ដេក

សម្ងំនៅដែរ ។

[ ១៥ ] មានានុស័យ ដេកសម្ងំនៅ ក្នុងទីណា ទិដ្ឋានុស័យ ។បេ។ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីណា មានានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនាទុំះ តែមានានុស័យ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរទុំះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ ទាំងមានានុស័យ ក៏ដេកសម្ងំនៅដែរ ។ មានានុស័យ ដេកសម្ងំនៅ ក្នុងទីណា ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មានានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរទុំះ ក្នុងកាមធាតុ តែភវរាគានុស័យ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ មានានុស័យ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុទុំះ ទាំងភវរាគានុស័យ ក៏ដេកសម្ងំនៅដែរ ។ មួយយ៉ាងទៀត ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា មានានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មានានុស័យ ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីណា មានានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនាទុំះ តែមានានុស័យ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរទុំះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ ទាំងមានានុស័យ ក៏ដេកសម្ងំនៅដែរ ។

[ ១៦ ] ទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទីណា វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីណា ទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ ទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទីណា ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ ទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងវេទនា ៣ នុ៎ះ ក្នុងកាមធាតុ តែភវរាគានុស័យ មិនដេកសម្ងំនៅ ក្នុងវេទនា ៣ នោះទេ ទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ ទាំងភវរាគានុស័យ ក៏ដេកសម្ងំនៅដែរ ។ មួយយ៉ាងទៀត ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា ទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ ទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីណា ទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។

[ ១៧ ] វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីណា ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងវេទនា ៣ នុ៎ះ ក្នុងកាមធាតុ តែភវរាគានុស័យ មិនដេកសម្ងំនៅ ក្នុងវេទនា ៣ នោះទេ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនុ៎ះ ទាំងភវរាគានុស័យ ក៏ដេកសម្ងំនៅដែរ ។ មួយយ៉ាងទៀត ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរ

ឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីណា វិចិកិច្ឆា-
នុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។

[ ១៨ ] ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ ដេក
សម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ ដេកសម្ងំ
នៅ ក្នុងទីណា ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អវិជ្ជានុស័យ
ដេកសម្ងំនៅ ក្នុងវេទនា ៣ នុ៎ះ ក្នុងកាមធាតុ តែភវរាគានុស័យ មិនដេក
សម្ងំនៅ ក្នុងវេទនា ៣ នោះទេ ។ អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងរូបធាតុ
និងក្នុងអរូបធាតុនុ៎ះ ទាំងភវរាគានុស័យ ក៏ដេកសម្ងំនៅដែរ ។

[ ១៩ ] កាមរាគានុស័យ និងបដិឃានុស័យ ដេកសម្ងំនៅ ក្នុងទីណា
មានានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ មួយយ៉ាង
ទៀត មានានុស័យ ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ និងបដិឃា-
នុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មានានុស័យ ដេកសម្ងំនៅ ក្នុង
រូបធាតុ និងក្នុងអរូបធាតុនុ៎ះ តែកាមរាគានុស័យ និងបដិឃានុស័យ មិនដេក
សម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ មានានុស័យ និងកាមរាគា-
នុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរនុ៎ះ ក្នុងកាមធាតុ តែបដិឃានុស័យ មិន
ដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ បដិឃានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនា
នុ៎ះ តែកាមរាគានុស័យ និងមានានុស័យ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនា
នោះទេ ។ កាមរាគានុស័យ និងបដិឃានុស័យ ដេកសម្ងំនៅ ក្នុងទីណា
ទិដ្ឋានុស័យ ។បេ។ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែន

ទេ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីណា កាមរាគា-
នុស័យ និងបដិឃានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ វិចិកិច្ឆានុស័យ
ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនុ៎ះ តែកាមរាគានុស័យ និងបដិ-
ឃានុស័យ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ វិចិកិច្ឆា-
នុស័យ និងកាមរាគានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរនុ៎ះ ក្នុងកាមធាតុ
តែបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ វិចិកិច្ឆានុស័យ និង
បដិឃានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានុ៎ះ ឯកាមរាគានុស័យ មិនដេក
សម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។ កាមរាគានុស័យ និងបដិឃានុស័យ ដេក
សម្ងំនៅ ក្នុងទីណា ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិន
មានទេ ។ មួយយ៉ាងទៀត ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា កាមរា-
គានុស័យ និងបដិឃានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។
កាមរាគានុស័យ និងបដិឃានុស័យ ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ
ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ
ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ និងបដិឃានុស័យ ដេកសម្ងំនៅ
ក្នុងទីនោះដែរឬ ។ អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុ
នុ៎ះ តែកាមរាគានុស័យ និងបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និង
ក្នុងអរូបធាតុនោះទេ អវិជ្ជានុស័យ និងកាមរាគានុស័យ ដេកសម្ងំនៅ ក្នុង
វេទនាពីរនុ៎ះ ក្នុងកាមធាតុ តែបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងវេទនាពីរ
នោះទេ អវិជ្ជានុស័យ និងបដិឃានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានុ៎ះ តែ

កាមរាគានុស័យ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។

[ ២០ ] កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ ដេកសម្ងំនៅ ក្នុងទីណា ទិដ្ឋានុស័យ ។បេ។ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ វិចិកិច្ឆានុស័យ និងមានានុស័យ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុទាំង តែកាមរាគានុស័យ និងបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ វិចិកិច្ឆានុស័យ កាមរាគានុស័យ និងមានានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ វិចិកិច្ឆានុស័យ និងបដិឃានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនាទាំង តែកាមរាគានុស័យ និងមានានុស័យ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។ កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ ដេកសម្ងំនៅ ក្នុងទីណា ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ ភវរាគានុស័យ និងមានានុស័យ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុទាំង តែកាមរាគានុស័យ និងបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ កាមរាគានុស័យ និងមានានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរទាំង ក្នុងកាមធាតុ តែភវរាគានុស័យ និងបដិឃានុស័យ

មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ បដិឃានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនាទុំះ តែកវាគានុស័យ កាមរាគានុស័យ និងមានានុស័យ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។ កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អវិជ្ជានុស័យ និងមានានុស័យ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុទុំះ តែកាមរាគានុស័យ និងបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ អវិជ្ជានុស័យ កាមរាគានុស័យ និងមានានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរទុំះ ក្នុងកាមធាតុ តែបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យ និងបដិឃានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនាទុំះ តែកាមរាគានុស័យ និងមានានុស័យ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។

[ ២១ ] កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទីណា វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ វិចិកិច្ឆានុស័យ មានានុស័យ និងទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុទុំះ តែកាមរាគានុស័យ និងបដិឃានុស័យ

មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ វិចិកិច្ឆានុស័យ កាម-
រាគានុស័យ មានានុស័យ និងទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរនុ៎ះ ក្នុង
កាមធាតុ តែបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ វិចិកិច្ឆា-
នុស័យ បដិឃានុស័យ និងទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានុ៎ះ តែ
កាមរាគានុស័យ និងមានានុស័យ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។
កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ ដេកសម្ងំនៅ
ក្នុងទីណា ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។
មួយយ៉ាងទៀត ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ
បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។
ភវរាគានុស័យ មានានុស័យ និងទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងរូបធាតុ និង
ក្នុងអរូបធាតុនុ៎ះ តែកាមរាគានុស័យ និងបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុង
រូបធាតុ និងក្នុងអរូបធាតុនោះទេ កាមរាគានុស័យ មានានុស័យ និងទិដ្ឋា-
នុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរនុ៎ះ ក្នុងកាមធាតុ តែភវរាគានុស័យ និង
បដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ បដិឃានុស័យ និង
ទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានុ៎ះ តែភវរាគានុស័យ កាមរាគា-
នុស័យ និងមានានុស័យ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ កាមរាគា-
នុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទី
ណា អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយ
យ៉ាងទៀត អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ បដិឃា-

នុស័យ មានានុស័យ និងទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អវិជ្ជានុស័យ មានានុស័យ និងទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុទុំះ តែកាមរាគានុស័យ និងបដិឃានុស័យ មិនដេកសម្ងំនៅក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ អវិជ្ជានុស័យ កាមរាគានុស័យ មានានុស័យ និងទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរទុំះ ក្នុងកាមធាតុ តែបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យ បដិឃានុស័យ និងទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនាទុំះ តែកាមរាគានុស័យ និងមានានុស័យ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។

[ ២២ ] កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីណា ភវរាគានុស័យ ដេកសម្ងំនៅក្នុងទីនោះដែរឬ។ មិនមានទេ ។ មួយយ៉ាងទៀត ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ ភវរាគានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុទុំះ តែកាមរាគានុស័យ និងបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ កាមរាគានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរទុំះ ក្នុងកាមធាតុ តែភវរាគានុស័យ និងបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ បដិឃានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនាទុំះ តែ

ភវរាគានុស័យ កាមរាគានុស័យ និងមានានុស័យ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។ កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អវិជ្ជានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនុ៎ះ តែកាមរាគានុស័យ និងបដិឃានុស័យ មិនដេកសម្ងំនៅក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ អវិជ្ជានុស័យ កាមរាគានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរនុ៎ះ ក្នុងកាមធាតុ តែបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យ បដិឃានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានុ៎ះ តែកាមរាគានុស័យ និងមានានុស័យ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។

[ ២៣ ] កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យ ដេកសម្ងំនៅ ក្នុងទី

នោះដែរឬ ។ អវិជ្ជានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និង ភវរាគានុស័យ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុទាំងនុ៎ះ តែកាមរាគានុស័យ និងបដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ អវិជ្ជានុស័យ កាមរាគានុស័យ មានានុស័យ ទិដ្ឋានុស័យ និង វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងវេទនាពីរនុ៎ះ ក្នុងកាមធាតុ តែបដិឃានុស័យ និងភវរាគានុស័យ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យ បដិឃានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានុ៎ះ តែកាមរាគានុស័យ មានានុស័យ និងភវរាគានុស័យ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។

[ ២៤ ] កាមរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា បដិឃានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត បដិឃានុស័យ របស់បុគ្គលណា ដេកសម្ងំនៅក្នុងទីណា កាមរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ កាមរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា មានានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត មានានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មានានុស័យ របស់អនាគាមិបុគ្គលនោះ ដេកសម្ងំនៅ ក្នុងវេទនាពីរ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគានុស័យ របស់អនាគាមិបុគ្គល

នោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ មានានុស័យ របស់បុគ្គល ៣ ពួកនោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគានុ-ស័យ របស់បុគ្គល ៣ ពួកនោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុង អរូបធាតុនោះទេ មានានុស័យ របស់បុគ្គល ៣ ពួកនោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរ ក្នុងកាមធាតុ ទាំងកាមរាគានុស័យ ក៏ដេកសម្ងំនៅដែរ ។ កាម-រាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា ទិដ្ឋានុស័យ ។បេ។ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ កាម-រាគានុស័យ របស់បុគ្គលពីរពួកនោះ ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុង កាមធាតុ តែវិចិកិច្ឆានុស័យ របស់បុគ្គលពីរពួកនោះ មិនដេកសម្ងំនៅ ក្នុង វេទនាពីរនោះទេ កាមរាគានុស័យ របស់បុថុជ្ជននោះ ដេកសម្ងំនៅ ក្នុង វេទនាពីរនោះ ក្នុងកាមធាតុ ទាំងវិចិកិច្ឆានុស័យ ក៏ដេកសម្ងំនៅដែរ ។ មួយ យ៉ាងទៀត វិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ វិចិកិច្ឆា-នុស័យ របស់បុថុជ្ជននោះ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ ក្នុងរូបធាតុ និង ក្នុងអរូបធាតុ តែកាមរាគានុស័យ របស់បុថុជ្ជននោះ មិនដេកសម្ងំនៅ ក្នុង ទុក្ខវេទនានោះទេ វិចិកិច្ឆានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុង វេទនាពីរនោះ ក្នុងកាមធាតុ ទាំងកាមរាគានុស័យ ក៏ដេកសម្ងំនៅដែរ ។ កាមរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា ភវរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ មួយ

យ៉ាងទៀត ភវរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា កាម-រាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ កាមរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អវិជ្ជានុស័យ របស់អនាគាមិបុគ្គលនោះ ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែកាមរាគានុស័យ របស់អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យ របស់បុគ្គល ៣ ពួកនោះ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែកាមរាគានុស័យ របស់បុគ្គល ៣ ពួកនោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ អវិជ្ជានុស័យ របស់បុគ្គល ៣ ពួកនោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ទាំងកាមរាគានុស័យ ក៏ដេកសម្ងំនៅដែរ ។

[ ២៥ ] បដិឃានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា មានានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត មានានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា បដិឃានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ បដិឃានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា ទិដ្ឋានុស័យ ។បេ។ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះ

ដែរឬ ។ បដិឃានុស័យ របស់បុគ្គលពីរពួកនោះ ដេកសម្ងំនៅ ក្នុងទុក្ខ-វេទនានោះ តែវិចិកិច្ឆានុស័យ របស់បុគ្គលពីរពួកនោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ បដិឃានុស័យ របស់បុថុជ្ជននោះ ដេកសម្ងំនៅ ក្នុងទុក្ខ-វេទនានោះ ទាំងវិចិកិច្ឆានុស័យ ក៏ដេកសម្ងំនៅដែរ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា បដិឃានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ វិចិកិច្ឆានុស័យ របស់បុថុជ្ជននោះ ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែបដិឃានុស័យ របស់បុថុជ្ជននោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ វិចិកិច្ឆានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ ទាំងបដិឃានុស័យ ក៏ដេកសម្ងំនៅដែរ ។ បដិឃានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា ភវរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរ ។ មិនមែនទេ ។ មួយយ៉ាងទៀត ភវរាគា-នុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា បដិឃានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ បដិឃានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា បដិឃានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅក្នុង ទីនោះដែរឬ ។ អវិជ្ជានុស័យ របស់អនាគាមិបុគ្គលនោះ ដេកសម្ងំនៅ ក្នុងវេទនា ៣ នោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ

*តែបដិឃានុស័យ របស់អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងវេទនា ៣ នោះទេ អវិជ្ជានុស័យ របស់បុគ្គល ៣ ពួកនោះ ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែបដិឃានុស័យ របស់បុគ្គល ៣ ពួកនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជា-នុស័យ របស់បុគ្គល ៣ ពួកនោះឯង ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ ទាំងបដិឃានុស័យ ក៏ដេកសម្ងំនៅដែរ ។*

*[ ២៦ ] មានានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា ទិដ្ឋា-នុស័យ ។បេ។ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មានានុស័យ របស់បុគ្គល ៣ ពួកនោះ ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែវិចិកិច្ឆានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ មានានុស័យរបស់បុថុជ្ជននោះ ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ ទាំងវិចិកិច្ឆានុស័យ ក៏ដេកសម្ងំនៅដែរ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា មានានុស័យរបស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ វិចិកិច្ឆានុស័យ របស់បុថុជ្ជននោះ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែមានានុស័យ របស់បុថុជ្ជននោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ វិចិកិច្ឆានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ ទាំងមានានុស័យ ក៏ដេកសម្ងំនៅដែរ ។ មានានុស័យ របស់បុគ្គលណា*

ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មានានុស័យ របស់បុគ្គល ៤ ពួកនោះ ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែកាមរាគានុស័យ របស់បុគ្គល ៤ ពួកនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ មានានុស័យ របស់បុគ្គល ៤ ពួកនោះឯង ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ ទាំងកាមរាគានុស័យ ក៏ដេកសម្ងំនៅដែរ ។ មួយយ៉ាងទៀត កាមរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា មានានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មានានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា មានានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អវិជ្ជានុស័យ របស់បុគ្គល ៤ ពួកនោះ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែមានានុស័យ របស់បុគ្គល ៤ ពួកនោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ អវិជ្ជានុស័យរបស់បុគ្គល ៤ ពួកនោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ ទាំងមានានុស័យ ក៏ដេកសម្ងំនៅដែរ ។

[ ២៧ ] ទិដ្ឋានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា

ទិដ្ឋានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។បេ។

[ ២៨ ] វិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា ភវរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ វិចិកិច្ឆា-នុស័យ របស់បុថុជ្ជននោះ ដេកសម្ងំនៅ ក្នុងវេទនា ៣ នោះ ក្នុងកាមធាតុ តែភវរាគានុស័យ របស់បុថុជ្ជននោះ មិនដេកសម្ងំនៅ ក្នុងវេទនា ៣ នោះទេ វិចិកិច្ឆានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុង អរូបធាតុនោះ ទាំងភវរាគានុស័យ ក៏ដេកសម្ងំនៅដែរ ។ មួយយ៉ាងទៀត ភវរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ ភវរាគានុស័យ របស់ បុគ្គល ៣ ពួកនោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែ វិចិកិច្ឆានុស័យ របស់បុគ្គល ៣ ពួកនោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និង ក្នុងអរូបធាតុនោះទេ ភវរាគានុស័យរបស់បុថុជ្ជននោះ ដេកសម្ងំនៅ ក្នុង រូបធាតុ និងក្នុងអរូបធាតុនោះ ទាំងវិចិកិច្ឆានុស័យ ក៏ដេកសម្ងំនៅដែរ ។ វិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អវិជ្ជានុស័យ របស់ បុគ្គល ៣ ពួកនោះ ដេកសម្ងំនៅ ក្នុងវេទនា ៣ នោះ ក្នុងកាមធាតុ ក្នុង រូបធាតុ និងក្នុងអរូបធាតុ តែវិចិកិច្ឆានុស័យ របស់បុគ្គល ៣ ពួកនោះ មិន

ដេកសម្ងំនៅ ក្នុងវេទនា ៣ នោះទេ អវិជ្ជានុស័យ របស់បុថុជ្ជននោះ ដេកសម្ងំនៅ ក្នុងវេទនា ៣ នោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ ទាំងវិចិកិច្ឆានុស័យ ក៏ដេកសម្ងំនៅដែរ ។

[ ២៩ ] ភវរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា ភវរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អវិជ្ជា-នុស័យ របស់បុគ្គល ៤ ពួកនោះ ដេកសម្ងំនៅ ក្នុងវេទនា ៣ នោះ ក្នុងកាមធាតុ តែភវរាគានុស័យ របស់បុគ្គល ៤ ពួកនោះ មិនដេកសម្ងំនៅ ក្នុងវេទនា ៣ នោះទេ អវិជ្ជានុស័យ របស់បុគ្គលទាំងនោះឯង ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ ទាំងភវរាគានុស័យ ក៏ដេកសម្ងំនៅដែរ ។

[ ៣០ ] កាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា មានានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត មានានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មានានុស័យ របស់អនាគាមិបុគ្គលនោះ ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែកាមរាគានុស័យ និងបដិឃានុស័យ របស់អនាគាមិបុគ្គលនោះ

មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ មានានុស័យ របស់បុគ្គល ៣ ពួក នោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គល ៣ ពួកនោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ មានានុស័យ និងកាមរាគានុស័យ របស់បុគ្គលទាំង នោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបដិឃានុស័យ របស់បុគ្គលទាំងនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ ។ កាមរាគា- នុស័យ និងបដិឃានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា ទិដ្ឋា- នុស័យ ។បេ។ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះ ដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ វិចិកិច្ឆានុស័យ របស់បុថុជ្ជននោះ ដេក សម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគានុស័យ និងបដិឃា- នុស័យ របស់បុថុជ្ជននោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុ នោះទេ វិចិកិច្ឆានុស័យ និងកាមរាគានុស័យ របស់បុគ្គលនោះឯង ដេក សម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបដិឃានុស័យ របស់បុគ្គល នោះមិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ វិចិកិច្ឆានុស័យ និងបដិឃានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែកាមរាគានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។ កាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា ភវរាគានុស័យ

របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត ភវរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ កាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អវិជ្ជានុស័យ របស់អនាគាមិបុគ្គលនោះ ដេកសម្ងំនៅ ក្នុងវេទនា ៣ នោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែកាមរាគានុស័យ និងបដិឃានុស័យ របស់អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងវេទនា ៣ នោះទេ អវិជ្ជានុស័យ របស់បុគ្គល ៣ ពួកនោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែកាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គល ៣ ពួកនោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ អវិជ្ជានុស័យ និងកាមរាគានុស័យ របស់បុគ្គលទាំងនោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបដិឃានុស័យ របស់បុគ្គលទាំងនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យ និងបដិឃានុស័យ របស់បុគ្គលទាំងនោះឯង ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែកាមរាគានុស័យ របស់បុគ្គលទាំងនោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។

[ ៣១ ] កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា ទិដ្ឋានុស័យ ។បេ។ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ វិចិកិច្ឆានុស័យ និងមានានុស័យ របស់បុថុជ្ជននោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ វិចិកិច្ឆានុស័យ កាមរាគានុស័យ និងមានានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបដិឃានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ វិចិកិច្ឆានុស័យ និងបដិឃានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែកាមរាគានុស័យ និងមានានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។ កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា ភវរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត ភវរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ របស់បុគ្គលណា ដេក

សម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អវិជ្ជានុស័យ របស់អនាគាមិបុគ្គលនោះ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែកាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ របស់អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ អវិជ្ជានុស័យ និងមានានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែកាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យ និងមានានុស័យ របស់បុគ្គល ៣ ពួកនោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគានុស័យ និងបដិឃានុស័យ របស់បុគ្គលទាំងនោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ អវិជ្ជានុស័យ កាមរាគានុស័យ និងមានានុស័យ របស់បុគ្គលទាំងនោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបដិឃានុស័យ របស់បុគ្គលទាំងនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ ។ អវិជ្ជានុស័យ និងបដិឃានុស័យ របស់បុគ្គលទាំងនោះឯង ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែកាមរាគានុស័យ និងមានានុស័យ របស់បុគ្គលទាំងនោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។

[ ៣២ ] កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ

របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា វិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត វិចិកិច្ឆា-នុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ បដិ-ឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ វិចិកិច្ឆានុស័យ មានានុស័យ និងទិដ្ឋានុស័យ របស់បុថុជ្ជននោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគា-នុស័យ និងបដិឃានុស័យ របស់បុថុជ្ជននោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ វិចិកិច្ឆានុស័យ កាមរាគានុស័យ មានានុស័យ និង ទិដ្ឋានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុង កាមធាតុ តែបដិឃានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងវេទនា ពីរនោះទេ វិចិកិច្ឆានុស័យ បដិឃានុស័យ និងទិដ្ឋានុស័យ របស់បុគ្គលនោះ ឯង ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែកាមរាគានុស័យ និងមានានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។ កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា ភវរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរ ឬ ។ មិនមានទេ ។ មួយយ៉ាងទៀត ភវរាគានុស័យ របស់បុគ្គលណា ដេក សម្ងំនៅ ក្នុងទីណា កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និង ទិដ្ឋានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ ភវរាគា-នុស័យ និងមានានុស័យ របស់បុគ្គល ៣ ពួកនោះ ដេកសម្ងំនៅ ក្នុងរូបធាតុ

និងក្នុងអរូបធាតុនោះ តែកាមរាគានុស័យ បដិឃានុស័យ និងទិដ្ឋានុស័យ របស់បុគ្គលទាំងនោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ ភវរាគានុស័យ មានានុស័យ និងទិដ្ឋានុស័យ របស់បុថុជ្ជននោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគានុស័យ និងបដិឃានុស័យ របស់បុថុជ្ជននោះ មិនដេកសម្ងំ នៅក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ ។ កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ បដិឃានុស័យ មានា-នុស័យ និងទិដ្ឋានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អវិជ្ជានុស័យ របស់អនាគាមិបុគ្គលនោះ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែកាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ របស់អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ អវិជ្ជានុស័យ និងមានានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែកាមរាគានុស័យ បដិឃានុស័យ និងទិដ្ឋានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យ និងមានានុស័យ របស់បុគ្គលពីរពួកនោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគានុស័យ បដិឃានុស័យ និងទិដ្ឋា-នុស័យ របស់បុគ្គលពីរពួកនោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុ

នោះទេ អវិជ្ជានុស័យ កាមរាគានុស័យ និងមានានុស័យ របស់បុគ្គលទាំង នោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបដិឃានុស័យ និងទិដ្ឋានុស័យ របស់បុគ្គលទាំងនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យ និងបដិឃានុស័យ របស់បុគ្គលទាំងនោះឯង ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែកាមរាគានុស័យ មានានុស័យ និងទិដ្ឋានុស័យ របស់បុគ្គលទាំងនោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ អវិជ្ជានុស័យ មានានុស័យ និងទិដ្ឋានុស័យ របស់បុថុជ្ជននោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគានុស័យ និងបដិឃានុស័យ របស់បុថុជ្ជននោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ អវិជ្ជានុស័យ កាមរាគានុស័យ មានានុស័យ និងទិដ្ឋានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបដិឃានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យ បដិឃានុស័យ និងទិដ្ឋានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែកាមរាគានុស័យ និងមានានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។

[ ៣៣ ] កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា ភវរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត ភវរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា កាមរាគា-

នុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ ភវរាគានុស័យ និងមានានុស័យ របស់បុគ្គល ៣ ពួកនោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគានុស័យ បដិឃានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុគ្គល ៣ ពួកនោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ ភវរាគានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុថុជ្ជននោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគានុស័យ និងបដិឃានុស័យ របស់បុថុជ្ជននោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ ។ កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អវិជ្ជានុស័យ របស់អនាគាមិបុគ្គលនោះ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែកាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ អវិជ្ជានុស័យ និងមានានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែកាមរាគានុស័យ បដិឃានុស័យ

ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យ និងមានានុស័យ របស់បុគ្គលពីរពួកនោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគានុស័យ បដិឃានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុគ្គលពីរពួកនោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ អវិជ្ជានុស័យ កាមរាគានុស័យ និងមានានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបដិឃានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុគ្គលទាំងនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យ និងបដិឃានុស័យ របស់បុគ្គលទាំងនោះឯង ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែកាមរាគានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុគ្គលទាំងនោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ អវិជ្ជានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុថុជ្ជននោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគានុស័យ និងបដិឃានុស័យ របស់បុថុជ្ជននោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ អវិជ្ជានុស័យ កាមរាគានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបដិឃានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យ បដិឃានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែកាមរាគានុស័យ និងមានានុស័យ របស់បុគ្គល

នោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។

[ ៣៤ ] កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា អវិជ្ជានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា ដេកសម្ងំនៅ ក្នុងទីណា កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យ របស់បុគ្គលនោះ ដេកសម្ងំនៅ ក្នុងទីនោះដែរឬ ។ អវិជ្ជានុស័យ មានានុស័យ និងភវរាគានុស័យ របស់អនាគាមិបុគ្គលនោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគានុស័យ បដិឃានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់អនាគាមិបុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ អវិជ្ជានុស័យ និងមានានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែកាមរាគានុស័យ បដិឃានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យរបស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែកាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ អវិជ្ជានុស័យ មានានុស័យ និងភវរាគានុស័យ របស់បុគ្គលពីរពួកនោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគា-

*នុស័យ បដិឃានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុគ្គលទាំងពីរពួកនោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ អវិជ្ជានុស័យ កាមរាគានុស័យ និងមានានុស័យ របស់បុគ្គលទាំងនោះឯង ដេកសម្ងំនៅក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបដិឃានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆា-នុស័យ និងភវរាគានុស័យ របស់បុគ្គលទាំងនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យ និងបដិឃានុស័យ របស់បុគ្គលទាំងនោះឯង ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែកាមរាគានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យ របស់បុគ្គលទាំងនោះ មិនដេកសម្ងំនៅក្នុងទុក្ខវេទនានោះទេ អវិជ្ជានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆា-នុស័យ និងភវរាគានុស័យ របស់បុថុជ្ជននោះ ដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគានុស័យ និងបដិឃានុស័យ របស់បុថុជ្ជននោះ មិនដេកសម្ងំនៅ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ អវិជ្ជានុស័យ កាម-រាគានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបដិឃានុស័យ និងភវរាគានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ អវិជ្ជានុស័យ បដិឃានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ របស់បុគ្គលនោះឯង ដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះ តែកាមរាគានុស័យ មានានុស័យ និងភវរាគានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅ ក្នុងទុក្ខវេទនានោះទេ ។*

***អនុលោម ចប់***

[ ៣៥ ] កាមរាគានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ បដិ-
ឃានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាង
ទៀត បដិឃានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ កាមរាគានុស័យ
របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ អើ ។ កាមរាគានុស័យ របស់
បុគ្គលណា មិនដេកសម្ងំនៅ មានានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំ
នៅដែរឬ ។ កាមរាគានុស័យ របស់អនាគាមិបុគ្គល មិនដេកសម្ងំនៅ តែ
មានានុស័យ របស់អនាគាមិបុគ្គលនោះ មិនមែនជាមិនដេកសម្ងំនៅទេ កាម-
រាគានុស័យ របស់ព្រះអរហន្ត មិនដេកសម្ងំនៅ ទាំងមានានុស័យ ក៏មិន
ដេកសម្ងំនៅដែរ ។ មួយយ៉ាងទៀត មានានុស័យ របស់បុគ្គលណា មិនដេក
សម្ងំនៅ កាមរាគានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ អើ ។
កាមរាគានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ ទិដ្ឋានុស័យ ។បេ។
វិចិកិច្ឆានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាង
ទៀង វិចិកិច្ឆានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ កាមរាគានុស័យ
របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ វិចិកិច្ឆានុស័យ របស់បុគ្គលពីរ
ពួក មិនដេកសម្ងំនៅ តែកាមរាគានុស័យ របស់បុគ្គលពីរពួកនោះ មិនមែន
ជាមិនដេកសម្ងំនៅទេ វិចិកិច្ឆានុស័យ របស់បុគ្គលពីរពួក មិនដេកសម្ងំនៅ
ទាំងកាមរាគានុស័យ ក៏មិនដេកសម្ងំនៅដែរ ។ កាមរាគានុស័យ របស់បុគ្គល
ណា មិនដេកសម្ងំនៅ ភវរាគានុស័យ ។បេ។ អវិជ្ជានុស័យ របស់បុគ្គល
នោះ មិនដេកសម្ងំនៅដែរឬ ។ កាមរាគានុស័យ របស់អនាគាមិបុគ្គល មិន

ដេកសម្ងំនៅ តែអវិជ្ជានុស័យ របស់អនាគាមិបុគ្គលនោះ មិនមែនជាមិនដេកសម្ងំនៅទេ កាមរាគានុស័យ របស់ព្រះអរហន្ត មិនដេកសម្ងំនៅ ទាំងអវិជ្ជានុស័យ ក៏មិនដេកសម្ងំនៅដែរ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ កាមរាគានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ អើ ។

[ ៣៦ ] បដិឃានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ មានានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ បដិឃានុស័យ របស់អនាគាមិបុគ្គល មិនដេកសម្ងំនៅ តែមានានុស័យ របស់អនាគាមិបុគ្គលនោះ មិនមែនជាមិនដេកសម្ងំនៅទេ បដិឃានុស័យ របស់ព្រះអរហន្ត មិនដេកសម្ងំនៅ ទាំងមានានុស័យ ក៏មិនដេកសម្ងំនៅដែរ ។ មួយយ៉ាងទៀត មានានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ បដិឃានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ អើ ។ បដិឃានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ ទិដ្ឋានុស័យ ។បេ។ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ បដិឃានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ វិចិកិច្ឆានុស័យ របស់បុគ្គលពីរពួក មិនដេកសម្ងំនៅ តែបដិឃានុស័យ របស់បុគ្គលពីរពួកនោះ មិនមែនជាមិនដេកសម្ងំនៅទេ វិចិកិច្ឆានុស័យ របស់បុគ្គលពីរពួក មិនដេកសម្ងំនៅ ទាំងបដិឃានុស័យ ក៏មិនដេកសម្ងំនៅដែរ ។ បដិឃានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ ភវរាគានុស័យ ។បេ។ អវិជ្ជា-

នុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ បដិឃានុស័យ របស់អនាគាមិបុគ្គល មិនដេកសម្ងំនៅ តែអវិជ្ជានុស័យ របស់អនាគាមិបុគ្គលនោះ មិនមែនជាមិនដេកសម្ងំនៅទេ បដិឃានុស័យ របស់ព្រះអរហន្ត មិនដេកសម្ងំនៅ ទាំងអវិជ្ជានុស័យ ក៏មិនដេកសម្ងំនៅដែរ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ បដិឃានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ អើ ។

[ ៣៧ ] មានានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ ទិដ្ឋានុស័យ ។បេ។ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត វិចិកិច្ឆានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ មានានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ វិចិកិច្ឆានុស័យ របស់បុគ្គល ៣ ពួក មិនដេកសម្ងំនៅ តែមានានុស័យ របស់បុគ្គល ៣ ពួកនោះ មិនមែនជាមិនដេកសម្ងំនៅទេ វិចិកិច្ឆានុស័យ របស់ព្រះអរហន្ត មិនដេកសម្ងំនៅ ទាំងមានានុស័យ ក៏មិនដេកសម្ងំនៅដែរ ។ មានានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ ។បេ។ ភវរាគានុស័យ អវិជ្ជានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ មានានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ អើ ។

[ ៣៨ ] ទិដ្ឋានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ អើ ។ មួយយ៉ាងទៀត វិចិកិច្ឆា-

នុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ ទិដ្ឋានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ អើ ។ ។បេ។

[ ៣៩ ] វិចិកិច្ឆានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ ភវរាគានុស័យ ។បេ។ អវិជ្ជានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ វិចិកិច្ឆានុស័យ របស់បុគ្គល ៣ ពួក មិនដេកសម្ងំនៅ តែអវិជ្ជានុស័យ របស់បុគ្គល ៣ ពួកនោះ មិនមែនជាមិនដេកសម្ងំនៅទេ វិចិកិច្ឆានុស័យ របស់ព្រះអរហន្ត មិនដេកសម្ងំនៅ ទាំងអវិជ្ជានុស័យ ក៏មិនដេកសម្ងំនៅដែរ ។ មួយយ៉ាងទៀត អវិជ្ជានុស័យ របស់បុគ្គលណា មិនដេកសម្ងំនៅ វិចិកិច្ឆានុស័យ របស់បុគ្គលនោះ មិនដេកសម្ងំនៅដែរឬ ។ អើ ។

ភវរាគានុស័យ និងកាមរាគានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនមែនជាមិនលះបង់បដិឃានុស័យ ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង មិនលះបង់ភវរាគានុស័យ និងបដិឃានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបុគ្គលនោះ មិនមែនជាមិនលះបង់កាមរាគានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង មិនលះបង់ភវរាគានុស័យផង មិនលះបង់កាមរាគានុស័យ និងបដិឃានុស័យផង ក្នុងរូបធាតុ ក្នុងអរូបធាតុ និងក្នុងអបរិយាបន្នៈ ពួកបុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គចេញ មិនលះបង់ភវរាគានុស័យផង មិនលះបង់កាមរាគានុស័យ និងបដិ-ឃានុស័យផង ក្នុងទីទាំងអស់ ។ បុគ្គលណា មិនលះបង់កាមរាគានុស័យ និងបដិឃានុស័យ ក្នុងទីណា បុគ្គលនោះ មិនលះបង់អវិជ្ជានុស័យ ក្នុងទីនោះដែរឬ ។ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ មិនលះបង់កាមរាគានុស័យ និងបដិឃានុស័យ ក្នុងវេទនា ៣ នោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែបុគ្គលនោះ មិនមែនជាមិនលះបង់អវិជ្ជានុស័យ ក្នុងវេទនា ៣ នោះទេ បុគ្គលនោះឯង មិនលះបង់កាមរាគានុស័យ និងបដិ-ឃានុស័យផង មិនលះបង់អវិជ្ជានុស័យផង ក្នុងអបរិយាបន្នៈ ពួកបុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គចេញ មិនលះបង់កាមរាគានុស័យ និងបដិឃានុស័យផង មិនលះបង់អវិជ្ជានុស័យផង ក្នុងទីទាំងអស់ ។ មួយយ៉ាងទៀត បុគ្គលណា មិនលះបង់អវិជ្ជានុស័យ ក្នុងទីណា បុគ្គលនោះ មិនលះបង់កាមរាគានុស័យ និងបដិឃានុស័យ ក្នុងទីនោះ

ដែរឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គនោះ មិនលះបង់អវិជ្ជា-
នុស័យ និងកាមរាគានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនមែនជា
មិនលះបង់បដិឃានុស័យ ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង មិនលះបង់
អវិជ្ជានុស័យ និងបដិឃានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបុគ្គល
នោះ មិនមែនជាមិនលះបង់កាមរាគានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះ
ឯង មិនលះបង់អវិជ្ជានុស័យផង មិនលះបង់កាមរាគានុស័យ និងបដិឃា-
នុស័យផង ក្នុងរូបធាតុ ក្នុងអរូបធាតុ និងក្នុងអបរិយាបន្នខនោះ ពួកបុគ្គល
ដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គចេញ មិន
លះបង់អវិជ្ជានុស័យផង មិនលះបង់កាមរាគានុស័យ និងបដិឃានុស័យផង
ក្នុងទីទាំងអស់ ។

[ ១៩៦ ] បុគ្គលណា មិនលះបង់កាមរាគានុស័យ បដិឃានុស័យ
និងមានានុស័យ ក្នុងទីណា បុគ្គលនោះ ( មិនលះបង់ ) ទិដ្ឋានុស័យ ។បេ។
មិនលះបង់វិចិកិច្ឆានុស័យ ក្នុងទីនោះដែរឬ ។ បុគ្គលទី ៨ នោះ មិនលះបង់
កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ ក្នុងវេទនា ៣ នោះ ក្នុង
កាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែបុគ្គលនោះ មិនមែនជាមិន
លះបង់វិចិកិច្ឆានុស័យ ក្នុងវេទនា ៣ នោះទេ បុគ្គលនោះឯង មិនលះបង់
កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យផង មិនលះបង់វិចិកិច្ឆា-
នុស័យផង ក្នុងអបរិយាបន្នខនោះ ពួកបុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរ
ពួកដែលព្រមព្រៀងដោយមគ្គ និងបុគ្គលទី ៨ ចេញ មិនលះបង់កាមរាគា-

នុស័យ បដិឃានុស័យ និងមានានុស័យផង មិនលះបង់វិចិកិច្ឆានុស័យផង ក្នុងទីទាំងអស់ ។ មួយយ៉ាងទៀត បុគ្គលណា មិនលះបង់វិចិកិច្ឆានុស័យ ក្នុងទីណា បុគ្គលនោះ មិនលះបង់កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ ក្នុងទីនោះដែរឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គនោះ មិនលះបង់វិចិកិច្ឆានុស័យ កាមរាគានុស័យ និងមានានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនមែនជាមិនលះបង់បដិឃានុស័យ ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង មិនលះបង់វិចិកិច្ឆានុស័យ បដិឃានុស័យ និងមានានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបុគ្គលនោះ មិនមែនជាមិនលះបង់កាមរាគានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង មិនលះបង់វិចិកិច្ឆានុស័យផង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យផង ក្នុងរូបធាតុ ក្នុងអរូបធាតុ និងក្នុងអបរិយាបន្នទោះ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ មិនលះបង់វិចិកិច្ឆានុស័យ កាមរាគានុស័យ និងបដិឃានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែបុគ្គលនោះ មិនមែនជាមិនលះបង់មានានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង មិនលះបង់វិចិកិច្ឆានុស័យផង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យផង ក្នុងទុក្ខវេទនានោះ ក្នុងអបរិយាបន្ន ពួកបុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គ និងបុគ្គលទី ៨ ចេញ មិនលះបង់វិចិកិច្ឆានុស័យផង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យផង ក្នុងទីទាំងអស់ ។ បុគ្គល

ណា មិនលះបង់កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ ក្នុងទីណា បុគ្គលនោះ មិនលះបង់ភវរាគានុស័យក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាង ទៀត បុគ្គលណា មិនលះបង់ភវរាគានុស័យ ក្នុងទីណា បុគ្គលនោះ មិន លះបង់កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ ក្នុងទីនោះដែរឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គនោះ មិនលះបង់ភវរាគានុស័យ កាមរាគានុស័យ និងមានានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនមែន ជាមិនលះបង់បដិឃានុស័យ ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង មិនលះបង់ ភវរាគានុស័យ បដិឃានុស័យ និងមានានុស័យ ក្នុងវេទនាពីរនោះ ក្នុង កាមធាតុ តែបុគ្គលនោះ មិនមែនជាមិនលះបង់កាមរាគានុស័យ ក្នុងវេទនា ពីរនោះទេ បុគ្គលនោះឯង មិនលះបង់ភវរាគានុស័យផង មិនលះបង់កាម-រាគានុស័យ បដិឃានុស័យ និងមានានុស័យផង ក្នុងរូបធាតុ ក្នុងអរូបធាតុ និងក្នុងអបរិយាបន្នទោះ បុគ្គលអ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ មិន លះបង់ភវរាគានុស័យ កាមរាគានុស័យ និងបដិឃានុស័យ ក្នុងវេទនាពីរ នោះ ក្នុងកាមធាតុ តែបុគ្គលនោះ មិនមែនជាមិនលះបង់មានានុស័យ ក្នុង វេទនាពីរនោះទេ បុគ្គលនោះឯង មិនលះបង់ភវរាគានុស័យផង មិនលះបង់ កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យផង ក្នុងទុក្ខវេទនា ក្នុង អបរិយាបន្នទោះ ពួកបុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រម ព្រៀងដោយមគ្គចេញ មិនលះបង់ភវរាគានុស័យផង មិនលះបង់កាមរាគា-នុស័យ បដិឃានុស័យ និងមានានុស័យផង ក្នុងទីទាំងអស់ ។ បុគ្គលណា

មិនលះបង់កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ ក្នុងទីណា បុគ្គល នោះ មិនលះបង់អវិជ្ជានុស័យ ក្នុងទីនោះដែរឬ ។ បុគ្គល អ្នកព្រមព្រៀង ដោយមគ្គដ៏ប្រសើរនោះ មិនលះបង់កាមរាគានុស័យ បដិឃានុស័យ និង មានានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនមែនជាមិនលះបង់ អវិជ្ជានុស័យ ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង មិនលះបង់កាមរាគា-នុស័យ បដិឃានុស័យ និងមានានុស័យផង មិនលះបង់អវិជ្ជានុស័យផង ក្នុងអបរិយាបន្នទោះ ពួកបុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែល ព្រមព្រៀងដោយមគ្គចេញ មិនលះបង់កាមរាគានុស័យ បដិឃានុស័យ និង មានានុស័យផង មិនលះបង់អវិជ្ជានុស័យផង ក្នុងទីទាំងអស់ ។ មួយយ៉ាង ទៀត បុគ្គលណា មិនលះបង់អវិជ្ជានុស័យ ក្នុងទីណា បុគ្គលនោះ មិន លះបង់កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ ក្នុងទីនោះដែរឬ ។ បុគ្គលអ្នកព្រមព្រៀងដោយអនាគាមិមគ្គនោះ មិនលះបង់អវិជ្ជានុស័យ កាម-រាគានុស័យ និងមានានុស័យ ក្នុងទុក្ខវេទនានោះ ។ តែបុគ្គលនោះ មិនមែន ជាមិនលះបង់បដិឃានុស័យ ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង មិនលះបង់ អវិជ្ជានុស័យ បដិឃានុស័យ និងមានានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបុគ្គលនោះ មិនមែនជាមិនលះបង់កាមរាគានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង មិនលះបង់អវិជ្ជានុស័យផង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យផង ក្នុងរូបធាតុ ក្នុងអរូបធាតុ និងក្នុងអបរិ-យាបន្នទោះ ពួកបុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀង

ដោយមគ្គចេញ មិនលះបង់អវិជ្ជានុស័យផង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យផង ក្នុងទីទាំងអស់ ។

[ ១៩៧ ] បុគ្គលណា មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ ក្នុងទីណា បុគ្គលនោះ មិនលះបង់វិចិកិច្ឆានុស័យ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា មិនលះបង់វិចិកិច្ឆានុស័យ ក្នុងទីណា បុគ្គលនោះ មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ ក្នុងទីនោះដែរឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គនោះ មិនលះបង់វិចិកិច្ឆានុស័យ កាមរាគានុស័យ មានានុស័យ និងទិដ្ឋានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនមែនជាមិនលះបង់បដិឃានុស័យ ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង មិនលះបង់វិចិកិច្ឆានុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបុគ្គលនោះ មិនមែនជាមិនលះបង់កាមរាគានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង មិនលះបង់វិចិកិច្ឆានុស័យផង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យផង ក្នុងរូបធាតុ ក្នុងអរូបធាតុ និងក្នុងអបរិយាបន្នៈនោះ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ មិនលះបង់វិចិកិច្ឆានុស័យ កាមរាគានុស័យ បដិឃានុស័យ និងទិដ្ឋានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែបុគ្គលនោះ មិនមែនជាមិនលះបង់មានានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង មិនលះបង់វិចិកិច្ឆានុស័យផង មិនលះបង់កាមរាគា-

នុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យផង ក្នុងទុក្ខវេទនានោះ ក្នុងអបរិយាបន្ន ពួកបុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គ និងបុគ្គលទី ៨ចេញ មិនលះបង់វិចិកិច្ឆានុស័យផង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងទិដ្ឋានុស័យផង ក្នុងទីទាំងអស់ ។បេ។

[ ១៩៨ ] បុគ្គលណា មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងទីណា បុគ្គលនោះ មិនលះបង់ភវរាគានុស័យ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា មិនលះបង់ភវរាគានុស័យ ក្នុងទីណា បុគ្គលនោះ មិនលះបង់កាម-រាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងទីនោះដែរឬ ។ បុគ្គលទី ៨ មិនលះបង់ភវរាគានុស័យ កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ ក្នុងវេទនា ៣ នោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែបុគ្គលនោះ មិនមែនជាមិនលះបង់ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងវេទនា ៣ នោះទេ បុគ្គលនោះឯង មិនលះបង់ភវរាគានុស័យផង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យផង ក្នុងអបរិយាបន្ននោះ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គនោះ មិនលះបង់ភវរាគានុស័យ កាមរាគានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនមែនជាមិនលះបង់បដិឃានុស័យ ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះ

ឯង មិនលះបង់កវរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបុគ្គលនោះ មិនមែនជាមិនលះបង់កាមរាគានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង មិនលះបង់កវរាគានុស័យផង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យផង ក្នុងរូបធាតុ ក្នុងអរូបធាតុ និងក្នុងអបរិយាបន្នទោះ បុគ្គលអ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ មិនលះបង់កវរាគានុស័យ កាមរាគានុស័យ បដិឃានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបុគ្គលនោះ មិនមែនជាមិនលះបង់មានានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង មិនលះបង់កវរាគានុស័យផង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យផង ក្នុងទុក្ខវេទនានោះ ក្នុងអបរិយាបន្ន ពួកបុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គ និងបុគ្គលទី ៨ ចេញ មិនលះបង់កវរាគានុស័យផង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យផង ក្នុងទីទាំងអស់ ។ បុគ្គលណា មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងទីណា បុគ្គលនោះ មិនលះបង់អវិជ្ជានុស័យ ក្នុងទីនោះដែរឬ ។ បុគ្គលអ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនមែនជាមិនលះបង់

*អវិជ្ជានុស័យ ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យផង មិនលះបង់អវិជ្ជានុស័យផង ក្នុងអបរិយាបន្នទោះ ពួកបុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គ និងបុគ្គលទី ៨ ចេញ មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យផង មិនលះបង់អវិជ្ជានុស័យផង ក្នុងទីទាំងអស់ ។ មួយយ៉ាងទៀត បុគ្គលណា មិនលះបង់អវិជ្ជានុស័យ ក្នុងណា បុគ្គលនោះ មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងទីនោះដែរឬ ។ បុគ្គលទី ៨ នោះ មិនលះបង់អវិជ្ជានុស័យ កាមរាគានុស័យ បដិឃានុស័យ និងមានានុស័យ ក្នុងវេទនា ៣ នោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែបុគ្គលនោះ មិនមែនជាមិនលះបង់ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងវេទនា ៣ នោះទេ បុគ្គលនោះឯង មិនលះបង់អវិជ្ជានុស័យផង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យផង ក្នុងអបរិយាបន្នទោះ បុគ្គលអ្នកព្រមព្រៀងដោយអនាគាមិមគ្គនោះ មិនលះបង់អវិជ្ជានុស័យ កាមរាគានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនមែនជាមិនលះបង់បដិឃានុស័យ ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង មិនលះបង់អវិជ្ជានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបុគ្គល*

នោះ មិនមែនជាមិនលះបង់ភវរាគានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង មិនលះបង់អវិជ្ជានុស័យផង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យផង ក្នុងរូបធាតុ ក្នុងអរូបធាតុ និងក្នុងអបរិយាបន្នៈនោះ ពួកបុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គ និងបុគ្គលទី ៨ ចេញ មិនលះបង់អវិជ្ជានុស័យផង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យផង ក្នុងទីទាំងអស់ ។

[ ១៩៩ ] បុគ្គលណា មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យ ក្នុងទីណា បុគ្គលនោះ មិនលះបង់អវិជ្ជានុស័យ ក្នុងទីនោះដែរឬ ។ បុគ្គលអ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនមែនជាមិនលះបង់អវិជ្ជានុស័យ ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យផង មិនលះបង់អវិជ្ជានុស័យផង ក្នុងអបរិយាបន្នៈនោះ ពួកបុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គ និងបុគ្គលទី ៨ ចេញ មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យផង មិនលះបង់អវិជ្ជានុស័យផង ក្នុងទីទាំងអស់ ។ មួយយ៉ាងទៀត

បុគ្គលណា មិនលះបង់អវិជ្ជានុស័យ ក្នុងទីណា បុគ្គលនោះ មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យ ក្នុងទីនោះដែរឬ ។ បុគ្គលទី ៨ នោះ មិនលះបង់អវិជ្ជា-នុស័យ កាមរាគានុស័យ បដិឃានុស័យ មានានុស័យ និងភវរាគានុស័យ ក្នុងវេទនា ៣ នោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែបុគ្គលនោះ មិនមែនជាមិនលះបង់ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងវេទនា ៣ នោះទេ បុគ្គលនោះឯង មិនលះបង់អវិជ្ជានុស័យផង មិនលះបង់កាមរាគា-នុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យផង ក្នុងអបរិយាបន្នៈនោះ បុគ្គលអ្នកព្រមព្រៀងដោយអនាគាមិមគ្គនោះ មិនលះបង់អវិជ្ជានុស័យ កាមរាគានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនមែនជាមិនលះបង់បដិឃានុស័យ ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង មិនលះបង់អវិជ្ជានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបុគ្គលនោះ មិនមែនជាមិនលះបង់កាមរាគានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គល

នោះឯង មិនលះបង់អវិជ្ជានុស័យផង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យផង ក្នុងរូបធាតុ ក្នុងអរូបធាតុ និងក្នុងអបរិយាបន្នៈនោះ ពួកបុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គ និងបុគ្គលទី ៨ ចេញ មិនលះបង់អវិជ្ជានុស័យផង មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យផង ក្នុងទីទាំងអស់ ។

បជហនវារៈ ចប់

# អដ្ឋកថា

# អនុសយយមកៈ

## បរិច្ឆេទបរិច្ឆិន្នុទ្ទេសវារៈ[១]

*ឥឡូវនេះ ជាកិច្ចពណ៌នាអត្ថនៃអនុសយយមកៈ តាមដែលព្រះមានព្រះភាគ ទ្រង់រួបរួមឯកទេសនៃកុសលធម៌ជាដើម ដែលទ្រង់សម្ដែងក្នុងមូលយមកៈនោះឯង ដោយអំណាចនៃអត្ថដែលបានហើយ ទ្រង់សម្ដែងក្នុងលំដាប់បន្ទាប់អំពីសង្ខារយមកៈ ។ បណ្ឌិត គប្បីជ្រាបការកំណត់បាលីក្នុងអនុសយយមកៈមុន ព្រោះថា ក្នុងអនុសយយមកៈនេះ ទ្រង់ធ្វើបាលីទេសនាម្យ៉ាងទៀត មិនដូចធ្វើទេសនាក្នុងខន្ធយមកៈជាដើមឡើយ ។*

*សួរថា ធ្វើទេសនាដូចម្ដេច ឆ្លើយថា ខាងដើម ទ្រង់សម្ដែង ៣ វារៈ គឺ* **បរិច្ឆេទវារ ១ បរិច្ឆិន្នុទ្ទេសវារ ១ ឧប្បត្តិដ្ឋានវារ ១** *ដើម្បីឲ្យសិក្សាអនុស័យទាំងឡាយ ដោយអាការ ៣ យ៉ាង គឺដោយបរិច្ឆេទ ដោយឧទ្ទេស និងដោយឧប្បត្តិដ្ឋាន បន្ទាប់អំពីនោះ ទ្រង់ក៏ប្រកបអនុស័យទាំងឡាយ ធ្វើយមកទេសនា ដោយអំណាចនៃមហាវារៈ ៧ ។*

*ក្នុងអនុសយយមកៈនោះ បទថា* **សត្ត អនុសយា** *នេះ ឈ្មោះថា បរិច្ឆេទវារៈ ( វារៈពោលដោយការកំណត់ ) ព្រោះភាពដែលអនុស័យទាំងឡាយ ទ្រង់កំណត់ចំនួនសម្ដែងថា អនុស័យនេះ មាន ៧ ប៉ុណ្ណោះ*

---

១- បរិច្ឆេទវារៈ និងបរិច្ឆិន្នុទ្ទេសវារៈនេះ មិនទាន់ដល់លេខឃ្នាបនៅឡើយទេ ។

*មិនច្រើនជាងនេះ មិនតិចជាងនេះ ដូច្នេះ ។*

*បទថា* **កាមរាគានុសយោ ។បេ។ អវិជ្ជានុសយោ** *នេះ ឈ្មោះថា បរិច្ឆិន្នុទ្ទេសហារៈ ( ហារៈពោលដោយឧទ្ទេសដែលកំណត់ហើយ ) ព្រោះភាពដែលហារៈនេះ ទ្រង់លើកត្រឹមតែឈ្មោះនៃធម៌ ដែលបានកំណត់ហើយដោយបរិច្ឆេទហារៈនោះ សម្តែងថា ឈ្មោះថា ធម៌ទាំងនេះ ជាធម៌ប្រភេទនោះ ដូច្នេះ ។*

*បទថា* **កត្ថ កាមរាគានុសយោ អនុសេតិ ។បេ។ ឯត្ថ អវិជ្ជា-នុសយោ អនុសេតិ** *នេះ ឈ្មោះថា ឧប្បត្តិដ្ឋានហារៈ ( ហារៈពោលដោយទីកើតឡើង ) ព្រោះភាពដែលហារៈនេះ ទ្រង់សម្តែងទីជាទីកើតឡើងនៃធម៌ទាំងនោះឯង យ៉ាងនេះថា អនុស័យទាំងនេះ រមែងដេកត្រាំក្នុងហារៈទាំងឡាយ ឈ្មោះនេះ ដូច្នេះ ។*

*ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ប្រកបអនុស័យទាំងឡាយ ហើយធ្វើយមកទេសនាដោយអំណាចនៃមហាហារៈទាំង ៧ ណា មហាហារៈទាំងនោះមានឈ្មោះដូច្នេះ គឺ* **អនុសយវារ** *គឺវារៈពោលអំពីអនុស័យ ១* **សានុ-សយវារ** *គឺវារៈពោលអំពីបុគ្គលមានអនុស័យ ១* **បជហនវារ** *គឺវារៈពោលអំពីការលះ ១* **បរិញ្ញាវារ** *គឺវារៈពោលអំពីការកំណត់ដឹង ១* **បហីនវារ** *គឺវារៈពោលអំពីការលះបានហើយ ១* **ឧប្បជ្ជនវារ** *គឺវារៈពោលអំពីការកើត ១* **ធាតុវារ** *គឺវារៈពោលអំពីធាតុ ១ ។*

*បណ្តាមហាវារៈទាំងនោះ វារៈទី ១ ឈ្មោះថា អនុសយវារៈ ។*

*អនុសយវារៈនោះ មាន ២ ន័យ គឺដោយអំណាចនៃអនុលោមន័យ និង បដិលោមន័យ ។ ក្នុងន័យទាំង ២ នោះ អនុលោមន័យ មាន ៣ អន្តរវារៈ ដោយអំណាចនៃបុគ្គល ១ ឱកាស ១ បុគ្គល និងឱកាសទាំងពីររួមគ្នា ១ គឺ*

**យស្ស អនុសេតិ** *ប្រែថា ... កំពុងដេកត្រាំដល់បុគ្គលណា នេះហៅថា បុគ្គលវារៈ ។*

**យត្ថ អនុសេតិ** *ប្រែថា ... កំពុងដេកត្រាំក្នុងទីណា នេះហៅថា ឱកាសវារៈ ។*

**យស្ស យត្ថា អនុសេតិ** *ប្រែថា ... កំពុងដេកត្រាំដល់បុគ្គលណា ក្នុងទីណា នេះហៅថា បុគ្គលោកាសវារៈ ។*

*ក្នុងអន្តរវារៈ ៣ នោះ ក្នុងបុគ្គលវារៈដំបូង មាន ២១ យមកៈ គឺ មានកាមរាគានុសយៈជាមូល ៦ យមកៈ ដោយព្រះបាលីថា*

**យស្ស កាមរាគានុសយោ អនុសេតិ តស្ស បដិឃានុសយោ អនុសេតិ យស្ស វា បន បដិឃានុសយោ អនុសេតិ តស្ស កាម-រាគានុសយោ អនុសេតិ ។**

**យស្ស កាមរាគានុសយោ អនុសេតិ តស្ស មានានុសយោ ... ទិដ្ឋានុសយោ ... វិចិកិច្ឆានុសយោ ... ភវរាគានុសយោ ... អវិជ្ជានុសយោ អនុសេតិ ។**

**យស្ស វា បន អវិជ្ជានុសយោ អនុសេតិ តស្ស កាមរាគា-នុសយោ អនុសេតិ ។**

*ដែលមានបដិឃានុស័យជាមូល ៥ យមកៈ មានមានានុស័យជាមូល ៤ យមកៈ មានទិដ្ឋានុស័យជាមូល ៣ យមកៈ មានវិចិកិច្ឆានុស័យជាមូល ២ យមកៈ មានភវរាគានុស័យជាមូល ១ យមកៈ ដោយអំណាចនៃការរាប់ហើយមិនរាប់ទៀត វារៈទាំងអស់ដែលមានមូល ១ ទើបរួមជា ២១ យមកៈ ដោយប្រការដូច្នេះ ។*

*បុគ្គលវារៈ ១៥ យមកៈដទៃទៀត គឺយមកៈដែលមានមូល ២ ដែលមកហើយក្នុងព្រះបាលីយ៉ាងនេះថា* **យស្ស កាមរាគានុសយោ ច បដិឃានុសយោ ច អនុសេន្តិ** *ដូច្នេះ មាន ៥ យមកៈ ដែលមានមូល ៣ មាន ៤ យមកៈ ដែលមានមូល ៤ មាន ៣ យមកៈ ដែលមានមូល ៥ មាន ២ យមកៈ ដែលមានមូល ៦ មាន ១ យមកៈ រួមក្នុងបុគ្គលវារៈ មាន ៣៦ យមកៈ គឺយមកៈដែលមានមូល ១ មាន ២១ យមកៈ ដែលមានមូល ២ ជាដើម មាន ១៥ យមកៈ ( ២១ + ១៥ = ៣៦ ) ដូច្នេះ ។*

*ក្នុងឱកាសវារៈក៏ដូចគ្នា គឺមាន ៣៦ ក្នុងបុគ្គលោកាសវារៈក៏ដូចគ្នា គឺមាន ៣៦ ព្រោះហេតុនោះ អន្តរវារៈទាំងអស់ ក្នុងអនុលោមន័យ ទើបជា ១០៨ យមកៈ ឯក្នុងបដិលោមន័យក៏ដូចគ្នា ដូច្នោះ ក្នុងមហាវារៈដំបូង គឺអនុសយវារៈ ទើបរួមជា ២១៦ យមកៈ ។ បណ្ឌិតគប្បីជ្រាបពាក្យបុច្ឆាត្រូវគុណដោយ ២ តែយមកៈនោះ អត្ថ គឺពាក្យវិសជ្ជនា គុណដោយ ២ អំពីពាក្យបុច្ឆានោះ ។ ក្នុងអនុសយវារៈនេះ យ៉ាងណា បណ្ឌិតគប្បីជ្រាបការរាប់យមកៈក្នុងយមកៈនីមួយៗ នៃមហាវារៈទាំង ៥ នេះ គឺសានុសយវារៈ*

បជហានវារៈ បរិញ្ញាវារៈ បហីនវារៈ និងឧប្បជ្ជនវារៈថា ពាក្យបុច្ឆា ត្រូវគុណដោយ ២ ក្នុង ១ យមកៈ អត្ថ គឺពាក្យវិសជ្ជនា ត្រូវគុណដោយ ២ អំពីពាក្យបុច្ឆានោះ ក៏យ៉ាងនោះ ។ តែក្នុងមហាវារៈ ៥ នេះ មានអត្ថប្លែក អំពី ៣ វារៈដំបូង គឺក្នុងឱកាសវារៈ ព្រះមានព្រះភាគមិនត្រាស់ពាក្យថា **យត្ថ យត្ថ** តែទ្រង់ធ្វើទេសនាដោយបញ្ចមីវិភត្តិថា **យតោ តតោ** ដូច្នេះ ពាក្យដ៏សេសដូចគ្នានោះឯង ។

ក្នុងមហាវារៈទាំងអស់ វារៈចុងក្រោយ ឈ្មោះថា ធាតុវារៈ វារៈនោះតាំងនៅ ២ យ៉ាង គឺបុច្ឆាវារៈ និងវិសជ្ជនាវារៈ សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ត្រាស់ក្នុងពាក្យបុច្ឆាវារៈនៃធាតុវារៈនោះថា កាលសត្វចុតិចាកកាមធាតុ ហើយកើតឡើងក្នុងកាមធាតុ ដូច្នេះ តែមិនត្រាស់ថា កាលសត្វកើតឡើងក្នុងកាមធាតុ ចុតិចាកកាមធាតុ ដូច្នេះ ឆ្លើយថា បើពោលដោយអត្ថហើយ មិនប្លែកគ្នា ព្រោះថា ពាក្យសួរទាំង ២ នេះ មានអត្ថតែមួយនោះឯង ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ពាក្យបុច្ឆាយមកៈនីមួយៗ នោះឯង អំពីយមកៈនីមួយៗ ដោយលំដាប់នៃពាក្យសួរក្នុងទីបំផុតនៃពាក្យសួរទាំងអស់ហើយ ទើបធ្វើពាក្យវិសជ្ជនាដោយន័យជាដើមថា កាលសត្វចុតិចាកកាមធាតុហើយ កើតឡើងក្នុងកាមធាតុ បុគ្គលខ្លះ មានអនុស័យ ៧ ដេកត្រាំ ដូច្នេះ ។ បណ្តាពាក្យសួរទាំងនោះ អនុលោមបុច្ឆា មានកាមធាតុជាមូល ៩ គឺសុទ្ធិកបុច្ឆា ៦ យមកៈ ដោយព្រះបាលីថា កាលសត្វចុតិចាកកាមធាតុ កើតឡើងក្នុងកាមធាតុ ... កើតឡើងក្នុងរូបធាតុ ... កើតឡើងក្នុង

*អរូបធាតុ ... កើតឡើងក្នុងភូមិដែលមិនមែនកាមធាតុ ... កើតឡើងក្នុងភូមិដែលមិនមែនរូបធាតុ ... កើតឡើងក្នុងភូមិដែលមិនមែនអរូបធាតុ ដូច្នេះ និងមិស្សកបុច្ឆា ៣ ទៀត គឺកាលសត្វចុតិចាកកាមធាតុ កើតឡើងក្នុងភូមិដែលមិនមែនកាមធាតុ ភូមិដែលមិនមែនអរូបធាតុ ... កើតឡើងក្នុងភូមិដែលមិនមែនរូបធាតុ ភូមិដែលមិនមែនអរូបធាតុ ... កើតឡើងក្នុងភូមិដែលមិនមែនកាមធាតុ ភូមិដែលមិនមែនរូបធាតុ ដូច្នេះ ។*

*អនុលោមបុច្ឆាដែលមានរូបធាតុជាមូលមាន ៩ ដែលមានអរូបធាតុជាមូលក៏មាន ៩ ដូចគ្នា រួមជាអនុលោមបុច្ឆា ២៧ ។ បដិលោមបុច្ឆាដែលមានភូមិមិនមែនកាមធាតុ ភូមិដែលមិនមែនរូបធាតុ ភូមិដែលមិនមែនអរូបធាតុជាមូល ក៏មាន ២៧ នោះឯង ។ រួមពាក្យសួរទាំងអស់ គឺ អនុលោមបុច្ឆា ២៧ បដិលោមបុច្ឆា ២៧ និងពាក្យសួរដែលជាទុកមូលកៈ ២៧ ទៀត ដូចព្រះបាលីថា* **នកាមធាតុយា នអរូបធាតុយា នរូបធាតុយា នអរូបធាតុយា នកាមធាតុយា នអរូបធាតុយា** *ដូច្នេះ ទើបជាពាក្យបុច្ឆា ៨១ ។ បណ្ឌិតគប្បីធ្វើការវិសជ្ជនាបញ្ហាក្នុងទីនេះ ដោយអំណាចនៃពាក្យសួរទាំងនោះ ។ សេចក្តីនេះ ជាការកំណត់បាលីក្នុងធាតុវារៈ និងគប្បីជ្រាបការកំណត់បាលីក្នុងអនុសយយមកៈទាំងអស់ ដោយប្រការដូច្នេះ ។*

*ពាក្យណាមួយ ក្នុងអនុសយយមកៈនេះ ដែលមានអត្ថលំបាក គប្បីជ្រាបការវិនិច្ឆយកថាក្នុងទីនោះៗ តាំងអំពីខាងដើមតទៅ ។*

*សួរថា ពាក្យថា អនុស័យ ឈ្មោះថា អនុស័យទាំងឡាយ ព្រោះអត្ថ*

*ដូចម្ដេច ឆ្លើយថា ឈ្មោះថា អនុស័យ ព្រោះអត្ថថា ដេកត្រាំ ។ សួរថា អនុស័យនោះ ឈ្មោះថា មានអត្ថថា ដេកត្រាំដូចម្ដេច ឆ្លើយថា ឈ្មោះយ៉ាងនោះ ព្រោះអត្ថថា មិនទាន់លះបាន ។*

*ពិតហើយ កិលេសទាំងនេះ ឈ្មោះថា ដេកត្រាំក្នុងសន្ដានរបស់សត្វ ព្រោះអត្ថថា មិនទាន់លះបាន ព្រោះហេតុនោះ ទើបអាចារ្យទាំងឡាយ ហៅកិលេសទាំងនោះថា អនុស័យ ។*

*បទថា* **អនុសេន្តិ** *អធិប្បាយថា បានហេតុ ដែលសមគួរហើយ ទើបកើតឡើង ។ មួ៉ាងទៀត កិលេសដែលមានអាការមិនទាន់លះបាន ឈ្មោះថា* **អនុសយនដ្ឋោ** *( អត្ថថា ដេកត្រាំ ) គប្បីមាន ។ មិនគួរពោលថា កិលេសមានអាការលះមិនទាន់បាននេះ រមែងកើតឡើង ព្រោះហេតុនោះ មិនគួរពោលថា អនុស័យទាំងឡាយកើតឡើង ដូច្នេះ ។ បទថា* **អនុសយា ឧប្បជ្ជន្តិ** *នេះ ក្នុងទីនេះ ជាពាក្យទទួលថា អនុស័យ គឺកិលេសដែលមានអាការលះមិនទាន់បាន ។ បទថា* **អនុសយោ** *ព្រះមានព្រះភាគ ត្រាស់ហៅកិលេសដែលមានកម្លាំង ព្រោះអត្ថថា មិនទាន់លះបាន ។*

*បណ្ឌិតគប្បីជ្រាបថា អនុស័យនេះ ជាចិត្តសម្បយុត្ត ប្រព្រឹត្តទៅដោយអារម្មណ៍ គឺដឹងអារម្មណ៍បាន ជាសហេតុកៈ ព្រោះអត្ថថា មានបច្ច័យតាក់តែង និងជាអកុសលតែម្យ៉ាង ជាអតីតខ្លះ ជាអនាគតខ្លះ ជាបច្ចុប្បន្នខ្លះ ព្រោះហេតុនោះ ទើបគួរពោលថា អនុស័យកើតឡើង ។*

*ក្នុងទីនេះ គប្បីជ្រាបពាក្យវិនិច្ឆ័យកថានេះជាប្រមាណដូចតទៅ*

*ក្នុងអភិធម្ម លោកបដិសេធវាទៈទាំងអស់ក្នុងកថាវត្ថុថា អនុស័យជាអព្យាក្រឹត អនុស័យជាអហេតុកៈ អនុស័យប្រាសចាកចិត្ត ដូច្នេះ ។*

*ក្នុងបដិសម្ភិទាមគ្គ លោកធ្វើពាក្យសួរថា លះកិលេសដែលកើតចំពោះមុខ ហើយពោលថា អ្នកមានព្យាយាមលះអនុស័យ ព្រោះភាពដែលអនុស័យទាំងនោះ ជាបច្ចុប្បន្ន មាន ។*

*តែក្នុងធម្មសង្គហៈ លោកពោលក្នុងបទភាជនីយនៃមោហៈថា ការកើតឡើងនៃអវិជ្ជានុស័យរួមជាមួយអកុសលចិត្តថា អនុស័យ គឺអវិជ្ជា សេចក្តីគ្របសង្កត់ គឺអវិជ្ជា គន្ទឹះ គឺអវិជ្ជា គឺមោហៈ ជាអកុសលមូលណា ក្នុងសម័យនោះ នេះមោហៈកើតមានក្នុងសម័យនោះ ដូច្នេះ ។*

*ក្នុងអនុសយយមកៈនេះ លោកពោលក្នុងឧប្បជ្ជនវារៈនៃមហាវារៈ ៧ ណាមួយថា កាមរាគានុស័យកើតឡើងដល់បុគ្គលណា បដិឃានុស័យកើតឡើងដល់បុគ្គលនោះដែរឬជាដើម ព្រោះហេតុនោះ ពាក្យណាដែលលោកអធិប្បាយថា ពាក្យថា ដេកត្រាំ ( សម្ងំនៅ ) គឺបានហេតុដែលសមគួរហើយ ទើបកើតឡើង ពាក្យនោះ គប្បីជ្រាបថា លោកពោលល្អហើយដោយអំណាចនៃបែបផែននេះជាប្រមាណ ។ ពាក្យដែលពោលថា អនុស័យប្រកបជាមួយចិត្ត ប្រព្រឹត្តទៅជាមួយអារម្មណ៍ គឺដឹងអារម្មណ៍បាន ពាក្យនោះ លោកក៏ពោលល្អហើយនោះឯង ដូច្នេះ ក៏គប្បីដល់នូវការសម្រេចក្នុងទីនេះថា ឈ្មោះថា អនុស័យនោះ ជាធម៌សម្រេចហើយ ប្រកបជាមួយចិត្ត និងជាអកុសលធម៌ ។ គប្បីជ្រាបវិគ្គហៈក្នុងពាក្យទាំងឡាយ ដែលមាន*

ពាក្យថា **កាមរាគានុសយោ** ជាដើមថា កាមរាគៈនោះផង ជាអនុស័យ ព្រោះអត្ថថា លះមិនទាន់បានផង ព្រោះហេតុនោះ ទើបឈ្មោះថា កាម-រាគានុស័យ ។ ក្នុងបទដ៏សេសក៏ន័យនេះឯង ។

# ឧប្បត្តិដ្ឋានវារៈ

[ ១ ] ឥឡូវនេះ ដើម្បីប្រកាសឧប្បត្តិដ្ឋានវារៈ គឺវារៈពោលដោយទីជាទីកើតឡើងនៃអនុស័យរបស់អនុស័យទាំងនោះ ទើបព្រះមានព្រះភាគត្រាស់ថា **កត្ថ កាមរាគានុសយោ អនុសេតិ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **កាមធាតុយា ទ្វីសុ វេទនាសុ** បានដល់ កាមរាគានុស័យកើតក្នុងវេទនាទាំង ២ គឺសុខវេទនា និងឧបេក្ខាវេទនាក្នុងកាមាវចរភូមិ ។

បទថា **ឯត្ថ កាមរាគានុសយោ អនុសេតិ** បានដល់ កាមរាគា-នុស័យកើតឡើងក្នុងវេទនាទាំង ២ នេះ អធិប្បាយថា កាមរាគានុស័យនេះ រមែងដេកត្រាំដោយអាការ ២ យ៉ាង គឺដោយអំណាចនៃការកើតរួម និងដោយអំណាចនៃអារម្មណ៍ក្នុងសុខវេទនា និងឧបេក្ខាវេទនា ដែលជាអកុសលទាំងឡាយ ។ អនុស័យនោះ ជាធម៌កើតព្រមជាមួយវេទនាខ្លះ និងឧបេក្ខា-វេទនាដែលជាអកុសលខ្លះ រមែងធ្វើវេទនាទាំង ២ នោះឲ្យជាអារម្មណ៍កើតឡើងខ្លះ ធ្វើវេទនាក្នុងកាមាវចរកុសលវិបាក និងកិរិយាដ៏សេសឲ្យជាអារម្មណ៍យ៉ាងនោះឯងកើតឡើងខ្លះ ។ ម្យ៉ាងទៀត អនុស័យនោះ កាល

ដេកត្រាំក្នុងវេទនាទាំង ២ ក្នុងកាមធាតុ រមែងដេកក្នុងសញ្ញា សង្ខារ និង វិញ្ញាណដែលសម្បយុត្តដោយវេទនាទាំង ២ នោះ ។ តែអនុស័យដែលដេកត្រាំក្នុងវេទនាទាំង ២ មិនអាចនឹងមិនកើតរួមជាមួយសញ្ញាជាដើម ដែលសម្បយុត្តដោយវេទនានោះ ឬមិនធ្វើសញ្ញាជាដើម ដែលសម្បយុត្តដោយវេទនានោះ ឲ្យជាអារម្មណ៍ហើយកើតឡើង ។

កាលបើភាពយ៉ាងនោះមាន ទើបវេទនាទាំង ២ នេះ ជាប្រធានក្នុងសម្បយុត្តធម៌ដ៏សេស ព្រោះការកើតឡើងនៃកាមរាគានុស័យ ព្រោះអត្ថថាគាប់ចិត្តដោយភាពជាសុខ ដែលមានការត្រេកអរ និងការស្ងប់ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា កាមរាគានុស័យ ដេកសម្ងំនៅក្នុងវេទនាពីរទុំះជាដើម ។ ពិតហើយ សុខវេទនាមាន ក្នុងវេនេយ្យសត្វដែលគប្បីត្រាស់ដឹងធម៌ ដើម្បីការត្រាស់ដឹងធម៌ ដោយអំណាចនៃសភាវៈដែលឧឡារ គឺយ៉ាងគ្រោតគ្រាត ។

ម្យ៉ាងទៀត កាមរាគានុស័យនេះ កាលដេកត្រាំដោយអំណាចនៃអារម្មណ៍ រមែងដេកក្នុងវេទនាទាំង ២ ក្នុងធម៌ដែលសម្បយុត្តដោយវេទនាទាំង ២ នេះ ត្រឹមប៉ុណ្ណោះក៏មិនមែន រមែងដេកត្រាំក្នុងរូបដែលគួរប្រាថ្នាជាដើមនោះឯង ពាក្យនេះ ព្រះមានព្រះភាគក៏ត្រាស់ក្នុងវិភង្គប្បករណ៍ថា ឥដ្ឋារម្មណ៍ណាក្នុងលោក មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ កាមរាគានុសយៈរបស់ពួកសត្វ រមែងដេកត្រាំក្នុងឥដ្ឋារម្មណ៍នោះ ដូច្នេះមិនមែនឬ សូម្បីក្នុងគម្ពីរយមកៈនេះ ក៏ត្រាស់ក្នុងបដិលោមន័យ របស់

អនុសយវារៈថា កាមរាគានុស័យ មិនដេកសម្ងំនៅ ក្នុងទីណា ទិដ្ឋានុស័យ មិនដេកសម្ងំនៅ ក្នុងទីនោះដែរឬ ដូច្នេះ ។ កាមរាគានុស័យ មិនដេកត្រាំ ក្នុងទីនេះ គឺត្រង់ទុក្ខវេទនា ត្រង់រូបធាតុ អរូបធាតុ តែទិដ្ឋានុស័យ មិនមែន មិនដេកត្រាំក្នុងទីនោះទេ កាមរាគានុស័យ មិនដេកត្រាំ ទិដ្ឋានុស័យ ក៏មិន ដេកត្រាំ ក្នុងទីនេះ គឺត្រង់អបរិយាបន្នធម៌ ។

ពិតហើយ ក្នុងសេចក្ដីនេះ កាមរាគានុស័យ វៀរទុក្ខវេទនា ព្រមទាំង សម្បយុត្តធម៌ វៀររូបាវចរធម៌ អរូបាវចរធម៌ ដែលប្រព្រឹត្តទៅក្នុងភូមិ និង វៀរលោកុត្តរធម៌ ៩ ព្រោះបានត្រាស់ថា កាមរាគានុស័យ មិនដេកត្រាំក្នុង ទុក្ខវេទនា និងក្នុងរូបធាតុជាដើម ទើបឈ្មោះថា ដេកត្រាំក្នុងរូប សំឡេង ក្លិន រស និងផោដ្ឋព្វៈដ៏សេស ។

សួរថា ព្រោះហេតុអ្វី ទើបមិនត្រាស់ពាក្យនោះក្នុងបករណ៍នេះ ឆ្លើយ ថា ព្រោះភាពដែលសភាវៈទាំងនោះជារបស់ល្អិត ។

ពិតហើយ ទ្រង់មិនត្រាស់ថា កាមរាគានុស័យ រមែងដេកសម្ងំនៅ ក្នុងរូបទាំងនេះជាដើម ព្រោះភាពដែលវេទនាទាំង ២ ប៉ុណ្ណោះជាសភាវៈ គ្រោតគ្រាត និងព្រោះភាពដែលអារម្មណ៍ទាំងនេះជាអារម្មណ៍ល្អិត ដោយ ន័យដែលបានពោលហើយខាងដើម តែកាលពោលដោយអត្ថហើយ រមែង កើតបាន ព្រោះហេតុនោះ គប្បីជ្រាបថា កាមរាគានុស័យ រមែងដេកត្រាំ ក្នុងរូបទាំងឡាយនោះឯងផងដែរ ។

ពិតហើយ ព្រះសាស្ដា មិនត្រាស់ដល់ធម៌ទាំងពួង ក្នុងទីទាំងពួង តែ

ធម៌ណា ដែលឃើញបានដោយអំណាចនៃសត្វ ដែលទ្រង់ទូន្មានដើម្បី ឲ្យដឹងធម៌ ក៏រមែងត្រាស់ធម៌ទាំងអស់ ដោយហេតុនេះ ទើបមិនត្រាស់ក្នុងទីខ្លះ ។ ពិតហើយ ពាក្យណាដែលទ្រង់ត្រាស់បុច្ឆាថា ទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទីណា ដូច្នេះ រមែងបានពាក្យវិសជ្ជនាយ៉ាងនេះថា ទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងទីនេះ គឺក្នុងធម៌ទាំងឡាយដែលទាក់ទងដោយសក្កាយៈទាំងពួង ដូច្នេះ ធម៌ទាំងអស់នោះ ទ្រង់ត្រាស់ហើយ ។

ក្នុងទីដទៃទៀត ពាក្យណា រមែងបាននូវពាក្យវិសជ្ជនា យ៉ាងនេះថា វិចិកិច្ឆានុស័យ មានានុស័យ និងទិដ្ឋានុស័យ រមែងដេកត្រាំក្នុងទីនេះ គឺត្រង់រូបធាតុ និងអរូបធាតុ វិចិកិច្ឆានុស័យ កាមរាគានុស័យ មានានុស័យ ទិដ្ឋានុស័យ រមែងដេកត្រាំក្នុងទីនេះ គឺត្រង់វេទនា ២ ក្នុងកាមធាតុ វិចិកិច្ឆានុស័យ បដិឃានុស័យ ទិដ្ឋានុស័យ អវិជ្ជានុស័យ ដេកត្រាំក្នុងទីនេះ គឺត្រង់ទុក្ខវេទនា ដូច្នេះ ទ្រង់មិនបានត្រាស់ពាក្យទាំងអស់នោះ ត្រាស់ត្រឹមតែវេទនា ៣ និងរូបធាតុ អរូបធាតុប៉ុណ្ណោះ ។ អរូបធម៌ដែលសម្បយុត្តដោយវេទនា និងរូបទាំងអស់ មិនបានត្រាស់ ។ មិនបានត្រាស់ក៏ពិតតែទិដ្ឋានុស័យ ក៏រមែងដេកត្រាំក្នុងទីនោះឯង ។ ក្នុងទីនេះ មិនបានត្រាស់ឥដ្ឋារម្មណ៍ មានរូបជាដើមក៏ពិត តែកាមរាគានុស័យ ក៏រមែងដេកត្រាំក្នុងរូបដែលជាឥដ្ឋារម្មណ៍យ៉ាងនោះឯង ។ បណ្ឌិតគប្បីជ្រាបទីជាទីដេកត្រាំនៃកាមរាគានុស័យដូចពណ៌នាមក ដូច្នេះ ។

បណ្ឌិតគប្បីជ្រាបទីជាទីដេកត្រាំនៃបដិឃានុស័យ ដោយព្រះបាលីថា

**ទុក្ខាយ វេទនាយ** *ជាដើមថា បានដល់ វេទនាទាំង ៣ គឺទោមនស្សវេទនា ២ និងទុក្ខវេទនាដែលសម្បយុត្តដោយកាយវិញ្ញាណ ១ ។ បដិឃានុស័យនោះ រមែងដេកត្រាំក្នុងទោមនស្សវេទនា ដោយអាការ ២ យ៉ាង គឺដោយអំណាចនៃការកើតឡើងព្រមគ្នា និងដោយអំណាចនៃអារម្មណ៍ និងរមែងដេកត្រាំក្នុងទុក្ខវេទនាដ៏សេស ដោយអំណាចនៃអារម្មណ៍ ។ បដិឃានុស័យនោះ កាលដេកត្រាំក្នុងវេទនាទាំងនោះ រមែងដេកត្រាំក្នុងសញ្ញាខន្ធជាដើមដែលសម្បយុត្តដោយវេទនាទាំងនោះ ។ ពិតហើយ បដិឃានុស័យនេះកើតឡើងរួមជាមួយវេទនាណា ក៏ជាសភាវៈកើតរួមជាមួយធម៌ទាំងឡាយមានសញ្ញាជាដើម ដែលសម្បយុត្តដោយវេទនានោះឯង ឬថា រមែងធ្វើវេទនាណាឲ្យជាអារម្មណ៍ ក៏រមែងធ្វើធម៌ទាំងឡាយ មានសញ្ញាជាដើម ដែលសម្បយុត្តដោយវេទនានោះឲ្យជាអារម្មណ៍ដូចគ្នា ។ កាលបើភាពយ៉ាងនោះមាន ទើបទុក្ខវេទនានោះឯង ជាធំក្នុងសម្បយុត្តធម៌ដ៏សេស ព្រោះការកើតឡើងនៃបដិឃានុស័យ ដោយអត្ថថា មិនគាប់ចិត្ត ព្រោះភាពដែលខ្វួនសោយទុក្ខក្នុងធម៌ដែលមិនគាប់ចិត្ត ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ពាក្យនេះថា បដិឃានុស័យ ដេកសម្ងំនៅ ក្នុងទុក្ខវេទនានុ៎ះ ដូច្នេះ ។ ពិតហើយសេចក្ដីសុខ គឺសុខវេទនា ក្នុងផៅពង្សនៃសត្វដែលទ្រង់ទូន្មានក្នុងការត្រាស់ដឹងធម៌ ដើម្បីការត្រាស់ដឹងធម៌ដោយអំណាចនៃសភាវៈដែលឧឡារមាន ។*

*ម្យ៉ាងទៀត បដិឃានុស័យនេះ កាលដេកត្រាំដោយអំណាចនៃអារម្មណ៍ រមែងមិនដេកត្រាំក្នុងទុក្ខវេទនា និងក្នុងសម្បយុត្តធម៌នៃវេទនានោះ តែម្យ៉ាង*

ប៉ុណ្ណោះទេ តែរមែងដេកត្រាំក្នុងធម៌ទាំងឡាយ មានរូបជាដើម ដែលមិនគួរប្រាថ្នាផងដែរ ។ ដូចពាក្យដែលត្រាស់ក្នុងគម្ពីរវិភង្គប្បករណ៍ថា អនិដ្ឋារម្មណ៍ណាក្នុងលោក មានសភាពមិនគួរស្រឡាញ់ មានសភាពមិនគួរត្រេកអរ បដិឃានុសយៈរបស់សត្វ រមែងដេកត្រាំក្នុងអនិដ្ឋារម្មណ៍នោះ ដូច្នេះ មិនមែនឬ ។ សូម្បីក្នុងបករណ៍នៃយមកៈនេះ ក្នុងបដិលោមន័យរបស់អនុសយវារៈក៏ត្រាស់ថា បដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងវេទនាពីរទុំះ ក្នុងកាមធាតុ តែកាមរាគានុស័យមិនមែនជាមិនដេកសម្ងំនៅ ក្នុងវេទនាពីរនោះទេ បដិឃានុស័យ មិនដេកសម្ងំនៅ ក្នុងរូបធាតុ ក្នុងអរូបធាតុ និងក្នុងអបរិយាបន្នទុំះ ទាំងកាមរាគានុស័យ ក៏មិនដេកសម្ងំនៅដែរ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់អធិប្បាយថា បដិឃានុស័យ រមែងដេកត្រាំក្នុងធម៌ទាំងឡាយដ៏សេស មានរូបជាដើម ដោយវៀរវេទនា ២ ( សុខវេទនា និងឧបេក្ខាវេទនា ) ព្រមទាំងសម្បយុត្តធម៌ វៀររូបាវចរធម៌ និងអរូបាវចរធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ និងវៀរលោកុត្តរធម៌ ៩ ព្រោះភាពដែលទេសនានោះ ទ្រង់ត្រាស់ថា បដិឃានុស័យ រមែងមិនដេកត្រាំក្នុងកាមាវចរវេទនាទាំង ២ និងក្នុងរូបធាតុជាដើម ដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ទើបមិនត្រាស់ពាក្យនោះក្នុងទីនេះ ឆ្លើយថា ព្រោះជាសភាវៈល្អិត ។

ពិតហើយ ព្រះមានព្រះភាគមិនត្រាស់ថា បដិឃានុស័យ រមែងដេកត្រាំដល់ធម៌ទាំងនេះ ព្រោះភាពដែលទុក្ខវេទនាជាធំ ដោយន័យដែល

ពោលហើយខាងដើមនោះឯង និងក្នុងធម៌ទាំងឡាយ មានរូបជាដើម ព្រោះជាធម៌ល្អិត ដូច្នេះ តែបើពោលដោយអត្ថហើយ រមែងកើតបាន ព្រោះហេតុនោះ គប្បីជ្រាបថា បដិឃានុស័យ រមែងដេកត្រាំក្នុងធម៌ទាំងឡាយ មានរូបជាដើមនោះឯង ដូច្នេះ ។

សួរថា វេទនាទាំង ២ ក្រៅអំពីនេះ ជាឥដ្ឋារម្មណ៍មិនជាអារម្មណ៍របស់បដិឃៈដែរឬ ឆ្លើយថា វេទនាទាំង ២ ក្រៅអំពីនេះ មិនជាអារម្មណ៍របស់បដិឃៈក៏មិនមែន ។

ពិតហើយ ទោមនស្សរបស់បុគ្គលដែលមានឈានសាបសូន្យហើយ រមែងកើតព្រោះប្រារព្ធវេទនាទាំងនោះ ដែលប្រព្រឹត្តទៅជាមួយសម្បយុត្តធម៌ ដោយអំណាចនៃការក្តៅក្រហាយ រមែងកើតព្រោះតាមរឭកដល់ការវិនាសរបស់បុគ្គលដែលបានឥដ្ឋារម្មណ៍ខ្លះ រមែងកើតព្រោះតាមរឭកដល់វត្ថុដែលមិនបានរបស់បុគ្គលដែលមិនបានឥដ្ឋារម្មណ៍ខ្លះ ។ សេចក្តីនេះ ត្រឹមតែជាទោមនស្សប៉ុណ្ណោះ មិនជាបដិឃានុស័យឡើយ ព្រោះបដិឃានុស័យនោះ ជាកិលេសដែលមានកម្លាំង ដែលកើតឡើងដោយអំណាចនៃការប៉ះខ្ទប់ក្នុងអនិដ្ឋារម្មណ៍ ព្រោះហេតុនោះ បដិឃៈ សូម្បីកើតរួមជាមួយទោមនស្សក្នុងទីនេះ រមែងមិនជាបដិឃានុស័យ ព្រោះមិនធ្វើបដិឃកិច្ចរបស់ខ្លួននោះឯង រមែងដល់នូវភាពជាអព្យាហារិក ។

ព្យាបាទ សូម្បីកើតរួមជាមួយចេតនាក្នុងបាណាតិបាត មិនឈ្មោះថាជាមនោកម្ម រមែងដល់នូវភាពជាអព្យាហារិក យ៉ាងណា សេចក្តីនេះ ក៏

យ៉ាងនោះ មិនជាបដិឃានុស័យ រមែងដល់នូវភាពជាអព្យោហារិក សមដូច លោកពោល ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ភិក្ខុនោះ រមែង លះបង់នូវបដិឃៈដោយទោមនស្ស ឯបដិឃានុស័យក៏ដេកសម្ងំនៅ ក្នុង ទោមនស្សនោះមិនបានទេ ដូច្នេះ ។ បណ្ឌិតគប្បីជ្រាបទីជាទីដេកត្រាំនៃ បដិឃានុស័យ ដូចពណ៌នាមក ដូច្នេះ ។

ទីជាទីដេកត្រាំនៃមានានុស័យ ដោយព្រះបាលីថា **កាមធាតុយា ទ្វីសុ វេទនាសុ** ជាដើម មាន ៣ យ៉ាង គឺកាមាវចរវេទនា ២ រូបធាតុ និង អរូបធាតុ ១ ។ បណ្ឌិតគប្បីជ្រាបការដេកត្រាំនៃមានានុស័យ ដែលជា សហជាត ដូចកាមរាគានុស័យក្នុងអកុសលវេទនាទាំងឡាយ ។ មានានុស័យ រមែងដេកត្រាំក្នុងកាមាវចរទាំងអស់ មួយអន្លើដោយសម្បយុត្តធម៌ក្នុងសុខ ទុក្ខ អទុក្ខមសុខវេទនាទាំងឡាយ និងក្នុងរូបធាតុទាំងឡាយ ដោយអំណាច នៃអារម្មណ៍ ។ ក្នុងបដិលោមន័យរបស់អនុសយវារៈ មានានុស័យនេះ វៀរទុក្ខវេទនា និងលោកុត្តរធម៌ ៩ រមែងដេកត្រាំក្នុងរូបធាតុ និងអរូបធាតុ ដ៏សេសប៉ុណ្ណោះ ព្រោះព្រះមានព្រះភាគត្រាស់ថា កាមរាគានុស័យ មិនដេក សម្ងំនៅ ក្នុងទុក្ខវេទនាទុ៎ះ ក្នុងអបរិយាបន្ន ទាំងមានានុស័យ ក៏មិនដេក សម្ងំនៅដែរ ដូច្នេះ ។ គប្បីជ្រាបទីជាទីដេកត្រាំនៃមានានុស័យ ដូចពណ៌នា មក ដូច្នេះ ។

ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ រមែងមិនដេកត្រាំក្នុងលោកុត្តរធម៌ តែម្យ៉ាងប៉ុណ្ណោះ ។ ពិតហើយ គង់ដេកត្រាំក្នុងធម៌ទាំងពួងនោះឯង ដែល

ប្រព្រឹត្តទៅក្នុងភូមិ ៣ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ទិដ្ឋានុស័យ ដេកសម្ងំនៅ ក្នុងពួកធម៌ដែលរាប់បញ្ចូលក្នុងសក្កាយទាំងអស់ទុំះ ។ វិចិកិច្ឆានុស័យ ដេកសម្ងំនៅ ក្នុងពួកធម៌ដែលរាប់បញ្ចូលក្នុងសក្កាយទាំងអស់ទុំះ ដូច្នេះ ។ ក្នុងបទទាំងនោះ ពាក្យថា ដែលរាប់បញ្ចូលក្នុងសក្កាយទាំងអស់ទុំះ បានដល់ ក្នុងធម៌ទាំងពួងដែលរាប់បញ្ចូលដោយសក្កាយ ព្រោះអត្ថថា អាស្រ័យសង្សារវដ្ដ ដូច្នេះ ។ ក្នុងសេចក្ដីនោះ បណ្ឌិតគប្បីជ្រាបថា ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យទាំងនេះ រមែងដេកត្រាំក្នុងចិត្តុប្បាទ ៥ ដួង គឺលោភសម្បយុត្តចិត្ត ៤ វិចិកិច្ឆាសម្បយុត្តចិត្ត ១ ដោយអំណាចនៃការដេកត្រាំ ដែលជាសហជាត ឬថា ធម៌ទាំង ២ នោះ រមែងដេកត្រាំ ដោយអំណាចនៃការដេកត្រាំក្នុងអារម្មណ៍ ក្នុងបវត្តិកាល ព្រោះប្រារព្ធចិត្តុប្បាទ ៥ ដួង ឬធម៌ដទៃ ដែលប្រព្រឹត្តទៅជាមួយភូមិ ៣ ដូច្នេះ បណ្ឌិតគប្បីជ្រាបទីជាទីដេកត្រាំនៃទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ដូចពណ៌នាមក ដូច្នេះ ។

ភវរាគានុស័យ បណ្ឌិតគប្បីពោលថា រមែងដេកត្រាំក្នុងវេទនា ២ ក្នុងកាមធាតុដោយអំណាចនៃការដេកត្រាំដែលជាសហជាត ព្រោះការកើតឡើងក្នុងទិដ្ឋិវិប្បយុត្តចិត្ត ៤ ដួងក៏ពិត តែភវរាគានុស័យនោះ កាលកើតជាមួយវេទនា ២ ក្នុងកាមធាតុ រមែងបានចំពោះក្នុងរូបាវចរធម៌ អរូបាវចរធម៌ប៉ុណ្ណោះ និងរមែងមិនធ្វើធម៌ឯណានីមួយ ដែលរាប់បញ្ចូលដោយកាមធាតុឲ្យជាអារម្មណ៍ ព្រោះហេតុនោះ ព្រះមានព្រះភាគត្រាស់ថា ភវរាគានុស័យ រមែងដេកត្រាំក្នុងទីនេះ គឺត្រង់រូបធាតុ ត្រង់អរូបធាតុនេះ ដោយ

កំណត់ដោយអំណាចនៃការដេកត្រាំក្នុងអារម្មណ៍ ដូច្នេះ ។ម្យ៉ាងទៀត ឈ្មោះថា រាគៈនេះ មាន ២ យ៉ាង ដោយអំណាចនៃកាមរាគៈ និងភវរាគៈ ។

ក្នុង ២ យ៉ាងនោះ កាមរាគៈ លោកពោលថា រមែងដេកត្រាំក្នុងវេទនា ២ ក្នុងកាមធាតុ ដូច្នេះ ។

បើភវរាគៈគប្បីកើតដូចកាមរាគៈយ៉ាងនេះសោត ការសម្តែងភវរាគៈនិងកាមរាគៈ ក៏គប្បីទាក់ទងគ្នា ព្រោះហេតុនោះ ទ្រង់ញែកកិលេស មានរាគៈជាដើម ២ យ៉ាង ដើម្បីសម្តែងការផ្សេងគ្នានៃកាមរាគៈ និងភវរាគៈហើយ ទើបទ្រង់សម្តែងទេសនាយ៉ាងនេះ ។ បណ្ឌិតគប្បីជ្រាបទីជាទីដេកត្រាំនៃភវរាគានុស័យ ដូចពណ៌នាមក ដូច្នេះ ។

អវិជ្ជានុស័យ រមែងដេកត្រាំក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា អវិជ្ជានុស័យ ដេកសម្ងំនៅក្នុងពួកធម៌ ដែលរាប់បញ្ចូលក្នុងសក្កាយទាំងអស់នុ៎ះ ដូច្នេះ ។ បណ្ឌិតគប្បីជ្រាបភាពដែលអវិជ្ជានុស័យជាធម៌ដេកត្រាំ ដែលជាសហជាត ក្នុងចិត្តុប្បាទ ១២ ដួង ។ បើពោលដោយអំណាចនៃការធ្វើឲ្យជាអារម្មណ៍ហើយ អវិជ្ជានុស័យ មិនប្រារព្ធធម៌ណាមួយ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ហើយប្រព្រឹត្តទៅមិនមាន ។ បណ្ឌិតគប្បីជ្រាបទីជាទីកើតឡើងនៃអវិជ្ជានុស័យ ដូចពណ៌នាមក ដូច្នេះ ។ នេះជាវិនិច្ឆ័យកថា ក្នុងបរិច្ឆេទវារៈ បរិច្ឆិន្នុទ្ទេសវារៈ ឧប្បត្តិដ្ឋានវារៈ មានប្រមាណប៉ុណ្ណោះ ។

# មហាវារៈ ៧

## អនុសយវារៈ

[ ២ ] ក្នុងអនុសយវារៈទី ១ នៃមហាវារៈ ៧ ពាក្យណាដែលពោលថា **យស្ស កាមរាគានុសយោ អនុសេតិ តស្ស បដិឃានុសយោ អនុសេតិ** ដូច្នេះ ពាក្យឆ្លើយទទួលថា **អាមន្តា** ដូច្នេះ ពាក្យនោះ ប្រាកដបីដូចឲ្យនូវចម្លើយដែលមិនជាក់ច្បាស់ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះកាមរាគៈ និងបដិឃៈមិនកើតក្នុងខណៈជាមួយគ្នា ដូចមនាយតនៈ ធម្មាយតនៈ កាយសង្ខារ វចីសង្ខារ រមែងកើតឡើងក្នុងខណៈជាមួយគ្នា ក្នុងពាក្យថា មនាយតនៈកើតឡើងដល់បុគ្គលណា ធម្មាយតនៈ កើតឡើងដល់បុគ្គលនោះដែរឬ ដូច្នេះ លោកឆ្លើយទទួលថា **អាមន្តា** ក្នុងខណៈនៃការកើតឡើងនៃខ្យល់អស្សាសបស្សាសៈ កាយសង្ខារកើតឡើង វចីសង្ខារកើតឡើងដល់បុគ្គលនោះជាដើម យ៉ាងណា កាមរាគៈ និងបដិឃៈ រមែងកើតយ៉ាងនោះ ក៏មិនមែន ព្រោះថា កាមរាគៈ រមែងកើតក្នុងលោភសហគតចិត្តុប្បាទ ៨ ដួង ឯបដិឃៈ រមែងកើតក្នុងទោមនស្សសហគតចិត្តុប្បាទ ២ ដួង ដោយប្រការដូច្នេះ ការកើតឡើងក្នុងខណៈតែមួយរបស់ធម៌ទាំងនោះ គឺកាមរាគៈ និងបដិឃៈ មិនមាន ព្រោះហេតុនោះ បណ្ឌិតគប្បីធ្វើពាក្យបដិសេធក្នុងទីនេះថា **នោ** ( មិនមែនទេ ) ដូច្នេះ ៗ ក្នុងទីនេះ លោកមិនកាន់យកវោហារដែលកំពុងប្រព្រឹត្តទៅ ដោយអំណាចនៃបច្ចុប្បន្នក្ខណៈ ហាក់បីដូចក្នុងយមកៈទាំងឡាយខាងដើម ព្រោះសេចក្ដីនោះ មិនបដិសេធក៏ត្រូវឆ្លើយទទួលថា **អាមន្តា** ដូច្នេះ ទើបគួរកាន់យកដោយប្រការដទៃ ៗ

*សួរថា គួរកាន់យកដោយអាការដូចម្ដេច ឆ្លើយថា ដោយអំណាចនៃកិលេសដែលមិនទាន់លះបាន ពិតហើយ វោហារដែលកំពុងប្រព្រឹត្តទៅថា* **អនុសេតិ** *នេះ លោកពោលសំដៅយកកិលេសដែលមិនទាន់លះបាន មិនមែនសំដៅយកភាពជាបច្ចុប្បន្នក្ខណៈ ព្រោះលោកពោលសំដៅយកភាពដែលកិលេស ដែលជាសភាវៈមិនទាន់លះបាន ដូច្នោះ បណ្ឌិតគប្បីជ្រាបអត្ថយ៉ាងនេះថា កាមរាគានុស័យដែលបុគ្គលណា មិនទាន់លះបាន សូម្បីបដិឃានុស័យ ក៏បុគ្គលនោះមិនទាន់លះបាន ព្រោះជាសភាវៈឲ្យដល់នូវភាពជាធម៌មិនដេកត្រាំ ក្នុងពាក្យបុច្ឆាថា កាមរាគានុស័យរបស់បុគ្គលណាដេកសម្ងំនៅ បដិឃានុស័យរបស់បុគ្គលនោះ ដេកសម្ងំនៅដែរឬ ដូច្នេះ ។*

*ម្យ៉ាងទៀត ក្នុងអនុស័យទាំងនោះ អនុស័យមួយដែលបុគ្គលណា មិនទាន់លះបាន អនុស័យក្រៅពីនេះ បុគ្គលនោះ ក៏មិនទាន់លះបាននោះឯង ព្រោះហេតុនោះ ទើបពោលថា* **អាមន្តា** *ដូច្នេះ ។*

*បើពាក្យណា លោកទទួលថា* **អាមន្តា** *ក្នុងឧប្បជ្ជនវារៈខាងមុខ ព្រោះពាក្យសួរយ៉ាងនេះថា កាមរាគានុស័យ កើតឡើងដល់បុគ្គលណា បដិឃានុស័យ កើតឡើងដល់បុគ្គលនោះដែរឬ ដូច្នេះ ។ ក្នុងពាក្យនោះ គប្បីកាន់យកអត្ថដូចម្ដេច ។ ក្នុងសេចក្ដីនោះ លោកកាន់យកដោយអំណាចនៃកិលេសដែលមិនទាន់លះបាននោះឯង ឬថា កាលបច្ច័យ គឺការកើតឡើងមាន ក៏គប្បីកាន់យកដោយអំណាចនៃការមិនបដិសេធការកើត ។*

*ឧបមាដូចជាងគំនូរជាដើម ផ្ដើមចិត្រកម្ម មានការគូរជាដើម កាល*

ការងារមិនទាន់សម្រេច ត្រូវមិត្តសម្លាញ់ជាដើមសួរថា អ្នកធ្វើអ្វីក្នុងថ្ងៃទាំងនេះ ក្នុងទីដែលខ្ញុំឃើញហើយ ក្នុងខណៈដែលមិនទាន់ធ្វើការងារទាំងនោះ ក៏រមែងពោលថា ខ្ញុំកំពុងធ្វើចិត្រកម្ម កំពុងធ្វើកដ្ឋកម្ម ( ការងារដែលធ្វើដោយឈើ ) ខណៈនោះ មិនបានធ្វើចិត្រកម្មជាដើមក៏ពិត តែក៏ឈ្មោះថា កំពុងធ្វើនោះឯង ព្រោះអាស្រ័យខណៈដែលធ្វើហើយ និងខណៈដែលគួរធ្វើតទៅ ព្រោះការងារមិនទាន់សម្រេច យ៉ាងណា អនុស័យទាំងឡាយ ក្នុងសន្តានណា ដែលមិនទាន់លះបាន ក៏យ៉ាងនោះឯង ឬថា កាលបច្ច័យឲ្យកើតអនុស័យទាំងនោះ នៅមានក្នុងសន្តានណា ការកើតឡើងនៃអនុស័យទាំងនោះ ដែលធម្មជាតមិនបានហាម ក្នុងសេចក្តីនោះ បណ្ឌិតគប្បីជ្រាបអត្ថនៃអនុស័យ ក្នុងខណៈដែលមិនទាន់កើតឡើងយ៉ាងនេះថា កាមរាគានុស័យកំពុងកើតឡើងដល់បុគ្គលណា ព្រោះអាស្រ័យកាលដែលធ្លាប់កើតហើយផង និងកើតឡើងក្នុងកាលដទៃផង បដិយានុស័យរបស់បុគ្គលនោះ ក៏ឈ្មោះថា កំពុងកើតឡើងនោះឯង ដូច្នេះ ក្នុងការវិសជ្ជនាដទៃអំពីនេះក្តី ដែលមានសភាពបែបនេះក្តី ក៏ន័យនេះឯង ។

បទថា **នោ ច តស្ស** នេះ ព្រះមានព្រះភាគ ត្រាស់ព្រោះភាពដែលកាមរាគៈ និងព្យាបាទ ជាសភាវៈដែលព្រះអនាគាមីលះបានហើយ ដោយមិនសេសសល់ ។

បទថា **តិណ្ណំ បុគ្គលានំ** បានដល់ ដល់បុថុជ្ជន ព្រះសោតាបន្ន និងព្រះសកទាគាមី ។

បទថា **ទ្វិន្នំ បុគ្គលានំ** បានដល់ ព្រះសោតាបន្ន និងព្រះសកទាគាមី ។ ក្នុងខណៈទាំងឡាយ ដែលមានសភាពបែបនេះ ខាងមុខក៏ន័យនេះឯង ។

ក្នុងពាក្យសួរទី ១ និងទី ២ នៃឱកាសវារៈ លោកធ្វើការបដិសេធថា **នោ** ដូច្នេះ ព្រោះកាមរាគានុស័យ ដេកត្រាំត្រង់វេទនា ២ ក្នុងកាមធាតុ បដិឃានុស័យ ដេកត្រាំត្រង់ទុក្ខវេទនា ។

ក្នុងពាក្យសួរទី ៣ លោកពោលទទួលថា **អាមន្តា** ព្រោះការដេកត្រាំនៃធម៌ទាំង ២ ក្នុងវេទនាទាំង ២ ក្នុងកាមធាតុ ។ ឋានៈ គឺទីជាទីកើតឡើងនៃមានានុស័យក្នុងរូបធាតុ អរូបធាតុ និងដោយកាមរាគានុស័យនោះជាទីដែលមិនទូទៅ ព្រោះហេតុនោះ ទើបត្រាស់ថា **នោ ច តត្ថ កាមរាគា-នុសយោ** ដូច្នេះ ។ ដោយន័យនេះ បណ្ឌិតគប្បីពិនិត្យមើលវារៈពោលអំពីទីជាទីកើតឡើងនៃអនុស័យទាំងពួង ហើយគប្បីជ្រាបទីជាទីកើតឡើងនៃអនុស័យទាំងពួង ដែលជាសាធារណៈ និងអសាធារណៈ ។

ក្នុងពាក្យសួរដែលមានមូល ២ ព្រោះកាមរាគានុស័យ និងបដិឃា-នុស័យ រមែងមិនកើតក្នុងទីជាមួយគ្នា និងរមែងមិនធ្វើធម៌តែមួយ ឲ្យជាអារម្មណ៍ ព្រោះហេតុនោះ ទើបធ្វើបដិសេធថា **នត្ថិ** ( មិនមានទេ ) ដូច្នេះ ។ ក្នុងទីនេះ មានអធិប្បាយថា អនុស័យទាំង ២ នេះ គប្បីដេកត្រាំក្នុងទីណា ទីនោះ រមែងមិនជាទីជាមួយគ្នា ព្រោះហេតុនោះ ពាក្យសួរនេះថា មានា-នុស័យ ដេកត្រាំក្នុងទីណា ដូច្នេះ ឈ្មោះថា មិនជាពាក្យបុច្ឆាឡើយ ។ ក្នុងអនុស័យដទៃៗ ដែលមានសភាពបែបនេះ ក៏ន័យនេះឯង ។

បទថា **ចតុន្នំ** ក្នុងបុគ្គលោកាសវារៈ បានដល់ បុគ្គល ៤ ពួក គឺ បុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី ។

ក្នុងបដិលោមន័យ ពាក្យសួរថា **យស្ស កាមរាគានុសយោ នានុសេតិ** ជាដើម ព្រះមានព្រះភាគ ទ្រង់សំដៅដល់ព្រះអនាគាមីហើយ ទើបត្រាស់សួរ ។ ពាក្យសួរថា **ទ្វិន្នំ បុគ្គលានំ សព្វត្ថ កាមរាគានុសយោ នានុសេតិ** ដូច្នេះ ព្រះមានព្រះភាគ ទ្រង់សំដៅដល់ព្រះអនាគាមី និងព្រះអរហន្ត ។ បណ្ឌិតគប្បីជ្រាបការកាន់យកកាមាវចរធម៌ទាំងអស់ ដែលសម្បយុត្តដោយវេទនា ដោយការកាន់យកវេទនា ក្នុងព្រះបាលីថា **កាមធាតុយា តីសុ វេទនាសុ** ដូច្នេះខ្លះ និងកាន់យកវត្ថុ និងអារម្មណ៍នៃធម៌ទាំងនោះខ្លះ ។

**អនុសយវារៈ ចប់**

## សានុសយវារកថា

[ ៦៨ ] ក្នុងសានុសយវារៈ ព្រះមានព្រះភាគត្រាស់ថា **យោ កាមរាគានុសយេន សានុសយោ** នេះ អធិប្បាយថា ប្រៀបដូចបុគ្គលដែលមានអាពាធ ដោយរោគណាមួយ មានរោគជរដែលពិតប្រាកដជាដើម ដរាបណា រោគទាំងឡាយ មិនទាន់ផុតអំពីបុគ្គលនោះ បុគ្គលនោះ ឈ្មោះថា ជាអ្នកមានរោគ ក្នុងខណៈនៃរោគនោះមិនទាន់កើត យ៉ាងណា សេចក្តីនេះ ក៏យ៉ាងនោះ អនុស័យទាំងឡាយនៃសត្វដែលមានកិលេស ដែលមានប្រក្រតីទៅតាមវដ្ដៈ មិនទាន់ដល់នូវការដកឡើង ដោយអរិយមគ្គ ដរាបណា

*សូម្បីក្នុងខណៈដែលអនុស័យទាំងនោះ មិនទាន់កើតឡើង បុគ្គលនោះ ក៏ឈ្មោះថា ជាអ្នកប្រព្រឹត្តទៅជាមួយអនុស័យ គឺមានអនុស័យនោះឯង ព្រោះអាស្រ័យភាពដែលសត្វជាអ្នកមានអនុស័យបែបនេះ ទើបឆ្លើយទទួលដោយពាក្យថា* **អាមន្តា** *ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីនេះ ដូចគ្នានឹងអនុសយវារៈនោះឯង ។*

*ក្នុងឱកាសវារៈ ព្រះមានព្រះភាគត្រាស់ថា* **រូបធាតុយា អរូបធាតុយា ឯត្ថ មានានុសយេន សានុសយោ** *អធិប្បាយថា ក្នុងធាតុទាំងឡាយនោះ ភាពដែលបុគ្គលប្រព្រឹត្តទៅជាមួយអនុស័យគប្បីប្រាកដ តែទីជាទីកើតឡើងនៃអនុស័យ មិនគប្បីប្រាកដ ដើម្បីសម្តែងទីជាទីកើតឡើងនៃអនុស័យនោះ ទើបទ្រង់ផ្តើមវារៈនេះ ព្រោះហេតុនោះ ទើបត្រាស់ថា* **តតោ មានានុសយេន សានុសយោ** *ជាដើម ។ កាលបើយ៉ាងនោះ ទើបជាការសម្តែងទីជាទីកើតឡើងនៃអនុស័យថា បុគ្គលដែលមានការដេកត្រាំដោយមានានុស័យ ដែលកើតឡើងអំពីធាតុទាំង ២ នោះ ដូច្នេះ ។ កាលទ្រង់មិនត្រាស់អត្ថនៃបញ្ហានេះ អត្ថនៃបញ្ហាដំបូង រមែងមិនប្រាកដ ព្រោះហេតុនោះ ទើបមិនត្រាស់អត្ថនៃបញ្ហាដំបូង គប្បីជ្រាបអត្ថនៃបញ្ហានោះយ៉ាងនេះ ។*

*បទថា* **យតោ កាមរាគានុសយេន** *បានដល់ ដោយកាមរាគានុស័យ ដែលកើតឡើងហើយអំពីទីណា ។*

*បទថា* **សានុសយោ** *បានដល់ បុគ្គល ឈ្មោះថា ជាអ្នកប្រព្រឹត្តទៅដោយអនុស័យ ដោយបដិឃានុស័យ ដែលកើតឡើងអំពីទីនោះ ដូច្នេះ តែ*

ព្រោះអនុស័យទាំង ២ គឺកាមរាគៈ និងបដិឃៈនោះ មិនកើតក្នុងទីតែមួយ ព្រោះហេតុនោះ ទើបធ្វើការបដិសេធថា **នោ** ដូច្នេះ ។

បទថា **អរហា សព្វត្ថ** នេះ លោកធ្វើសត្តមីវិភត្តិ ក្នុងទីសម្តែងអត្ថដោយឥតសេសសល់ ដោយអំណាចនៃអត្ថនេះថា ព្រះអរហន្តជាអ្នកមិនមានអនុស័យណាមួយដែលកើតឡើងក្នុងធម៌ទាំងពួង ដូច្នេះ ។ គប្បីជ្រាបវិនិច្ឆ័យអត្ថក្នុងពាក្យទាំងពួងដោយឧបាយនេះ ។

**សានុសយវារៈ ចប់**

## បជហានវារៈ

[ ១៣៤ ] ក្នុងបជហានវារៈ បទថា **បជហាតិ** បានដល់ រមែងលះអនុស័យដោយមគ្គនោះ គឺរមែងធ្វើឲ្យដល់នូវភាពជាធម្មជាត មិនកើតឡើងតទៅទៀត ដោយអំណាចនៃបហានបរិញ្ញា ។

បទថា **អាមន្តា** ជាពាក្យឆ្លើយទទួល ដោយសំដៅយកព្រះអរិយបុគ្គល ដែលតាំងនៅក្នុងអនាគាមិមគ្គ ។

បទថា **តទេកដ្ឋំ បជហាតិ** នេះ ត្រាស់សំដៅយកភាពដែលអនុស័យនោះ តាំងនៅក្នុងទីតែមួយក្នុងការលះ ។

បទថា **នោ** នេះ បដិសេធ សំដៅយកព្រះអរិយបុគ្គលដែលតាំងនៅក្នុងអរហត្តមគ្គ ។

បទថា **យតោ កាមរាគានុសយំ បជហាតិ** បានដល់ រមែងលះ

កាមរាគានុស័យដែលកើតឡើងអំពីទីណា ។

បទថា **អដ្ឋមកោ** បានដល់ ព្រះអរិយបុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គ ដោយរាប់តាំងអំពីព្រះអរិយបុគ្គល ដែលតាំងនៅក្នុងអរហត្តផល ( ជាទី ១ ) ព្រះអរិយបុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គនោះ ទើបឈ្មោះថា ជាព្រះអរិយបុគ្គលទី ៨ ។ ពិតហើយ ព្រះអរហន្តជាបុគ្គលទី ១ ព្រោះភាពដែលលោកជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ ដោយការរាប់តាមលំដាប់ទក្ខិណេយ្យបុគ្គល ។ ព្រះអរិយបុគ្គល ដែលតាំងនៅក្នុងអរហត្តមគ្គជាទី ២ ព្រះអរិយបុគ្គល ដែលតាំងនៅក្នុងអនាគាមិផលជាទី ៣ ព្រះអរិយបុគ្គល ដែលតាំងនៅក្នុងអនាគាមិមគ្គជាទី ៤ ។បេ។ ព្រះអរិយបុគ្គល ដែលតាំងនៅក្នុងសោតាបត្តិមគ្គជាទី ៨ ។ ព្រះអរិយបុគ្គល ដែលតាំងនៅក្នុងសោតាបត្តិមគ្គនោះ ត្រាស់ថា ជាបុគ្គលទី ៨ ក្នុងទីនេះ ។ម្យ៉ាងទៀត បទថា **អដ្ឋមកោ** នេះ ជានាមសញ្ញា ( ពាក្យសម្គាល់ឈ្មោះ ) របស់លោក ។

បទថា **អនាមិមគ្គសមង្គិញ្ច អដ្ឋមកញ្ច ឋបេត្វា អវសេសា** បាន

*ដល់ ព្រះសេក្ខៈ និងព្រះអសេក្ខៈទាំងឡាយ មួយអន្លើដោយបុថុជ្ជន ។ ពិត ហើយ ក្នុងបុគ្គលទាំងនោះ បុថុជ្ជន លះកាមរាគានុស័យមិនបាន ព្រោះ ភាពដែលបុថុជ្ជននោះ មិនមានបហានប្បរិញ្ញា អធិប្បាយថា បុគ្គលដ៏សេស វៀរបុគ្គលដែលដល់ព្រមដោយមគ្គទាំង ២ ( សោតាបត្តិមគ្គបុគ្គល និង អនាគាមិមគ្គបុគ្គល ) ក្នុងព្រះបាលីថា* **ទ្វិន្នំ មគ្គសមង្គីនំ** *ដូច្នេះ ព្រោះ ភាពដែលអនុស័យទាំងនោះ លោកលះបានហើយ គប្បីជ្រាបវិនិច្ឆ័យក្នុង បទទាំងពួងដោយន័យនេះឯង ។៚*

**អដ្ឋកថាបជហានវារៈ ចប់**

# អភិធម្មបិដក ៩០

# យមក ចតុត្ថភាគ

## បរិញ្ញាវារៈ

[ ១ ] បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យ ( ធម៌ដែលដេកត្រាំនៅក្នុងសន្ដានចិត្ត គឺកាមរាគៈ ) បុគ្គលនោះ កំណត់ដឹងនូវបដិឃានុស័យ ( ធម៌ដែលដេកត្រាំនៅក្នុងសន្ដានចិត្ត គឺបដិឃៈ ) ឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវបដិឃានុស័យ បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យឬ ។ អើ ។ បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យ បុគ្គលនោះ កំណត់ដឹងនូវមានានុស័យ ( ធម៌ដែលដេកត្រាំ នៅក្នុងសន្ដានចិត្ត គឺមានៈ ) ឬ ។ បុគ្គលនោះ កំណត់ដឹងនូវកិលេស ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវមានានុស័យ បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យឬ ។ មិនមែនទេ ។ បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យ បុគ្គលនោះ ( កំណត់ដឹង ) នូវទិដ្ឋានុស័យ ( ធម៌ដែលដេកត្រាំនៅក្នុងសន្ដានចិត្ត គឺទិដ្ឋិ ) ។បេ។ កំណត់ដឹងនូវវិចិកិច្ឆានុស័យ ( ធម៌ដែលដេកត្រាំនៅក្នុងសន្ដានចិត្ត គឺវិចិកិច្ឆា ) ឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវវិចិកិច្ឆានុស័យ បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យឬ ។ បុគ្គលនោះ កំណត់ដឹងនូវកិលេស ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ បុគ្គលណា កំណត់

ដឹងនូវកាមរាគានុស័យ បុគ្គលនោះ កំណត់ដឹងនូវភវរាគានុស័យ ( ធម៌ដែលដេកត្រាំនៅក្នុងសន្តានចិត្ត គឺភវរាគៈ ) ។បេ។ កំណត់ដឹង នូវអវិជ្ជានុស័យ ( ធម៌ដែលដេកត្រាំនៅក្នុងសន្តានចិត្ត គឺអវិជ្ជា ) ឬ ។ បុគ្គលនោះ កំណត់ដឹងនូវកិលេស ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវអវិជ្ជានុស័យ បុគ្គលនោះ កំណត់ដឹងនូវកាម-រាគានុស័យឬ ។ មិនមែនទេ ។

[ ២ ] បុគ្គលណា កំណត់ដឹងនូវបដិឃានុស័យ បុគ្គលនោះ កំណត់ដឹងនូវមានានុស័យឬ ។ បុគ្គលនោះ កំណត់ដឹងនូវកិលេស ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវមានានុស័យ បុគ្គលនោះ កំណត់ដឹងនូវបដិឃានុស័យឬ ។ មិនមែនទេ ។ បុគ្គលណា កំណត់ដឹង នូវបដិឃានុស័យ បុគ្គលនោះ ( កំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ កំណត់ដឹង នូវវិចិកិច្ឆានុស័យឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវវិចិកិច្ឆានុស័យ បុគ្គលនោះ កំណត់ដឹង នូវបដិឃានុស័យឬ ។ បុគ្គលនោះ កំណត់ដឹងនូវកិលេស ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ បុគ្គលណា កំណត់ដឹងនូវបដិឃានុស័យ បុគ្គលនោះ ( កំណត់ដឹង ) នូវភវរាគានុស័យ ។បេ។ កំណត់ដឹងនូវអវិជ្ជា-នុស័យឬ ។ បុគ្គលនោះ កំណត់ដឹងនូវកិលេស ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវអវិជ្ជានុស័យ បុគ្គលនោះ កំណត់ដឹងនូវបដិឃានុស័យឬ ។ មិនមែនទេ ។

[ ៣ ] បុគ្គលណា កំណត់ដឹង នូវមានានុស័យ បុគ្គលនោះ ( កំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ កំណត់ដឹងនូវវិចិកិច្ឆានុស័យឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវវិចិកិច្ឆានុស័យ បុគ្គលនោះ កំណត់ដឹងនូវមានានុស័យឬ ។ បុគ្គលនោះ កំណត់ដឹងនូវកិលេស ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ បុគ្គលណា កំណត់ដឹងនូវមានា-នុស័យ បុគ្គលនោះ ( កំណត់ដឹង ) នូវភវរាគានុស័យ ។បេ។ កំណត់ដឹងនូវអវិជ្ជានុស័យឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវអវិជ្ជានុស័យ បុគ្គលនោះ កំណត់ដឹងនូវមានានុស័យឬ ។ អើ ។

[ ៤ ] បុគ្គលណា កំណត់ដឹង នូវទិដ្ឋានុស័យ បុគ្គលនោះ កំណត់ដឹង នូវវិចិកិច្ឆានុស័យឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹង នូវវិចិកិច្ឆានុស័យ បុគ្គលនោះ កំណត់ដឹង នូវទិដ្ឋានុស័យឬ ។ អើ ។បេ។

[ ៥ ] បុគ្គលណា កំណត់ដឹង នូវវិចិកិច្ឆានុស័យ បុគ្គលនោះ ( កំណត់ដឹង ) នូវភវរាគានុស័យ ។បេ។ បុគ្គលនោះ កំណត់ដឹងនូវអវិជ្ជានុស័យឬ ។ បុគ្គលនោះ កំណត់ដឹងនូវកិលេស ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវអវិជ្ជានុស័យ បុគ្គលនោះ កំណត់ដឹងនូវវិចិកិច្ឆានុស័យឬ ។ មិនមែនទេ ។

[ ៦ ] បុគ្គលណា កំណត់ដឹងនូវភវរាគានុស័យ បុគ្គលនោះ កំណត់ដឹងនូវអវិជ្ជានុស័យឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវ

អវិជ្ជានុស័យ បុគ្គលនោះ កំណត់ដឹង នូវភវរាគានុស័យឬ ។ អើ ។

[ ៧ ] បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង បុគ្គលនោះ កំណត់ដឹងនូវមានានុស័យឬ ។ បុគ្គលនោះ កំណត់ដឹងនូវកិលេស ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវមានានុស័យ បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផងឬ ។ មិនមែនទេ ។ បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង បុគ្គលនោះ ( កំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ កំណត់ដឹងនូវវិចិកិច្ឆានុស័យឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវវិចិកិច្ឆានុស័យ បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ។ បុគ្គលនោះ កំណត់ដឹងនូវកិលេស ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង បុគ្គលនោះ ( កំណត់ដឹង ) នូវភវរាគានុស័យ ។បេ។ កំណត់ដឹងនូវអវិជ្ជានុស័យឬ ។ បុគ្គលនោះ កំណត់ដឹងនូវកិលេស ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវអវិជ្ជានុស័យ បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផងឬ ។ មិនមែនទេ ។

[ ៨ ] បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង បុគ្គលនោះ ( កំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ កំណត់ដឹងនូវវិចិកិច្ឆានុស័យឬ ។ មិនមានទេ ។ មួយយ៉ាងទៀត

បុគ្គលណា កំណត់ដឹងនូវវិចិកិច្ឆានុស័យ បុគ្គលនោះ កំណត់ដឹងនូវកាម-រាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផងឬ ។ បុគ្គលនោះ កំណត់ដឹងនូវកិលេសដែលតាំងនៅ ជាមួយគ្នានឹងអនុស័យនោះ ។ បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានា-នុស័យផង បុគ្គលនោះ កំណត់ដឹងនូវភវរាគានុស័យ ។បេ។ កំណត់ដឹងនូវអវិជ្ជានុស័យឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវអវិជ្ជានុស័យ បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃា-នុស័យផង នូវមានានុស័យផងឬ ។ បុគ្គលនោះ កំណត់ដឹងនូវមានានុស័យ ។

[ ៩ ] បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃា-នុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង បុគ្គលនោះ កំណត់ដឹងនូវវិចិកិច្ឆានុស័យឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវវិចិកិច្ឆានុស័យ បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផងឬ ។ បុគ្គលនោះ កំណត់ដឹងនូវទិដ្ឋានុស័យ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃា-នុស័យផង នូវមានានុស័យផង ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។បេ។

[ ១០ ] បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃា-នុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង បុគ្គលនោះ ( កំណត់ដឹង ) នូវភវរាគានុស័យ ។បេ។ កំណត់ដឹងនូវ

អវិជ្ជានុស័យឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹង នូវអវិជ្ជានុស័យ បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃា-នុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ឬ ។ បុគ្គលនោះ កំណត់ដឹងនូវមានានុស័យ ។

[ ១១ ] បុគ្គលណា កំណត់ដឹង នូវកាមរាគានុស័យផង នូវបដិឃា-នុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង នូវភវរាគានុស័យផង បុគ្គលនោះ កំណត់ដឹងនូវអវិជ្ជានុស័យឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវអវិជ្ជានុស័យ បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង នូវភវរាគានុស័យផងឬ ។ បុគ្គលនោះ កំណត់ដឹងនូវមានានុស័យផង នូវភវរាគានុស័យផង ។

[ ១២ ] បុគ្គល កំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីណា កំណត់ដឹង នូវបដិឃានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវបដិឃានុស័យ ក្នុងទីណា កំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ បុគ្គល កំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីណា កំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវមានានុស័យ ក្នុងទីណា កំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គល កំណត់ដឹងនូវមានានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុ ក្នុងទីនោះ តែមិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុ

នោះទេ កំណត់ដឹងនូវមានានុស័យផង កំណត់ដឹងនូវកាមរាគានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ។ បុគ្គល កំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីណា ( កំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ កំណត់ដឹងនូវវិចិកិច្ឆា-នុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា កំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គល កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនានោះ ក្នុងរូបធាតុ និង ក្នុងអរូបធាតុ តែមិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទុក្ខវេទនានោះទេ កំណត់ដឹងនូវវិចិកិច្ឆានុស័យផង កំណត់ដឹងនូវកាមរាគានុស័យផង ក្នុង វេទនាពីរនោះ ក្នុងកាមធាតុ ។ បុគ្គល កំណត់ដឹង នូវកាមរាគានុស័យ ក្នុងទីណា កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ មួយ យ៉ាងទៀត បុគ្គល កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា កំណត់ដឹងនូវ កាមរាគានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ បុគ្គល កំណត់ដឹងនូវកាម-រាគានុស័យ ក្នុងទីណា កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា កំណត់ដឹង នូវកាមរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គល កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុង ទុក្ខវេទនានោះ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែមិនកំណត់ដឹងនូវកាម-រាគានុស័យ ក្នុងទុក្ខវេទនានោះទេ កំណត់ដឹងនូវអវិជ្ជានុស័យផង កំណត់ ដឹងនូវកាមរាគានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ។

[ ១៣ ] បុគ្គល កំណត់ដឹងនូវបដិឃានុស័យ ក្នុងទីណា កំណត់ដឹង

នូវមានានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត បុគ្គល កំណាត់ដឹងនូវមានានុស័យ ក្នុងទីណា កំណាត់ដឹងនូវបដិឃានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ បុគ្គល កំណាត់ដឹងនូវបដិឃានុស័យ ក្នុងទីណា ( កំណាត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ កំណាត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលកំណាត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា កំណាត់ដឹងនូវបដិឃានុស័យ ក្នុងទីនោះឬ ។ បុគ្គល កំណាត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែមិនកំណាត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះទេ កំណាត់ដឹងនូវវិចិកិច្ឆា-នុស័យផង កំណាត់ដឹងនូវបដិឃានុស័យផង ក្នុងទុក្ខវេទនានោះ ។ បុគ្គល កំណាត់ដឹងនូវបដិឃានុស័យ ក្នុងទីណា កំណាត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត បុគ្គលកំណាត់ដឹងនូវភវរាគានុ-ស័យ ក្នុងទីណា កំណាត់ដឹងនូវបដិឃានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ បុគ្គល កំណាត់ដឹងនូវបដិឃានុស័យ ក្នុងទីណា កំណាត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលកំណាត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា កំណាត់ដឹងនូវបដិឃានុស័យ ក្នុងទីនោះឬ ។ បុគ្គល កំណាត់ដឹងនូវអវិជ្ជានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែមិនកំណាត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះទេ កំណាត់ដឹងនូវអវិជ្ជា-នុស័យផង កំណាត់ដឹង នូវបដិឃានុស័យផង ក្នុងទុក្ខវេទនានោះ ។

[ ១៤ ] បុគ្គល កំណាត់ដឹងនូវមានានុស័យ ក្នុងទីណា ( កំណាត់ដឹង )

នូវទិដ្ឋានុស័យ ។បេ។ កំណត់ដឹង នូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា កំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ បុគ្គល កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនានោះ តែមិនកំណត់ដឹងនូវមានានុស័យ ក្នុងទុក្ខវេទនានោះទេ កំណត់ដឹងនូវវិចិកិច្ឆានុស័យផង កំណត់ដឹងនូវមានានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ ។ បុគ្គលកំណត់ដឹងនូវមានា-នុស័យ ក្នុងទីណា កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គល កំណត់ដឹងនូវមានានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែមិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងវេទនាពីរនោះទេ កំណត់ដឹងនូវមានានុស័យផង កំណត់ដឹងនូវភវរាគានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា កំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ អើ ។ បុគ្គល កំណត់ដឹងនូវមានានុស័យ ក្នុងទីណា កំណត់ដឹងនូវអវិជ្ជានុស័យក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា កំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ បុគ្គល កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទុក្ខវេទនានោះ តែមិនកំណត់ដឹងនូវមានានុស័យ ក្នុងទុក្ខវេទនានោះទេ កំណត់ដឹងនូវអវិជ្ជានុស័យផង កំណត់ដឹងនូវមានានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ ។

[ ១៥ ] បុគ្គល កំណត់ដឹងនូវទិដ្ឋានុស័យ ក្នុងទីណា កំណត់ដឹងនូវ

វិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា កំណត់ដឹងនូវទិដ្ឋានុស័យ ក្នុងទីនោះឬ ។ អើ ។ ។បេ។

[ ១៦ ] បុគ្គល កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គល កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងវេទនា ៣ នោះ ក្នុងកាមធាតុ តែមិនកំណត់ដឹង នូវភវរាគានុស័យ ក្នុងវេទនា ៣ នោះទេ កំណត់ដឹងនូវវិចិកិច្ឆានុស័យផង កំណត់ដឹងនូវភវរាគា-នុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ អើ ។ បុគ្គល កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា កំណត់ដឹង នូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ អើ ។

[ ១៧ ] បុគ្គល កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គល កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងវេទនា ៣ នោះ ក្នុងកាមធាតុ តែមិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងវេទនា ៣ នោះទេ កំណត់ដឹងនូវអវិជ្ជា-នុស័យផង កំណត់ដឹងនូវភវរាគានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុ

នោះ ។

[ ១៨ ] បុគ្គលកំណត់ដឹង នូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីណា កំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលកំណត់ដឹង នូវមានានុស័យ ក្នុងទីណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីនោះឬ ។ បុគ្គលកំណត់ដឹងនូវមានានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ កំណត់ដឹងនូវមានានុស័យផង នូវកាមរាគានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែមិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះទេ ។ បុគ្គល កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីណា ( កំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវវិចិកិច្ឆា-នុស័យ ក្នុងទីណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីនោះឬ ។ បុគ្គល កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ កំណត់ដឹងនូវវិចិកិច្ឆានុស័យផង នូវកាមរាគានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែមិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះទេ កំណត់ដឹងនូវវិចិកិច្ឆានុស័យផង នូវបដិឃានុស័យផង ក្នុងទុក្ខវេទនានោះ តែមិនកំណត់ដឹងនូវកាមរាគានុស័យ

ក្នុងទុក្ខវេទនានោះទេ ។ បុគ្គល កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិ-ឃានុស័យផង ក្នុងទីណា កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីនោះឬ ។ មិនមែនទេ ។ បុគ្គល កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីណា កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីនោះឬ ។ បុគ្គល កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ កំណត់ដឹងនូវអវិជ្ជានុស័យផង នូវកាមរាគានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែមិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះទេ កំណត់ដឹងនូវអវិជ្ជានុស័យផង នូវបដិឃានុស័យផង ក្នុងទុក្ខវេទនានោះ តែមិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទុក្ខវេទនានោះទេ ។

[ ១៩ ] បុគ្គលកំណត់ដឹង នូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងទីណា ( កំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា កំណត់ដឹងនូវកាមរាគា-នុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងទីនោះឬ ។ បុគ្គល

កំណត់ដឹងនូវវិចិកិច្ឆានុស័យផង នូវមានានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ កំណត់ដឹងនូវវិចិកិច្ឆានុស័យផង នូវកាមរាគានុស័យផង នូវមានានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែមិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះទេ កំណត់ដឹងនូវវិចិកិច្ឆានុស័យផង នូវបដិឃានុស័យផង ក្នុងទុក្ខវេទនានោះ តែមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវមានានុស័យផង ក្នុងទុក្ខវេទនានោះទេ ។ បុគ្គលកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងទីណា កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងទីនោះឬ ។ បុគ្គល កំណត់ដឹងនូវភវរាគានុស័យផង នូវមានានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ ។ បុគ្គល កំណត់ដឹងនូវកាម-រាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងទីណា កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងទីនោះឬ ។ បុគ្គល កំណត់ដឹងនូវអវិជ្ជានុស័យផង នូវមានានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ

តែមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ កំណត់ដឹងនូវអវិជ្ជានុស័យផង នូវកាមរាគានុស័យផង នូវមានានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែមិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះទេ កំណត់ដឹងនូវអវិជ្ជានុស័យផង នូវបដិឃានុស័យផង ក្នុងទុក្ខវេទនានោះ តែមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវមានានុស័យផង ក្នុងទុក្ខវេទនានោះទេ ។

[ ២០ ] បុគ្គល កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង ក្នុងទីណា កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង ក្នុងទីនោះឬ ។ បុគ្គលកំណត់ដឹងនូវវិចិកិច្ឆានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ កំណត់ដឹងនូវវិចិកិច្ឆានុស័យផង នូវកាមរាគានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែមិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះទេ កំណត់ដឹងនូវវិចិកិច្ឆានុស័យផង នូវបដិឃានុស័យផង នូវទិដ្ឋានុស័យផង ក្នុងទុក្ខវេទនានោះ តែមិនកំណត់ដឹង នូវកាមរាគានុស័យផង នូវមានានុស័យផង ក្នុងទុក្ខវេទនានោះទេ ។បេ។

[ ២១ ] បុគ្គល កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងទីណា កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា កំណត់ដឹងនូវកាម-រាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងទីនោះឬ ។ បុគ្គល កំណត់ដឹងនូវភវរាគា-នុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ ។ បុគ្គល កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងទីណា បុគ្គល កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិ-ឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងទីនោះឬ ។ បុគ្គល កំណត់ដឹងនូវអវិជ្ជានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ កំណត់ដឹងនូវអវិជ្ជានុស័យផង នូវកាម-រាគានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យ

ផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែមិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះទេ កំណត់ដឹងនូវអវិជ្ជានុស័យផង នូវបដិឃានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងទុក្ខវេទនានោះ តែមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវមានានុស័យផង ក្នុងទុក្ខវេទនានោះទេ ។

[ ២២ ] បុគ្គល កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង នូវភវរាគានុស័យផង ក្នុងទីណា កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គល កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង នូវភវរាគានុស័យផង ក្នុងទីនោះឬ ។ បុគ្គល កំណត់ដឹងនូវអវិជ្ជានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង នូវភវរាគានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ កំណត់ដឹងនូវអវិជ្ជានុស័យផង នូវកាមរាគានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែមិនកំណត់ដឹងនូវបដិឃានុស័យផង នូវភវរាគានុស័យផង ក្នុងវេទនាពីរនោះទេ កំណត់ដឹងនូវអវិជ្ជានុស័យផង នូវបដិឃានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងទុក្ខវេទនានោះ តែមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវមានានុស័យផង នូវភវ-

រាគានុស័យផង ក្នុងទុក្ខវេទនានោះទេ ។

[ ២៣ ] បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹង នូវបដិឃានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវបដិឃានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ បុគ្គលនោះ កំណត់ដឹងនូវកិលេស ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវមានានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីណា បុគ្គលនោះ ( កំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គលទី ៨ នោះ កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនានោះ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែបុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ទាំងកំណត់ដឹងនូវកាមរាគានុស័យ ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវភវរាគានុស័យ

ក្នុងទីនោះឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវកវរាគានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ បុគ្គលនោះ កំណត់ដឹងនូវកិលេស ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។

[ ២៤ ] បុគ្គលណា កំណត់ដឹងនូវបដិឃានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវមានានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវបដិឃានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ បុគ្គលណា កំណត់ដឹងនូវបដិឃានុស័យ ក្នុងទីណា បុគ្គលនោះ ( កំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវបដិឃានុស័យ ក្នុងទីនោះឬ ។ បុគ្គលទី ៨ នោះ កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែបុគ្គលនោះ មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនានោះ ទាំងកំណត់ដឹងនូវបដិឃានុស័យ ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ បុគ្គលណា

កំណាត់ដឹងនូវបដិឃានុស័យ ក្នុងទីណា បុគ្គលនោះ កំណាត់ដឹងនូវកវរាគា-នុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណាត់ដឹងនូវកវរាគានុស័យ ក្នុងទីណា បុគ្គលនោះ កំណាត់ដឹងនូវបដិឃា-នុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ បុគ្គលណា កំណាត់ដឹងនូវបដិឃានុស័យ ក្នុងទីណា បុគ្គលនោះ កំណាត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ បុគ្គល នោះ កំណាត់ដឹងនូវកិលេស ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ មួយយ៉ាងទៀត បុគ្គលណា កំណាត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា បុគ្គល នោះ កំណាត់ដឹងនូវបដិឃានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។

[ ២៥ ] បុគ្គលណា កំណាត់ដឹង នូវមានានុស័យ ក្នុងទីណា បុគ្គល នោះ ( កំណាត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ កំណាត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណាត់ដឹងនូវ វិចិកិច្ឆានុស័យ ក្នុងទីណា បុគ្គលនោះ កំណាត់ដឹងនូវមានានុស័យ ក្នុងទី នោះឬ ។ បុគ្គលទី ៨ នោះ កំណាត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនា នោះ តែបុគ្គលនោះ មិនកំណាត់ដឹងនូវមានានុស័យ ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង កំណាត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ ទាំងកំណាត់ដឹងនូវមានានុស័យ ដែលតាំងនៅ ជាមួយគ្នានឹងអនុស័យនោះ ។ បុគ្គលណា កំណាត់ដឹងនូវមានានុស័យ ក្នុងទី ណា បុគ្គលនោះ កំណាត់ដឹងនូវកវរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គល អ្នក ព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ កំណាត់ដឹងនូវមានានុស័យ ក្នុងវេទនា

ពីរនោះ ក្នុងកាមធាតុ តែបុគ្គលនោះ មិនកំណត់ដឹងនូវកវរាគានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង កំណត់ដឹងនូវមានានុស័យផង កំណត់ដឹងនូវកវរាគានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវកវរាគានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ អើ ។ បុគ្គលណា កំណត់ដឹងនូវមានានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនកំណត់ដឹងនូវមានានុស័យ ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង កំណត់ដឹងនូវអវិជ្ជានុស័យផង កំណត់ដឹងនូវមានានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ ។

[ ២៦ ] បុគ្គលណា កំណត់ដឹងនូវទិដ្ឋានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវទិដ្ឋានុស័យ ក្នុងទីនោះឬ ។ អើ ។ ។បេ។

[ ២៧ ] បុគ្គលណា កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកវរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គលទី ៨ នោះ កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងវេទនា ៣ នោះ ក្នុងកាមធាតុ តែបុគ្គលនោះ មិន

កំណត់ដឹងនូវភវរាគានុស័យ ក្នុងវេទនា ៣ នោះទេ បុគ្គលនោះឯង កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ ទាំងកំណត់ដឹងនូវភវរាគានុស័យ ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។ បុគ្គលណា កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ បុគ្គលនោះ កំណត់ដឹងនូវកិលេស ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ មិនមែនទេ ។

[ ២៨ ] បុគ្គលណា កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងវេទនា ៣ នោះ ក្នុងកាមធាតុ តែបុគ្គលនោះ មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងវេទនា ៣ នោះទេ បុគ្គលនោះឯង កំណត់ដឹងនូវអវិជ្ជានុស័យផង កំណត់ដឹងនូវភវរាគានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ ។

[ ២៩ ] បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃា-

នុស័យផង ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវមានានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីនោះឬ ។ មិនមែនទេ ។ បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីណា បុគ្គលនោះ ( កំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ កំណត់ដឹងនូវ វិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីនោះឬ ។ បុគ្គលទី ៨ នោះ កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែបុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ បុគ្គលនោះឯង កំណត់ដឹងនូវវិចិកិច្ឆា-នុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុផង កំណត់ដឹងនូវកាមរាគានុស័យ ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះផង តែបុគ្គលនោះ មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនានោះផង កំណត់ដឹងនូវបដិឃានុស័យ ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះផង តែមិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទុក្ខវេទនានោះទេ ។ បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវភវ-

*រាគានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីនោះឬ ។ មិនមែនទេ ។ បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកាម-រាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីនោះឬ ។ មិនមែនទេ ។*

*[ ៣០ ] បុគ្គលណា កំណត់ដឹង នូវកាមរាគានុស័យផង នូវបដិ-ឃានុស័យផង នូវមានានុស័យផង ក្នុងទីណា បុគ្គលនោះ ( កំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានា-នុស័យផង ក្នុងទីនោះឬ ។ បុគ្គលទី ៨ នោះ កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះផង កំណត់ដឹងនូវមានានុស័យ ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះផង តែបុគ្គលនោះ មិនកំណត់ដឹងនូវកាម-រាគានុស័យផង នូវបដិឃានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ បុគ្គលនោះឯង កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុផង កំណត់ដឹងនូវកាមរាគានុស័យផង នូវមានានុស័យ ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះផង តែបុគ្គលនោះ មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនា*

នោះផង កំណត់ដឹងនូវបដិឃានុស័យ ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះផង តែបុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវមានានុស័យផង ក្នុងទុក្ខវេទនានោះទេ ។ បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងទីនោះឬ ។ បុគ្គលនោះ កំណត់ដឹងនូវមានានុស័យ ។ បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងទីនោះឬ ។ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនកំណត់ដឹងនូវកាម-រាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង កំណត់ដឹងនូវអវិជ្ជានុស័យផង នូវមានានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែបុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងវេទនាពីរនោះទេ ។

[ ៣១ ] បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង ក្នុងទីនោះឬ ។ បុគ្គលទី ៨ នោះ កំណត់ដឹងនូវវិចិកិច្ឆានុស័យផង នូវទិដ្ឋានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះផង កំណត់ដឹងនូវមានានុស័យ ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះផង តែបុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ បុគ្គលនោះឯង កំណត់ដឹងនូវវិចិកិច្ឆានុស័យផង នូវទិដ្ឋានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុផង កំណត់ដឹងនូវកាមរាគានុស័យផង នូវមានានុស័យ ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះផង តែបុគ្គលនោះ មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះ បុគ្គលនោះឯង កំណត់ដឹងនូវវិចិកិច្ឆានុស័យផង នូវទិដ្ឋានុស័យផង ក្នុងទុក្ខវេទនានោះផង កំណត់ដឹងនូវបដិឃានុស័យ ដែលតាំងនៅជាមួយគ្នានឹងអនុស័យនោះផង តែបុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវមានានុស័យផង ក្នុងទុក្ខវេទនានោះទេ ។បេ។

[ ៣២ ] បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង

ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងទីនោះឬ ។ បុគ្គលនោះ កំណត់ដឹងនូវមានានុស័យ ។ បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងទីនោះឬ ។ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង កំណត់ដឹងនូវអវិជ្ជានុស័យផង នូវមានានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែបុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងវេទនាពីរនោះទេ ។

[ ៣៣ ] បុគ្គលណា កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃា-

នុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង នូវភវរាគានុស័យផង ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវអវិជ្ជា-នុស័យ ក្នុងទីណា បុគ្គលនោះ កំណត់ដឹងនូវកាមរាគានុស័យផង នូវបដិ-ឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង នូវភវរាគានុស័យផង ក្នុងទីនោះឬ ។ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ កំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង នូវភវរាគានុស័យផង ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង កំណត់ដឹងនូវអវិជ្ជានុស័យផង នូវមានា-នុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆា-នុស័យផង នូវភវរាគានុស័យផង ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង កំណត់ដឹងនូវអវិជ្ជានុស័យផង នូវមានានុស័យផង នូវភវរាគានុស័យផង ក្នុងរូបធាតុនិងក្នុងអរូបធាតុនោះ តែបុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងរូបធាតុនិងក្នុងអរូបធាតុនោះទេ ។

អនុលោម ចប់

[ ៣៨ ] បុគ្គលណា មិនកំណត់ដឹងនូវកាមរាគានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវបដិឃានុស័យឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងនូវបដិឃានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យឬ ។ អើ ។ បុគ្គលណា មិនកំណត់ដឹងនូវកាមរាគានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវមានានុស័យឬ ។ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ មិនកំណត់ដឹងនូវកាមរាគានុស័យ តែមិនមែនជាមិនកំណត់ដឹងនូវមានានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គចេញ មិនកំណត់ដឹងនូវកាមរាគានុស័យផង មិនកំណត់ដឹងនូវមានានុស័យផង ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងនូវមានានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ មិនកំណត់ដឹងនូវមានានុស័យ តែមិនមែនជាមិនកំណត់ដឹងនូវកាមរាគានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គចេញ មិនកំណត់ដឹងនូវមានានុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង ។ បុគ្គលណា មិនកំណត់ដឹងនូវកាមរាគានុស័យ បុគ្គលនោះ ( មិនកំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យឬ ។ បុគ្គលទី ៨ មិនកំណត់ដឹងនូវកាមរាគានុស័យ តែមិនមែនជាមិនកំណត់ដឹងនូវវិចិកិច្ឆានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ និងបុគ្គលទី ៨ ចេញ មិនកំណត់ដឹងនូវកាមរាគានុស័យផង មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង ។ មួយយ៉ាងទៀត

បុគ្គលណា មិនកំណាត់ដឹងនូវវិចិកិច្ឆានុស័យ បុគ្គលនោះ មិនកំណាត់ដឹងនូវកាមរាគានុស័យឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ មិនកំណាត់ដឹងនូវវិចិកិច្ឆានុស័យ តែមិនមែនជាមិនកំណាត់ដឹង នូវកាមរាគានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ និង បុគ្គលទី ៨ ចេញ មិនកំណាត់ដឹងនូវវិចិកិច្ឆានុស័យផង មិនកំណាត់ដឹងនូវកាមរាគានុស័យផង ។ បុគ្គលណា មិនកំណាត់ដឹងនូវកាមរាគានុស័យ បុគ្គលនោះ ( មិនកំណាត់ដឹង ) នូវភវរាគានុស័យ ។បេ។ មិនកំណាត់ដឹងនូវអវិជ្ជានុស័យឬ ។ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ មិនកំណាត់ដឹងនូវកាមរាគានុស័យ តែមិនមែនជាមិនកំណាត់ដឹងនូវអវិជ្ជានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គចេញ មិនកំណាត់ដឹងនូវកាមរាគានុស័យផង មិនកំណាត់ដឹងនូវអវិជ្ជានុស័យផង ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណាត់ដឹងនូវអវិជ្ជានុស័យ បុគ្គលនោះ មិនកំណាត់ដឹងនូវកាមរាគានុស័យឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ មិនកំណាត់ដឹងនូវអវិជ្ជានុស័យ តែមិនមែនជាមិនកំណាត់ដឹង នូវកាមរាគានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គ មិនកំណាត់ដឹងនូវអវិជ្ជានុស័យផង មិនកំណាត់ដឹងនូវកាមរាគានុស័យផង ។

[ ៣៥ ] បុគ្គលណា មិនកំណាត់ដឹងនូវបដិឃានុស័យ បុគ្គលនោះ មិនកំណាត់ដឹងនូវមានានុស័យឬ ។ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ មិនកំណាត់ដឹងនូវបដិឃានុស័យ តែមិនមែនជាមិនកំណាត់ដឹងនូវមានានុស័យ

ទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គចេញ មិនកំណាត់ដឹងនូវបដិឃានុស័យផង មិនកំណាត់ដឹងនូវមានានុស័យផង ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណាត់ដឹងនូវមានានុស័យ បុគ្គលនោះ មិនមិនកំណាត់ដឹងនូវបដិឃានុស័យឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ មិនកំណាត់ដឹងនូវមានានុស័យ តែមិនមែនជាមិនកំណាត់ដឹងនូវបដិឃានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គចេញ មិនកំណាត់ដឹងនូវមានានុស័យផង មិនកំណាត់ដឹងនូវបដិឃានុស័យផង ។ បុគ្គលណា មិនកំណាត់ដឹងនូវបដិឃានុស័យ បុគ្គលនោះ ( មិនកំណាត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ មិនកំណាត់ដឹងនូវវិចិកិច្ឆា-នុស័យឬ ។ បុគ្គលទី ៨ មិនកំណាត់ដឹងនូវបដិឃានុស័យ តែមិនមែនជាមិនកំណាត់ដឹងនូវវិចិកិច្ឆានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលដែលព្រមព្រៀងដោយអនាគាមិមគ្គ និងបុគ្គលទី ៨ ចេញ មិនកំណាត់ដឹងនូវបដិ-ឃានុស័យផង មិនកំណាត់ដឹងនូវវិចិកិច្ឆានុស័យផង ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណាត់ដឹងនូវវិចិកិច្ឆានុស័យ បុគ្គលនោះ មិនកំណាត់ដឹងនូវបដិឃានុស័យឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ មិនកំណាត់ដឹងនូវវិចិកិច្ឆានុស័យ តែមិនមែនជាមិនកំណាត់ដឹងនូវបដិឃានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ និងបុគ្គលទី ៨ ចេញ មិនកំណាត់ដឹងនូវវិចិកិច្ឆានុស័យផង មិនកំណាត់ដឹងនូវបដិឃា-នុស័យផង ។ បុគ្គលណា មិនកំណាត់ដឹងនូវបដិឃានុស័យ បុគ្គលនោះ ( មិន

កំណាត់ដឹង ) នូវភវរាគានុស័យ ។បេ។ មិនកំណាត់ដឹងនូវអវិជ្ជានុស័យឬ ។ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ មិនកំណាត់ដឹងនូវបដិឃានុស័យ តែមិនមែនជាមិនកំណាត់ដឹងនូវអវិជ្ជានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គចេញ មិនកំណាត់ដឹងនូវបដិឃានុស័យផង មិនកំណាត់ដឹងនូវអវិជ្ជានុស័យផង ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណាត់ដឹងនូវអវិជ្ជានុស័យ បុគ្គលនោះ មិនកំណាត់ដឹងនូវបដិឃានុស័យឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ មិនកំណាត់ដឹងនូវអវិជ្ជានុស័យ តែមិនមែនជាមិនកំណាត់ដឹងនូវបដិឃានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គចេញ មិនកំណាត់ដឹងនូវអវិជ្ជានុស័យផង មិនកំណាត់ដឹងនូវបដិឃានុស័យផង ។

[ ៣៦ ] បុគ្គលណា មិនកំណាត់ដឹងនូវមានានុស័យ បុគ្គលនោះ ( មិនកំណាត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ មិនកំណាត់ដឹងនូវវិចិកិច្ឆានុស័យឬ ។ បុគ្គលទី ៨ មិនកំណាត់ដឹងនូវមានានុស័យ តែមិនមែនជាមិនកំណាត់ដឹងនូវវិចិកិច្ឆានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលអ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងបុគ្គលទី ៨ ចេញ មិនកំណាត់ដឹងនូវមានានុស័យផង មិនកំណាត់ដឹងនូវវិចិកិច្ឆានុស័យផង ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណាត់ដឹងនូវវិចិកិច្ឆានុស័យ បុគ្គលនោះ មិនកំណាត់ដឹងនូវមានានុស័យឬ ។ បុគ្គលអ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ មិនកំណាត់ដឹងនូវវិចិកិច្ឆានុស័យ តែមិនមែនជាមិនកំណាត់ដឹងនូវមានានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គល

អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងបុគ្គលទី ៨ចេញ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង មិនកំណត់ដឹងនូវមានានុស័យផង ។ បុគ្គលណា មិនកំណត់ដឹងនូវមានានុស័យ បុគ្គលនោះ ( មិនកំណត់ដឹង ) នូវភវរាគានុស័យ ។បេ។ មិនកំណត់ដឹងនូវអវិជ្ជានុស័យឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងនូវអវិជ្ជានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវមានា-នុស័យឬ ។ អើ ។

[ ៣៧ ] បុគ្គលណា មិនកំណត់ដឹងនូវទិដ្ឋានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវទិដ្ឋានុស័យឬ ។ អើ ។ ។បេ។

[ ៣៨ ] បុគ្គលណា មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ បុគ្គលនោះ ( មិនកំណត់ដឹង ) នូវភវរាគានុស័យ ។បេ។ មិនកំណត់ដឹងនូវអវិជ្ជានុស័យឬ ។ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ តែមិនមែនជាមិនកំណត់ដឹងនូវអវិជ្ជានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលអ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងបុគ្គលទី ៨ ចេញ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង មិនកំណត់ដឹងនូវអវិជ្ជានុស័យផង ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងនូវអវិជ្ជានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យឬ ។ បុគ្គលទី ៨ មិនកំណត់ដឹងនូវអវិជ្ជានុស័យ តែមិនមែនជាមិនកំណត់ដឹងនូវវិចិកិច្ឆានុស័យទេ បុគ្គលដ៏សេស វៀរលែងតែ

បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងបុគ្គលទី ៨ ចេញ មិនកំណត់ដឹងនូវអវិជ្ជានុស័យផង មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង ។

[ ៣៩ ] បុគ្គលណា មិនកំណត់ដឹងនូវភវរាគានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវអវិជ្ជានុស័យឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងនូវអវិជ្ជានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវភវរាគានុស័យឬ ។ អើ ។

[ ៤០ ] បុគ្គលណា មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង បុគ្គលនោះ មិនកំណត់ដឹងនូវមានានុស័យឬ ។ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង តែមិនមែនជាមិនកំណត់ដឹងនូវមានានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គចេញ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង មិនកំណត់ដឹងនូវមានានុស័យផង ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងនូវមានានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផងឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ មិនកំណត់ដឹងនូវមានានុស័យ តែមិនមែនជាមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផងទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គចេញ មិនកំណត់ដឹងនូវមានានុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ។ បុគ្គលណា មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវ

បដិឃានុស័យផង បុគ្គលនោះ ( មិនកំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យឬ ។ បុគ្គលទី ៨ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង តែមិនមែនជាមិនកំណត់ដឹងនូវវិចិកិច្ឆានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ និងបុគ្គលទី ៨ ចេញ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផងឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ តែមិនមែនជាមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផងទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ និងបុគ្គលទី ៨ ចេញ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ។ បុគ្គលណា មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង បុគ្គលនោះ ( មិនកំណត់ដឹង ) នូវភវរាគានុស័យ ។បេ។ មិនកំណត់ដឹងនូវអវិជ្ជានុស័យឬ ។ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង តែមិនមែនជាមិនកំណត់ដឹងនូវអវិជ្ជានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួកដែលព្រមព្រៀងដោយមគ្គចេញ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង មិនកំណត់ដឹងនូវអវិជ្ជានុស័យផង ។ មួយយ៉ាងទៀត

បុគ្គលណា មិនកំណត់ដឹងនូវអវិជ្ជានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផងឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ មិនកំណត់ដឹងនូវអវិជ្ជានុស័យ តែមិនមែនជាមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផងទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គចេញ មិនកំណត់ដឹងនូវអវិជ្ជា-នុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ។

[ ៤១ ] បុគ្គលណា មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិ-ឃានុស័យផង នូវមានានុស័យផង បុគ្គលនោះ ( មិនកំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យឬ ។ បុគ្គលទី ៨ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង តែមិនមែនជាមិនកំណត់ដឹងនូវវិចិកិច្ឆានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គ និងបុគ្គលទី ៨ ចេញ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផងឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង នូវមានានុស័យផង តែមិនមែនជាមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផងទេ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ

ផង នូវកាមរាគានុស័យផង នូវបដិឃានុស័យផង តែមិនមែនជាមិនកំណត់ដឹងនូវមានានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គ និងបុគ្គលទី ៨ ចេញ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ។ បុគ្គលណា មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង បុគ្គលនោះ ( មិនកំណត់ដឹង ) នូវភវរាគានុស័យ ។បេ។ មិនកំណត់ដឹងនូវអវិជ្ជានុស័យឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងនូវអវិជ្ជានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផងឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ មិនកំណត់ដឹងនូវអវិជ្ជានុស័យផង នូវមានានុស័យផង តែមិនមែនជាមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផងទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គចេញ មិនកំណត់ដឹងនូវអវិជ្ជានុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ។

[ ៤២ ] បុគ្គលណា មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង បុគ្គលនោះ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផងឬ ។ បុគ្គលអ្នក

ព្រមព្រៀងដោយអនាគាមិមគ្គ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង តែមិនមែនជាមិនកំណត់ដឹង នូវកាមរាគានុស័យផង នូវបដិឃានុស័យផងទេ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង នូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវទិដ្ឋានុស័យផង តែមិនមែនជាមិនកំណត់ដឹងនូវមានានុស័យទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គ និងបុគ្គលទី ៨ ចេញ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង ។បេ។

[ ៤៣ ] បុគ្គលណាមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង បុគ្គលនោះ ( មិនកំណត់ដឹង ) នូវភវរាគានុស័យ ។បេ។ មិនកំណត់ដឹងនូវអវិជ្ជានុស័យឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងនូវអវិជ្ជានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផងឬ ។ បុគ្គលទី ៨ មិនកំណត់ដឹងនូវអវិជ្ជានុស័យផង នូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង តែមិនមែនជាមិនកំណត់ដឹងនូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផងទេ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ មិនកំណត់ដឹងនូវអវិជ្ជានុស័យផង នូវមានានុស័យផង នូវ

ទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង តែមិនមែនជាមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផងទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គ និងបុគ្គលទី ៨ ចេញ មិនកំណត់ដឹងនូវអវិជ្ជានុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ។

[ ៤៤ ] បុគ្គលណា មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង នូវភវរាគានុស័យផង បុគ្គលនោះ មិនកំណត់ដឹងនូវអវិជ្ជានុស័យឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងនូវអវិជ្ជានុស័យ បុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង នូវភវរាគានុស័យផង ឬ ។ បុគ្គលទី ៨ មិនកំណត់ដឹងនូវអវិជ្ជានុស័យផង នូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវភវរាគានុស័យផង តែមិនមែនជាមិនកំណត់ដឹងនូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផងទេ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គ មិនកំណត់ដឹងនូវអវិជ្ជានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង នូវភវរាគានុស័យផង តែមិនមែនជាមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផងទេ បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គ និងបុគ្គលទី ៨ ចេញ មិនកំណត់ដឹងនូវអវិជ្ជានុស័យផង មិនកំណត់ដឹងនូវ

កាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង នូវភវរាគានុស័យផង ។

[ ៤៥ ] បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទុក្ខវេទនានោះ តែមិនមែនជាមិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទុក្ខវេទនានោះទេ មិនកំណត់ដឹងនូវកាមរាគានុស័យផង មិនកំណត់ដឹងនូវបដិឃានុស័យផង ក្នុងរូបធាតុ ក្នុងអរូបធាតុ និងក្នុងអបរិយាបន្នៈនោះ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែមិនមែនជាមិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងវេទនាពីរនោះទេ មិនកំណត់ដឹងនូវបដិឃានុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង ក្នុងរូបធាតុ ក្នុងអរូបធាតុ និងក្នុងអបរិយាបន្ននោះ ។ បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែមិនមែនជាមិនកំណត់ដឹងនូវមានានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ មិនកំណត់ដឹងនូវកាមរាគានុស័យផង មិនកំណត់ដឹងនូវមានានុស័យផង ក្នុងទុក្ខវេទនានោះ ក្នុងអបរិយាបន្ន ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវមានានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីនោះឬ ។ អើ ។ បុគ្គល

មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីណា ( មិនកំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ បុគ្គលមិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទុក្ខវេទនានោះ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែមិនមែនជាមិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ មិនកំណត់ដឹងនូវកាមរាគានុស័យផង មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង ក្នុងអបរិយាបន្ននោះ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីនោះឬ ។ អើ ។ បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែមិនមែនជាមិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ មិនកំណត់ដឹងនូវកាមរាគានុស័យផង មិនកំណត់ដឹងនូវភវរាគានុស័យផង ក្នុងទុក្ខវេទនានោះ ក្នុងអបរិយាបន្ន ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែមិនមែនជាមិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងវេទនាពីរនោះទេ មិនកំណត់ដឹងនូវភវរាគានុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង ក្នុងទុក្ខវេទនានោះ ក្នុងអបរិយាបន្ន ។ បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវ

កាមរាគានុស័យ ក្នុងទុក្ខវេទនានោះ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែមិនមែនជាមិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទុក្ខវេទនានោះទេ មិនកំណត់ដឹងនូវកាមរាគានុស័យផង មិនកំណត់ដឹងនូវអវិជ្ជានុស័យផង ក្នុងអបរិយាបន្ននោះ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីនោះឬ ។ អើ ។

[ ៤៦ ] បុគ្គល មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែមិនមែនជាមិនកំណត់ដឹងនូវមានានុស័យ ក្នុងវេទនាពីរនោះទេ មិនកំណត់ដឹងនូវបដិឃានុស័យផង មិនកំណត់ដឹងនូវមានានុស័យផង ក្នុងអបរិយាបន្ននោះ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវមានានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវមានានុស័យ ក្នុងទុក្ខវេទនានោះ តែមិនមែនជាមិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទុក្ខ-វេទនានោះទេ មិនកំណត់ដឹងនូវមានានុស័យផង មិនកំណត់ដឹងនូវបដិឃា-នុស័យផង ក្នុងអបរិយាបន្ននោះ ។ បុគ្គល មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទីណា ( មិនកំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែមិនមែនជាមិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងវេទនាពីរនោះទេ មិនកំណត់ដឹងនូវបដិ-

យានុស័យផង មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង ក្នុងអបរិយាបន្នទោះ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទីនោះឬ ។ អើ ។ បុគ្គល មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែមិនមែនជាមិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនេះទេ មិនកំណត់ដឹងនូវបដិឃានុស័យផង មិនកំណត់ដឹងនូវភវ-រាគានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ និងក្នុងអបរិយាបន្ន ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទុក្ខវេទនានោះ តែមិនមែនជាមិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទុក្ខ-វេទនានោះទេ មិនកំណត់ដឹងនូវភវរាគានុស័យផង មិនកំណត់ដឹងនូវបដិ-ឃានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ និងក្នុងអបរិយាបន្ន ។ បុគ្គល មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែមិនមែនជាមិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងវេទនាពីរនោះទេ មិនកំណត់ដឹងនូវបដិឃានុស័យផង មិនកំណត់ដឹងនូវអវិជ្ជានុស័យផង ក្នុងអបរិយាបន្ននោះ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវបដិឃានុស័យ

ក្នុងទីនោះឬ ។ អើ ។

[ ៤៧ ] បុគ្គល មិនកំណត់ដឹងនូវមានានុស័យ ក្នុងទីណា ( មិនកំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ មិនកំណត់ដឹង នូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវមានានុស័យ ក្នុងទុក្ខវេទនានោះ តែមិនមែនជាមិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនានោះទេ មិនកំណត់ដឹង នូវមានានុស័យផង មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង ក្នុងអបរិយាបន្ននោះ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ អើ ។ បុគ្គល មិនកំណត់ដឹងនូវមានានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែមិនមែនជាមិនកំណត់ដឹងនូវមានានុស័យ ក្នុងវេទនាពីរនោះទេ មិនកំណត់ដឹងនូវភវរាគានុស័យផង មិនកំណត់ដឹងនូវមានានុស័យផង ក្នុងទុក្ខវេទនានោះ ក្នុងអបរិយាបន្ន ។ បុគ្គល មិនកំណត់ដឹងនូវមានានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវមានានុស័យ ក្នុងទុក្ខវេទនានោះ តែមិនមែនជាមិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទុក្ខវេទនានោះទេ មិនកំណត់ដឹងនូវមានានុស័យផង មិនកំណត់ដឹងនូវអវិជ្ជានុស័យផង ក្នុងអបរិយាបន្ននោះ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា

មិនកំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ អើ ។

[ ៤៨ ] បុគ្គល មិនកំណត់ដឹងនូវទិដ្ឋានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលមិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវទិដ្ឋានុស័យ ក្នុងទីនោះឬ ។ អើ ។ ។បេ។

[ ៤៩ ] បុគ្គល មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលមិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងវេទនា ៣ នោះ ក្នុងកាមធាតុ តែមិនមែនជាមិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងវេទនា ៣ នោះទេ មិនកំណត់ដឹងនូវភវរាគានុស័យផង មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង ក្នុងអបរិយាបន្នទោះទេ ។ បុគ្គល មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ អើ ។

[ ៥០ ] បុគ្គល មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងវេទនា ៣ នោះ ក្នុងកាមធាតុ តែមិនមែនជាមិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងវេទនា ៣ នោះទេ មិនកំណត់ដឹងនូវភវរាគានុស័យផង មិនកំណត់ដឹង

នូវអវិជ្ជានុស័យផង ក្នុងអបរិយាបន្នទោះ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ អើ ។

[ ៥១ ] បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីណា មិនកំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែមិនមែនជាមិនកំណត់ដឹងនូវមានានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង មិនកំណត់ដឹងនូវមានានុស័យផង ក្នុងអបរិយាបន្នទោះ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹង នូវមានានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវមានានុស័យផង នូវកាមរាគានុស័យផង ក្នុងទុក្ខវេទនានោះ តែមិនមែនជាមិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទុក្ខវេទនានោះទេ មិនកំណត់ដឹងនូវមានានុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងអបរិយាបន្នទោះ ។ បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីណា ( មិនកំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែមិនមែនជាមិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងរូបធាតុ

និងក្នុងអរូបធាតុនោះទេ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃា-
នុស័យផង មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យផង ក្នុងអបរិយាបន្ននោះ ។ មួយ
យ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា មិនកំណត់
ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីនោះឬ ។ អើ ។
បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីណា
មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវ
កាមរាគានុស័យផង នូវបដិឃានុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ
តែមិនមែនជាមិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុ
នោះទេ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង មិន
កំណត់ដឹងនូវភវរាគានុស័យផង ក្នុងអបរិយាបន្ននោះ ។ មួយយ៉ាងទៀត
បុគ្គល មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវកាម-
រាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់
ដឹងនូវភវរាគានុស័យផង នូវកាមរាគានុស័យផង ក្នុងទុក្ខវេទនានោះ តែមិន
មែនជាមិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទុក្ខវេទនានោះទេ មិនកំណត់ដឹង
នូវភវរាគានុស័យផង នូវបដិឃានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ
តែមិនមែនជាមិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងវេទនាពីរនោះទេ មិន
កំណត់ដឹងនូវភវរាគានុស័យផង មិនកំណត់ដឹង នូវកាមរាគានុស័យផង នូវ
បដិឃានុស័យផង ក្នុងអបរិយាបន្ននោះ ។ បុគ្គល មិនកំណត់ដឹងនូវកាម
រាគានុស័យផង នូវបដិឃានុស័យផង ក្នុងទីណា មិនកំណត់ដឹងនូវអវិជ្ជានុស័យ

ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃា-នុស័យផង ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែមិនមែនជាមិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង មិនកំណត់ដឹងនូវអវិជ្ជានុស័យផង ក្នុងអបរិយាបន្ននោះ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃា-នុស័យផង ក្នុងទីនោះឬ ។ អើ ។

[ ៥២ ] បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងទីណា ( មិនកំណត់ដឹង ) នូវទិដ្ឋានុស័យ ។បេ។ មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវកាម-រាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងទីនោះឬ ។ អើ ។ បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងទីណា មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានា-នុស័យផង ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវភវរាគានុស័យផង នូវកាមរាគានុស័យផង នូវមានានុស័យផង ក្នុងទុក្ខវេទនានោះ តែមិនមែនជាមិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទុក្ខវេទនានោះទេ មិនកំណត់ដឹងនូវភវ-

រាគានុស័យផង នូវបដិឃានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែមិនមែនជាមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវមានានុស័យផង ក្នុងវេទនាពីរនោះទេ មិនកំណត់ដឹងនូវភវរាគានុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងអបរិយាបន្នៈនោះ ។ បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងទីណា មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង ក្នុងទីនោះឬ ។ អើ ។

[ ៥៣ ] បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង ក្នុងទីណា មិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលមិនកំណត់ដឹងនូវវិចិកិច្ឆានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង ក្នុងទីនោះឬ ។ អើ ។ ។បេ។

[ ៥៤ ] បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងទីណា មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវភវរាគានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវ

កាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងទីនោះឬ ។ បុគ្គល មិនកំណត់ដឹងនូវភវរាគានុស័យផង នូវកាមរាគានុស័យផង នូវមានានុស័យផង ក្នុងទុក្ខវេទនានោះ តែមិនមែនជាមិនកំណត់ដឹងនូវបដិឃានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងទុក្ខវេទនានោះទេ មិនកំណត់ដឹងនូវភវរាគានុស័យផង នូវបដិឃានុស័យផង ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែមិនមែនជាមិនកំណត់ដឹងនូវកាមរាគានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងវេទនាពីរនោះទេ មិនកំណត់ដឹងនូវភវរាគានុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងអបរិយាបន្នទនោះ ។ បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងទីណា មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង ក្នុងទីនោះឬ ។ អើ ។

[ ៥៥ ] បុគ្គល មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង នូវភវរាគានុស័យផង ក្នុងទីណា មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីនោះ

ឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គល មិនកំណត់ដឹងនូវអវិជ្ជានុស័យ ក្នុងទីណា មិនកំណត់ដឹងនូវកាមរាគានុស័យផង នូវបដិឃានុស័យផង នូវមានានុស័យផង នូវទិដ្ឋានុស័យផង នូវវិចិកិច្ឆានុស័យផង នូវភវរាគានុស័យផង ក្នុងទីនោះឬ ។ អើ ។

[ ៥៦ ] បុគ្គលណា មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីណា បុគ្គលនោះ មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទីនោះឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គនោះ មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនមែនជាមិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទុក្ខវេទនានោះទេ បុគ្គលនោះឯង មិនកំណត់ដឹងនូវកាមរាគានុស័យផង មិនកំណត់ដឹងនូវបដិឃានុស័យផង ក្នុងរូបធាតុ ក្នុងអរូបធាតុ និងក្នុងអបរិយាបន្នទោះ បុគ្គលដ៏សេស វៀរលែងតែបុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គចេញ មិនកំណត់ដឹងនូវកាមរាគានុស័យផង មិនកំណត់ដឹងនូវបដិឃានុស័យផង ក្នុងទីទាំងអស់ ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងទីណា បុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គនោះ មិនកំណត់ដឹងនូវបដិឃានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបុគ្គលនោះ មិនមែនជាមិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង មិនកំណត់ដឹងនូវបដិឃានុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង ក្នុងរូបធាតុ ក្នុងអរូបធាតុ និងក្នុងអបរិយាបន្នទោះ បុគ្គលដ៏សេស

*វៀរលែងតែបុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គចេញ មិនកំណត់ដឹងនូវបដិឃានុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង ក្នុងទីទាំងអស់ ។ បុគ្គលណា មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីណា បុគ្គលនោះ មិនកំណត់ដឹងនូវមានានុស័យ ក្នុងទីនោះឬ ។ បុគ្គល អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ ក្នុងរូបធាតុ និងក្នុងអរូបធាតុ តែបុគ្គលនោះ មិនមែនជាមិនកំណត់ដឹងនូវមានានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង មិនកំណត់ដឹងនូវកាមរាគានុស័យផង មិនកំណត់ដឹងនូវមានានុស័យផង ក្នុងទុក្ខវេទនានោះ ក្នុងអបរិយាបន្ន បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គចេញ មិនកំណត់ដឹងនូវកាមរាគានុស័យផង មិនកំណត់ដឹងនូវមានានុស័យផង ក្នុងទីទាំងអស់ ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងនូវមានានុស័យ ក្នុងទីណា បុគ្គលនោះ មិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងទីនោះឬ ។ បុគ្គល អ្នកព្រមព្រៀងដោយអនាគាមិមគ្គនោះ មិនកំណត់ដឹងនូវមានានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបុគ្គលនោះ មិនមែនជាមិនកំណត់ដឹងនូវកាមរាគានុស័យ ក្នុងវេទនាពីរនោះទេ បុគ្គលនោះឯង មិនកំណត់ដឹងនូវមានានុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង ក្នុងទុក្ខ-វេទនានោះ ក្នុងរូបធាតុ ក្នុងអរូបធាតុ និងក្នុងអបរិយាបន្ន បុគ្គលដ៏សេស វៀរលែងតែបុគ្គលពីរពួក ដែលព្រមព្រៀងដោយមគ្គចេញ មិនកំណត់ដឹងនូវមានានុស័យផង មិនកំណត់ដឹងនូវកាមរាគានុស័យផង ក្នុងទីទាំងអស់ ។*

នុស័យ និងវិចិកិច្ឆានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ តែកាម-
រាគានុស័យ និងបដិឃានុស័យ មិនគួរពោលថា លះបង់ផង ថាមិនលះបង់
ផងទេ បុគ្គលនោះឯង មិនលះបង់អវិជ្ជានុស័យ និងមានានុស័យ ក្នុងវេទនា
ពីរនោះ ក្នុងកាមធាតុ តែបុគ្គលនោះ មិនមែនជាមិនលះបង់កាមរាគានុស័យ
ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងវេទនាពីរនោះទេ តែបដិឃានុស័យ មិន

គួរពោលថា លះបង់ផង ថាមិនលះបង់ផងទេ បុគ្គលនោះឯង មិនលះបង់អវិជ្ជានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលនោះ មិនមែនជាមិនលះបង់បដិ-ឃានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនានោះទេ តែកាម-រាគានុស័យ និងមានានុស័យ មិនគួរពោលថា លះបង់ផង ថាមិនលះបង់ផងទេ បុគ្គលពីរពួកនោះ មិនលះបង់អវិជ្ជានុស័យ និងមានានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែបុគ្គលពីរពួកនោះ មិនមែនជាមិនលះបង់ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ តែកាមរាគានុស័យ និងបដិឃានុស័យ មិនគួរពោលថា លះបង់ផង ថាមិនលះបង់ផងទេ បុគ្គលទាំងនោះឯង មិនលះបង់អវិជ្ជានុស័យ កាមរាគានុស័យ និងមានានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបុគ្គលទាំងនោះ មិនមែនជាមិនលះបង់ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងវេទនាពីរនោះទេ តែបដិឃានុស័យ មិនគួរពោលថា លះបង់ផង ថាមិនលះបង់ផងទេ បុគ្គលទាំងនោះឯង មិនលះបង់អវិជ្ជានុស័យ និងបដិឃានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលទាំងនោះ មិនមែនជាមិនលះបង់ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនានោះទេ តែកាមរាគានុស័យ និងមានានុស័យ មិនគួរពោលថា លះបង់ផង ថាមិនលះបង់ផងទេ បុថុជ្ជននោះ មិនលះបង់អវិជ្ជានុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែកាមរាគានុស័យ និងបដិឃានុស័យ មិនគួរពោលថា លះបង់ផង ថាមិនលះបង់ផងទេ បុគ្គលនោះឯង មិនលះបង់អវិជ្ជានុស័យ កាមរាគា-

នុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបដិឃានុស័យ មិនគួរពោលថា លះបង់ផង ថាមិនលះបង់ផងទេ បុគ្គលនោះឯង មិនលះបង់អវិជ្ជានុស័យ បដិឃានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនានោះ តែកាមរាគានុស័យ និងមានានុស័យ មិនគួរពោលថា លះបង់ផង ថាមិនលះបង់ផងទេ ។

[ ១៣២ ] បុគ្គលណា មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យ ក្នុងទីណា បុគ្គលនោះ មិនលះបង់អវិជ្ជានុស័យ ក្នុងទីនោះឬ ។ មិនមានទេ ។ មួយយ៉ាងទៀត បុគ្គលណា មិនលះបង់អវិជ្ជានុស័យ ក្នុងទីណា បុគ្គលនោះ មិនលះបង់កាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆា-នុស័យ និងភវរាគានុស័យ ក្នុងទីនោះឬ ។ អនាគាមិបុគ្គលនោះ មិនលះបង់អវិជ្ជានុស័យ មានានុស័យ និងភវរាគានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែអនាគាមិបុគ្គលនោះ មិនមែនជាមិនលះបង់ទិដ្ឋានុស័យ និងវិចិកិច្ឆា-នុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ តែកាមរាគានុស័យ និងបដិឃានុស័យ មិនគួរពោលថា លះបង់ផង ថាមិនលះបង់ផងទេ បុគ្គលនោះឯង មិនលះបង់អវិជ្ជានុស័យ និងមានានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបុគ្គលនោះ មិនមែនជាមិនលះបង់កាមរាគានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងវេទនាពីរនោះទេ តែបដិឃានុស័យ និងភវរាគានុស័យ មិនគួរពោលថា លះបង់ផង ថាមិនលះបង់ផងទេ បុគ្គលនោះឯង មិនលះបង់

អវិជ្ជានុស័យ ក្នុងទុក្ខវេទនានោះទេ តែបុគ្គលនោះ មិនមែនជាមិនលះបង់ បដិឃានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនានោះទេ តែ កាមរាគានុស័យ មានានុស័យ និងភវរាគានុស័យ មិនគួរពោលថា លះបង់ ផង ជាមិនលះបង់ផងទេ បុគ្គលពីរពួកនោះ មិនលះបង់អវិជ្ជានុស័យ មានានុស័យ និងភវរាគានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះ តែបុគ្គល ទាំងនោះ មិនមែនជាមិនលះបង់ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុនោះទេ តែកាមរាគានុស័យ និងបដិឃានុស័យ មិនគួរពោល ថា លះបង់ផង ជាមិនលះបង់ផងទេ បុគ្គលទាំងនោះឯង មិនលះបង់អវិជ្ជា-នុស័យ កាមរាគានុស័យ និងមានានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុ តែបុគ្គលទាំងនោះ មិនមែនជាមិនលះបង់ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុង វេទនាពីរនោះទេ តែបដិឃានុស័យ និងភវរាគានុស័យ មិនគួរពោលថា លះបង់ផង ជាមិនលះបង់ផងទេ បុគ្គលទាំងនោះឯង មិនលះបង់អវិជ្ជានុស័យ និងបដិឃានុស័យ ក្នុងទុក្ខវេទនានោះ តែបុគ្គលទាំងនោះ មិនមែនជាមិន លះបង់ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនានោះទេ តែកាមរាគា-នុស័យ មានានុស័យ និងភវរាគានុស័យ មិនគួរពោលថា លះបង់ផង ជា មិនលះបង់ផងទេ បុថុជ្ជននោះ មិនលះបង់អវិជ្ជានុស័យ មានានុស័យ ទិដ្ឋា-នុស័យ វិចិកិច្ឆានុស័យ និងភវរាគានុស័យ ក្នុងរូបធាតុ និងក្នុងអរូបធាតុ នោះទេ តែកាមរាគានុស័យ និងបដិឃានុស័យ មិនគួរពោលថា លះបង់ផង ជាមិនលះបង់ផងទេ បុគ្គលនោះឯង មិនលះបង់អវិជ្ជានុស័យ កាមរាគា-

នុស័យ មានានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងវេទនាពីរនោះ ក្នុងកាមធាតុទេ តែបដិឃានុស័យ និងភវរាគានុស័យ មិនគួរពោលថា លះបង់ផង ថាមិនលះបង់ផងទេ បុគ្គលនោះឯង មិនលះបង់អវិជ្ជានុស័យ បដិឃានុស័យ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ក្នុងទុក្ខវេទនានោះ តែ កាមរាគានុស័យ មានានុស័យ និងភវរាគានុស័យ មិនគួរពោលថា លះបង់ផង ថាមិនលះបង់ផងទេ ។

បហីនវារៈ ចប់

## ឧប្បជ្ជនវារៈ

[ ១៣៣ ] កាមរាគានុស័យ របស់បុគ្គលណា កើតឡើង បដិឃានុស័យ របស់បុគ្គលនោះ កើតឡើងឬ ។ អើ ។ មួយយ៉ាងទៀត បដិឃានុស័យ របស់បុគ្គលណា កើតឡើង កាមរាគានុស័យ របស់បុគ្គលនោះ កើតឡើង ឬ ។ អើ ។ កាមរាគានុស័យ របស់បុគ្គលណា កើតឡើង មានានុស័យ របស់បុគ្គលនោះ កើតឡើងឬ ។ អើ ។ មួយយ៉ាងទៀត មានានុស័យ របស់បុគ្គលណា កើតឡើង កាមរាគានុស័យ របស់បុគ្គលនោះ កើតឡើង ឬ ។ មានានុស័យ របស់អនាគាមិបុគ្គល កើតឡើង តែកាមរាគានុស័យ របស់អនាគាមិបុគ្គលនោះ មិនកើតឡើងទេ មានានុស័យ របស់បុគ្គល ៣ ពួក កើតឡើងផង កាមរាគានុស័យ កើតឡើងផង ។ ( បណ្ឌិតគប្បី

សម្តែងឲ្យពិស្តារផងចុះ ) ។

[ ១៣៤ ] កាមរាគានុស័យ របស់បុគ្គលណា មិនកើតឡើង បដិឃានុស័យ របស់បុគ្គលនោះ មិនកើតឡើងឬ ។ អើ ។ មួយយ៉ាងទៀត បដិឃានុស័យ របស់បុគ្គលណា មិនកើតឡើង កាមរាគានុស័យ របស់បុគ្គលនោះ មិនកើតឡើងឬ ។ អើ ។ កាមរាគានុស័យ របស់បុគ្គលណា មិនកើតឡើង មានានុស័យ របស់បុគ្គលនោះ មិនកើតឡើងឬ ។ កាមរាគានុស័យ របស់អនាគាមិបុគ្គល មិនកើតឡើង តែមានានុស័យ របស់អនាគាមិបុគ្គលនោះ មិនមែនជាមិនកើតឡើងទេ កាមរាគានុស័យ របស់ព្រះអរហន្ត មិនកើតឡើងផង មានានុស័យ មិនកើតឡើងផង ។ មួយយ៉ាងទៀត មានានុស័យ របស់បុគ្គលណា មិនកើតឡើង កាមរាគានុស័យ របស់បុគ្គលនោះ មិនកើតឡើងឬ ។ អើ ។ ( បណ្ឌិតគប្បីសម្តែងឲ្យពិស្តារផងចុះ ) ។

ឧប្បជ្ជនវារៈ ចប់

## ធាតុវារៈ

[ ១៣៥ ] បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុង

រូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គលដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យ ប៉ុន្មានបែកធ្លាយទៅ ។

[ ១៣៦ ] បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ

មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងភព មិនមែនកាមធាតុ និងមិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។

[ ១៣៧ ] បុគ្គល ដែលច្យុតចាកអរូបធាតុ កាលទៅកើតក្នុងអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកអរូបធាតុ កាលទៅកើតក្នុងកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកអរូបធាតុ កាលទៅកើតក្នុងរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល

ដែលច្យុតចាកអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិន មែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិន ដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាក អរូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យ ប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គលដែលច្យុតចាកអរូបធាតុ កាលទៅកើត ក្នុង ភពមិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំ នៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។

[ ១៣៨ ] បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ កាលទៅ កើតក្នុងកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិន ដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ កាលទៅកើតក្នុងរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំ នៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គលដែលច្យុតចាកភពមិនមែនជាកាមធាតុ កាលទៅកើតក្នុងអរូបធាតុ មាន អនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យ ប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គលដែលច្យុតចាកភព មិនមែនជាកាមធាតុ កាល ទៅកើតក្នុងភព មិនមែនជាកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភពមិនមែនជាកាមធាតុ កាលទៅកើតក្នុងភព មិនមែនជា

រូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គលដែលច្យុតចាកភព មិនមែនជាកាមធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ មិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គលដែលច្យុតចាកភព មិនមែនជាកាមធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គលដែលច្យុតចាកភព មិនមែនជាកាមធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ មិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។

[ ១៣៩ ] បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ កាលទៅកើតក្នុងកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ កាលទៅកើតក្នុងរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គលដែលច្យុតចាកភព មិនមែនជារូបធាតុ កាលទៅកើតក្នុងអរូបធាតុ

មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ មិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។

[ ១៤០ ] បុគ្គល ដែលច្យុតចាកភព មិនមែនជាអរូបធាតុ កាលទៅ

កើតក្នុងកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាអរូបធាតុ កាលទៅកើតក្នុងរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាអរូបធាតុ កាលទៅកើតក្នុងអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេក

សម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ មិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។

[ ១៤១ ] បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ មិនមែនជាអរូបធាតុ កាលទៅកើតក្នុងរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ

កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។

[ ១៤២ ] បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងអរូបធាតុ មាន

អនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យ

ប៉ុន្មាន បែកធ្លាយទៅ ។

[ ១៤៣ ] បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ កាលទៅកើតក្នុងកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ កាលទៅកើតក្នុងរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ កាលទៅកើតក្នុងអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជា

រូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ មានអនុស័យប៉ុន្មាន ដេកសម្ងំនៅ អនុស័យប៉ុន្មាន មិនដេកសម្ងំនៅ អនុស័យប៉ុន្មាន បែកធ្លាយទៅ ។

[ ១៤៤ ] បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងកាមធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមាន

អនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ អនុស័យដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកកាមធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យដែលបែកធ្លាយទៅ មិនមានឡើយ ។

[ ១៤៥ ] បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងរូបធាតុ

ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងកាមធាតុ មានអនុស័យតែ ៧ ប៉ុណ្ណោះ ដេកសម្ងំនៅ អនុស័យដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងភពមិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំ

ទៅ អនុស័យដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យតែ ៧ ប៉ុណ្ណោះ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាករូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យដែលបែកធ្លាយទៅ មិនមានឡើយ ។

[ ១៤៦ ] បុគ្គល ដែលច្យុតចាកអរូបធាតុ កាលទៅកើតក្នុងអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកអរូបធាតុ កាលទៅកើតក្នុងកាមធាតុ មានអនុស័យតែ ៧ ប៉ុណ្ណោះ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកអរូបធាតុ ឈ្មោះថា ទៅកើតក្នុងរូបធាតុ មិនមានឡើយ ។ បុគ្គលនោះ កាលទៅកើតក្នុងខាងក្រោម រមែងកើតតែក្នុងកាមធាតុ មានអនុស័យតែ ៧ ប៉ុណ្ណោះ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកអរូបធាតុ កាល

ទៅកើតក្នុងភព មិនមែនជារូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ មានអនុស័យតែ ៧ ប៉ុណ្ណោះ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកអរូបធាតុ ឈ្មោះថា ទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ មិនមានឡើយ ។ បុគ្គលនោះ កាលទៅកើតក្នុងខាងក្រោម រមែងកើតតែក្នុងកាមធាតុ មានអនុស័យតែ ៧ ប៉ុណ្ណោះ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យតែ ៧ ប៉ុណ្ណោះ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។

[ ១៤៧ ] បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ កាលទៅកើតក្នុងកាមធាតុ មានអនុស័យតែ ៧ ប៉ុណ្ណោះ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ កាលទៅកើតក្នុងរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ

ខ្ទះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ កាលទៅកើតក្នុងអរូបធាតុ ខ្ទះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភពមិនមែនជាកាមធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ ខ្ទះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ ខ្ទះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ ខ្ទះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ ខ្ទះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ កាលទៅ

កើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យតែ ៧ ប៉ុណ្ណោះ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។

[ ១៤៨ ] បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ កាលទៅកើតក្នុងកាមធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ កាលទៅកើតក្នុងរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ កាលទៅកើតក្នុងអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ កាលទៅ

កើតក្នុងភព មិនមែនជារូបធាតុ ខ្ទះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្ទះមាន អនុស័យ ៥ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែន ជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ ខ្ទះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៣ ដេក សម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុត ចាកភព មិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និង មិនមែនជាអរូបធាតុ ខ្ទះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែក ធ្លាយទៅ មិនមានឡើយ ។ បុគ្គលដែលច្យុតចាកភព មិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ ខ្ទះមាន អនុស័យ ៧ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៥ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែន ជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ ខ្ទះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្ទះ មានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមាន ឡើយ ។

[ ១៤៩ ] បុគ្គល ដែលច្យុតចាកភព មិនមែនជាអរូបធាតុ កាល ទៅកើតក្នុងកាមធាតុ ខ្ទះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្ទះមានអនុស័យ ៥

ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាអរូបធាតុ កាលទៅកើតក្នុងរូបធាតុ ខ្លះមាន អនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមាន អនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាអរូបធាតុ កាលទៅកើតក្នុងអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះ មានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមាន ឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាអរូបធាតុ កាលទៅកើត ក្នុងភព មិនមែនជាកាមធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមាន អនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែន ជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេក សម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែល ច្យុតចាកភព មិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះ មានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមាន ឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាអរូបធាតុ កាលទៅកើត ក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ ខ្លះមានអនុស័យ ៧

ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។

[ ១៥០ ] បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងកាមធាតុ មានអនុស័យតែ ៧ ប៉ុណ្ណោះ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព

មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យតែ ៧ ប៉ុណ្ណោះ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព

មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។

[ ១៥១ ] បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងកាមធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះ

មានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។

[ ១៥២ ] បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ កាលទៅកើតក្នុងកាមធាតុ មានអនុស័យតែ ៧ ប៉ុណ្ណោះ ដេក

សម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ ឈ្មោះថា ទៅកើតក្នុងរូបធាតុ មិនមានឡើយ ។ បុគ្គលនោះ កាលទៅកើតក្នុងខាងក្រោម រមែងកើតតែក្នុងកាមធាតុ អនុស័យ មានតែ ៧ ប៉ុណ្ណោះ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ កាលទៅកើតក្នុងអរូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភពមិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជាអរូបធាតុ មានអនុស័យតែ ៧ ប៉ុណ្ណោះ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ ឈ្មោះ

ថា ទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជាអរូបធាតុ មិនមានឡើយ ។ បុគ្គលនោះ កាលទៅកើតក្នុងខាងក្រោម រមែងទៅកើតតែក្នុងកាមធាតុ មានអនុស័យតែ ៧ ប៉ុណ្ណោះ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជារូបធាតុ និងមិនមែនជាអរូបធាតុ មានអនុស័យតែ ៧ ប៉ុណ្ណោះ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។ បុគ្គល ដែលច្យុតចាកភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ កាលទៅកើតក្នុងភព មិនមែនជាកាមធាតុ និងមិនមែនជារូបធាតុ ខ្លះមានអនុស័យ ៧ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៥ ដេកសម្ងំនៅ ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ អនុស័យ ដែលបែកធ្លាយទៅ មិនមានឡើយ ។

ធាតុវារៈ ចប់

អនុសយយមកៈទី ៧ ចប់

យមកប្បករណៈលើកដំបូង ចប់

# អដ្ឋកថា

# យមក ចតុត្ថភាគ

## បរិញ្ញាវារៈ

[ ១ ] *ក្នុងបរិញ្ញាវារៈ បទថា* **បរិជានាតិ** *បានដល់ រមែងដឹងច្បាស់ដោយបរិញ្ញាទាំង ៣ ។ ពាក្យដ៏សេសក្នុងទីនេះ មានន័យដូចពោលហើយខាងដើមនោះឯង ។ ពិតហើយ សូម្បីវារៈនេះ ព្រះអង្គក៏ទ្រង់វិសជ្ជនាដោយអំណាចព្រះអរិយបុគ្គលដែលតាំងនៅក្នុងមគ្គប៉ុណ្ណោះ ដូចគ្នានឹងបជហនវារៈ ៕*

### អដ្ឋកថាបរិញ្ញាវារៈ ចប់

## បហីនវារៈ

[ ៦៧ ] *ព្រះអង្គទ្រង់ផ្ដើមទេសនាក្នុងបហីនវារៈ ដោយអំណាចនៃព្រះអរិយបុគ្គលដែលតាំងនៅក្នុងផល ព្រោះថា អនុស័យទាំង ២ នេះដែលព្រះអនាគាមីលះបានហើយ ព្រោះហេតុនោះ ទើបឆ្លើយទទួលថា* **អាមន្តា** *ដូច្នេះ ។*

*ក្នុងឱកាសវារៈ ព្រោះពាក្យសួរថា* **យត្ថ កាមរាគានុសយោ បហីនោ តត្ថ បដិឃានុសយោ បហីនោ** *បុគ្គល លះបង់កាមរាគានុស័យក្នុងទីណា*

*លះបង់បដិឃានុស័យ ក្នុងទីនោះឬ ដូច្នេះ ទើបលោកពោលថា* **ន វត្តព្វោ បហីយតិ វា អប្បហីយតិ វា** *មិនគួរពោលថា លះបង់ផង ថាមិនលះបង់ផងទេ ដូច្នេះ ។*

*សួរថា លោកពោលពាក្យនោះ ព្រោះហេតុអ្វី ឆ្លើយថា ព្រោះភាពដែលភូមិនោះជាទីកើតឡើង ដែលមិនទូទៅ ។*

*ពិតហើយ ទីជាទីកើតឡើងនៃកាមរាគានុស័យក៏ម្យ៉ាង របស់បដិឃានុស័យក៏ម្យ៉ាង គឺអនុស័យរបស់មគ្គបុគ្គលដែលមិនចម្រើនហើយ រមែងកើតឡើងក្នុងភូមិណា កាលលោកចម្រើនមគ្គឲ្យកើតឡើងហើយ អនុស័យនោះ ក៏ឈ្មោះថា លះបានហើយក្នុងទីនោះឯង ។ បណ្ដាអនុស័យទាំង ២ នោះ បដិឃានុស័យ រមែងមិនកើតឡើងក្នុងទីជាទីកើតឡើង នៃកាមរាគានុស័យនោះឯង សូម្បីកាមរាគានុស័យ ក៏មិនកើតឡើងក្នុងទីដែលជាទីតាំងនៃបដិឃានុស័យ ព្រោះហេតុនោះ ទើបមិនគួរពោលថា អនុស័យនោះលោកលះបានហើយ ឬលះមិនទាន់បានក្នុងទីនោះ ព្រោះថា កាមរាគានុស័យនោះ លោកលះបានហើយ ក្នុងទីជាទីកើតរបស់ខ្លួន ទើបមិនគួរពោលថា អនុស័យនោះ លោកលះបានហើយក្នុងទីនោះ ព្រោះភាពដែលលោកមិនទាន់លះបាន ។ ទីណា ជាទីកើតឡើងនៃកាមរាគានុស័យ មិនគួរពោលថា លោកមិនទាន់លះបានហើយក្នុងទីនោះ ព្រោះភាពដែលកាមរាគានុស័យនោះមិនបាននៅក្នុងទីនោះ ។*

*ក្នុងពាក្យនេះថា* **យត្ថ កាមរាគានុសយោ បហីនោ តត្ថ មានា-នុសយោ បហីនោ** *នេះ ព្រះមានព្រះភាគ សំដៅយកទីជាទីសាធារណៈ ទើបត្រាស់ថា* **អាមន្តា** *ព្រោះថា កាមរាគានុស័យ រមែងដេកត្រាំក្នុងវេទនា ២ ក្នុងកាមធាតុ មានានុស័យ រមែងដេកត្រាំក្នុងវេទនាទាំង ២ នោះផង ក្នុងរូបធាតុ និងអរូបធាតុទាំងឡាយផងនោះឯង តែមានានុស័យនោះ វៀរទីជាទីអសាធារណៈ ក្នុងទីជាទីសាធារណៈ ឈ្មោះថា លោកលះបានហើយមួយអន្លើដោយកាមរាគានុស័យ ព្រោះហេតុនោះ ទើបទទួលថា* **អាមន្តា** *ដូច្នេះ ។*

*បណ្ឌិតគប្បីជ្រាបភាពជាអ្នកលះបានហើយ និងពាក្យដែលមិនគប្បីពោល ក្នុងឱកាសវារៈទាំងពួង ដោយន័យនេះ ។*

*បទថា* **ឆត្តិ** *ក្នុងអាគតដ្ឋានទាំងឡាយ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដូចពាក្យដែលពោលហើយខាងដើមនោះឯង ។ បុគ្គលោកាសវារៈ មានគតិដូចឱកាសវារៈនោះឯង ។ ក្នុងបដិលោមន័យ បទថា* **យស្ស កាមរាគា-នុសយោ អប្បហីនោ** *នេះ ព្រះមានព្រះភាគ ត្រាស់សួរដោយអំណាចនៃភាពជាបុថុជ្ជន ព្រះសោតាបន្ន និងព្រះសកទាគាមី ។ ពិតហើយ អនុស័យទាំង ២ នេះ បុគ្គល ៦ ពួក តាំងអំពីបុថុជ្ជន រហូតដល់ព្រះអរិយបុគ្គលដែលតាំងនៅក្នុងអនាគាមិមគ្គ មិនទាន់លះបានក៏ពិត ទោះជាយ៉ាងនោះ ក្នុងទីនេះ ទ្រង់បំណងយកព្រះអរិយបុគ្គលដែលតាំងនៅក្នុងមគ្គ ព្រោះព្រះបាលីថា* **តិណ្ណំ បុគ្គលានំ ទ្វិន្នំ បុគ្គលានំ** *ខាងមុខជាដើម ព្រោះហេតុនោះ*

*ទើបត្រាស់ថា* **អាមន្តា** *ដោយសំដៅយកបុថុជ្ជន ព្រះសោតាបន្ន និងព្រះសកទាគាមីប៉ុណ្ណោះ ។*

*បទថា* **ទ្វិន្នំ បុគ្គលានំ** *បានដល់ ព្រះសោតាបន្ន និងព្រះសកទាគាមី ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងបុគ្គលវារៈដោយន័យនេះឯង ។ ឱកាសវារៈ និងបុគ្គលោកាសវារៈ គប្បីជ្រាបដោយន័យដែលពោលហើយខាងដើមនោះឯង ៕៚*

**អដ្ឋកថាបហីនវារៈ ចប់**

# ឧប្បជ្ជនវារៈ

*[ ១៣៣ ] ក្នុងឧប្បជ្ជនវារៈ ដូចគ្នានឹងអនុសយវារៈនោះឯង ៕៚*

**អដ្ឋកថាឧប្បជ្ជនវារៈ ចប់**

# ធាតុវារៈ

## ធាតុបុច្ឆាវារៈ

[ ១៣៥ ] បណ្ឌិតគប្បីជ្រាបអត្ថក្នុងបុច្ឆាវារៈ នៃធាតុវារៈជាដំបូងថា **កតិ អនុសយា អនុសេន្តិ** បានដល់ អនុស័យប៉ុន្មាន មិនទៅតាមសន្តាន ហើយអាស្រ័យនៅ ។

បទថា **កតិ អនុសយា ឆានុសេន្តិ** បានដល់ អនុស័យប៉ុន្មាន មិនទៅតាមសន្តាន ហើយអាស្រ័យនៅ ។

បទថា **កតិ អនុសយា ភង្គា** សេចក្តីថា បណ្ឌិតគប្បីចែកយ៉ាងនេះថា អនុស័យប៉ុន្មាន រមែងដេកត្រាំ អនុស័យប៉ុន្មាន មិនដេកត្រាំ ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីនេះ ពាក្យណា ដែលគួរពោល ពាក្យនោះ លោកក៏ពោលហើយ ក្នុងទីជាទីកំណត់ព្រះបាលីខាងដើមនោះឯង ។

## ធាតុវិសជ្ជនាវារៈ

[ ១៤៤ ] ក្នុងនិទ្ទេសវារៈ លោកពោលដោយអំណាចនៃបុថុជ្ជនថា **កស្សចិ សត្ត អនុសយា អនុសេន្តិ** ខ្ចះមានអនុស័យ ៧ ដេកសម្ងំនៅ ដូច្នេះ ។

បទថា **កស្សចិ បញ្ច** ខ្ចះមានអនុស័យ ៥ នេះ លោកពោលដោយអំណាចនៃព្រះសោតាបន្ន និងព្រះសកទាគាមី ។ ពិតហើយ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ដែលលោកទាំងនោះលះបានហើយ ព្រោះហេតុនោះ ទើបអនុស័យ ៥ ប៉ុណ្ណោះ ដេកត្រាំ ដូច្នេះ ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្តីនេះថា ព្រះមានព្រះភាគទ្រង់កាន់យកអត្ថ ក្នុងបទថា **ឧប្បជ្ជន្តិ** នៃបទថា **អនុសេន្តិ** ក្នុងអនុសយវារៈ យ៉ាងណា ក្នុងធាតុវារៈនេះ មិនគប្បីកាន់យកយ៉ាងនោះ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះអនុស័យនោះ មិនកើតឡើងក្នុងខណៈនោះ ។

ពិតហើយ កាលបុគ្គលកំពុងកើតឡើងក្នុងកាមធាតុ វិបាកចិត្ត និងរូបដែលមានកម្មជាសមុដ្ឋាននោះឯង រមែងកើតអំពីអកុសលចិត្ត រមែងមិនមាន ( ក្នុងខណៈនោះ ) ។ អនុស័យទាំងឡាយ រមែងកើតឡើងក្នុងខណៈនៃអកុសលចិត្ត រមែងមិនកើតឡើងក្នុងខណៈនៃវិបាកចិត្ត ព្រោះហេតុនោះ ព្រោះការមិនកើតក្នុងខណៈនោះ ទើបមិនគួរកាន់យកអត្ថយ៉ាងនោះ ។

សួរថា គប្បីកាន់យកដូចម្តេច ឆ្លើយថា រមែងរកបានដោយប្រការណា ក៏គប្បីកាន់យកដោយប្រការនោះ ។

សួរថា រកបានដូចម្តេច ឆ្លើយថា រកបាន ព្រោះអត្ថថា ជាកិលេសដែលមិនទាន់លះបាន ។ ដូចបុគ្គលដល់ព្រមដោយកុសលចិត្ត និងអព្យាកតចិត្ត ព្រោះភាពដែលរាគៈ ទោសៈ និងមោហៈដែលខ្លួនមិនទាន់លះបាន ក៏លោកហៅថា បុគ្គលមានរាគៈ ទោសៈ និងមោហៈ យ៉ាងណា សេចក្តីនេះក៏យ៉ាងនោះ ព្រះមានព្រះភាគត្រាស់ថា អនុស័យនោះៗ រមែងដេកត្រាំដល់បុគ្គលនោះៗ ក្នុងខណៈនៃបដិសន្ធិ ព្រោះភាពដែលអនុស័យដែលមគ្គភាវនាមិនទាន់បានលះ ដូច្នេះ ។ ព្រះមានព្រះភាគ មិនបានត្រាស់ថា អនុស័យ

*ទាំងនោះ រមែងដេកត្រាំតែម្យ៉ាង តែគប្បីជ្រាបថា អនុស័យទាំងនោះ ឈ្មោះថា ដេកត្រាំ ព្រោះភាពជាសភាវៈដែលមិនទាន់លះបាននោះឯង ដូច្នេះ ។*

*បទថា* **អនុសយា ភង្គា នត្ថិ** *អធិប្បាយថា ឈ្មោះថា អនុស័យដែលបណ្ឌិតគប្បីចែកយ៉ាងនេះថា អនុស័យណា ដេកត្រាំដល់បុគ្គលណា អនុស័យនោះប៉ុណ្ណោះ រមែងដេកត្រាំ អនុស័យណា មិនបានដេកត្រាំ អនុស័យនោះប៉ុណ្ណោះ ក៏រមែងមិនដេកត្រាំ អនុស័យនេះ រមែងដេកត្រាំនិងមិនដេកត្រាំ អនុស័យនេះ ដេកត្រាំគប្បីមាន មិនដេកត្រាំគប្បីមាន ដូច្នេះ រមែងមិនមាន ។*

*បទថា* **រូបធាតុំ ឧបបជ្ជន្តស្ស កស្សចិ តយោ** *នេះ ត្រាស់ដោយអំណាចនៃព្រះអនាគាមី ។ ពិតហើយ កាមរាគៈ បដិឃៈ ទិដ្ឋិ និងវិចិកិច្ឆានុស័យទាំង ៤ ព្រះអនាគាមីលះបានហើយ ដោយមិនសេសសល់ អនុស័យ ៣ ក្រៅអំពីនេះ លោកមិនទាន់លះបាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **កស្សចិ តយោ អនុសយា អនុសេន្តិ** *ខ្លះមានអនុស័យ ៣ ដេកសម្ងំនៅ ដូច្នេះ ។*

*បទថា* **ន កាមធាតុំ** *អធិប្បាយថា កើតឡើងក្នុងធាតុទាំង ២ ដ៏សេស ព្រោះភាពដែលលោកបដិសេធកាមធាតុ ។*

*បទថា* **សត្តេវ** *នេះ ព្រះមានព្រះភាគទ្រង់កំណត់ហើយ ត្រាស់ថា ឈ្មោះថា ការកើតឡើងក្នុងកាមធាតុរបស់ព្រះអរិយសាវក ដែលចុតិចាករូបធាតុ មិនមាន មានតែបុថុជ្ជនប៉ុណ្ណោះ ព្រោះហេតុនោះ ទើបត្រាស់ថា*

**សត្តេ** ដូច្នេះ ។ កាលបុគ្គលចុតិចាកអរូបធាតុហើយ កើតឡើងក្នុងកាមធាតុ ក្នុងបទថា **សត្តេ** នេះ ក៏ន័យនេះឯង ។

សួរថា ក្នុងបទថា **រូបធាតុយា ឧបបត្តិ នត្ថិ** ដូច្នេះ ការកើតឡើងក្នុងរូបធាតុ មិនមាន ព្រោះហេតុអ្វី ឆ្លើយថា ព្រោះការមិនមានរូបាវចរជ្ឈាន ដែលជាធម៌ឲ្យសម្រេចក្នុងការកើតឡើងនោះ ។

ពិតហើយ បុគ្គលនោះ កើតឡើងក្នុងធាតុនោះ ព្រោះឈានកន្លងរូបសញ្ញាដោយប្រការទាំងពួង ព្រោះហេតុនោះ ទើបរូបាវចរជ្ឈាន របស់លោកមិនមានក្នុងទីនោះ ព្រោះការមិនមានរូបាវចរជ្ឈាននោះ បណ្ឌិតគប្បីជ្រាបថា ការកើតឡើងក្នុងរូបធាតុ មិនមាន ដូច្នេះ ។

បទថា **អរូបធាតុយា ចុតស្ស ច កាមធាតុំ** នេះ ទ្រង់បំណងយកអរូបធាតុប៉ុណ្ណោះ ។ គប្បីជ្រាបអត្ថក្នុងវិសជ្ជនាទាំងពួង ដោយន័យនេះដូច្នេះឯង ៕

**ធាតុវារកថា ចប់**

**អដ្ឋកថាអនុសយយមកៈ ចប់**

# អភិធម្មបិដក ~៩១

# យមក បញ្ចមភាគ

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## ចិត្តយមកៈទី ៨

### បុគ្គលវារុទ្ទេស

[ ១ ] ចិត្តរបស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ នឹងរលត់ នឹងមិនកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងរលត់ នឹងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង រមែងមិនរលត់ ។ ចិត្តរបស់បុគ្គលណា រមែងមិនកើតឡើង តែងរលត់ ចិត្តរបស់បុគ្គលនោះ នឹងមិនរលត់ នឹងកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងមិនរលត់ នឹងកើតឡើង ចិត្តរបស់បុគ្គលនោះ រមែងមិនកើតឡើង តែងរលត់ ។

[ ២ ] ចិត្តរបស់បុគ្គលណា រមែងកើតឡើង ចិត្តរបស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយ ឬក៏ចិត្តរបស់បុគ្គលណា កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង ។ ចិត្តរបស់បុគ្គលណា រមែងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយ ឬក៏ចិត្តរបស់បុគ្គលណា មិនកើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា រមែងមិនកើត

ឡើង ៗ

[ ៣ ] ចិត្តរបស់បុគ្គលណា រមែងរលត់ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយ ឬក៏ចិត្តរបស់បុគ្គលណា កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ រមែងរលត់ ៗ ចិត្តរបស់បុគ្គលណា រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយ ឬក៏ចិត្តរបស់បុគ្គលណា មិនកើតឡើងហើយ ចិត្តរបស់បុគ្គលនោះ រមែងមិនរលត់ ៗ

[ ៤ ] ចិត្តរបស់បុគ្គលណា រមែងកើតឡើង ចិត្តរបស់បុគ្គលនោះ ឈ្មោះថា ធ្លាប់កើតឡើងហើយ ឬក៏ចិត្តរបស់បុគ្គលណា ធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង ៗ ចិត្តរបស់បុគ្គលណា រមែងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ ឈ្មោះថា មិនធ្លាប់កើតឡើងហើយ ឬក៏ចិត្តរបស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ មិនកើតឡើង ៗ ចិត្តរបស់បុគ្គលណា រមែងកើតឡើង ចិត្តរបស់បុគ្គលនោះ នឹងកើតឡើងឬ ក៏ចិត្តរបស់បុគ្គលណា នឹងកើតឡើង ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង ៗ ចិត្តរបស់បុគ្គលណា មិនកើតឡើង ចិត្តរបស់បុគ្គលនោះ នឹងមិនកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ រមែងមិនកើតឡើង ៗ ចិត្តរបស់បុគ្គលណា ធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា នឹងកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងកើតឡើង ចិត្តរបស់បុគ្គលនោះ ធ្លាប់កើតឡើងហើយ ៗ ចិត្តរបស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា នឹងមិនកើតឡើង

ឬក៏ចិត្តរបស់បុគ្គលណា នឹងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ។

[ ៥ ] ចិត្តរបស់បុគ្គលណា រមែងរលត់ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា ធ្លាប់រលត់ហើយ ឬក៏ចិត្តរបស់បុគ្គលណា ធ្លាប់រលត់ហើយ ចិត្តរបស់បុគ្គលនោះ រមែងរលត់ ។ ចិត្តរបស់បុគ្គលណា រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា មិនធ្លាប់រលត់ហើយ ឬក៏ចិត្តរបស់បុគ្គលណា មិនធ្លាប់រលត់ហើយ ចិត្តរបស់បុគ្គលនោះ រមែងមិនរលត់ ។ ចិត្តរបស់បុគ្គលណា រមែងរលត់ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា នឹងរលត់ ឬក៏ចិត្តរបស់បុគ្គលណា នឹងរលត់ ចិត្តរបស់បុគ្គលនោះ រមែងរលត់ ។ ចិត្តរបស់បុគ្គលណា រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា នឹងមិនរលត់ ឬក៏ចិត្តរបស់បុគ្គលណា នឹងមិនរលត់ ចិត្តរបស់បុគ្គលនោះ រមែងមិនរលត់ ។ ចិត្តរបស់បុគ្គលណា ធ្លាប់រលត់ហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា នឹងរលត់ទៅ ឬក៏ចិត្តរបស់បុគ្គលណា នឹងរលត់ ចិត្តរបស់បុគ្គលនោះ ធ្លាប់រលត់ហើយ ។ ចិត្តរបស់បុគ្គលណា មិនធ្លាប់រលត់ហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា នឹងមិនរលត់ ឬក៏ចិត្តរបស់បុគ្គលណា នឹងមិនរលត់ ចិត្តរបស់បុគ្គលនោះ មិនធ្លាប់រលត់ហើយ ។

[ ៦ ] ចិត្តរបស់បុគ្គលណា រមែងកើតឡើង ចិត្តរបស់បុគ្គលនោះ ឈ្មោះថា ធ្លាប់រលត់ហើយ ឬក៏ចិត្តរបស់បុគ្គលណា ធ្លាប់រលត់ហើយ ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង ។ ចិត្តរបស់បុគ្គលណា មិនកើតឡើង ចិត្ត

របស់បុគ្គលនោះ ឈ្មោះថា មិនធ្លាប់រលត់ហើយ ឬក៏ចិត្តរបស់បុគ្គលណា មិនធ្លាប់រលត់ហើយ ចិត្តរបស់បុគ្គលនោះ រមែងមិនកើតឡើង ។ ចិត្តរបស់បុគ្គលណា រមែងកើតឡើង ចិត្តរបស់បុគ្គលនោះ ឈ្មោះថា នឹងរលត់ ឬក៏ចិត្តរបស់បុគ្គលណា នឹងរលត់ ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង ។ ចិត្តរបស់បុគ្គលណា រមែងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ ឈ្មោះថា នឹងមិនរលត់ ឬក៏ចិត្តរបស់បុគ្គលណា នឹងមិនរលត់ ចិត្តរបស់បុគ្គលនោះ រមែងមិនកើតឡើង ។ ចិត្តរបស់បុគ្គលណា ធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា នឹងរលត់ ឬក៏ចិត្តរបស់បុគ្គលណា នឹងរលត់ ចិត្តរបស់បុគ្គលនោះ ធ្លាប់កើតឡើងហើយ ។ ចិត្តរបស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា នឹងមិនរលត់ ឬក៏ចិត្តរបស់បុគ្គលណា នឹងមិនរលត់ ចិត្តរបស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ។

[ ៧ ] ចិត្តរបស់បុគ្គលណា រមែងកើតឡើង ចិត្តរបស់បុគ្គលនោះ ឈ្មោះថា រមែងមិនរលត់ ឬក៏ចិត្តរបស់បុគ្គលណា រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង ។ ចិត្តរបស់បុគ្គលណា រមែងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ ឈ្មោះថា រមែងរលត់ ឬក៏ចិត្តរបស់បុគ្គលណា រមែងរលត់ ចិត្តរបស់បុគ្គលនោះ រមែងមិនកើតឡើង ។

[ ៨ ] ចិត្តរបស់បុគ្គលណា កំពុងកើតឡើង ចិត្តរបស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយ ឬក៏ចិត្តរបស់បុគ្គលណា កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ កំពុងកើតឡើង ។ ចិត្តរបស់បុគ្គលណា កាលមិនកើតឡើង

ចិត្តរបស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយ ឬក៏ចិត្តរបស់បុគ្គលណា មិនកើតឡើងហើយ ចិត្តរបស់បុគ្គលនោះ កាលមិនកើតឡើងទេ ។

[ ៩ ] ចិត្តរបស់បុគ្គលណា កំពុងរលត់ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយ ឬក៏ចិត្តរបស់បុគ្គលណា កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ក៏កំពុងរលត់ ។ ចិត្តរបស់បុគ្គលណា កាលមិនរលត់ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយ ឬក៏ចិត្តរបស់បុគ្គលណា មិនកើតឡើងហើយ ចិត្តរបស់បុគ្គលនោះ កាលមិនរលត់ ។

[ ១០ ] ចិត្តរបស់បុគ្គលណា កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា ធ្លាប់កើតឡើងហើយ ឬក៏ចិត្តរបស់បុគ្គលណា ធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ក៏កើតឡើងហើយ ។ ចិត្តរបស់បុគ្គលណា កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា នឹងកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងកើតឡើង ចិត្តរបស់បុគ្គលនោះ ក៏កើតឡើងហើយ ។ ចិត្តរបស់បុគ្គលណា មិនកើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា មិនធ្លាប់កើតឡើងហើយ ឬក៏ចិត្តរបស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ក៏មិនកើតឡើងហើយ ។ ចិត្តរបស់បុគ្គលណា មិនកើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា នឹងមិនកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ មិនកើតឡើងហើយ ។ ចិត្តរបស់បុគ្គលណា មិនកើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា នឹងមិនកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ មិន

កើតឡើងហើយ ។

[ ១១ ] ចិត្តរបស់បុគ្គលណា ធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយ ក៏មិនមែន ចិត្តរបស់បុគ្គលនោះ នឹងកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងកើតឡើង ចិត្តរបស់បុគ្គលនោះ កើតឡើងហើយក៏មិនមែន ចិត្តរបស់បុគ្គលនោះ ធ្លាប់កើតឡើងហើយ ។ ចិត្តរបស់បុគ្គលនោះ ដែលកើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា ធ្លាប់កើតឡើងហើយ ។ ចិត្តរបស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយ ក៏មិនមែន ចិត្តរបស់បុគ្គលនោះ នឹងមិនកើតឡើងទេ ឬក៏ចិត្តរបស់បុគ្គលណា នឹងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ មិនកើតឡើងហើយ ក៏មិនមែន ចិត្តរបស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ។

[ ១២ ] ចិត្តកើតឡើងហើយ ( ក៏មាន ) កំពុងកើតឡើង ( ក៏មាន ) ចិត្តកំពុងកើតឡើង ( ក៏មាន ) កើតឡើងហើយ ( ក៏មាន ) ។ ចិត្តមិនកើតឡើងហើយ ( ក៏មាន ) កាលមិនកើតឡើង ( ក៏មាន ) ចិត្ត កាលមិនកើតឡើង ( ក៏មាន ) មិនកើតឡើងហើយ ( ក៏មាន ) ។

[ ១៣ ] ចិត្តរលត់ហើយ ( ក៏មាន ) កំពុងរលត់ ( ក៏មាន ) ចិត្តកំពុងរលត់ ( ក៏មាន ) រលត់ហើយ ( ក៏មាន ) ។ ចិត្តមិនរលត់ហើយ ( ក៏មាន ) កាលមិនរលត់ ( ក៏មាន ) ចិត្ត កាលមិនរលត់ ( ក៏មាន ) មិនរលត់ហើយ ( ក៏មាន ) ។

[ ១៤ ] ចិត្តរបស់បុគ្គលណា កាលកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តរបស់បុគ្គលនោះ កាលនឹងរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ឬក៏ចិត្តរបស់បុគ្គលណា កាលនឹងរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តរបស់បុគ្គលនោះ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ។ ចិត្តរបស់បុគ្គលណា កាលមិនទាន់កើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តរបស់បុគ្គលនោះ កាលមិនទាន់រលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ឬក៏ចិត្តរបស់បុគ្គលណា កាលមិនទាន់រលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តរបស់បុគ្គលនោះ កាលមិនទាន់កើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ។

## ធម្មវារុទ្ទេស

[ ១៥ ] ចិត្តណា រមែងកើតឡើង មិនរលត់ ចិត្តនោះ នឹងរលត់ នឹងមិនកើតឡើង ឬក៏ចិត្តណានឹងរលត់ នឹងមិនកើតឡើង ចិត្តនោះ រមែងកើតឡើង រមែងមិនរលត់ ។ ចិត្តណា រមែងកើតឡើង តែងរលត់ ចិត្តនោះ នឹងមិនរលត់ នឹងកើតឡើង ឬក៏ចិត្តណា នឹងមិនរលត់ នឹងកើតឡើង ចិត្តនោះ រមែងមិនកើតឡើង រមែងរលត់ ។

[ ១៦ ] ចិត្តណា រមែងកើតឡើង ចិត្តនោះ ឈ្មោះថា កើតឡើងហើយ

ឬក៏ចិត្តណា កើតឡើងហើយ ចិត្តនោះ ឈ្មោះថា រមែងកើតឡើង ។ ចិត្តណា រមែងមិនកើតឡើង ចិត្តនោះ ឈ្មោះថា មិនកើតឡើងហើយ ឬក៏ចិត្តណា មិនកើតឡើងហើយ ចិត្តនោះ ឈ្មោះថា រមែងមិនកើតឡើង ។

[ ១៧ ] ចិត្តណារលត់ ចិត្តនោះ ឈ្មោះថា កើតឡើងហើយ ឬក៏ចិត្តណា កើតឡើងហើយ ចិត្តនោះ រមែងរលត់ ។ ចិត្តណា រមែងមិនរលត់ ចិត្តនោះ ឈ្មោះថា មិនកើតឡើងហើយ ឬក៏ចិត្តណា ដែលមិនកើតឡើងហើយ ចិត្តនោះ ឈ្មោះថា រមែងមិនរលត់ ។

[ ១៨ ] ចិត្តណា រមែងកើតឡើង ចិត្តនោះ ឈ្មោះថា ធ្លាប់កើតឡើងហើយ ឬក៏ចិត្តណា ធ្លាប់កើតឡើងហើយ ចិត្តនោះ រមែងកើតឡើង ។ ចិត្តណា រមែងមិនកើតឡើង ចិត្តនោះ ឈ្មោះថា មិនធ្លាប់កើតឡើងហើយ ឬក៏ចិត្តណា មិនធ្លាប់កើតឡើងហើយ ចិត្តនោះ ឈ្មោះថា រមែងមិនកើតឡើង ។ ចិត្តណា រមែងកើតឡើង ចិត្តនោះ ឈ្មោះថា នឹងកើតឡើង ឬក៏ចិត្តណា នឹងកើតឡើង ចិត្តនោះ ឈ្មោះថា រមែងកើតឡើង ។ ចិត្តណា រមែងមិនកើតឡើង ចិត្តនោះ ឈ្មោះថា នឹងមិនកើតឡើង ឬក៏ចិត្តណា នឹងមិនកើតឡើង ចិត្តនោះ ឈ្មោះថា រមែងមិនកើតឡើង ។ ចិត្តណា ធ្លាប់កើតឡើងហើយ ចិត្តនោះ ឈ្មោះថា នឹងកើតឡើង ឬក៏ចិត្តណា នឹងកើតឡើង ចិត្តនោះ ឈ្មោះថា ធ្លាប់កើតឡើងហើយ ។ ចិត្តណា មិនធ្លាប់កើតឡើងហើយ ចិត្តនោះ ឈ្មោះថា នឹងមិនកើតឡើង ឬក៏ចិត្តណា នឹងមិនកើតឡើង ចិត្តនោះ ឈ្មោះថា មិនធ្លាប់កើតឡើងហើយ ។

[ ១៩ ] ចិត្តណា រមែងរលត់ ចិត្តនោះ ឈ្មោះថា ធ្លាប់រលត់ហើយ ឬក៏ចិត្តណា ធ្លាប់រលត់ហើយ ចិត្តនោះ ឈ្មោះថា រមែងរលត់ ។ ចិត្តណា រមែងមិនរលត់ ចិត្តនោះ ឈ្មោះថា មិនធ្លាប់រលត់ហើយ ឬក៏ចិត្តណា មិនធ្លាប់រលត់ហើយ ចិត្តនោះ ឈ្មោះថា រមែងមិនរលត់ ។ ចិត្តណា រមែងរលត់ ចិត្តនោះ ឈ្មោះថា នឹងរលត់ ឬក៏ចិត្តណា នឹងរលត់ ចិត្តនោះ ឈ្មោះថា រមែងរលត់ ។ ចិត្តណា រមែងមិនរលត់ ចិត្តនោះ ឈ្មោះថា នឹងមិនរលត់ ឬក៏ចិត្តណា នឹងមិនរលត់ ចិត្តនោះ ឈ្មោះថា រមែងមិនរលត់ ។ ចិត្តណា ធ្លាប់រលត់ហើយ ចិត្តនោះ ឈ្មោះថា នឹងរលត់ ឬក៏ចិត្តណា នឹងរលត់ ចិត្តនោះ ឈ្មោះថា ធ្លាប់រលត់ហើយ ។ ចិត្តណា មិនធ្លាប់រលត់ ចិត្តនោះ ឈ្មោះថា នឹងមិនរលត់ ឬក៏ចិត្តណា នឹងមិនរលត់ ចិត្តនោះ ឈ្មោះថា មិនធ្លាប់រលត់ហើយ ។

[ ២០ ] ចិត្តណា រមែងកើតឡើង ចិត្តនោះ ឈ្មោះថា ធ្លាប់រលត់ហើយ ឬក៏ចិត្តណា ធ្លាប់រលត់ហើយ ចិត្តនោះ ឈ្មោះថា រមែងកើតឡើង ។ ចិត្តណា រមែងមិនកើតឡើង ចិត្តនោះ ឈ្មោះថា មិនធ្លាប់រលត់ហើយ ឬក៏ចិត្តណា មិនធ្លាប់រលត់ហើយ ចិត្តនោះ ឈ្មោះថា រមែងមិនកើតឡើង ។ ចិត្តណា រមែងកើតឡើង ចិត្តនោះ ឈ្មោះថា នឹងរលត់ ឬក៏ចិត្តណា នឹងរលត់ ចិត្តនោះ ឈ្មោះថា រមែងកើតឡើង ។ ចិត្តណា រមែងមិនកើតឡើង ចិត្តនោះ ឈ្មោះថា នឹងមិនរលត់ ឬក៏ចិត្តណា នឹងមិនរលត់ ចិត្តនោះ ឈ្មោះថា រមែងមិនកើតឡើង ។ ចិត្តណា ធ្លាប់កើតឡើងហើយ ចិត្តនោះ ឈ្មោះថា

នឹងរលត់ ឬក៏ចិត្តណា នឹងរលត់ ចិត្តនោះ ឈ្មោះថា ធ្លាប់កើតឡើងហើយ ។ ចិត្តណា មិនធ្លាប់កើតឡើងហើយ ចិត្តនោះ ឈ្មោះថា នឹងមិនរលត់ ឬក៏ចិត្តណា នឹងមិនរលត់ ចិត្តនោះ ឈ្មោះថា មិនធ្លាប់កើតឡើងហើយ ។

[ ២១ ] ចិត្តណា រមែងកើតឡើង ចិត្តនោះ ឈ្មោះថា មិនរលត់ ឬក៏ចិត្តណា រមែងមិនរលត់ ចិត្តនោះ ឈ្មោះថា រមែងកើតឡើង ។ ចិត្តណា រមែងមិនកើតឡើង ចិត្តនោះ ឈ្មោះថា រមែងរលត់ ឬក៏ចិត្តណា រមែងរលត់ ចិត្តនោះ ឈ្មោះថា រមែងមិនកើតឡើង ។

[ ២២ ] ចិត្តណា កំពុងកើតឡើង ចិត្តនោះ ឈ្មោះថា កើតឡើងហើយ ឬក៏ចិត្តណា កើតឡើងហើយ ចិត្តនោះ ឈ្មោះថា កំពុងកើតឡើង ។ ចិត្តណា កាលមិនកើតឡើង ចិត្តនោះ ឈ្មោះថា មិនកើតឡើងហើយ ឬក៏ចិត្តណា មិនកើតឡើងហើយ ចិត្តនោះ ឈ្មោះថា កាលមិនកើតឡើង ។

[ ២៣ ] ចិត្តណា កំពុងរលត់ ចិត្តនោះ ឈ្មោះថា កើតឡើងហើយ ឬក៏ចិត្តណា កើតឡើងហើយ ចិត្តនោះ ឈ្មោះថា កំពុងរលត់ ។ ចិត្តណា កាលមិនរលត់ ចិត្តនោះ ឈ្មោះថា មិនកើតឡើងហើយ ឬក៏ចិត្តណា មិនកើតឡើងហើយ ចិត្តនោះ ឈ្មោះថា កាលមិនរលត់ ។

[ ២៤ ] ចិត្តណា កើតឡើងហើយ ចិត្តនោះ ឈ្មោះថា ធ្លាប់កើតឡើងហើយ ឬក៏ចិត្តណា ធ្លាប់កើតឡើងហើយ ចិត្តនោះ ឈ្មោះថា កើតឡើងហើយ ។ ចិត្តណា កើតឡើងហើយ ចិត្តនោះ ឈ្មោះថា នឹងកើតឡើង ឬក៏ចិត្តណា នឹងកើតឡើង ចិត្តនោះ ឈ្មោះថា កើតឡើងហើយ ។ ចិត្តណា មិន

កើតឡើងហើយ ចិត្តនោះ ឈ្មោះថា មិនធ្លាប់កើតឡើងហើយ ឬក៏ចិត្តណា មិនធ្លាប់កើតឡើងហើយ ចិត្តនោះ ឈ្មោះថា មិនកើតឡើងហើយ ។ ចិត្តណា មិនកើតឡើងហើយ ចិត្តនោះ ឈ្មោះថា នឹងមិនកើតឡើង ឬក៏ចិត្តណា នឹងមិនកើតឡើង ចិត្តនោះ ឈ្មោះថា មិនកើតឡើងហើយ ។

[ ២៥ ] ចិត្តណា ធ្លាប់កើតឡើងហើយ ចិត្តនោះ ឈ្មោះថា កើតឡើងហើយ ក៏មិនមែន គឺចិត្តនោះ នឹងកើតឡើង ឬក៏ចិត្តណា នឹងកើតឡើង ចិត្តនោះ ឈ្មោះថា កើតឡើងហើយ ក៏មិនមែន គឺចិត្តនោះ ធ្លាប់កើតឡើងហើយ ។ ចិត្តណា មិនធ្លាប់កើតឡើងហើយ ចិត្តនោះ ឈ្មោះថា មិនកើតឡើងហើយ ក៏មិនមែន គឺចិត្តនោះ នឹងមិនកើតឡើង ឬក៏ចិត្តណា នឹងមិនកើតឡើង ចិត្តនោះ ឈ្មោះថា មិនកើតឡើងហើយ ក៏មិនមែន គឺចិត្តនោះ មិនធ្លាប់កើតឡើងហើយ ។

[ ២៦ ] ចិត្តកើតឡើងហើយ ( ក៏មាន ) កំពុងកើតឡើង ( ក៏មាន ) ចិត្តកំពុងកើតឡើង ( ក៏មាន ) កើតឡើងហើយ ( ក៏មាន ) ។ ចិត្តមិនកើតឡើងហើយ ( ក៏មាន ) កាលមិនកើតឡើង ( ក៏មាន ) ចិត្ត កាលមិនកើតឡើង ( ក៏មាន ) មិនកើតឡើងហើយ ( ក៏មាន ) ។

[ ២៧ ] ចិត្តរលត់ហើយ ( ក៏មាន ) កំពុងរលត់ ( ក៏មាន ) ចិត្តកំពុងរលត់ ( ក៏មាន ) រលត់ហើយ ( ក៏មាន ) ។ ចិត្តមិនរលត់ហើយ ( ក៏មាន ) កាលមិនរលត់ ( ក៏មាន ) ចិត្ត កាលមិនរលត់ ( ក៏មាន ) មិនរលត់ហើយ ( ក៏មាន ) ។

[ ២៨ ] ចិត្តណា កំពុងកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តនោះ កំពុងរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ឬក៏ចិត្តណា កំពុងរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តនោះ កំពុងកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ។ ចិត្តណា កាលមិនកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តនោះ កាលមិនរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ឬក៏ចិត្តណា កាលមិនរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តនោះ កាលមិនកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ។

## បុគ្គលធម្មវារុទ្ទេស

[ ២៩ ] ចិត្តណា របស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា នឹងរលត់ នឹងមិនកើតឡើង ឬក៏ចិត្តណា របស់បុគ្គលណា នឹងរលត់ នឹងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងកើតឡើង រមែងមិនរលត់ ។ ចិត្តណា របស់បុគ្គលណា រមែងមិនកើតឡើង រមែងរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា នឹងមិនរលត់ នឹងកើតឡើង ឬក៏ចិត្តណា របស់បុគ្គលណា នឹងមិនរលត់ នឹងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងមិនកើតឡើង រមែងរលត់ ។

[ ៣០ ] ចិត្តណា របស់បុគ្គលណា រមែងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយ ឬក៏ចិត្តណា របស់បុគ្គលណា កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងកើតឡើង ។ ចិត្តណា របស់បុគ្គលណា រមែងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងកើតឡើង ។ ចិត្តណា របស់បុគ្គលណា រមែងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយ ឬក៏ចិត្តណា របស់បុគ្គលណា មិនកើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងមិនកើតឡើង ។

[ ៣១ ] ចិត្តណា របស់បុគ្គលណា រមែងរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយ ឬក៏ចិត្តណា របស់បុគ្គលណា កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងរលត់ ។ ចិត្តណា របស់បុគ្គលណា រមែងមិនរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយ ឬក៏ចិត្តណា របស់បុគ្គលណា មិនកើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងមិនរលត់ ។

[ ៣២ ] ចិត្តណា របស់បុគ្គលណា រមែងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា ធ្លាប់កើតឡើងហើយ ឬក៏ចិត្តណា របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងកើតឡើង ។ ចិត្តណា របស់បុគ្គលណា រមែងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា មិនធ្លាប់កើតឡើងហើយ ឬក៏ចិត្តណា របស់បុគ្គលណា មិនធ្លាប់

កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងមិនកើតឡើង ។ ចិត្តណា របស់បុគ្គលណា រមែងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា នឹងកើតឡើង ឬក៏ចិត្តណា របស់បុគ្គលណា នឹងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងកើតឡើង ។ ចិត្តណា របស់បុគ្គលណា រមែងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា នឹងមិនកើតឡើង ឬក៏ចិត្តណា របស់បុគ្គលណា នឹងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងមិនកើតឡើង ។ ចិត្តណា របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា នឹងកើតឡើង ឬក៏ចិត្តណា របស់បុគ្គលណា នឹងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា ធ្លាប់កើតឡើងហើយ ។ ចិត្តណា របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា នឹងមិនកើតឡើង ឬក៏ចិត្តណា របស់បុគ្គលណា នឹងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា មិនធ្លាប់កើតឡើងហើយ ។

[ ៣៣ ] ចិត្តណា របស់បុគ្គលណា រមែងរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា ធ្លាប់រលត់ហើយ ឬក៏ចិត្តណា របស់បុគ្គលណា ធ្លាប់រលត់ហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងរលត់ ។ ចិត្តណា របស់បុគ្គលណា រមែងមិនរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា មិនធ្លាប់រលត់ហើយ ឬក៏ចិត្តណា របស់បុគ្គលណា មិនធ្លាប់រលត់ហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងមិនរលត់ ។ ចិត្តណា របស់បុគ្គលណា

រមែងរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា នឹងរលត់ ឬក៏ចិត្តណា របស់បុគ្គលណា នឹងរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងរលត់ ។ ចិត្តណា របស់បុគ្គលណា រមែងមិនរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា នឹងមិនរលត់ ឬក៏ចិត្តណា របស់បុគ្គលណា នឹងមិនរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងមិនរលត់ ។ ចិត្តណា របស់បុគ្គលណា ធ្លាប់រលត់ហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា នឹងរលត់ ឬក៏ចិត្តណា របស់បុគ្គលណា នឹងរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា ធ្លាប់រលត់ហើយ ។ ចិត្តណា របស់បុគ្គលណា មិនធ្លាប់រលត់ហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា នឹងមិនរលត់ ឬក៏ចិត្តណា របស់បុគ្គលណា នឹងមិនរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា មិនធ្លាប់រលត់ហើយ ។

[ ៣៤ ] ចិត្តណា របស់បុគ្គលណា រមែងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា ធ្លាប់រលត់ហើយ ឬក៏ចិត្តណា របស់បុគ្គលណា ធ្លាប់រលត់ហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងកើតឡើង ។ ចិត្តណា របស់បុគ្គលណា រមែងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា មិនធ្លាប់រលត់ហើយ ឬក៏ចិត្តណា របស់បុគ្គលណា មិនធ្លាប់រលត់ហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងមិនកើតឡើង ។ ចិត្តណា របស់បុគ្គលណា រមែងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា នឹងរលត់ ឬក៏ចិត្តណា របស់បុគ្គលណា នឹងរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះ

ថា រមែងកើតឡើង ។ ចិត្តណា របស់បុគ្គលណា រមែងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា នឹងមិនរលត់ ឬក៏ចិត្តណា របស់បុគ្គលណា នឹងមិនរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងមិនកើតឡើង ។ ចិត្តណា របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា នឹងរលត់ ឬក៏ចិត្តណា របស់បុគ្គលណា នឹងរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា ធ្លាប់កើតឡើងហើយ ។ ចិត្តណា របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា នឹងរលត់ ឬក៏ចិត្តណា របស់បុគ្គលណា នឹងមិនរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា មិនធ្លាប់កើតឡើងហើយ ។

[ ៣៥ ] ចិត្តណា របស់បុគ្គលណា រមែងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងមិនរលត់ ឬក៏ចិត្តណា របស់បុគ្គលណា រមែងមិនរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងកើតឡើង ។ ចិត្តណា របស់បុគ្គលណា រមែងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងរលត់ ឬក៏ចិត្តណា របស់បុគ្គលណា រមែងរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា រមែងមិនកើតឡើង ។

[ ៣៦ ] ចិត្តណា របស់បុគ្គលណា កំពុងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយ ឬក៏ចិត្តណា របស់បុគ្គលណា កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា កំពុងកើតឡើង ។ ចិត្តណា របស់បុគ្គលណា កាលមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះ

ថា មិនកើតឡើងហើយ ឬក៏ចិត្តណា របស់បុគ្គលណា មិនកើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា កាលមិនកើតឡើង ។

[ ៣៧ ] ចិត្តណា របស់បុគ្គលណា កំពុងរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយ ឬក៏ចិត្តណា របស់បុគ្គលណា កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា កំពុងរលត់ ។ ចិត្តណា របស់បុគ្គលណា កាលមិនរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយ ឬក៏ចិត្តណា របស់បុគ្គលណា មិនកើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា កាលមិនរលត់ ។

[ ៣៨ ] ចិត្តណា របស់បុគ្គលណា កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា ធ្លាប់កើតឡើងហើយ ឬក៏ចិត្តណា របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយ ។ ចិត្តណា របស់បុគ្គលណា កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា នឹងកើតឡើង ឬក៏ចិត្តណា របស់បុគ្គលណា នឹងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយ ។ ចិត្តណា របស់បុគ្គលណា មិនកើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា មិនធ្លាប់កើតឡើងហើយ ឬក៏ចិត្តណា របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយ ។ ចិត្តណា របស់បុគ្គលណា មិនកើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា នឹងមិនកើតឡើង ឬក៏ចិត្តណា របស់បុគ្គលណា នឹងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ

ឈ្មោះថា មិនកើតឡើងហើយ ។

[ ៣៩ ] ចិត្តណា របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយ ក៏មិនមែន គឺចិត្តនោះ របស់បុគ្គលនោះ នឹងកើតឡើង ឬក៏ចិត្តណា របស់បុគ្គលណា នឹងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយ ក៏មិនមែន គឺចិត្តនោះ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយ ។ ចិត្តណា របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយ ក៏មិនមែន គឺចិត្តនោះ របស់បុគ្គលនោះ នឹងមិនកើតឡើង ឬក៏ចិត្តណា របស់បុគ្គលណា នឹងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយ ក៏មិនមែន គឺចិត្តនោះ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ។

[ ៤០ ] ចិត្តកើតឡើងហើយ ( ក៏មាន ) កំពុងកើតឡើង ( ក៏មាន ) ចិត្តកំពុងកើតឡើង ( ក៏មាន ) កើតឡើងហើយ ( ក៏មាន ) ។ ចិត្តមិនកើតឡើងហើយ ( ក៏មាន ) កាលមិនកើតឡើង ( ក៏មាន ) ចិត្ត កាលមិនកើតឡើង ( ក៏មាន ) មិនកើតឡើងហើយ ( ក៏មាន ) ។

[ ៤១ ] ចិត្តរលត់ហើយ ( ក៏មាន ) កំពុងរលត់ ( ក៏មាន ) ចិត្តកំពុងរលត់ ( ក៏មាន ) រលត់ហើយ ( ក៏មាន ) ។ ចិត្តមិនរលត់ហើយ ( ក៏មាន ) កាលមិនរលត់ ( ក៏មាន ) ចិត្ត កាលមិនរលត់ ( ក៏មាន ) មិនរលត់ហើយ ( ក៏មាន ) ។

*[ ៤២ ] ចិត្តណា របស់បុគ្គលណា កាលកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តនោះ របស់បុគ្គលនោះ កាលរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ឬក៏ចិត្តណា របស់បុគ្គលណា កាលរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តនោះ របស់បុគ្គលនោះ កាលកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ។ ចិត្តណា របស់បុគ្គលណា កាលមិនកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តនោះ របស់បុគ្គលនោះ កាលមិនរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ឬក៏ចិត្តណា របស់បុគ្គលណា កាលមិនរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តនោះ របស់បុគ្គលនោះ កាលមិនកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ។*

## មិស្សកវារុទ្ទេស

*[ ៤៣ ] ចិត្តប្រកបដោយរាគៈ របស់បុគ្គលណា រមែងកើតឡើង ចិត្តប្រាសចាករាគៈ របស់បុគ្គលណា រមែងកើតឡើង ចិត្តប្រកបដោយទោសៈ របស់បុគ្គលណា រមែងកើតឡើង ចិត្តប្រាសចាកទោសៈ របស់បុគ្គលណា រមែងកើតឡើង ចិត្តប្រកបដោយមោហៈ របស់បុគ្គលណា រមែងកើតឡើង ចិត្តប្រាសចាកមោហៈ របស់បុគ្គលណា រមែងកើតឡើង ចិត្តរួញរារបស់បុគ្គលណា រមែងកើតឡើង ចិត្តរាយមាយ របស់បុគ្គលណា រមែងកើតឡើង*

*ចិត្តជាមហគ្គតៈ ( រូបាវចរ និងអរូបាវចរ ) របស់បុគ្គលណា រមែងកើតឡើង ចិត្តជាអមហគ្គតៈ ( លោកិយ និងលោកុត្តរ ) របស់បុគ្គលណា រមែងកើតឡើង ចិត្តជាសឧត្តរៈ ( លោកិយ ) របស់បុគ្គលណា រមែងកើតឡើង ចិត្តជាអនុត្តរៈ ( លោកុត្តរ ) របស់បុគ្គលណា រមែងកើតឡើង ចិត្តដែលតម្កល់មាំ របស់បុគ្គលណា រមែងកើតឡើង ចិត្តដែលមិនបានតម្កល់មាំ របស់បុគ្គលណា រមែងកើតឡើង ចិត្តរួចស្រឡះ ( ចាកអាសវក្កិលេស ) របស់បុគ្គលណា រមែងកើតឡើង ចិត្តមិនរួចស្រឡះ របស់បុគ្គលណា រមែងកើតឡើង ចិត្តជាកុសល របស់បុគ្គលណា រមែងកើតឡើង ចិត្តជាអកុសល របស់បុគ្គលណា រមែងកើតឡើង ចិត្តជាអព្យាក្រឹត របស់បុគ្គលណា រមែងកើតឡើង ចិត្តប្រកបដោយសុខវេទនា របស់បុគ្គលណា រមែងកើតឡើង ( ធម៌ទាំងនេះ បណ្ឌិតគប្បីរើឡើងដរាបដល់សរណៈ និងអរណៈដោយឧបាយនេះ ) ចិត្តជាអរណៈ ( មិនសៅហ្មង ) របស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់ ចិត្តជាអរណៈរបស់បុគ្គលនោះ នឹងរលត់ នឹងមិនកើតឡើង ឬក៏ចិត្តជាអរណៈ របស់បុគ្គលណា នឹងរលត់ នឹងមិនកើតឡើង ចិត្តជាអរណៈ របស់បុគ្គលនោះ រមែងកើតឡើង រមែងមិនរលត់ ។*

**ឧទ្ទេសវារៈ ចប់**

# បុគ្គលវារនិទ្ទេស

[ ៤៤ ] សួរ. ចិត្តរបស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ នឹងរលត់ នឹងមិនកើតឡើងទេឬ ។ ឆ្លើយ. ចិត្តរបស់ពួកជននោះ រមែងកើតឡើង រមែងមិនរលត់ នឹងរលត់ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈ ( ខណៈជាទីកើត ) នៃបច្ឆិមចិត្ត ឯចិត្តរបស់ពួកជននោះក្រៅនេះ រមែងកើតឡើង រមែងមិនរលត់ នឹងរលត់ផង នឹងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ។ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងរលត់ នឹងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង រមែងមិនរលត់មែនឬ ។ អើ ។ ចិត្តរបស់បុគ្គលណា រមែងមិនកើតឡើង រមែងរលត់ ចិត្តរបស់បុគ្គលនោះ នឹងមិនរលត់ នឹងកើតឡើងឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងមិនរលត់ នឹងកើតឡើង ចិត្តរបស់បុគ្គលនោះ រមែងមិនកើតឡើង រមែងរលត់ឬ ។ មិនមានទេ ។

[ ៤៥ ] ចិត្តរបស់បុគ្គលណា រមែងកើតឡើង ចិត្តរបស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ រមែងកើតឡើងឬ ។ ចិត្តរបស់ពួកជននោះ កើតឡើងហើយ ក្នុងភង្គក្ខណៈ ( ខណៈជាទីបែកធ្លាយ ) នៃចិត្ត តែចិត្តរបស់ពួកជននោះ រមែងមិនកើតឡើងទេ ចិត្តរបស់ពួកជននោះ កើតឡើងហើយផង រមែងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ។ ចិត្តរបស់បុគ្គលណា រមែងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយឬ ។ ចិត្តរបស់ពួកជននោះ រមែងមិនកើតឡើងក្នុងភង្គក្ខណៈនៃចិត្ត តែចិត្ត

របស់ពួកជននោះ ឈ្មោះថា មិនកើតឡើងហើយ ក៏មិនមែន ចិត្តរបស់ពួកជននោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ រមែងមិនកើតឡើងផង មិនកើតឡើងហើយផង ។ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា មិនកើតឡើងហើយ ចិត្តរបស់បុគ្គលនោះ រមែងមិនកើតឡើងឬ ។ អើ ។

[ ៤៦ ] ចិត្តរបស់បុគ្គលណា រមែងរលត់ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ រមែងរលត់ឬ ។ ចិត្តរបស់ពួកជននោះ កើតឡើងហើយ ក្នុងឧប្បាទក្ខណៈនៃចិត្ត តែចិត្តរបស់ពួកជននោះ រមែងមិនរលត់ទេ ចិត្តរបស់ពួកជននោះ កើតឡើងហើយផង រមែងរលត់ផង ក្នុងភង្គក្ខណៈនៃចិត្ត ។ ចិត្តរបស់បុគ្គលណា រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយឬ ។ ចិត្តរបស់ពួកជននោះ រមែងមិនរលត់ក្នុងឧប្បាទក្ខណៈនៃចិត្ត តែចិត្តរបស់ពួកជននោះ ឈ្មោះថា មិនកើតឡើងហើយ ក៏មិនមែន ចិត្តរបស់ពួកជននោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ រមែងមិនរលត់ផង មិនកើតឡើងហើយផង ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា មិនកើតឡើងហើយ ចិត្តរបស់បុគ្គលនោះ រមែងមិនរលត់ទេឬ ។ អើ ។

[ ៤៧ ] ចិត្តរបស់បុគ្គលណា រមែងកើតឡើង ចិត្តរបស់បុគ្គលនោះ ឈ្មោះថា ធ្លាប់កើតឡើងហើយឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា ធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ រមែងកើតឡើងឬ ។ ចិត្តរបស់

ពួកជនទោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ ធ្លាប់កើតឡើងហើយ ក្នុងភង្គក្ខណៈនៃចិត្ត តែចិត្តរបស់ពួកជនទោះ រមែងមិនកើតឡើងទេ ចិត្តរបស់ពួកជនទោះ ឈ្មោះថា ធ្លាប់កើតឡើងហើយផង រមែងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ។ ចិត្តរបស់បុគ្គលណា រមែងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយទេឬ ។ ធ្លាប់កើតឡើងហើយ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ រមែងមិនកើតឡើងឬ ។ មិនមានទេ ។ ចិត្តរបស់បុគ្គលណា រមែងកើតឡើង ចិត្តរបស់បុគ្គលនោះ នឹងកើតឡើងឬ ។ ចិត្តរបស់ពួកជនទោះ រមែងកើតឡើង ក្នុងឧប្បាទក្ខណៈ ( ខណៈជាទីកើតឡើង ) នៃបច្ឆិមចិត្ត តែចិត្តរបស់ពួកជនទោះ នឹងកើតឡើង ក៏មិនមែន ចិត្តរបស់ពួកជនទោះ ក្រៅនេះ រមែងកើតឡើងផង នឹងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងកើតឡើង ចិត្តរបស់បុគ្គលនោះ រមែងកើតឡើងឬ ។ ចិត្តរបស់ពួកជនទោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ ឈ្មោះថា នឹងកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត តែចិត្តរបស់ពួកជនទោះ រមែងមិនកើតឡើងទេ ក៏មិនមែន ចិត្តរបស់ពួកជនទោះ នឹងកើតឡើងផង រមែងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ។ ចិត្តរបស់បុគ្គលណា រមែងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ នឹងមិនកើតឡើងទេឬ ។ ចិត្តរបស់ពួកជនទោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ រមែងមិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត តែចិត្តរបស់ពួកជនទោះ នឹងមិនកើតឡើង

*ក៏មិនមែន ចិត្តរបស់ពួកជននោះ រមែងមិនកើតឡើងផង នឹងមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ។ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ រមែងមិនកើតឡើងទេឬ ។ ចិត្តរបស់ពួកជននោះ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត តែចិត្តរបស់ពួកជននោះ រមែងមិនកើតឡើង ក៏មិនមែន ចិត្តរបស់ពួកជននោះ នឹងមិនកើតឡើងផង រមែងមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ។ ចិត្តរបស់បុគ្គលណា ធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ នឹងកើតឡើងឬ ។ ចិត្តរបស់ពួកជននោះ ធ្លាប់កើតឡើងហើយ ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត តែចិត្តរបស់ពួកជននោះ នឹងកើតឡើងក៏មិនមែន ចិត្តរបស់ពួកជននោះ ក្រៅពីនេះ ធ្លាប់កើតឡើងហើយផង នឹងកើតឡើងផង ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងកើតឡើង ចិត្តរបស់បុគ្គលនោះ កើតឡើងហើយឬ ។ អើ ។ ចិត្តរបស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ មិនមានទេ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយទេឬ ។ ធ្លាប់កើតឡើងហើយ ។*

*[ ៤៨ ] ចិត្តរបស់បុគ្គលណា រមែងរលត់ ចិត្តរបស់បុគ្គលនោះ ធ្លាប់រលត់ហើយឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា ធ្លាប់រលត់ហើយ ចិត្តរបស់បុគ្គលនោះ តែងរលត់ឬ ។ ចិត្តរបស់ពួកជននោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ ធ្លាប់រលត់ហើយ ក្នុងឧប្បាទក្ខណៈនៃចិត្ត តែចិត្តរបស់ពួកជននោះ តែងរលត់ ក៏មិនមែន ចិត្តរបស់ពួកជននោះ ធ្លាប់*

*រលត់ហើយផង តែងរលត់ផង ក្នុងភង្គក្ខណៈនៃចិត្ត ។ ចិត្តរបស់បុគ្គលណា រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ មិនធ្លាប់រលត់ហើយទេឬ ។ ធ្លាប់រលត់ហើយ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា មិនធ្លាប់រលត់ហើយ ចិត្តរបស់បុគ្គលនោះ រមែងមិនរលត់ទេឬ ។ មិនមានទេ ។ ចិត្តរបស់បុគ្គលណា រមែងរលត់ ចិត្តរបស់បុគ្គលនោះ នឹងរលត់ឬ ។ ចិត្តរបស់ពួកជននោះ រមែងរលត់ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត តែចិត្តរបស់ពួកជននោះ នឹងរលត់ក៏មិនមែន ចិត្តរបស់ពួកជននោះ ក្រៅពីនេះ រមែងរលត់ផង នឹងរលត់ផង ក្នុងភង្គក្ខណៈនៃចិត្ត ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងរលត់ ចិត្តរបស់បុគ្គលនោះ រមែងរលត់ឬ ។ ចិត្តរបស់ពួកជននោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ នឹងរលត់ក្នុងឧប្បាទក្ខណៈនៃចិត្ត តែចិត្តរបស់ពួកជននោះ រមែងរលត់ ក៏មិនមែន ចិត្តរបស់ពួកជននោះ នឹងរលត់ផង រមែងរលត់ផង ក្នុងភង្គក្ខណៈនៃចិត្ត ។ ចិត្តរបស់បុគ្គលណា រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ នឹងមិនរលត់ឬ ។ នឹងរលត់ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងមិនរលត់ ចិត្តរបស់បុគ្គលនោះ រមែងមិនរលត់ទេឬ ។ រមែងរលត់ ។ ចិត្តរបស់បុគ្គលណា ធ្លាប់រលត់ហើយ ចិត្តរបស់បុគ្គលនោះ នឹងរលត់ឬ ។ ចិត្តរបស់ពួកជននោះ ធ្លាប់រលត់ហើយ ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត តែចិត្តរបស់ពួកជននោះ នឹងរលត់ ក៏មិនមែន ចិត្តរបស់ពួកជននោះ ក្រៅពីនេះ ធ្លាប់រលត់ហើយផង នឹងរលត់ផង ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងរលត់ ចិត្តរបស់បុគ្គលនោះ ធ្លាប់រលត់ហើយឬ ។ អើ ។ ចិត្តរបស់បុគ្គលណា មិន*

ធ្លាប់រលត់ហើយ ចិត្តរបស់បុគ្គលនោះ នឹងមិនរលត់ឬ ។ មិនមានទេ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងមិនរលត់ ចិត្តរបស់បុគ្គលនោះ មិនធ្លាប់រលត់ហើយឬ ។ ធ្លាប់រលត់ហើយ ។

[ ៤៩ ] ចិត្តរបស់បុគ្គលណា រមែងកើតឡើង ចិត្តរបស់បុគ្គលនោះ ធ្លាប់រលត់ហើយឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា ធ្លាប់រលត់ហើយ ចិត្តរបស់បុគ្គលនោះ រមែងកើតឡើងឬ ។ ចិត្តរបស់ពួកជននោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ ធ្លាប់រលត់ហើយ ក្នុងភង្គក្ខណៈនៃចិត្ត តែចិត្តរបស់ពួកជននោះ រមែងកើតឡើង ក៏មិនមែន ចិត្តរបស់ពួកជននោះ ធ្លាប់រលត់ហើយផង រមែងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ។ ចិត្តរបស់បុគ្គលណា រមែងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ មិនធ្លាប់រលត់ហើយឬ ។ ធ្លាប់រលត់ហើយ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា មិនធ្លាប់រលត់ហើយ ចិត្តរបស់បុគ្គលនោះ រមែងមិនកើតឡើងឬ ។ មិនមាន ។ ចិត្តរបស់បុគ្គលណា រមែងកើតឡើង ចិត្តរបស់បុគ្គលនោះ នឹងរលត់ឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងរលត់ ចិត្តរបស់បុគ្គលនោះ រមែងកើតឡើងឬ ។ ចិត្តរបស់ពួកជននោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ នឹងរលត់ ក្នុងភង្គក្ខណៈនៃចិត្ត តែចិត្តរបស់ពួកជននោះ រមែងកើតឡើង ក៏មិនមែន ចិត្តរបស់ពួកជននោះ នឹងរលត់ផង រមែងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ។ ចិត្តរបស់បុគ្គលណា រមែងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ នឹងមិនរលត់ទេឬ ។ ចិត្តរបស់ពួកជននោះ គឺលោកដែល

ចូលកាន់និរោធ និងពួកអសញ្ញសត្វ រមែងមិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត តែចិត្តរបស់ពួកជននោះ នឹងមិនរលត់ ក៏មិនមែន ចិត្តរបស់ពួកជននោះ រមែងមិនកើតឡើងផង នឹងមិនរលត់ផង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងមិនរលត់ ចិត្តរបស់បុគ្គលនោះ រមែងមិនកើតឡើងឬ ។ អើ ។ ចិត្តរបស់បុគ្គលណា ធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ នឹងរលត់ឬ ។ ចិត្តរបស់ពួកជននោះ ធ្លាប់កើតឡើងហើយ ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត តែចិត្តរបស់ពួកជននោះ នឹងរលត់ ក៏មិនមែន ចិត្តរបស់ពួកជននោះ ក្រៅពីនេះ ធ្លាប់កើតឡើងហើយផង នឹងរលត់ផង ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងរលត់ ចិត្តរបស់បុគ្គលនោះ ធ្លាប់កើតឡើងហើយឬ ។ អើ ។ ចិត្តរបស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ នឹងមិនរលត់ទេឬ ។ មិនមានទេ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងមិនរលត់ ចិត្តរបស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយឬ ។ ធ្លាប់កើតឡើងហើយ ។

[ ៥០ ] ចិត្តរបស់បុគ្គលណា រមែងកើតឡើង ចិត្តរបស់បុគ្គលនោះ មិនរលត់ទេឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ រមែងកើតឡើងឬ ។ ចិត្តរបស់ពួកជននោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ រមែងមិនរលត់ទេ តែចិត្តរបស់ពួកជននោះ រមែងកើតឡើង ក៏មិនមែន ចិត្តរបស់ពួកជននោះ រមែងមិនរលត់ផង រមែងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ។ ចិត្តរបស់បុគ្គលណា

រមែងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ តែងរលត់ឬ ។ ចិត្តរបស់ពួកជននោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ រមែងមិនកើតឡើងទៀតទេ តែចិត្តរបស់ពួកជននោះ រមែងរលត់ក៏មិនមែន ចិត្តរបស់ពួកជននោះ រមែងមិនកើតឡើងផង រមែងរលត់ផង ក្នុងភង្គក្ខណៈនៃចិត្ត ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា រមែងរលត់ ចិត្តរបស់បុគ្គលនោះ មិនកើតឡើងឬ ។ អើ ។

[ ៥១ ] ចិត្តរបស់បុគ្គលណា កំពុងកើតឡើង ចិត្តរបស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា កំពុងកើតឡើងឬ ។ ចិត្តរបស់ពួកជននោះ កើតឡើងហើយ ក្នុងភង្គក្ខណៈនៃចិត្ត តែចិត្តរបស់ពួកជននោះ កំពុងកើតឡើង ក៏មិនមែន ចិត្តរបស់ពួកជននោះ កើតឡើងហើយផង កំពុងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ។ តែចិត្តរបស់បុគ្គលណា កាលមិនកើតឡើង ចិត្តរបស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយឬ ។ ចិត្តរបស់ពួកជននោះ កាលមិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត តែចិត្តរបស់ពួកជននោះ មិនកើតឡើងហើយ ក៏មិនមែន ចិត្តរបស់ពួកជននោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ កាលមិនកើតឡើងផង មិនកើតឡើងហើយផង ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា មិនកើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងទេឬ ។ អើ ។

[ ៥២ ] ចិត្តរបស់បុគ្គលណា កាលរលត់ ចិត្តរបស់បុគ្គលនោះ

ឈ្មោះថា កើតឡើងហើយឬ ។ អើ ។ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា កំពុងរលត់ឬ ។ ចិត្តរបស់ពួកជននោះ កើតឡើងហើយ ក្នុងឧប្បាទក្ខណៈនៃចិត្ត តែចិត្តរបស់ពួកជននោះ កំពុងរលត់ ក៏មិនមែន ចិត្តរបស់ពួកជននោះ កើតឡើងហើយផង កំពុងរលត់ផង ក្នុងភង្គក្ខណៈនៃចិត្ត ។ ចិត្តរបស់បុគ្គលណា កាលមិនរលត់ ចិត្តរបស់បុគ្គលនោះ មិនកើតឡើងហើយឬ ។ ចិត្តរបស់ពួកជននោះ កាលមិនរលត់ ក្នុងឧប្បាទក្ខណៈនៃចិត្ត តែចិត្តរបស់ពួកជននោះ មិនកើតឡើងហើយ ក៏មិនមែន ចិត្តរបស់ពួកជននោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ កាលមិនរលត់ផង មិនកើតឡើងហើយផង ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា មិនកើតឡើងហើយ ចិត្តរបស់បុគ្គលនោះ កាលមិនរលត់ឬទេ ។ អើ ។

[ ៥៣ ] ចិត្តរបស់បុគ្គលណា កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា ធ្លាប់កើតឡើងហើយឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា ធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយឬ ។ ចិត្តរបស់ពួកជននោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ ធ្លាប់កើតឡើងហើយ តែចិត្តរបស់ពួកជននោះ កើតឡើងហើយ ក៏មិនមែន ចិត្តរបស់ពួកជននោះ ដែលព្រមព្រៀងដោយចិត្ត ធ្លាប់កើតឡើងហើយផង កើតឡើងហើយផង ។ ចិត្តរបស់បុគ្គលណា កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ នឹងកើតឡើងឬ ។ ចិត្តរបស់ពួកជននោះ ដែលព្រមព្រៀងដោយបច្ឆិម-

ចិត្ត កើតឡើងហើយ តែចិត្តរបស់ពួកជននោះ នឹងកើតឡើង ក៏មិនមែន ចិត្តរបស់ពួកជននោះ ក្រៅពីនេះ ដែលព្រមព្រៀងដោយចិត្ត កើតឡើងហើយផង នឹងកើតឡើងផង ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងកើតឡើង ចិត្តរបស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយឬ ។ ចិត្តរបស់ពួកជននោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ នឹងកើតឡើង តែចិត្តរបស់ពួកជននោះ កើតឡើងហើយ ក៏មិនមែន ចិត្តរបស់ពួកជននោះ ដែលព្រមព្រៀងដោយចិត្ត នឹងកើតឡើងផង កើតឡើងហើយផង ។ ចិត្តរបស់បុគ្គលណា មិនកើតឡើងហើយ ចិត្តរបស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយឬ ។ ធ្លាប់កើតឡើងហើយ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ចិត្តរបស់បុគ្គលនោះ មិនកើតឡើងហើយឬ ។ មិនមានទេ ។ ចិត្តរបស់បុគ្គលណា មិនកើតឡើងហើយ ចិត្តរបស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ នឹងកើតឡើង ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។

[ ៥៤ ] ចិត្តរបស់បុគ្គលណា ធ្លាប់កើតឡើងហើយ តែចិត្តរបស់បុគ្គលនោះ កើតឡើងហើយ ក៏មិនមែន ចិត្តរបស់បុគ្គលនោះ នឹងកើតឡើងឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងកើតឡើង តែចិត្តរបស់បុគ្គលនោះ កើតឡើងហើយ ក៏មិនមែន ចិត្តរបស់បុគ្គលនោះ ធ្លាប់កើតឡើងហើយឬ ។ អើ ។ ចិត្តរបស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ តែចិត្តរបស់បុគ្គលនោះ មិនកើតឡើងហើយ ក៏មិនមែន ចិត្តរបស់បុគ្គលនោះ នឹងមិនកើត

ឡើងឬ ។ មិនមានទេ ។ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា នឹងមិនកើតឡើង តែចិត្តរបស់បុគ្គលនោះ មិនកើតឡើងហើយ ក៏មិនមែន ចិត្តរបស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយឬ ។ ធ្លាប់កើតឡើងហើយ ។

[ ៥៥ ] ចិត្តកើតឡើងហើយ ( ក៏មាន ) កំពុងកើតឡើង ( ក៏មាន ) ឬ ។ ចិត្តកើតឡើងហើយ ក្នុងភង្គក្ខណៈ ឈ្មោះថា កំពុងកើតឡើង ក៏មិនមែន គឺកើតឡើងហើយផង កំពុងកើតឡើងផង ក្នុងឧប្បាទក្ខណៈ ។ ចិត្តកំពុងកើតឡើង ( ក៏មាន ) កើតឡើងហើយ ( ក៏មាន ) ឬ ។ អើ ។ ចិត្តមិនកើតឡើងហើយ ( ក៏មាន ) កាលមិនកើតឡើង ( ក៏មាន ) ឬ ។ អើ ។ ចិត្តកាលមិនកើតឡើង ( ក៏មាន ) មិនកើតឡើងហើយ ( ក៏មាន ) ឬ ។ ចិត្តកាលមិនកើតឡើង ក្នុងភង្គក្ខណៈ ឈ្មោះថា មិនកើតឡើងហើយ ក៏មិនមែន ចិត្តជាអតីត និងអនាគត ឈ្មោះថា កាលមិនកើតឡើងផង មិនកើតឡើងហើយផង ។

[ ៥៦ ] ចិត្តរលត់ហើយ ( ក៏មាន ) កាលរលត់ ( ក៏មាន ) ឬ ។ មិនមែនទេ ។ ចិត្តកាលរលត់ ( ក៏មាន ) រលត់ហើយ ( ក៏មាន ) ឬ ។ មិនមែនទេ ។ ចិត្តមិនរលត់ហើយ ( ក៏មាន ) កាលមិនរលត់ ( ក៏មាន ) ឬ ។ ចិត្តមិនរលត់ហើយ ក្នុងភង្គក្ខណៈ តែឈ្មោះថា កាលមិនរលត់ក៏មិនមែន គឺចិត្តជាអនាគត មិនរលត់ផង កាលមិនរលត់ផង ក្នុងឧប្បាទក្ខណៈ ។ ចិត្តកាលមិនរលត់ ( ក៏មាន ) មិនរលត់ហើយ ( ក៏មាន ) ឬ ។ ចិត្តជាអតីតកាលមិនរលត់ទេ តែឈ្មោះថា មិនរលត់ហើយ ក៏មិនមែន ចំណែកខាងចិត្ត

ជាអនាគត កាលមិនរលត់ផង មិនរលត់ហើយផង ក្នុងឧប្បាទក្ខណៈ ។

[ ៥៧ ] ចិត្តរបស់បុគ្គលណា កាលកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តរបស់បុគ្គលនោះ កាលរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយឬ ។ ចិត្តក្នុងភង្គក្ខណៈ ជាចិត្តកន្លងនូវឧប្បាទក្ខណៈ មិនកន្លងនូវភង្គក្ខណៈទេ ចិត្តកន្លងហើយ ជាចិត្តកន្លងនូវឧប្បាទក្ខណៈផង កន្លងនូវភង្គក្ខណៈផង ។ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា កំពុងរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តរបស់បុគ្គលនោះ កំពុងកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយឬ ។ ចិត្តកន្លងហើយ ។ ចិត្តរបស់បុគ្គលណា កាលមិនកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តរបស់បុគ្គលនោះ កាលមិនរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយឬ ។ ចិត្តក៏ជាអនាគត ក្នុងឧប្បាទក្ខណៈ ។ ម្យ៉ាងទៀត ចិត្តរបស់បុគ្គលណា កាលមិនរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តរបស់បុគ្គលនោះ កាលមិនកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយឬ ។ ចិត្តក្នុងភង្គក្ខណៈ ជាចិត្តមិនកន្លងនូវភង្គក្ខណៈទេ ទាំងមិនកន្លងនូវឧប្បាទក្ខណៈ ក៏មិនមែន គឺចិត្តជាអនាគត ក្នុងឧប្បាទក្ខណៈ មិនកន្លងនូវភង្គក្ខណៈផង មិនកន្លងនូវឧប្បាទក្ខណៈផង ។

# ធម្មវារនិទ្ទេស

[ ៥៨ ] ចិត្តណា រមែងកើតឡើង រមែងមិនរលត់ ចិត្តនោះ នឹងរលត់ នឹងមិនកើតឡើងទេឬ ។ អើ ។ម្យ៉ាងទៀត ចិត្តណា នឹងរលត់ នឹងមិនកើតឡើង ចិត្តនោះ រមែងកើតឡើង រមែងមិនរលត់ទេឬ ។ អើ ។ ចិត្តណា រមែងមិនកើតឡើង រមែងរលត់ ចិត្តនោះ នឹងមិនរលត់ នឹងកើតឡើងឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ចិត្តណា នឹងមិនរលត់ នឹងកើតឡើង ចិត្តនោះ រមែងមិនកើតឡើង រមែងរលត់ឬ ។ មិនមានទេ ។

[ ៥៩ ] ចិត្តណា រមែងកើតឡើង ចិត្តនោះ ឈ្មោះថា កើតឡើងហើយឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តណា កើតឡើងហើយ ចិត្តនោះ រមែងកើតឡើងឬ ។ ចិត្តកើតឡើងហើយ ក្នុងភង្គក្ខណៈ តែចិត្តនោះ រមែងកើតឡើង ក៏មិនមែន ចិត្តកើតឡើងហើយផង រមែងកើតឡើងផង ក្នុងឧប្បាទក្ខណៈ ។ ចិត្តណា រមែងមិនកើតឡើង ចិត្តនោះ មិនកើតឡើងហើយឬ ។ ចិត្ត រមែងមិនកើតឡើង ក្នុងភង្គក្ខណៈ តែចិត្តនោះ មិនកើតឡើងហើយ ក៏មិនមែន គឺចិត្តជាអតីត និងអនាគត រមែងមិនកើតឡើងផង មិនកើតឡើងហើយផង ។ ម្យ៉ាងទៀត ចិត្តណា មិនកើតឡើងហើយ ចិត្តនោះ រមែងមិនកើតឡើងឬ ។ អើ ។

[ ៦០ ] ចិត្តណា រមែងរលត់ ចិត្តនោះ ឈ្មោះថា កើតឡើងហើយឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តណា កើតឡើងហើយ ចិត្តនោះ រមែងរលត់ឬ ។ ចិត្តកើតឡើងហើយ ក្នុងឧប្បាទក្ខណៈ តែចិត្តនោះ រមែងរលត់ ក៏មិនមែន ចិត្តកើតឡើងហើយផង រមែងរលត់ផង ក្នុងភង្គក្ខណៈ ។ ចិត្តណា រមែងមិនរលត់ ចិត្តនោះ ឈ្មោះថា មិនកើតឡើងហើយឬ ។ ចិត្ត រមែងមិនរលត់ ក្នុង

ឧប្បាទក្ខណៈ ( តែចិត្តនោះ រមែងមិនរលត់ ក៏មិនមែន ) ចិត្តនោះ ឈ្មោះថា មិនកើតឡើងហើយ ក៏មិនមែន គឺចិត្តជាអតីត និងអនាគត រមែងមិនរលត់ផង មិនកើតឡើងហើយផង ។ មួយវិញទៀត ចិត្តណា មិនកើតឡើងហើយ ចិត្តនោះ រមែងមិនរលត់ទេឬ ។ អើ ។

[ ៦១ ] ចិត្តណា រមែងកើតឡើង ចិត្តនោះ ឈ្មោះថា ធ្លាប់កើតឡើងហើយឬ ។ មិនមែនទេ ។ មួយវិញទៀត ចិត្តណា ធ្លាប់កើតឡើងហើយ ចិត្តនោះ រមែងកើតឡើងឬ ។ មិនមែនទេ ។ ចិត្តណា រមែងមិនកើតឡើង ចិត្តនោះ មិនធ្លាប់កើតឡើងហើយឬ ។ ចិត្តដែលកន្លងហើយ រមែងមិនកើតឡើងទេ តែចិត្តនោះ ឈ្មោះថា មិនធ្លាប់កើតឡើងហើយ ក៏មិនមែន គឺចិត្តជាអនាគត ក្នុងភង្គក្ខណៈ រមែងមិនកើតឡើងផង មិនធ្លាប់កើតឡើងហើយផង ។ មួយវិញទៀត ចិត្តណា មិនធ្លាប់កើតឡើងហើយ ចិត្តនោះ រមែងមិនកើតឡើងឬ ។ ចិត្តក្នុងឧប្បាទក្ខណៈ មិនធ្លាប់កើតឡើងហើយ ទាំងចិត្តនោះ រមែងមិនកើតឡើង ក៏មិនមែន គឺចិត្តជាអនាគត ក្នុងភង្គក្ខណៈ មិនធ្លាប់កើតឡើងហើយផង រមែងមិនកើតឡើងផង ។ ចិត្តណា រមែងកើតឡើង ចិត្តនោះ នឹងកើតឡើងឬ ។ មិនមែនទេ ។ មួយវិញទៀត ចិត្តណា នឹងកើតឡើង ចិត្តនោះ រមែងកើតឡើងឬ ។ មិនមែនទេ ។ ចិត្តណា រមែងមិនកើតឡើង ចិត្តនោះ នឹងមិនកើតឡើងទេឬ ។ ចិត្តជាអនាគត រមែងមិនកើតឡើងទេ តែចិត្តនោះ នឹងមិនកើតឡើង ក៏មិនមែន គឺចិត្តដែលកន្លងហើយ ក្នុងភង្គក្ខណៈ រមែងមិនកើតឡើងផង នឹងមិនកើតឡើងផង ។ មួយវិញទៀត ចិត្តណា នឹងមិនកើតឡើង

ចិត្តនោះ រមែងមិនកើតឡើងឬ ។ ចិត្តក្នុងឧប្បាទក្ខណៈ នឹងមិនកើតឡើងទេ តែចិត្តនោះ រមែងមិនកើតឡើង ក៏មិនមែន គឺចិត្តដែលកន្លងហើយ ក្នុងភង្គក្ខណៈ នឹងមិនកើតឡើងផង រមែងមិនកើតឡើងផង ។ ចិត្តណា ធ្លាប់កើតឡើងហើយ ចិត្តនោះ នឹងកើតឡើងឬ ។ មិនមែនទេ ។ម្យ៉ាងទៀត ចិត្តណា នឹងកើតឡើង ចិត្តនោះ ធ្លាប់កើតឡើងហើយឬ ។ មិនមែនទេ ។ ចិត្តណា មិនធ្លាប់កើតឡើងហើយ ចិត្តនោះ នឹងមិនកើតឡើងទេឬ ។ ចិត្តជាអនាគត មិនធ្លាប់កើតឡើងហើយ តែចិត្តនោះ នឹងមិនកើតឡើង ក៏មិនមែន ចិត្តជាបច្ចុប្បន្ន មិនធ្លាប់កើតឡើងហើយផង នឹងមិនកើតឡើងផង ។ ម្យ៉ាងទៀត ចិត្តណា នឹងមិនកើតឡើង ចិត្តនោះ មិនធ្លាប់កើតឡើងហើយទេឬ ។ ចិត្តជាអតីត នឹងមិនកើតឡើងទេ តែចិត្តនោះ មិនធ្លាប់កើតឡើងហើយ ក៏មិនមែន ចិត្តជាបច្ចុប្បន្ន នឹងមិនកើតឡើងផង មិនធ្លាប់កើតឡើងហើយផង ។

[ ៦២ ] ចិត្តណា រមែងរលត់ ចិត្តនោះ ធ្លាប់រលត់ហើយឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ចិត្តណា ធ្លាប់រលត់ហើយ ចិត្តនោះ រមែងរលត់ឬ ។ មិនមែនទេ ។ ចិត្តណា រមែងមិនរលត់ ចិត្តនោះ មិនធ្លាប់រលត់ហើយឬ ។ ចិត្តជាអតីត រមែងមិនរលត់ តែចិត្តនោះ មិនធ្លាប់រលត់ហើយ ក៏មិនមែន ចិត្តជាអនាគត ក្នុងឧប្បាទក្ខណៈ រមែងមិនរលត់ផង មិនធ្លាប់រលត់ហើយផង ។ ម្យ៉ាងទៀត ចិត្តណា មិនធ្លាប់រលត់ហើយ ចិត្តនោះ រមែងមិនរលត់ទេឬ ។ ចិត្តក្នុងភង្គក្ខណៈ មិនធ្លាប់រលត់ហើយ តែចិត្តនោះ រមែងមិនរលត់ ក៏មិនមែន ចិត្តជាអនាគត ក្នុងឧប្បាទក្ខណៈ មិនធ្លាប់រលត់ហើយផង រមែងមិន

រលត់ផង ។ ចិត្តណា រមែងរលត់ ចិត្តនោះ នឹងរលត់ឬ ។ មិនមែនទេ ។ មួយវិញទៀត ចិត្តណា នឹងរលត់ ចិត្តនោះ រមែងរលត់ឬ ។ មិនមែនទេ ។ ចិត្តណា រមែងមិនរលត់ ចិត្តនោះ នឹងមិនរលត់ទេឬ ។ ចិត្តជាអនាគត ក្នុងឧប្បាទក្ខណៈ រមែងមិនរលត់ទេ តែចិត្តនោះ នឹងមិនរលត់ ក៏មិនមែន ចិត្តជាអតីត រមែងមិនរលត់ផង នឹងមិនរលត់ផង ។ មួយវិញទៀត ចិត្តណា នឹងមិនរលត់ ចិត្តនោះ រមែងមិនរលត់ទេឬ ។ ចិត្តក្នុងភង្គក្ខណៈ នឹងមិនរលត់ តែចិត្តនោះ រមែងមិនរលត់ ក៏មិនមែន ចិត្តជាអតីត នឹងមិនរលត់ផង រមែងមិនរលត់ផង ។ ចិត្តណា ធ្លាប់រលត់ហើយ ចិត្តនោះ នឹងរលត់ឬ ។ មិនមែនទេ ។ មួយវិញទៀត ចិត្តណា នឹងរលត់ ចិត្តនោះ ធ្លាប់រលត់ហើយឬ ។ មិនមែនទេ ។ ចិត្តណា មិនធ្លាប់រលត់ហើយ ចិត្តនោះ នឹងមិនរលត់ទេឬ ។ ចិត្តជាអនាគត ក្នុងឧប្បាទក្ខណៈ មិនធ្លាប់រលត់ហើយ តែចិត្តនោះ នឹងមិនរលត់ ក៏មិនមែន ចិត្តក្នុងភង្គក្ខណៈ មិនធ្លាប់រលត់ហើយផង នឹងមិនរលត់ផង ។ មួយវិញទៀត ចិត្តណា នឹងមិនរលត់ ចិត្តនោះ មិនធ្លាប់រលត់ហើយទេឬ ។ ចិត្តជាអតីត នឹងមិនរលត់ទេ តែចិត្តនោះ មិនធ្លាប់រលត់ហើយ ក៏មិនមែន ចិត្តក្នុងភង្គក្ខណៈ នឹងមិនរលត់ផង មិនធ្លាប់រលត់ហើយផង ។

[ ៦៣ ] ចិត្តណា រមែងកើតឡើង ចិត្តនោះ ធ្លាប់រលត់ហើយឬ ។ មិនមែនទេ ។ មួយវិញទៀត ចិត្តណា ធ្លាប់រលត់ហើយ ចិត្តនោះ រមែងកើតឡើងឬ ។ មិនមែនទេ ។ ចិត្តណា រមែងមិនកើតឡើង ចិត្តនោះ មិនធ្លាប់រលត់ហើយឬ ។ ចិត្តជាអតីត រមែងមិនកើតឡើងទេ តែចិត្តនោះ មិនធ្លាប់រលត់

ហើយក៏មិនមែន ចំណែកចិត្តជាអនាគត ក្នុងភង្គក្ខណៈ រមែងមិនកើតឡើងផង មិនធ្លាប់រលត់ហើយផង ។ម្យ៉ាងទៀត ចិត្តណា មិនធ្លាប់រលត់ហើយ ចិត្តនោះ រមែងមិនកើតឡើងទេឬ ។ ចិត្តក្នុងឧប្បាទក្ខណៈ មិនធ្លាប់រលត់ហើយ តែចិត្តនោះ រមែងមិនកើតឡើង ក៏មិនមែន ចំណែកខាងចិត្តជាអនាគត ក្នុងភង្គក្ខណៈ មិនធ្លាប់រលត់ហើយផង រមែងមិនកើតឡើងផង ។ ចិត្តណា រមែងកើតឡើង ចិត្តនោះ នឹងរលត់ឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តណា នឹងរលត់ ចិត្តនោះ រមែងកើតឡើងឬ ។ ចិត្តជាអនាគត នឹងរលត់ តែចិត្តនោះ រមែងកើតឡើង ក៏មិនមែន ចិត្តក្នុងឧប្បាទក្ខណៈ នឹងរលត់ផង រមែងកើតឡើងផង ។ ចិត្តណា រមែងមិនកើតឡើង ចិត្តនោះ នឹងមិនរលត់ទេឬ ។ ចិត្តជាអនាគត រមែងមិនកើតឡើងទេ តែចិត្តនោះ នឹងមិនរលត់ ក៏មិនមែន ចំណែកខាងចិត្តជាអតីត ក្នុងភង្គក្ខណៈ រមែងមិនកើតឡើងផង នឹងមិនរលត់ផង ។ ម្យ៉ាងទៀត ចិត្តណា នឹងមិនរលត់ ចិត្តនោះ រមែងមិនកើតឡើងឬ ។ អើ ។ ចិត្តណា ធ្លាប់កើតឡើងហើយ ចិត្តនោះ នឹងមិនរលត់ឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ចិត្តណា នឹងរលត់ ចិត្តនោះ ធ្លាប់កើតឡើងហើយឬ ។ មិនមែនទេ ។ ចិត្តណា មិនធ្លាប់កើតឡើងហើយ ចិត្តនោះ នឹងមិនរលត់ទេឬ ។ ចំណែកខាងចិត្តជាអនាគត ក្នុងឧប្បាទក្ខណៈ មិនធ្លាប់កើតឡើងហើយ តែចិត្តនោះ នឹងមិនរលត់ ក៏មិនមែន ចិត្តក្នុងភង្គក្ខណៈ មិនធ្លាប់កើតឡើងហើយផង នឹងមិនរលត់ផង ។ ម្យ៉ាងទៀត ចិត្តណា នឹងមិនរលត់ ចិត្តនោះ មិនធ្លាប់កើតឡើងហើយទេឬ ។ ចិត្តជាអតីត នឹងមិនរលត់ទេ តែចិត្តនោះ

មិនធ្លាប់កើតឡើងហើយ ក៏មិនមែន ចិត្តក្នុងភង្គក្ខណៈ នឹងមិនរលត់ផង មិនធ្លាប់កើតឡើងហើយផង ។

[ ៦៤ ] ចិត្តណា រមែងកើតឡើង ចិត្តនោះ រមែងមិនរលត់ទេឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តណា រមែងមិនរលត់ ចិត្តនោះ រមែងកើតឡើងឬ ។ ចិត្តជាអតីត និងអនាគត រមែងមិនរលត់ទេ តែចិត្តនោះ កើតឡើងក៏មិនមែន ចិត្តក្នុងឧប្បាទក្ខណៈ រមែងមិនរលត់ផង រមែងកើតឡើងផង ។ ចិត្តណា រមែងមិនកើតឡើង ចិត្តនោះ រមែងរលត់ឬ ។ ចិត្តជាអតីត និងអនាគត រមែងមិនកើតឡើងទេ តែចិត្តនោះ រមែងរលត់ ក៏មិនមែន ចិត្តក្នុងភង្គក្ខណៈ រមែងមិនកើតឡើងផង រមែងរលត់ផង ។ ម្យ៉ាងទៀតចិត្តណា រមែងរលត់ ចិត្តនោះ រមែងមិនកើតឡើងឬ ។ អើ ។

[ ៦៥ ] ចិត្តណា កំពុងកើតឡើង ចិត្តនោះ ឈ្មោះថា កើតឡើងហើយឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តណា កើតឡើងហើយ ចិត្តនោះ ឈ្មោះថា កំពុងកើតឡើងឬ ។ ចិត្តក្នុងភង្គក្ខណៈ កើតឡើងហើយ តែចិត្តនោះ ឈ្មោះថា កំពុងកើតឡើង ក៏មិនមែន ចិត្តក្នុងឧប្បាទក្ខណៈ កើតឡើងហើយផង កំពុងកើតឡើងផង ។ ចិត្តណា កាលមិនកើតឡើង ចិត្តនោះ ឈ្មោះថា មិនកើតឡើងហើយឬ ។ ចិត្តក្នុងភង្គក្ខណៈ កាលមិនកើតឡើងទេ តែចិត្តនោះ ឈ្មោះថា មិនកើតឡើងហើយ ក៏មិនមែន ចិត្តជាអតីត និងអនាគត កាលមិនកើតឡើងផង មិនកើតឡើងហើយផង ។ ម្យ៉ាងទៀត ចិត្តណា មិនកើតឡើងហើយ ចិត្តនោះ ឈ្មោះថា កាលមិនកើតឡើងឬ ។ អើ ។

[ ៦៦ ] ចិត្តណា កំពុងរលត់ ចិត្តនោះ ឈ្មោះថា កើតឡើងហើយឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តណា កើតឡើងហើយ ចិត្តនោះ ឈ្មោះថា កំពុងរលត់ឬ ។ ចិត្តក្នុងឧប្បាទក្ខណៈ កើតឡើងហើយ តែចិត្តនោះ កាលរលត់ ក៏មិនមែន ចិត្តក្នុងភង្គក្ខណៈ កើតឡើងហើយផង កំពុងរលត់ផង ។ ចិត្តណា កាលមិនរលត់ ចិត្តនោះ ឈ្មោះថា មិនកើតឡើងហើយឬ ។ ចិត្តក្នុងឧប្បាទក្ខណៈ កាលមិនរលត់ទេ តែចិត្តនោះ មិនកើតឡើងហើយ ក៏មិនមែន ចិត្តជាអតីត និងអនាគត កាលមិនរលត់ផង មិនកើតឡើងហើយផង ។ ម្យ៉ាងទៀត ចិត្តណា មិនកើតឡើងហើយ ចិត្តនោះ ឈ្មោះថា កាលមិនរលត់ឬ ។ អើ ។

[ ៦៧ ] ចិត្តណា កើតឡើងហើយ ចិត្តនោះ ធ្លាប់កើតឡើងហើយឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ចិត្តណា ធ្លាប់កើតឡើងហើយ ចិត្តនោះ ឈ្មោះថា កើតឡើងហើយឬ ។ មិនមែនទេ ។ ចិត្តណា កើតឡើងហើយ ចិត្តនោះ នឹងកើតឡើងឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ចិត្តណា នឹងកើតឡើង ចិត្តនោះ ឈ្មោះថា កើតឡើងហើយឬ ។ មិនមែនទេ ។ ចិត្តណា មិនកើតឡើងហើយ ចិត្តនោះ ឈ្មោះថា ធ្លាប់កើតឡើងហើយឬ ។ ចិត្តជាអតីត មិនកើតឡើងហើយ តែចិត្តនោះ មិនធ្លាប់កើតឡើងហើយ ក៏មិនមែន ចិត្តជាអនាគត មិនកើតឡើងហើយផង មិនធ្លាប់កើតឡើងហើយផង ។ ម្យ៉ាងទៀត ចិត្តណា មិនធ្លាប់កើតឡើងហើយ ចិត្តនោះ ឈ្មោះថា មិនកើតឡើងហើយឬ ។ ចិត្តជាបច្ចុប្បន្ន មិនធ្លាប់កើតឡើងហើយ តែចិត្តនោះ មិនកើតឡើងហើយក៏មិនមែន

ចិត្តជាអនាគត មិនធ្លាប់កើតឡើងហើយផង មិនកើតឡើងហើយផង ។ ចិត្តណា មិនកើតឡើងហើយ ចិត្តនោះ នឹងមិនកើតឡើងទេឬ ។ ចិត្តជាអនាគត មិនកើតឡើងហើយ តែចិត្តនោះ នឹងមិនកើតឡើង ក៏មិនមែន ចិត្តជាអតីត មិនកើតឡើងហើយផង នឹងមិនកើតឡើងផង ។ម្យ៉ាងទៀត ចិត្តណា នឹងមិនកើតឡើង ចិត្តនោះ ឈ្មោះថា មិនកើតឡើងហើយឬ ។ ចិត្តជាបច្ចុប្បន្ន នឹងមិនកើតឡើងទេ តែចិត្តនោះ មិនកើតឡើងហើយ ក៏មិនមែន ចិត្តជាអតីត នឹងមិនកើតឡើងផង មិនកើតឡើងហើយផង ។

[ ៦៨ ] ចិត្តណា ធ្លាប់កើតឡើងហើយ តែចិត្តនោះ ឈ្មោះថា កើតឡើងហើយ ក៏មិនមែន ចិត្តនោះ នឹងកើតឡើងឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ចិត្តណា នឹងកើតឡើង តែចិត្តនោះ កើតឡើងហើយ ក៏មិនមែន ចិត្តនោះ ឈ្មោះថា ធ្លាប់កើតឡើងហើយឬ ។ មិនមែនទេ ។ ចិត្តណា មិនធ្លាប់កើតឡើងហើយ តែចិត្តនោះ មិនកើតឡើងហើយ ក៏មិនមែន ចិត្តនោះ នឹងមិនកើតឡើងទេឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តណា នឹងមិនកើតឡើងទេ តែចិត្តនោះ មិនកើតឡើងហើយ ក៏មិនមែន ចិត្តនោះ ឈ្មោះថា មិនធ្លាប់កើតឡើងហើយឬ ។ អើ ។

[ ៦៩ ] ចិត្តកើតឡើងហើយ ( ក៏មាន ) កំពុងកើតឡើង ( ក៏មាន ) ឬ ។ ចិត្តក្នុងភង្គក្ខណៈ កើតឡើងហើយ តែឈ្មោះថា កំពុងកើតឡើង ក៏មិនមែន គឺចិត្តក្នុងឧប្បាទក្ខណៈ កើតឡើងហើយផង កំពុងកើតឡើងផង ។ ចិត្តកំពុងកើតឡើង ( ក៏មាន ) កើតឡើងហើយ ( ក៏មាន ) ឬ ។ អើ ។

ចិត្តមិនកើតឡើងហើយ ( ក៏មាន ) កាលមិនកើតឡើង ( ក៏មាន ) ឬ ។ អើ ។ ចិត្ត កាលមិនកើតឡើង ( ក៏មាន ) មិនកើតឡើងហើយ ( ក៏មាន ) ឬ ។ ចិត្តក្នុងភង្គក្ខណៈ កាលមិនកើតឡើង ឈ្មោះថា មិនកើតឡើងហើយ ក៏មិនមែន ចិត្តជាអតីត និងអនាគត កាលមិនកើតឡើងផង មិនកើតឡើងហើយផង ។

[ ៧០ ] ចិត្តរលត់ហើយ ( ក៏មាន ) កំពុងរលត់ ( ក៏មាន ) ឬ ។ មិនមែនទេ ។ ចិត្តកំពុងរលត់ ( ក៏មាន ) រលត់ហើយ ( ក៏មាន ) ឬ ។ មិនមែនទេ ។ ចិត្តមិនរលត់ហើយ ( ក៏មាន ) កាលមិនរលត់ ( ក៏មាន ) ឬ ។ ចិត្តក្នុងភង្គក្ខណៈ មិនរលត់ហើយ តែចិត្តនោះ កាលមិនរលត់ ក៏មិនមែន ចំណែកខាងចិត្តជាអនាគត ក្នុងឧប្បាទក្ខណៈ មិនរលត់ហើយផង កាលមិនរលត់ផង ។ ចិត្ត កាលមិនរលត់ ( ក៏មាន ) មិនរលត់ហើយ ( ក៏មាន ) ឬ ។ ចិត្តជាអតីត កាលមិនរលត់ តែចិត្តនោះ មិនរលត់ហើយ ក៏មិនមែន ចំណែកខាងចិត្តជាអនាគត ក្នុងឧប្បាទក្ខណៈ កាលមិនរលត់ផង មិនរលត់ហើយផង ។

[ ៧១ ] ចិត្តណា កាលកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តនោះ កាលនឹងរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយឬ ។ ចិត្តក្នុងភង្គក្ខណៈ កន្លងនូវឧប្បាទក្ខណៈ មិនកន្លងនូវភង្គក្ខណៈទេ ចិត្តជាអតីត ទើបជាចិត្តកន្លងនូវឧប្បាទក្ខណៈផង កន្លងនូវភង្គក្ខណៈផង ។ម្យ៉ាងទៀត ចិត្តណា កាលរលត់

ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តនោះ កាលនឹងកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយឬ ។ ចិត្តកន្លងហើយ ។ ចិត្តណា កាលមិនកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តនោះ កាលមិនរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយឬ ។ ចំណែកខាងចិត្តក្នុងឧប្បាទក្ខណៈ មិនទាន់មកដល់ទេ ។ម្យ៉ាងទៀត ចិត្តណា កាលមិនរលត់ ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយ ចិត្តនោះ កាលមិនកើតឡើង ជាចិត្តកន្លងនូវខណៈទាំងពួង ឈ្មោះថា មានកាលកន្លងហើយឬ ។ ចិត្តក្នុងភង្គក្ខណៈ មិនកន្លងនូវភង្គក្ខណៈទេ តែមិនកន្លងនូវឧប្បាទក្ខណៈ ក៏មិនមែន ចំណែកខាងចិត្តជាអនាគត ក្នុងឧប្បាទក្ខណៈទើបជាចិត្តមិនកន្លងនូវភង្គក្ខណៈផង មិនកន្លងនូវឧប្បាទក្ខណៈផង ។

## បុគ្គលធម្មវារនិទ្ទេស

[ ៧២ ] ចិត្តណា របស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់ ចិត្តនោះ របស់បុគ្គលនោះ នឹងរលត់ នឹងមិនកើតឡើងឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា នឹងរលត់ នឹងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ រមែងកើតឡើង រមែងមិនរលត់ឬ ។ អើ ។ ចិត្តណា របស់បុគ្គលណា រមែងមិនកើតឡើង តែងរលត់ ចិត្តនោះ របស់បុគ្គលនោះ នឹងមិនរលត់ នឹងកើតឡើងឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា នឹងមិនរលត់ នឹងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ រមែងមិនកើត

ឡើង រមែងរលត់ឬ ។ មិនមានទេ ។

[ ៧៣ ] ចិត្តណា របស់បុគ្គលណា រមែងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយឬ ។ អើ ។ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ រមែងកើតឡើងឬ ។ ចិត្តក្នុងភង្គក្ខណៈ កើតឡើងហើយ តែចិត្តនោះ របស់បុគ្គលនោះ រមែងកើតឡើង ក៏មិនមែន ចិត្តក្នុងឧប្បាទក្ខណៈ កើតឡើងហើយផង រមែងកើតឡើងផង ។ ចិត្តណា របស់បុគ្គលណា រមែងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយឬ ។ ចិត្តក្នុងភង្គក្ខណៈ រមែងមិនកើតឡើងទេ តែចិត្តនោះ របស់បុគ្គលនោះ មិនកើតឡើងហើយ ក៏មិនមែន ចិត្តជាអតីត និងអនាគត រមែងមិនកើតឡើងផង មិនកើតឡើងហើយផង ។ ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា មិនកើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ រមែងមិនកើតឡើងទេឬ ។ អើ ។

[ ៧៤ ] ចិត្តណា របស់បុគ្គលណា រមែងរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា កើតឡើងហើយឬ ។ អើ ។ ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ រមែងរលត់ឬ ។ ចិត្តក្នុងឧប្បាទក្ខណៈ កើតឡើងហើយ តែចិត្តនោះ របស់បុគ្គលនោះ រមែងរលត់ ក៏មិនមែន ចិត្តក្នុងភង្គក្ខណៈ កើតឡើងហើយផង រមែងរលត់ផង ។ ចិត្តណា របស់បុគ្គលណា រមែងមិនរលត់ ចិត្តនោះ របស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយឬ ។ ចិត្តក្នុងឧប្បាទក្ខណៈ រមែងមិនរលត់ទេ តែចិត្ត

នោះ របស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយផង ក៏មិនមែន ចិត្តជាអតីត និងអនាគត រមែងមិនរលត់ផង មិនកើតឡើងហើយផង ។ ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា មិនកើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ រមែងមិនរលត់ទេឬ ។ អើ ។

[ ៧៥ ] ចិត្តណា របស់បុគ្គលណា រមែងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ រមែងកើតឡើងឬ ។ មិនមែនទេ ។ ចិត្តណា របស់បុគ្គលណា មិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយទេឬ ។ ចិត្តជាអតីត រមែងមិនកើតឡើងទេ តែចិត្តនោះ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ក៏មិនមែន ចំណែកខាងចិត្តជាអនាគត ក្នុងភង្គក្ខណៈ រមែងមិនកើតឡើងផង មិនធ្លាប់កើតឡើងហើយផង ។ ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ រមែងមិនកើតឡើងទេឬ ។ ចិត្តក្នុងឧប្បាទក្ខណៈ មិនធ្លាប់កើតឡើងហើយ តែចិត្តនោះ របស់បុគ្គលនោះ រមែងមិនកើតឡើង ក៏មិនមែន ចំណែកខាងចិត្តជាអនាគត ក្នុងភង្គក្ខណៈ មិនធ្លាប់កើតឡើងហើយផង រមែងមិនកើតឡើងផង ។ ចិត្តណា របស់បុគ្គលណា រមែងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា នឹងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ រមែងកើតឡើងឬ ។ មិនមែនទេ ។ ចិត្តណា របស់បុគ្គលណា

រមែងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ នឹងមិនកើតឡើងទេឬ ។ ចិត្តជាអនាគត រមែងមិនកើតឡើងទេ តែចិត្តនោះ របស់បុគ្គលនោះ នឹងមិនកើតឡើង ក៏មិនមែន ចំណែកខាងចិត្តជាអតីត ក្នុងភង្គក្ខណៈ រមែងមិនកើតឡើងផង នឹងមិនកើតឡើងផង ។ ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា នឹងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ រមែងមិនកើតឡើងទេឬ ។ ចិត្តក្នុងឧប្បាទក្ខណៈ នឹងមិនកើតឡើងទេ តែចិត្តនោះ របស់បុគ្គលនោះ រមែងមិនកើតឡើង ក៏មិនមែន ចំណែកខាងចិត្តជាអតីត ក្នុងភង្គក្ខណៈ នឹងមិនកើតឡើងផង រមែងមិនកើតឡើងផង ។ ចិត្តណា របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា នឹងកើតឡើង ចិត្តនោះ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយឬ ។ មិនមែនទេ ។ ចិត្តណា របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ចិត្តនោះ របស់បុគ្គលនោះ នឹងមិនកើតឡើងទេឬ ។ ចិត្តជាអនាគត មិនធ្លាប់កើតឡើងហើយ តែចិត្តនោះ របស់បុគ្គលនោះ នឹងមិនកើតឡើង ក៏មិនមែន ចិត្តជាបច្ចុប្បន្ន មិនធ្លាប់កើតឡើងហើយផង នឹងមិនកើតឡើងផង ។ ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា នឹងមិនកើតឡើង ចិត្តនោះ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយទេឬ ។ ចិត្តជាអតីត នឹងមិនកើតឡើងទេ តែចិត្តនោះ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ក៏មិនមែន ចិត្តជាបច្ចុប្បន្ន នឹងមិនកើតឡើងផង មិនធ្លាប់កើតឡើងហើយផង ។

[ ៧៦ ] ចិត្តណា របស់បុគ្គលណា រមែងរលត់ ចិត្តនោះ របស់បុគ្គល

នោះ ធ្លាប់រលត់ហើយឬ ។ មិនមែនទេ ។ម្យ៉ាងទៀត ចិត្តណា របស់បុគ្គល ណា ធ្លាប់រលត់ហើយ ចិត្តនោះ របស់បុគ្គលនោះ រមែងរលត់ឬ ។ មិនមែន ទេ ។ ចិត្តណា របស់បុគ្គលណា រមែងមិនរលត់ ចិត្តនោះ របស់បុគ្គលនោះ មិនធ្លាប់រលត់ហើយទេឬ ។ ចិត្តជាអតីត រមែងមិនរលត់ទេ តែចិត្តនោះ របស់ បុគ្គលនោះ មិនធ្លាប់រលត់ហើយ ក៏មិនមែន ចំណែកខាងចិត្តជាអនាគត ក្នុង ឧប្បាទក្ខណៈ រមែងមិនរលត់ផង មិនធ្លាប់រលត់ហើយផង ។ ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា មិនធ្លាប់រលត់ហើយ ចិត្តនោះ របស់បុគ្គលនោះ រមែងមិនរលត់ទេឬ ។ ចិត្តក្នុងភង្គក្ខណៈ មិនធ្លាប់រលត់ហើយ តែចិត្តនោះ របស់បុគ្គលនោះ រមែងមិនរលត់ ក៏មិនមែន ចំណែកខាងចិត្តជាអនាគត ក្នុង ឧប្បាទក្ខណៈ មិនធ្លាប់រលត់ហើយផង រមែងមិនរលត់ផង ។ ចិត្តណា របស់ បុគ្គលណា រមែងរលត់ ចិត្តនោះ របស់បុគ្គលនោះ នឹងរលត់ឬ ។ មិនមែន ទេ ។ ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា នឹងរលត់ ចិត្តនោះ របស់បុគ្គល នោះ រមែងរលត់ឬ ។ មិនមែនទេ ។ ចិត្តណា របស់បុគ្គលណា រមែងមិន រលត់ ចិត្តនោះ របស់បុគ្គលនោះ នឹងមិនរលត់ទេឬ ។ ចិត្តជាអនាគត ក្នុង ឧប្បាទក្ខណៈ រមែងមិនរលត់ទេ តែចិត្តនោះ របស់បុគ្គលនោះ នឹងមិនរលត់ ក៏មិនមែន ចិត្តជាអតីត រមែងមិនរលត់ផង នឹងមិនរលត់ផង ។ ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា នឹងមិនរលត់ ចិត្តនោះ របស់បុគ្គលនោះ រមែង មិនរលត់ទេឬ ។ ចិត្តក្នុងភង្គក្ខណៈ នឹងមិនរលត់ទេ តែចិត្តនោះ របស់បុគ្គល នោះ រមែងមិនរលត់ ក៏មិនមែន ចិត្តជាអតីត នឹងមិនរលត់ផង រមែងមិន

រលត់ផង ។ ចិត្តណា របស់បុគ្គលណា ធ្លាប់រលត់ហើយ ចិត្តនោះ របស់បុគ្គលនោះ នឹងរលត់ឬ ។ មិនមែនទេ ។ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា នឹងរលត់ ចិត្តនោះ របស់បុគ្គលនោះ ធ្លាប់រលត់ហើយឬ ។ មិនមែនទេ ។ ចិត្តណា របស់បុគ្គលណា មិនធ្លាប់រលត់ហើយ ចិត្តនោះ របស់បុគ្គលនោះ នឹងមិនរលត់ទេឬ ។ ចិត្តជាអនាគត ក្នុងឧប្បាទក្ខណៈ មិនធ្លាប់រលត់ហើយ តែចិត្តនោះ របស់បុគ្គលនោះ នឹងមិនរលត់ ក៏មិនមែន ចិត្តក្នុងភង្គក្ខណៈ មិនធ្លាប់រលត់ហើយផង នឹងមិនរលត់ផង ។ ម្យ៉ាងទៀត ចិត្តណា របស់បុគ្គលណា នឹងមិនរលត់ ចិត្តនោះ របស់បុគ្គលនោះ មិនធ្លាប់រលត់ហើយទេឬ ។ ចិត្តជាអតីត នឹងមិនរលត់ទេ តែចិត្តនោះ របស់បុគ្គលនោះ មិនធ្លាប់រលត់ហើយ ក៏មិនមែន ចិត្តក្នុងភង្គក្ខណៈ នឹងមិនរលត់ផង មិនធ្លាប់រលត់ហើយផង ។

## មិស្សកវារនិទ្ទេស

[ ៧៧ ] យស្សចិត្តកន័យ ( ន័យដែលនិយាយអំពីចិត្ត របស់បុគ្គលណា ) គឺលោកសម្តែងហើយតាមភាពរបស់ខ្លួន យំចិត្តកន័យ ( ន័យដែលនិយាយអំពីចិត្តណា ) ក្តី យស្សយំចិត្តកន័យ ( ន័យនិយាយអំពីចិត្តរបស់បុគ្គលណា និងចិត្តណា ) ក្តី គឺលោកសម្តែងហើយ ដោយសេចក្តីតែមួយ ។ ចិត្តប្រកបដោយរាគៈ របស់បុគ្គលណា ។បេ។ ពួកធម៌ជាកុសល ពួកធម៌ជាអកុសល ពួកធម៌ជាអព្យាក្រឹត ពួកធម៌ដែលប្រកបដោយសុខវេទនា ពួកធម៌ដែលប្រកបដោយទុក្ខវេទនា ពួកធម៌ដែលប្រកបដោយអទុក្ខមសុខវេទនា ។បេ។

ពួកធម៌ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ ពួកធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ពួកធម៌មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ពួកធម៌ជាហេតុ ពួកធម៌មិនមែនជាហេតុ ។បេ។ ពួកធម៌ជាសរណៈ ( ប្រកបដោយសេចក្ដីសៅហ្មង ) ពួកធម៌ជាអរណៈ ( មិនមានសេចក្ដីសៅហ្មង ) ។ យមកៈ ៣ យ៉ាង គឺ មូលយមកៈ ១ ចិត្តយមកៈ ១ ធម្មយមកៈ ១ រមែងដល់ ( នូវការរួបរួម ) ដរាបដល់ពួកធម៌ជាសរណៈ និងពួកធម៌ជាអរណៈ ។

**ចិត្តយមកៈ ចប់**

# អដ្ឋកថា

# ចិត្តយមកៈ

## ឧទ្ទេសវារៈ

[ ១ ] ឥឡូវនេះ ជាកិច្ចពណ៌នាអត្ថនៃចិត្តយមកៈ ដែលព្រះមានព្រះភាគ ទ្រង់បន្ត្របបន្ត្រមជាឯកទេសមួយដោយឡែក ដោយអំណាចនៃធម៌ទាំងឡាយ មានកុសលធម៌ជាដើមដែលរកបាន ដែលបានសម្តែងហើយក្នុងមូលយមកៈទាំងនោះឯងហើយ ទើបសម្តែងបន្ទាប់អំពីអនុសយយមកៈ ។

ក្នុងចិត្តយមកៈនោះ ដំបូង គប្បីជ្រាបបាលីវវត្ថាន គឺការកំណត់មាតិកាដូចតទៅ

ក្នុងចិត្តយមកៈនេះ មាន ២ វារៈ **មាតិកាឋបនវារ** គឺវារៈដែលពោលអំពីការតាំងមាតិកា ១ **ឋបិតមាតិកាវិសជ្ជនាវារ** វារៈដែលពោលអំពីការវិសជ្ជនាមាតិកាដែលតាំងទុកហើយ ១ ។

ក្នុងមាតិកាឋបនវារៈនោះ ក្នុងខាងដើម មាន ៣ សុទ្ធិកមហាវារៈ គឺ **បុគ្គលវារ** វារៈដែលពោលអំពីបុគ្គល ១ **ធម្មវារ** វារៈដែលពោលអំពីធម៌ ១ **បុគ្គលធម្មវារ** វារៈដែលពោលអំពីបុគ្គល និងធម៌ ១ ។

ក្នុងវារៈទាំង ៣ នោះ វារៈណា សម្តែងប្រភេទនៃធម៌ មានការកើតនិងការរលត់របស់ចិត្តជាដើម ដោយលើកបុគ្គលសម្តែងយ៉ាងនេះថា **យស្ស**

**ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ** ចិត្តរបស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់ ដូច្នេះ ( ជាដើម ) វារៈនោះ ឈ្មោះថា **បុគ្គលវារ** ។

វារៈណា សម្ដែងប្រភេទនៃធម៌ មានការកើត និងការរលត់របស់ចិត្តជាដើម ដោយលើកធម៌ប៉ុណ្ណោះសម្ដែងយ៉ាងនេះថា **យំ ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ** ចិត្តណា រមែងកើតឡើង មិនរលត់ ដូច្នេះ ( ជាដើម ) វារៈនោះ ឈ្មោះថា **ធម្មវារ** ។

វារៈណា សម្ដែងប្រភេទនៃធម៌ មានការកើត និងការរលត់ជាដើមរបស់ចិត្ត ប្រព្រឹត្តទៅដោយលើកបុគ្គល និងធម៌ទាំងពីរយ៉ាង សម្ដែងយ៉ាងនេះថា **យស្ស យំ ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ** ប្រែថា ចិត្តណា របស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់ ដូច្នេះ ( ជាដើម ) វារៈនោះ ឈ្មោះថា **បុគ្គលធម្មវារ** ។

បន្ទាប់អំពីនោះ ដោយអំណាចនៃ ១៦ បទ មានបទថា **យស្ស សរាគំ ចិត្តំ** ជាដើម ទើបបានមិស្សកវារៈ ៤៨ វារៈ គឺបុគ្គលវារៈ ១៦ វារៈ ធម្មវារៈ ១៦ វារៈ បុគ្គលធម្មវារៈ ១៦ វារៈ ។ មិស្សកវារៈក្រៅអំពីនេះ ប្លែកគ្នាដោយសរាគបទជាដើម ។ មិស្សកវារៈ ៤៨ វារៈនោះ ព្រះមានព្រះភាគ ទ្រង់សម្ដែងត្រឹមតែសរាគបទជាដើម ហើយទ្រង់សង្ខេប ។

បន្ទាប់អំពីនោះ ដោយអំណាចនៃបទអភិធម្មមាតិកាក៏រាប់បាន ២៦៦ បទ ដោយន័យថា **យស្ស កុសលំ ចិត្តំ** ជាដើម ទើបបាននូវមិស្សកវារៈ ៧៩៨ វារៈទៀត គឺបុគ្គលវារៈ ២៦៦ វារៈ ធម្មវារៈ ២៦៦ វារៈ បុគ្គលធម្មវារៈ

២៦៦ វារៈ ។ វារៈក្រៅអំពីនេះ បែកចេញទៅដោយកុសលបទជាដើម ។ សូម្បីវារៈទាំងនោះ ទ្រង់ក៏សម្ដែងត្រឹមតែកុសលបទជាដើម ហើយទ្រង់សង្ខេបដូចគ្នា ។ ក្នុងចិត្តយមកៈនេះ បទទាំងឡាយណា មានបទវិសជ្ជនាទំនងដូចគ្នាជាដើម មិនប្រកបដោយចិត្ត បទទាំងឡាយនោះ ព្រះមានព្រះភាគទ្រង់កាន់យកជាមោឃបុច្ឆា ។

បណ្ដាវារៈទាំង ៣ នោះ សុទ្ធិកបុគ្គលមហាវារៈដែលជាវារៈដំបូង មានអនន្តរវារៈ ១៤ វារៈ គឺឧប្បាទនិរោធកាលសម្ភេទវារៈ គឺវារៈពោលអំពីការប្រកបគ្នានៃកាលរបស់ឧប្បាទ និងនិរោធ ១ ឧប្បាទុប្បន្នវារៈ គឺវារៈពោលអំពីឧប្បាទ ( ខណៈ ) និងកើតឡើងហើយ ១ និរោធុប្បន្នវារៈ គឺវារៈពោលអំពីនិរោធ ( សមាបត្តិ ) និងកើតឡើងហើយ ១ ឧប្បាទវារៈ គឺវារៈពោលអំពីឧប្បាទ ( ខណៈ ) ១ និរោធវារៈ គឺវារៈពោលអំពីនិរោធ ( សមាបត្តិ ) ១ ឧប្បាទនិរោធវារៈ គឺវារៈពោលអំពីឧប្បាទ ( ខណៈ ) និងនិរោធ ( សមា-បត្តិ ) ១ ឧប្បជ្ជមាននិរោធវារៈ គឺវារៈពោលអំពីកំពុងកើតឡើង និងនិរោធ ( សមាបត្តិ ) ១ ឧប្បជ្ជមានុប្បន្នវារៈ គឺវារៈពោលអំពីកំពុងកើតឡើង និងកើតឡើងហើយ ១ និរុជ្ឈមានុប្បន្នវារៈ គឺវារៈពោលអំពីកំពុងរលត់ និងកើតឡើងហើយ ១ ឧប្បន្នុប្បាទវារៈ គឺវារៈពោលអំពីកើតឡើងហើយ និងឧប្បាទ ( ខណៈ ) ១ អតីតានាគតវារៈ គឺវារៈពោលអំពីអតីត និងអនាគត ១ ឧប្បន្នុប្បជ្ជមានវារៈ គឺវារៈពោលអំពីកើតឡើងហើយ និងកំពុងកើតឡើង ១ និរុទ្ធនិរុជ្ឈមានវារៈ គឺវារៈពោលអំពីរលត់ហើយ និងកំពុងរលត់ ១

អតិក្កន្តកាលវារៈ គឺវារៈពោលអំពីមានកាលកន្លងហើយ ១ ។

បណ្ដាអនន្តរវារៈ ១៤ វារៈនោះ ក្នុង ៣ វារៈ គឺឧប្បាទវារៈ ១ និរោធវារៈ ១ ឧប្បាទនិរោធវារៈ ១ ដោយអំណាចអនុលោម និងបដិលោម ទើបមាន ១៨ យមកៈ ( គូ ) ព្រោះចាត់វារៈនីមួយៗ ជា ៦ ។ ក្នុងឧប្បន្នុប្បាទវារៈ បានយមកៈ ៤ ( ៤ គូ ) គឺដោយអនុលោម ២ បដិលោម ២ ដោយអំណាចកាលដែលជាអតីត និងអនាគត ។ ក្នុង ១០ វារៈ គឺ ៣ វារៈ ដ៏សេស ដែលទ្រង់សម្ដែងខាងដើម ៣ វារៈ ដែលសម្ដែងក្នុងចន្លោះ និង ៤ វារៈ ដែលសម្ដែងហើយខាងចុង គឺវារៈទី ៧-៨-៩ ចាត់វារៈនីមួយៗ ជា ២ គឺដោយអនុលោម ១ បដិលោម ១ ទើបជាយមកៈ ២០ ។

ក្នុងអនន្តរវារៈទាំង ១៤ វារៈ កំណត់ដោយបុច្ឆា ៨៤ ចាត់ជាយមកៈបាន ៤២ មានអត្ថ ១៦៨ ដោយប្រការដូច្នេះ ។ ១២៦ យមកៈ រមែងមានក្នុងមហាវារៈទាំង ៣ ។ ម្យ៉ាងទៀត ក្នុងសុទ្ធិកបុគ្គលមហាវារៈមួយ មានយ៉ាងណា ក្នុងសុទ្ធិកធម្មវារៈ និងសុទ្ធិកបុគ្គលធម្មវារៈ ក៏មានយ៉ាងនោះ ។

បណ្ឌិតគប្បីជ្រាបពាក្យបុច្ឆាជាទ្វេគុណ អំពីយមកៈនោះ និងអត្ថជាទ្វេគុណអំពីបុច្ឆានោះ ។ ក្នុងចិត្តយមកៈនេះ មានយមកៈច្រើនពាន់ ដោយយកវារៈទាំង ៣ នេះ គុណនឹង ១៦ បទ ដោយអំណាចសរាគបទជាដើម និងគុណដោយ ២៦៦ បទ ដោយអំណាចកុសលបទជាដើម ឯព្រះបាលីលោកសង្ខេបថា បុច្ឆា ទ្វេគុណអំពីយមកៈនោះ អត្ថ ( វិសជ្ជនា ) ក៏ទ្វេគុណអំពីបុច្ឆានោះ ដូច្នេះ ។ បណ្ឌិតគប្បីជ្រាបការកំណត់ព្រះបាលី ក្នុងចិត្តយមកៈ

នេះ ដូចពណ៌នាមក ដូច្នេះ ។ល។

## មាតិកាឋបនវារៈ(១) ចប់

# និទ្ទេស

## បុគ្គលវារៈ

[ ៤៤ ] ឥឡូវនេះ ដើម្បីវិសជ្ជនាបទមាតិកាដោយលំដាប់ តាមដែលតាំងទុក ទើបព្រះមានព្រះភាគ ទ្រង់ផ្ដើមពាក្យថា **យស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **ឧប្បជ្ជតិ** សេចក្ដីថា កំពុងកើត ព្រោះដល់ព្រមដោយឧប្បាទក្ខណៈ ។ បទថា **ន និរុជ្ឈតិ** សេចក្ដីថា មិនមែនកំពុងរលត់ ព្រោះមិនដល់និរោធក្ខណៈ ។ បទថា **តស្ស ចិត្តំ** សេចក្ដីថា ព្រះមានព្រះភាគត្រាស់សួរថា ចាប់តាំងអំពីនោះ ចិត្តរបស់បុគ្គលនោះ នឹងរលត់ នឹងមិនកើតមែនទេ ដូច្នេះ ។ បទថា **តេសំ ចិត្តំ** សេចក្ដីថា ឧប្បាទក្ខណៈនៃចុតិចិត្តដូងចុងក្រោយនៃចិត្តទាំងអស់ របស់ព្រះខីណាស្រពពួកណា ដែលមានវដ្តទុក្ខកាត់ផ្ដាច់ហើយ កំពុងប្រព្រឹត្តទៅ ចុតិចិត្តនោះឯង របស់ព្រះខីណាស្រពទាំងនោះ ឈ្មោះថា កំពុងកើត ព្រោះដល់ឧប្បាទៈ មិនមែនកំពុង

១- មាតិកាឋបនវារៈ ក៏គឺឧទ្ទេសវារៈនោះឯង តែទីនេះ យើងរក្សាទុកតាមអដ្ឋកថា ។

រលត់ ព្រោះមិនទាន់ដល់ភង្គក្ខណៈ ។ តែឥឡូវនេះ ចិត្តនោះ របស់ព្រះខីណាស្រពទាំងនោះ ឈ្មោះថា នឹងរលត់ ព្រោះដល់ភង្គក្ខណៈ បន្ទាប់អំពីនោះ ចិត្តដទៃ ឈ្មោះថា នឹងមិនកើតឡើង ព្រោះមិនបានធ្វើបដិសន្ធិបច្ចុប្បន្នអំពីចិត្តនោះ ។ បទថា **ឥតរេសំ** បានដល់ ចិត្តរបស់ព្រះសេក្ខៈ ព្រះអសេក្ខៈ និងបុថុជ្ជនដ៏សេស វៀរព្រះខីណាស្រពដែលដល់ព្រមដោយបច្ឆិមចិត្ត ។ បទថា **និរុជ្ឈិស្សតិ ចេវ ឧប្បជ្ជិស្សតិ ច** សេចក្ដីថា ចិត្តណា ដល់ឧប្បាទក្ខណៈ ចិត្តនោះឯង នឹងរលត់ទៅ ។ ចំណែកចិត្តដទៃ នឹងកើតផង នឹងរលត់ផង ក្នុងអត្តភាពនោះ ឬក្នុងអត្តភាពដទៃ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់សំដៅយកចិត្តរបស់ព្រះខីណាស្រពបែបនោះឯង ក្នុងបុច្ឆាវិសជ្ជនាទី ២ ទើបត្រាស់ថា **អាមន្តា** ដូច្នេះ ។ បទថា **ឧប្បជ្ជតិ និរុជ្ឈតិ** បានដល់ បច្ឆិមចិត្តរបស់ព្រះអរហន្ត ក្នុងភង្គក្ខណៈខ្លះ ចិត្តដែលកំពុងរលត់របស់បុគ្គលដ៏សេសខ្លះ ។ ចាប់តាំងអំពីចិត្តនោះមក បុគ្គលណាមួយអាចពោលថា ចិត្តរបស់ព្រះអរហន្ត នឹងមិនរលត់មុន តែមិនអាចពោលថា នឹងកើត ។ បុគ្គលណាមួយអាចពោលថា ចិត្តរបស់បុគ្គលដ៏សេស នឹងកើត នឹងមិនអាចពោលថា មិនមែននឹងរលត់ ព្រោះហេតុនោះ ទើបទ្រង់បដិសេធថា **នោ** ដូច្នេះ ។

ក្នុងទុតិយបញ្ហា ចិត្តរបស់បុគ្គលណា មិនមែននឹងរលត់ តែនឹងកើត បុគ្គលនោះឯង មិនមាន ព្រោះហេតុនោះ ទើបទ្រង់ហាមដោយពាក្យថា **នត្ថិ** ( បដិក្ខេបវិសជ្ជនា ) ដូច្នេះ ។

*បទថា* **ឧប្បន្នំ** *នេះ ជាឈ្មោះរបស់ចិត្តដែលដល់ព្រមដោយការកើត ជាឈ្មោះរបស់ចិត្តដែលដល់ឧប្បាទហើយ មិនទាន់រលត់ទៅ ។ ក្នុងវារៈនោះ ព្រះមានព្រះភាគ ទ្រង់សំដៅយកភាពដែលចិត្តដល់ព្រមដោយឧប្បាទ ទើបត្រាស់ថា* **អាមន្តា** ។ *បទថា* **តេសំ ចិត្តំ ឧប្បន្នំ** *ព្រះមានព្រះភាគត្រាស់សំដៅយកចិត្តដែលដល់ឧប្បាទហើយមិនទាន់រលត់ទៅ ។ បទថា* **អនុប្បន្នំ** *បានដល់ មិនទាន់ដល់ឧប្បាទ ។ ក្នុងបទថា* **តេសំ ចិត្តំ ឧប្បជ្ជិត្ថ** *នេះ សេចក្តីថា ចិត្តរបស់បុគ្គលទាំងអស់ ជាបច្ចុប្បន្នក្ខណៈមុននោះឯង ឈ្មោះថា ធ្លាប់កើតហើយ ព្រោះកន្លងហើយ នូវឧប្បាទក្ខណៈ ។*

*បទថា* **ឧប្បជ្ជិត្ថ ចេវ ឧប្បជ្ជតិ ច** *អធិប្បាយថា ធ្លាប់កើត ព្រោះដល់ហើយនូវឧប្បាទក្ខណៈ ឈ្មោះថា កំពុងកើត ព្រោះមិនទាន់កន្លងឧប្បាទក្ខណៈ ព្រោះភាពដែលបុគ្គលអ្នកចូលនិរោធសមាបត្តិ ចិត្តធ្លាប់កើតឡើងហើយក្នុងកាលមុនអំពីនិរោធ និងព្រោះអសញ្ញសត្តបុគ្គល ចិត្តធ្លាប់កើតឡើងហើយ ក្នុងសញ្ញីភព ។*

*បទថា* **ឧប្បាទក្ខណោ អនាគតញ្ច** *គឺ* **ឧប្បាទក្ខណោ ច ចិត្តំ អនាគតញ្ច ចិត្តំ** *បានដល់ ចិត្តក្នុងឧប្បាទក្ខណៈ និងចិត្តដែលជាអនាគត ។*

*[ ៥៧ ] ក្នុងអតិក្កន្តកាលវារៈ បទថា* **ឧប្បជ្ជមានំ ខណំ** *បានដល់ ឧប្បាទក្ខណៈ ។ ក្នុងវារៈនោះ ឧប្បាទក្ខណៈ មិនឈ្មោះថា កំពុងកើតក៏ពិតតែព្រះមានព្រះភាគ ក៏ត្រាស់យ៉ាងនោះ ព្រោះជាខណៈរបស់ចិត្តកំពុងកើត ។ បទថា* **ខណំ វីតិក្កន្តំ អតិក្កន្តកាលំ** *អធិប្បាយថា ឧប្បាទក្ខណៈនោះឯង*

កន្លងហើយមិនយូរ ជាចិត្តកន្លងហើយ ទើបរាប់ថា មានកាលកន្លងហើយ ។ បទថា **និរុជ្ឈមានំ ខណំ** បានដល់ និរោធក្ខណៈ ។ ក្នុងបទនោះ និរោធក្ខណៈ មិនឈ្មោះថា កំពុងរលត់ក៏ពិត តែក៏ត្រាស់យ៉ាងនោះ ព្រោះជាខណៈរបស់ចិត្តដែលកំពុងរលត់ ។ បទថា **ខណំ វីតិក្កន្តំ អតិក្កន្តកាលំ** សេចក្ដីថា ព្រះមានព្រះភាគត្រាស់សួរថា ចិត្តរបស់បុគ្គលនោះ ជាចិត្តកន្លងសូម្បីនិរោធក្ខណៈយ៉ាងនេះ ឈ្មោះថា មានកាលកន្លងហើយ ពិតឬ ។ ក្នុងសេចក្ដីនោះ ព្រោះចិត្តក្នុងភង្គក្ខណៈ កន្លងខណៈដែលជាឧប្បាទក្ខណៈហើយ រាប់ថា មានកាលកន្លងហើយ កាលចិត្តកន្លងខណៈ ដែលជានិរោធក្ខណៈហើយ ក៏មិនឈ្មោះថា មានកាលកន្លងហើយ តែចិត្តដែលជាអតីត ជាចិត្តកន្លងនូវខណៈដែលជាខណៈទាំង ២ ឈ្មោះថា មានកាលកន្លងហើយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់វិសជ្ជនាថា ក្នុងភង្គក្ខណៈ ចិត្តកន្លងឧប្បា-ទក្ខណៈ តែមិនកន្លងភង្គក្ខណៈ ចិត្តដែលជាអតីត កន្លងឧប្បាទក្ខណៈផង កន្លងភង្គក្ខណៈផង ដូច្នេះ ។

ក្នុងការវិសជ្ជនាបញ្ហាទី ២ ព្រោះចិត្តដែលអតីត កន្លងខណៈទាំង ២ ទើបឈ្មោះថា មានកាលកន្លងហើយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អតីតំ ចិត្តំ** ដូច្នេះ ។

ក្នុងការវិសជ្ជនាបដិលោមបញ្ហា ព្រោះចិត្តក្នុងឧប្បាទក្ខណៈ និងចិត្តដែលជាអនាគត ជាចិត្តកន្លងខណៈទាំង ២ គឺឧប្បាទក្ខណៈ និងភង្គក្ខណៈ តែមិនឈ្មោះថា មានកាលកន្លងហើយ ព្រោះភាពដែលខណៈទាំងនោះ មិន

*ទាន់កន្លងទៅ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **ឧប្បាទក្ខណេ ចិត្តំ អនាគតំ ចិត្តំ** *ដូច្នេះ ។ ក្នុងការវិសជ្ជនាបញ្ហាទី ២ ប្រាកដច្បាស់ហើយ ។ គប្បីជ្រាបអត្ថក្នុងការវិសជ្ជនាបញ្ហាទាំងពួង ក្នុងធម្មវារៈ ដោយឧបាយនេះឯង ។*

*[ ៧២ ] បុគ្គលធម្មវារៈ ក៏មានគតិដូចធម្មវារៈនោះឯង ។ មិស្សកវារៈទាំងអស់ ព្រះមានព្រះភាគទ្រង់សម្តែងសង្ខេបត្រឹមតែមាតិកា ដោយន័យថា* **យស្ស សរាគំ ចិត្តំ** *ជាដើម ចំណែកសេចក្តីពិស្តារនៃអត្ថទាំងនោះ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលខាងដើមនោះឯង ។ ក្នុងវារៈទាំងនោះ មានបុច្ឆាដូចគ្នា ព្រោះជាបញ្ហាគប្បីឲ្យពិស្តារយ៉ាងនេះថា* **យស្ស សរាគំ ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ តស្ស ចិត្តំ និរុជ្ឈិស្សតិ នុប្បជ្ជិស្សតិ** *ជាដើម តែព្រោះចិត្តមានរាគៈ មិនមែនបច្ឆិមចិត្ត ព្រោះហេតុនោះ ទើបការវិសជ្ជនាឈ្មោះថា មិនដូចគ្នា ព្រោះបញ្ហាថា ចិត្តមានរាគៈរបស់បុគ្គលណា កំពុងកើត មិនមែនកំពុងរលត់ ចិត្តរបស់បុគ្គលនោះ នឹងរលត់ មិនមែននឹងកើតពិតមែនឬ ដូច្នេះជាដើម លោកឲ្យពាក្យវិសជ្ជនាថា* **នោ** *ដូច្នេះ ដោយប្រការដូច្នេះ វិសជ្ជនាបញ្ហានោះៗ គប្បីជ្រាបតាមសមគួរដល់បុច្ឆានោះៗ ដូច្នេះឯង ។*

## អដ្ឋកថាចិត្តយមកៈ ចប់

# អភិធម្មបិដក

# ធម្មយមកៈ

## បណ្ណត្តិវារៈ

### ឧទ្ទេសវារៈ

[ ៧៨ ] ពួកកុសល ឈ្មោះថា កុសលធម៌ ពួកកុសលធម៌ ឈ្មោះថា កុសល ។ ពួកអកុសល ឈ្មោះថា អកុសលធម៌ ពួកអកុសលធម៌ ឈ្មោះថា អកុសល ។ ពួកអព្យាកតៈ ឈ្មោះថា អព្យាកតធម៌ ពួកអព្យាកតធម៌ ឈ្មោះថា អព្យាកតៈ ។

[ ៧៩ ] មិនមែនកុសល ឈ្មោះថា មិនមែនកុសលធម៌ មិនមែនកុសលធម៌ ឈ្មោះថា មិនមែនកុសល ។ មិនមែនអកុសល ឈ្មោះថា មិនមែនអកុសលធម៌ មិនមែនអកុសលធម៌ ឈ្មោះថា មិនមែនអកុសល ។ មិនមែនអព្យាកតៈ ឈ្មោះថា មិនមែនអព្យាកតធម៌ មិនមែនអព្យាកតធម៌ ឈ្មោះថា មិនមែនអព្យាកតៈ ។

[ ៨០ ] ពួកកុសល ឈ្មោះថា កុសលធម៌ ពួកធម៌ ឈ្មោះថា អកុសលធម៌ ។ ពួកកុសល ឈ្មោះថា កុសលធម៌ ពួកធម៌ ឈ្មោះថា អព្យាកតធម៌ ។ ពួកអកុសល ឈ្មោះថា អកុសលធម៌ ពួកធម៌ ឈ្មោះថា កុសលធម៌ ។ ពួកអកុសល ឈ្មោះថា អកុសលធម៌ ពួកធម៌ ឈ្មោះថា

អព្យាកតធម៌ ។ ពួកអព្យាកតៈ ឈ្មោះថា អព្យាកតធម៌ ពួកធម៌ ឈ្មោះថា កុសលធម៌ ។ ពួកអព្យាកតៈ ឈ្មោះថា អព្យាកតធម៌ ពួកធម៌ ឈ្មោះថា អកុសលធម៌ ។

[ ៨១ ] មិនមែនកុសល ឈ្មោះថា មិនមែនកុសលធម៌ មិនមែនធម៌ ឈ្មោះថា មិនមែនអកុសលធម៌ ។ មិនមែនកុសល ឈ្មោះថា មិនមែនកុសលធម៌ មិនមែនធម៌ ឈ្មោះថា មិនមែនអព្យាកតធម៌ ។ មិនមែនអកុសល ឈ្មោះថា មិនមែនអកុសលធម៌ មិនមែនធម៌ ឈ្មោះថា មិនមែនកុសលធម៌ ។ មិនមែនអកុសល ឈ្មោះថា មិនមែនអកុសលធម៌ មិនមែនធម៌ ឈ្មោះថា មិនមែនអព្យាកតធម៌ ។ មិនមែនអព្យាកតៈ ឈ្មោះថា មិនមែនអព្យាកតធម៌ មិនមែនធម៌ ឈ្មោះថា មិនមែនកុសលធម៌ ។ មិនមែនអព្យាកតៈ ឈ្មោះថា មិនមែនអព្យាកតធម៌ មិនមែនធម៌ ឈ្មោះថា មិនមែនអកុសលធម៌ ។

[ ៨២ ] ពួកកុសល ឈ្មោះថា ធម៌ ពួកធម៌ ឈ្មោះថា កុសល ។ ពួកអកុសល ឈ្មោះថា ធម៌ ពួកធម៌ ឈ្មោះថា អកុសល ។ ពួកអព្យាកតៈ ឈ្មោះថា ធម៌ ពួកធម៌ ឈ្មោះថា អព្យាកតៈ ។

[ ៨៣ ] មិនមែនកុសល ឈ្មោះថា មិនមែនធម៌ មិនមែនធម៌ ឈ្មោះថា មិនមែនកុសល ។ មិនមែនអកុសល ឈ្មោះថា មិនមែនធម៌ មិនមែនធម៌ ឈ្មោះថា មិនមែនអកុសល ។ មិនមែនអព្យាកតៈ ឈ្មោះថា មិនមែនធម៌ មិនមែនធម៌ ឈ្មោះថា មិនមែនអព្យាកតៈ ។

[ ៨៤ ] ពួកកុសល ឈ្មោះថា ធម៌ ពួកធម៌ ឈ្មោះថា អកុសល ។

ពួកកុសល ឈ្មោះថា ធម៌ ពួកធម៌ ឈ្មោះថា អព្យាកតៈ ។ ពួកអកុសល ឈ្មោះថា ធម៌ ពួកធម៌ ឈ្មោះថា កុសល ។ ពួកអកុសល ឈ្មោះថា ធម៌ ពួកធម៌ ឈ្មោះថា អព្យាកតៈ ។ ពួកអព្យាកតៈ ឈ្មោះថា ធម៌ ពួកធម៌ ឈ្មោះថា កុសល ។ ពួកអព្យាកតៈ ឈ្មោះថា ធម៌ ពួកធម៌ ឈ្មោះថា អកុសល ។

[ ៨៥ ] មិនមែនកុសល ឈ្មោះថា មិនមែនធម៌ មិនមែនធម៌ ឈ្មោះថា មិនមែនអកុសល ។ មិនមែនកុសល ឈ្មោះថា មិនមែនធម៌ មិនមែនធម៌ ឈ្មោះថា មិនមែនអព្យាកតៈ ។ មិនមែនអកុសល ឈ្មោះថា មិនមែនធម៌ មិនមែនធម៌ ឈ្មោះថា មិនមែនកុសល ។ មិនមែនអកុសល ឈ្មោះថា មិនមែនធម៌ មិនមែនធម៌ ឈ្មោះថា មិនមែនអព្យាកតៈ ។ មិនមែនអព្យាកតៈ ឈ្មោះថា មិនមែនធម៌ មិនមែនធម៌ ឈ្មោះថា មិនមែនកុសល ។ មិនមែនអព្យាកតៈ ឈ្មោះថា មិនមែនធម៌ មិនមែនធម៌ ឈ្មោះថា មិនមែនអកុសល ។

ឧទ្ទេសវារៈ ចប់

## និទ្ទេសវារៈ

[ ៨៦ ] សួរ. ពួកកុសល ឈ្មោះថា កុសលធម៌ឬ ។ ឆ្លើយ. អើ ។ ពួកកុសលធម៌ ឈ្មោះថា កុសលឬ ។ អើ ។ ពួកអកុសល ឈ្មោះថា អកុសលធម៌ឬ ។ អើ ។ ពួកអកុសលធម៌ ឈ្មោះថា អកុសលឬ ។ អើ ។

ពួកអព្យាកតៈ ឈ្មោះថា អព្យាកតធម៌ឬ ។ អើ ។ ពួកអព្យាកតធម៌ ឈ្មោះថា អព្យាកតៈឬ ។ អើ ។

[ ៨៧ ] មិនមែនកុសល ឈ្មោះថា មិនមែនកុសលធម៌ឬ ។ អើ ។ មិនមែនកុសលធម៌ ឈ្មោះថា មិនមែនកុសលឬ ។ អើ ។ មិនមែនអកុសល ឈ្មោះថា មិនមែនអកុសលធម៌ឬ ។ អើ ។ មិនមែនអកុសលធម៌ ឈ្មោះថា មិនមែនអកុសលឬ ។ អើ ។ មិនមែនអព្យាកតៈ ឈ្មោះថា មិនមែនអព្យាកតធម៌ឬ ។ អើ ។ មិនមែនអព្យាកតធម៌ ឈ្មោះថា មិនមែនអព្យាកតៈឬ ។ អើ ។

[ ៨៨ ] ពួកកុសល ឈ្មោះថា កុសលធម៌ឬ ។ អើ ។ ពួកធម៌ ឈ្មោះថា អកុសលធម៌ឬ ។ ពួកអកុសលធម៌ ឈ្មោះថា ធម៌ផង អកុសលធម៌ផង ពួកធម៌ដ៏សេស ( ក្រៅពីនេះ ) ឈ្មោះថា មិនមែនអកុសលធម៌ទេ ។ ពួកកុសល ឈ្មោះថា កុសលធម៌ឬ ។ អើ ។ ពួកធម៌ ឈ្មោះថា អព្យាកតធម៌ឬ ។ ពួកអព្យាកតធម៌ ឈ្មោះថា ធម៌ផង អព្យាកតធម៌ផង ពួកធម៌ដ៏សេស ឈ្មោះថា មិនមែនអព្យាកតធម៌ទេ ។ ពួកអកុសល ឈ្មោះថា អកុសលធម៌ឬ ។ អើ ។ ពួកធម៌ ឈ្មោះថា កុសលធម៌ឬ ។ ពួកកុសលធម៌ ឈ្មោះថា ធម៌ផង កុសលធម៌ផង ពួកធម៌ដ៏សេស ឈ្មោះថា មិនមែនកុសលធម៌ទេ ។ ពួកអកុសល ឈ្មោះថា អកុសលធម៌ឬ ។ អើ ។ ពួកធម៌ ឈ្មោះថា អព្យាកតធម៌ឬ ។ ពួកអព្យាកតធម៌ ឈ្មោះថា ធម៌ផង អព្យាកតធម៌ផង ពួកធម៌ដ៏សេស ឈ្មោះថា មិនមែនអព្យាកតធម៌ទេ ។ ពួក

អព្យាកតៈ ឈ្មោះថា អព្យាកតធម៌ឬ ។ អើ ។ ពួកធម៌ ឈ្មោះថា កុសលធម៌ឬ ។ ពួកកុសលធម៌ ឈ្មោះថា ធម៌ផង កុសលធម៌ផង ពួកធម៌ដ៏សេស ឈ្មោះថា មិនមែនកុសលធម៌ទេ ។ ពួកអព្យាកតៈ ឈ្មោះថា អព្យាកតធម៌ឬ ។ អើ ។ ពួកធម៌ ឈ្មោះថា អកុសលធម៌ឬ ។ ពួកអកុសលធម៌ ឈ្មោះថា ធម៌ផង អកុសលធម៌ផង ពួកធម៌ដ៏សេស ឈ្មោះថា មិនមែនអកុសលធម៌ទេ ។

[ ៨៩ ] មិនមែនកុសល ឈ្មោះថា មិនមែនកុសលធម៌ឬ ។ អើ ។ មិនមែនធម៌ ឈ្មោះថា មិនមែនអកុសលធម៌ឬ ។ អើ ។ មិនមែនកុសល ឈ្មោះថា មិនមែនអកុសលធម៌ឬ ។ អើ ។ មិនមែនធម៌ ឈ្មោះថា មិនមែនអព្យាកតធម៌ឬ ។ អើ ។ មិនមែនអកុសល ឈ្មោះថា មិនមែនអកុសលធម៌ឬ ។ អើ ។ មិនមែនធម៌ ឈ្មោះថា មិនមែនកុសលធម៌ឬ ។ អើ ។ មិនមែនអកុសល ឈ្មោះថា មិនមែនអកុសលធម៌ឬ ។ អើ ។ មិនមែនធម៌ ឈ្មោះថា មិនមែនអព្យាកតធម៌ឬ ។ អើ ។ មិនមែនអព្យាកតៈ ឈ្មោះថា មិនមែនអព្យាកតធម៌ឬ ។ អើ ។ មិនមែនធម៌ ឈ្មោះថា មិនមែនកុសលធម៌ឬ ។ អើ ។ មិនមែនអព្យាកតៈ ឈ្មោះថា មិនមែនអព្យាកតធម៌ឬ ។ អើ ។ មិនមែនធម៌ ឈ្មោះថា មិនមែនអកុសលធម៌ឬ ។ អើ ។

[ ៩០ ] ពួកកុសល ឈ្មោះថា ធម៌ឬ ។ អើ ។ ពួកធម៌ ឈ្មោះថា កុសលធម៌ឬ ។ ពួកកុសលធម៌ ឈ្មោះថា ធម៌ផង កុសលធម៌ផង ពួកធម៌ដ៏សេស ឈ្មោះថា មិនមែនកុសលធម៌ទេ ។ ពួកអកុសល ឈ្មោះថា ធម៌ឬ ។

អើ ។ ពួកធម៌ ឈ្មោះថា អកុសលធម៌ឬ ។ ពួកអកុសលធម៌ ឈ្មោះថា ធម៌ផង កុសលធម៌ផង ពួកធម៌ដ៏សេស ឈ្មោះថា មិនមែនអកុសលធម៌ទេ ។ ពួកអព្យាកតៈ ឈ្មោះថា ធម៌ឬ ។ អើ ។ ពួកធម៌ ឈ្មោះថា អព្យាកតធម៌ឬ ។ ពួកអព្យាកតធម៌ ឈ្មោះថា ធម៌ផង អព្យាកតធម៌ផង ពួកធម៌ដ៏សេស ឈ្មោះថា មិនមែនអព្យាកតធម៌ទេ ។

[ ៩១ ] មិនមែនកុសល ឈ្មោះថា មិនមែនធម៌ឬ ។ ពួកធម៌ដ៏សេស វៀរលែងតែកុសលចេញ ឈ្មោះថា មិនមែនកុសលធម៌ទេ ពួកធម៌ដ៏សេស វៀរលែងតែកុសល និងពួកធម៌ចេញ ឈ្មោះថា មិនមែនកុសលផង មិនមែនធម៌ផង ។ មិនមែនធម៌ ឈ្មោះថា មិនមែនកុសលធម៌ឬ ។ អើ ។ មិនមែនអកុសល ឈ្មោះថា មិនមែនធម៌ឬ ។ ពួកធម៌ដ៏សេស វៀរលែងតែអកុសលចេញ ឈ្មោះថា មិនមែនអកុសលធម៌ទេ ពួកធម៌ដ៏សេស វៀរលែងតែអកុសល និងពួកធម៌ចេញ ឈ្មោះថា មិនមែនអកុសលផង មិនមែនធម៌ផង ។ មិនមែនធម៌ ឈ្មោះថា មិនមែនអកុសលធម៌ឬ ។ អើ ។ មិនមែនអព្យាកតៈ ឈ្មោះថា មិនមែនធម៌ឬ ។ ពួកធម៌ដ៏សេស វៀរលែងតែអព្យាកតៈចេញ ឈ្មោះថា មិនមែនអព្យាកតធម៌ទេ ពួកធម៌ដ៏សេស វៀរលែងតែអព្យាកតៈ និងពួកធម៌ចេញ ឈ្មោះថា មិនមែនអព្យាកតៈផង មិនមែនធម៌ផង ។ មិនមែនធម៌ ឈ្មោះថា មិនមែនអព្យាកតធម៌ឬ ។ អើ ។

[ ៩២ ] ពួកកុសល ឈ្មោះថា ធម៌ឬ ។ អើ ។ ពួកធម៌ ឈ្មោះថា អកុសលធម៌ឬ ។ ពួកអកុសលធម៌ ឈ្មោះថា ធម៌ផង អកុសលធម៌ផង

ពួកធម៌ដ៏សេស ឈ្មោះថា មិនមែនអកុសលធម៌ទេ ។ ពួកកុសល ឈ្មោះថា ធម៌ឬ ។ អើ ។ ពួកធម៌ ឈ្មោះថា អព្យាកតធម៌ឬ ។ ពួកអព្យាកតធម៌ ឈ្មោះថា ធម៌ផង អព្យាកតធម៌ផង ពួកធម៌ដ៏សេស ឈ្មោះថា មិនមែនអព្យាកតធម៌ទេ ។ ពួកអកុសល ឈ្មោះថា ធម៌ឬ ។ អើ ។ ពួកធម៌ ឈ្មោះថា កុសលធម៌ឬ ។ ពួកកុសលធម៌ ឈ្មោះថា ធម៌ផង កុសលធម៌ផង ពួកធម៌ដ៏សេស ឈ្មោះថា មិនមែនកុសលធម៌ទេ ។ ពួកអកុសល ឈ្មោះថា ធម៌ឬ ។ អើ ។ ពួកធម៌ ឈ្មោះថា អព្យាកតធម៌ឬ ។ ពួកអព្យាកតធម៌ ឈ្មោះថា ធម៌ផង អព្យាកតធម៌ផង ពួកធម៌ដ៏សេស ឈ្មោះថា មិនមែនអព្យាកតធម៌ទេ ។ ពួកអព្យាកតៈ ឈ្មោះថា ធម៌ឬ ។ អើ ។ ពួកធម៌ ឈ្មោះថា កុសលធម៌ឬ ។ ពួកកុសលធម៌ ឈ្មោះថា ធម៌ផង កុសលធម៌ផង ពួកធម៌ដ៏សេស ឈ្មោះថា មិនមែនកុសលធម៌ទេ ។ ពួកអព្យាកតៈ ឈ្មោះថា ធម៌ឬ ។ អើ ។ ពួកធម៌ ឈ្មោះថា អកុសលធម៌ឬ ។ ពួកអកុសលធម៌ ឈ្មោះថា ធម៌ផង អកុសលធម៌ផង ពួកធម៌ដ៏សេស ឈ្មោះថា មិនមែនអកុសលធម៌ទេ ។

[ ៩៣ ] មិនមែនកុសល ឈ្មោះថា មិនមែនធម៌ឬ ។ ពួកធម៌ដ៏សេស វៀរលែងតែកុសលចេញ ឈ្មោះថា មិនមែនកុសលធម៌ទេ ពួកធម៌ដ៏សេស វៀរលែងតែកុសល និងពួកធម៌ចេញ ឈ្មោះថា មិនមែនកុសលផង មិនមែនធម៌ផង ។ មិនមែនធម៌ ឈ្មោះថា មិនមែនអកុសលធម៌ឬ ។ អើ ។ មិនមែនកុសល ឈ្មោះថា មិនមែនធម៌ឬ ។ ពួកធម៌ដ៏សេស វៀរលែងតែកុសល

ចេញ ឈ្មោះថា មិនមែនកុសលធម៌ទេ ពួកធម៌ដ៏សេស វៀរលែងតែកុសល និងពួកធម៌ចេញ ឈ្មោះថា មិនមែនកុសលផង មិនមែនធម៌ផង ។ មិនមែនធម៌ ឈ្មោះថា មិនមែនអព្យាកតធម៌ឬ ។ អើ ។ មិនមែនអកុសល ឈ្មោះថា មិនមែនធម៌ឬ ។ ពួកធម៌ដ៏សេស វៀរលែងតែអកុសលចេញ ឈ្មោះថា មិនមែនអកុសលធម៌ទេ ពួកធម៌ដ៏សេស វៀរលែងតែអកុសល និងពួកធម៌ចេញ ឈ្មោះថា មិនមែនអកុសលផង មិនមែនធម៌ផង ។ មិនមែនធម៌ ឈ្មោះថា មិនមែនកុសលធម៌ឬ ។ អើ ។ មិនមែនអកុសល ឈ្មោះថា មិនមែនធម៌ឬ ។ ពួកធម៌ដ៏សេស វៀរលែងតែអកុសលចេញ ឈ្មោះថា មិនមែនអកុសលធម៌ទេ ពួកធម៌ដ៏សេស វៀរលែងតែអកុសល និងពួកធម៌ចេញ ឈ្មោះថា មិនមែនអកុសលផង មិនមែនធម៌ផង ។ មិនមែនធម៌ ឈ្មោះថា មិនមែនអព្យាកតធម៌ឬ ។ អើ ។ មិនមែនអព្យាកតៈ ឈ្មោះថា មិនមែនធម៌ឬ ។ ពួកធម៌ដ៏សេស វៀរលែងតែអព្យាកតៈចេញ ឈ្មោះថា មិនមែនអព្យាកតធម៌ទេ ពួកធម៌ដ៏សេស វៀរលែងតែអព្យាកតៈ និងពួកធម៌ចេញ ឈ្មោះថា មិនមែនអព្យាកតៈផង មិនមែនធម៌ផង ។ មិនមែនធម៌ ឈ្មោះថា មិនមែនកុសលធម៌ឬ ។ អើ ។ មិនមែនអព្យាកតៈ ឈ្មោះថា មិនមែនធម៌ឬ ។ ពួកធម៌ដ៏សេស វៀរលែងតែអព្យាកតៈចេញ ឈ្មោះថា មិនមែនអព្យាកតធម៌ទេ ពួកធម៌ដ៏សេស វៀរលែងតែអព្យាកតៈ និងពួកធម៌ចេញ ឈ្មោះថា មិនមែនអព្យាកតៈផង មិនមែនធម៌ផង ។ មិនមែនធម៌ ឈ្មោះថា

មិនមែនអកុសលធម៌ឬ ។ អើ ។

និទ្ទេសវារៈ ចប់

បណ្ណត្តិវារៈ ចប់

# បវត្តិវារៈ

[ ៩៤ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើងឬ ។ មិនមែនទេ ។ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើង ឬ ។ មិនមែនទេ ។

[ ៩៥ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ កើតឡើងឬ ។ ពួកកុសលធម៌ របស់ពួកសត្វនោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃពួកកុសលក្នុងអរូបភព តែពួកអព្យាកតធម៌របស់ពួកសត្វនោះ មិនកើតឡើងទេ ឯពួកកុសលធម៌ របស់ពួកសត្វនោះ ទើបកើតឡើង ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអព្យាកតធម៌ ក៏កើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា កើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងឬ ។ ពួកអព្យាកតធម៌ របស់ពួកសត្វទាំងអស់នោះ កាលកើតឡើង កើតឡើងក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងបវត្តិកាល តែពួកកុសលធម៌

របស់ពួកសត្វនោះ មិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ៩៦ ] ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ កើតឡើងឬ ។ ពួកអកុសលធម៌ របស់ពួកសត្វនោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ក្នុងអរូបភព តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនកើតឡើងទេ ឯពួកអកុសលធម៌ របស់ពួកសត្វនោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអព្យាកតធម៌ ក៏កើតឡើងដែរ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌របស់បុគ្គលណា កើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើងឬ ។ ពួកអព្យាកតធម៌ របស់ពួកសត្វទាំងអស់នោះ កាលកើតឡើង កើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងបវត្តិកាល តែពួកអកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអកុសលធម៌ ក៏កើតឡើងដែរ ។

[ ៩៧ ] ពួកកុសលធម៌ កើតឡើង ក្នុងទីណា ពួកអកុសលធម៌ កើតឡើង ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ កើតឡើង ក្នុងទីណា ពួកកុសលធម៌ កើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ៩៨ ] ពួកកុសលធម៌ កើតឡើង ក្នុងទីណា ពួកអព្យាកតធម៌

កើតឡើង ក្នុងទីនោះឬ ។ អើ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ កើតឡើង ក្នុងទីណា ពួកកុសលធម៌ កើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ កើតឡើង ក្នុងទីនោះ គឺក្នុងអសញ្ញសត្វ តែពួកកុសលធម៌ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ ទើបកើតឡើងក្នុងទីនោះ គឺក្នុងចតុវោការភព និងក្នុងបញ្ចវោការភព ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ៩៩ ] ពួកកុសលធម៌ កើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ កើតឡើង ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ កើតឡើង ក្នុងទីណា ពួកអកុសលធម៌ កើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ កើតឡើងក្នុងទីនោះ គឺក្នុងអសញ្ញសត្វ តែពួកអកុសលធម៌ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ ទើបកើតឡើងក្នុងទីនោះ គឺក្នុងចតុវោការភព និងក្នុងបញ្ចវោការភព ទាំងពួកអកុសលធម៌ ក៏កើតឡើងដែរ ។

[ ១០០ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។ មិនមែនទេ ។

[ ១០១ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកសត្វនោះ កើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ក្នុងអរូបភព តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនកើតឡើង

ក្នុងទីនោះទេ ឯពួកកុសលធម៌ របស់ពួកសត្វនោះ ទើបកើតឡើងក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអព្យាកតធម៌ ក៏កើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកសត្វទាំងអស់នោះ កាលកើតឡើង កើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងបវត្តិកាល តែកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើងក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ ទើបកើតឡើងក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយក្នុងបញ្ចវោការភព ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ១០២ ] ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកសត្វនោះ កើតឡើងក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ក្នុងអរូបភព តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនកើតឡើងក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកសត្វនោះ ទើបកើតឡើងក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអព្យាកតធម៌ ក៏កើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើងក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកសត្វទាំងអស់នោះ កាលកើតឡើង កើតឡើងក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល

ក្នុងបវត្តិកាល តែពួកអកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើងក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ ទើបកើតឡើងក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអកុសលធម៌ក៏កើតឡើងដែរ ។

[ ១០៣ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ ពួកកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ តែពួកអកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើងក៏មិនមែន ឯពួកកុសលធម៌ របស់សត្វទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល និងចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈ ( ខណៈជាទីបែកធ្លាយ ) នៃចិត្ត ទាំងពួកអកុសលធម៌ ក៏មិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ ពួកអកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយទេ តែពួកកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកសត្វទាំងអស់នោះ គឺពួកលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល និងចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត ទាំងពួកកុសលធម៌ ក៏មិនកើតឡើងដែរ ។

[ ១០៤ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអព្យាកតធម៌របស់បុគ្គលនោះ មិនកើតឡើងដែរឬ ។ ពួកកុសលធម៌ របស់ពួកសត្វទាំងអស់នោះ កាលកើតឡើង មិនកើតឡើងក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងបវត្តិកាល តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកសត្វទាំងអស់នោះ កាលច្យុត មិនកើតឡើងក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ក្នុងអរូបភព ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ទាំងពួកអព្យាកតធម៌ ក៏មិនកើតឡើងដែរ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ ពួកអព្យាកតធម៌របស់ពួកសត្វនោះ មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ក្នុងអរូបភព តែពួកកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក៏មិនមែន ឯពួកអព្យាកតធម៌ របស់ពួកសត្វទាំងអស់នោះ កាលច្យុត មិនកើតឡើងក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ក្នុងអរូបភព ក្នុងភង្គក្ខណៈនៃចិត្តក្នុងបវត្តិកាល ទាំងពួកកុសលធម៌ ក៏មិនកើតឡើងដែរ ។

[ ១០៥ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ ពួកអកុសលធម៌ របស់ពួកសត្វទាំងអស់នោះ កាលកើតឡើង មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងបវត្តិកាល តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកសត្វទាំង

អស់នោះ កាលច្យុត មិនកើតឡើងក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ក្នុងអរូបភព ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ទាំងពួកអព្យាកតធម៌ ក៏មិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ ពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ក្នុងអរូបភពទេ តែពួកអកុសលធម៌របស់ពួកសត្វនោះ មិនកើតឡើង ក៏មិនមែន ឯពួកអព្យាកតធម៌ របស់ពួកសត្វទាំងអស់នោះ កាលច្យុត មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ក្នុងអរូបភព ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ទាំងពួកអកុសលធម៌ ក៏មិនកើតឡើងដែរ ។

[ ១០៦ ] ពួកកុសលធម៌ មិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ មិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ១០៧ ] ពួកកុសលធម៌ មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ មិនកើតឡើង ក្នុងទីនោះឬ ។ កើតឡើង ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ មិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ មិនកើតឡើង ក្នុងទីនោះឬ ។ មិនមានទេ ។

[ ១០៨ ] ពួកអកុសលធម៌ មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ មិនកើតឡើង ក្នុងទីនោះឬ ។ កើតឡើង ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ មិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ មិនកើតឡើង ក្នុងទីនោះឬ ។

មិនមានទេ ។

[ ១០៩ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ តែពួកអកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើងក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ មិនកើតឡើងក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល និងចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈនៃចិត្ត ទាំងពួកអកុសលធម៌ ក៏មិនកើតឡើងដែរ ។ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ តែពួកកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើងក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល និងចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈនៃចិត្ត ទាំងពួកកុសលធម៌ ក៏មិនកើតឡើងដែរ ។

[ ១១០ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកសត្វទាំងអស់នោះ កាលកើតឡើង មិនកើតឡើង ក្នុង

ទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងបវត្តិកាល តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក្នុងទីនោះ ក៏មិនមែនឯពួកកុសលធម៌ របស់ពួកសត្វទាំងអស់នោះ កាលច្យុត មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ក្នុងអរូបភព ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ទាំងពួកអព្យាកតធម៌ ក៏មិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ក្នុងអរូបភពទេ តែពួកកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកអព្យាកតធម៌ របស់ពួកសត្វទាំងអស់នោះ កាលច្យុត មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ក្នុងអរូបភព ក្នុងឧប្បាទក្ខណៈនៃចិត្តក្នុងបវត្តិកាល ទាំងពួកកុសលធម៌ ក៏មិនកើតឡើងដែរ ។

[ ១១១ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកសត្វទាំងអស់នោះ កាលកើតឡើង មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងបវត្តិកាល តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនកើតឡើងក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកសត្វទាំងអស់នោះ កាលច្យុត មិនកើតឡើងក្នុង

ទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ក្នុងអរូបភព ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ទាំងពួកអព្យាកតធម៌ ក៏មិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនកើតឡើងក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ក្នុងអរូបភពទេ តែពួកអកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកអព្យាកតធម៌ របស់ពួកសត្វទាំងអស់នោះ កាលច្យុត មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ក្នុងអរូបភព ក្នុងភង្គក្ខណៈនៃចិត្តក្នុងបវត្តិកាល ទាំងពួកអកុសលធម៌ ក៏មិនកើតឡើងដែរ ។

[ ១១២ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយឬ ។ អើ ។

[ ១១៣ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ កើតឡើងហើយឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា កើតឡើងហើយ ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយឬ ។ អើ ។

[ ១១៤ ] ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ពួក

អព្យាកតធម៌ របស់បុគ្គលនោះ កើតឡើងហើយឬ ។ អើ ។ម៉្យាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា កើតឡើងហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយឬ ។ អើ ។

[ ១១៥ ] ពួកកុសលធម៌ កើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ ម៉្យាងទៀត ពួកអកុសលធម៌ កើតឡើងហើយ ក្នុងទីណា ពួកកុសលធម៌ កើតឡើងហើយ ក្នុងទីនោះ ឬ ។ អើ ។

[ ១១៦ ] ពួកកុសលធម៌ កើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ ម៉្យាងទៀត ពួកអព្យាកតធម៌ កើតឡើងហើយ ក្នុងទីណា ពួកកុសលធម៌ កើតឡើងហើយ ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ កើតឡើងហើយ ក្នុងទីនោះ គឺក្នុងអសញ្ញសត្វ តែពួកកុសលធម៌ មិនកើតឡើងហើយ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ កើតឡើងហើយ ក្នុងទីនោះ គឺក្នុងចតុវោការភព និងបញ្ចវោការភព ទាំងពួកកុសលធម៌ ក៏កើតឡើងហើយដែរ ។

[ ១១៧ ] ពួកអកុសលធម៌ កើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ ម៉្យាងទៀត ពួកអព្យាកតធម៌ កើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ កើតឡើងហើយ ក្នុងទីនោះ ឬ ។ ពួកអព្យាកតធម៌ កើតឡើងហើយ ក្នុងទីនោះ គឺក្នុងអសញ្ញសត្វ តែពួកអកុសលធម៌ មិនកើតឡើងហើយ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ កើត

ឡើងហើយ ក្នុងទីនោះ គឺក្នុងចតុវោការភព និងបញ្ចវោការភព ទាំងពួកអកុសលធម៌ ក៏កើតឡើងហើយដែរ ។

[ ១១៨ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ កាលអកុសលចិត្តទី ២ របស់ពួកសត្វក្នុងសុទ្ធាវាស កាលប្រព្រឹត្តទៅ ពួកអកុសលធម៌ របស់ពួកសុទ្ធាវាសសត្វនោះ កើតឡើងហើយ ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកសុទ្ធាវាសសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ គឺចតុវោការ និងបញ្ចវោការ កើតឡើងហើយ ក្នុងទីនោះ ទាំងពួកកុសលធម៌ ក៏កើតឡើងហើយដែរ ។

[ ១១៩ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា កើតឡើងហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ កាលចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វ កាលប្រព្រឹត្តទៅ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វនោះ កើតឡើងហើយ ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះ ឯពួកអព្យាកតធម៌

របស់សត្វទាំងនោះ ក្រៅពីនេះ គឺចតុវោការ និងបញ្ចវោការ កើតឡើង ហើយ ក្នុងទីនោះ ទាំងពួកកុសលធម៌ ក៏កើតឡើងហើយដែរ ។

[ ១២០ ] ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា កើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ កាលចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វ កាលប្រព្រឹត្តទៅ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វនោះ កើតឡើងហើយ ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះ ឯពួកអព្យាកត-ធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ គឺចតុវោការ និងបញ្ចវោការ កើតឡើង ហើយ ក្នុងទីនោះ ទាំងពួកអកុសលធម៌ ក៏កើតឡើងហើយដែរ ។

[ ១២១ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយឬ ។ មិនមានទេ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយឬ ។ មិនមានទេ ។

[ ១២២ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយឬ ។ មិនមានទេ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយឬ ។ មិនមានទេ ។

[ ១២៣ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយឬ ។ មិនមានទេ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយឬ ។ មិនមានទេ ។

[ ១២៤ ] ពួកកុសលធម៌ មិនកើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ មិនកើតឡើងហើយ ក្នុងទីណា ពួកកុសលធម៌ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។

[ ១២៥ ] ពួកកុសលធម៌ មិនកើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ កើតឡើងហើយ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ មិនកើតឡើងហើយ ក្នុងទីណា ពួកកុសលធម៌ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ មិនមានទេ ។

[ ១២៦ ] ពួកអកុសលធម៌ មិនកើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ កើតឡើងហើយ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ មិនកើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ មិនមានទេ ។

[ ១២៧ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ កាលអកុសលចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វ កាលប្រព្រឹត្តទៅ

ពួកកុសលធម៌របស់ពួកសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះ ក៏មិនមែន កាលចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វ កាលប្រព្រឹត្តទៅ ពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះ ទាំងពួកអកុ-សលធម៌ ក៏មិនកើតឡើងហើយដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។

[ ១២៨ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ កាលចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វ កាលប្រព្រឹត្តទៅ ពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកសត្វនោះ កាលចូលទៅកាន់សុទ្ធាវាស មិនកើតឡើងហើយ ក្នុងទីនោះទេ ទាំងពួកអព្យាកតធម៌ ក៏មិនកើតឡើងហើយដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនកើតឡើងហើយក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។

[ ១២៩ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។

កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កាលប្រព្រឹត្តទៅ ពួកអកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែពួកអព្យាកតធម៌របស់ពួកសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកសត្វនោះ កាលចូលទៅកាន់សុទ្ធាវាស មិនកើតឡើងហើយ ក្នុងទីនោះ ទាំងពួកអព្យាកតធម៌ ក៏មិនកើតឡើងហើយដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌របស់បុគ្គលណា មិនកើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។

[ ១៣០ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ គឺគោត្រភូចិត្តក្នុងលំដាប់នៃចិត្តណា ពួកកុសលធម៌ របស់ពួកសត្វនោះ នឹងកើតឡើង តែពួកអកុសលធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើងទេ ឯពួកកុសលធម៌ របស់ពួកសត្វនោះ ក្រៅពីនោះ នឹងកើតឡើង ទាំងពួកអកុសលធម៌ ក៏នឹងកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ អើ ។

[ ១៣១ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកកុសលធម៌ របស់បុគ្គល

នោះ នឹងកើតឡើងឬ ។ ពួកអព្យាកតធម៌ របស់បុគ្គលដែលជាព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ នឹងកើតឡើង តែពួកកុសលធម៌ របស់ពួកបុគ្គលនោះ នឹងមិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកបុគ្គលនោះក្រៅពីនេះ នឹងកើតឡើង ទាំងពួកកុសលធម៌ ក៏នឹងកើតឡើងដែរ ។

[ ១៣២ ] ពួកអកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកអព្យាកតធម៌របស់បុគ្គលនោះ នឹងកើតឡើងឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ ពួកអព្យាកតធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកសត្វនោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណានោះ នឹងកើតឡើង តែពួកអកុសលធម៌របស់ពួកសត្វនោះ នឹងមិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ នឹងកើតឡើង ទាំងពួកអកុសលធម៌ ក៏នឹងកើតឡើងដែរ ។

[ ១៣៣ ] ពួកកុសលធម៌ នឹងកើតឡើង ក្នុងទីណា ពួកអកុសលធម៌ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ នឹងកើតឡើងក្នុងទីណា ពួកកុសលធម៌ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ១៣៤ ] ពួកកុសលធម៌ នឹងកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ នឹងកើតឡើងក្នុងទីណា ពួកកុសលធម៌ នឹងកើតឡើងក្នុងទីនោះឬ ។ ពួកអព្យាកត-ធម៌ នឹងកើតឡើងក្នុងទីនោះ គឺក្នុងអសញ្ញសត្វ តែពួកកុសលធម៌ នឹងមិន

កើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ នឹងកើតឡើងក្នុងទីនោះ គឺក្នុងចតុវោការភព និងបញ្ចវោការភព ទាំងពួកកុសលធម៌ ក៏នឹងកើតឡើងដែរ ។

[ ១៣៥ ] ពួកកុសលធម៌ នឹងកើតឡើងក្នុងទីណា ពួកអព្យាកតធម៌ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។ មួយវិញទៀត ពួកអព្យាកតធម៌ នឹងកើតឡើង ក្នុងទីណា ពួកអកុសលធម៌ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ នឹងកើតឡើង ក្នុងទីនោះ គឺក្នុងអសញ្ញសត្វ តែពួកអកុសលធម៌ នឹងមិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ នឹងកើតឡើង ក្នុងទីនោះ គឺក្នុងចតុវោការភព និងបញ្ចវោការភព ទាំងពួកអកុសលធម៌ ក៏នឹងកើតឡើងដែរ ។

[ ១៣៦ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកសត្វនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងចតុវោការភព និងបញ្ចវោការភព នឹងកើតឡើង តែពួកអកុសលធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឯពួកកុសលធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ គឺចតុវោការ និងបញ្ចវោការ នឹងកើតឡើង ក្នុងទីនោះ ទាំងពួកអកុសលធម៌ ក៏នឹងកើតឡើងដែរ ។ មួយវិញទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ១៣៧ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា

ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកអសញ្ញសត្វនោះ នឹងកើតឡើង ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ គឺចតុវោការ និងបញ្ចវោការ នឹងកើតឡើង ទាំងពួកកុសលធម៌ ក៏នឹងកើតឡើងដែរ ។

[ ១៣៨ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកសត្វ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា និងរបស់ពួកអសញ្ញសត្វនោះ នឹងកើតឡើង ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ គឺចតុវោការ និងបញ្ចវោការ នឹងកើតឡើង ទាំងពួកអកុសលធម៌ ក៏នឹងកើតឡើងដែរ ។

[ ១៣៩ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួក

អកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ អើ ។ម៉្យាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកកុសលធម៌របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ ពួកអកុសលធម៌ របស់ពួកសត្វនោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងមិនកើតឡើងទេ តែពួកកុសលធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើង ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ នឹងមិនកើតឡើងទេ ទាំងពួកកុសលធម៌ ក៏នឹងមិនកើតឡើងដែរ ។

[ ១៤០ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ ពួកកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ នឹងមិនកើតឡើងទេ តែពួកអព្យាកតធម៌ របស់ពួកព្រះអរហន្តនោះ នឹងមិនកើតឡើងក៏មិនមែន ឯពួកកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ នឹងមិនកើតឡើង ទាំងពួកអព្យាកតធម៌ ក៏នឹងមិនកើតឡើងដែរ ។ ម៉្យាងទៀត ពួកអព្យាកតធម៌របស់បុគ្គលណា នឹងមិនកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ អើ ។

[ ១៤១ ] ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ ពួកអកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកសត្វ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណានោះ នឹងមិនកើតឡើងទេ

តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើង ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកសត្វអ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ ក៏នឹងមិនកើតឡើងទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនកើតឡើងដែរ ។ មួយវិញទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ អើ ។

[ ១៤២ ] ពួកកុសលធម៌ នឹងមិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ អើ ។ មួយវិញទៀត ពួកអកុសលធម៌ នឹងមិនកើតឡើងក្នុងទីណា ពួកកុសលធម៌ នឹងមិនកើតឡើងក្នុងទីនោះឬ ។ អើ ។

[ ១៤៣ ] ពួកកុសលធម៌ នឹងមិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ នឹងកើតឡើង ។ មួយវិញទៀត ពួកអព្យា-កតធម៌ នឹងមិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ មិនមានទេ ។

[ ១៤៤ ] ពួកអកុសលធម៌ នឹងមិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ នឹងកើតឡើង ។ មួយវិញទៀត ពួកអព្យាកតធម៌ នឹងមិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ មិនមានទេ ។

[ ១៤៥ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ អើ ។ មួយវិញទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង

ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកសត្វនោះ ដែលជាសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងមិនកើតឡើង ក្នុងទីនោះទេ តែពួកកុសលធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកអសញ្ញសត្វនោះ នឹងមិនកើតឡើងទេ ទាំងពួកកុសលធម៌ ក៏នឹងមិនកើតឡើងដែរ ។

[ ១៤៦ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកអសញ្ញសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើងក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកសត្វអ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ១៤៧ ] ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ

និងរបស់ពួកសត្វដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា និងរបស់ពួកអសញ្ញសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកសត្វអ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ១៤៨ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ពួកកុសលធម៌របស់បុគ្គលនោះ កើតឡើងឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ ធ្លាប់កើតឡើងហើយ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកកុសលធម៌របស់ពួកសត្វនោះ មិនកើតឡើងទេ ឯពួកអកុសលធម៌ របស់ពួកសត្វនោះ ធ្លាប់កើតឡើងហើយ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ១៤៩ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ពួកកុសលធម៌ របស់បុគ្គល

នោះ កើតឡើងឬ ។ ពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ ធ្លាប់កើតឡើងហើយ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ ធ្លាប់កើតឡើងហើយ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ១៥០ ] ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយឬ ។ អើ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើងឬ ។ ពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ ធ្លាប់កើតឡើងហើយ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែអកុសលធម៌ របស់ពួកជននោះ មិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ ធ្លាប់កើតឡើងហើយ ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ទាំងពួកអកុសលធម៌ ក៏កើតឡើងដែរ ។

[ ១៥១ ] ពួកកុសលធម៌ កើតឡើង ក្នុងទីណា ។បេ។

[ ១៥២ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ

ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើងក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកជននោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ១៥៣ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើងក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ១៥៤ ] ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើងក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។ ពួក

អព្យាកតធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ទាំងពួកអកុសលធម៌ ក៏កើតឡើងដែរ ។

[ ១៥៥ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយឬ ។ ធ្លាប់កើតឡើងហើយ ។ មួយវិញទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ មិនមានទេ ។

[ ១៥៦ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអព្យាកតធម៌របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយឬ ។ ធ្លាប់កើតឡើងហើយ ។ មួយវិញទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ មិនមានទេ ។

[ ១៥៧ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយឬ ។ ធ្លាប់កើតឡើងហើយ ។ មួយវិញទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ មិនមានទេ ។

[ ១៥៨ ] ពួកកុសលធម៌ មិនកើតឡើង ក្នុងទីណា ។បេ។

[ ១៥៩ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា

ពួកអកុសលធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកសត្វទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកសត្វនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក៏មិនមែន កាលបើចិត្តទីពីររបស់ពួកសុទ្ធាវាសសត្វ កាលប្រព្រឹត្តទៅ ឯពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនកើតឡើង ក្នុងទីនោះទេ ទាំងពួកអកុសលធម៌ ក៏មិនធ្លាប់កើតឡើងហើយដែរ ។ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ១៦០ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកសត្វនោះ កាលចូលទៅកាន់សុទ្ធាវាស មិនកើតឡើង ក្នុងទីនោះទេ ទាំងពួកអព្យាកតធម៌ ក៏មិនធ្លាប់កើតឡើងហើយដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ១៦១ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទី

ណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកសត្វនោះ កាលចូលទៅកាន់សុទ្ធាវាស មិនកើតឡើង ក្នុងទីនោះ ទាំងពួកអព្យាកតធម៌ ក៏មិនធ្លាប់កើតឡើងហើយដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ១៦២ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ ពួកជន នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ពួកកុសលធម៌ របស់ពួកជននោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើងទេ ឯពួកកុសលធម៌ របស់ពួកជននោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ក្រៅពីនេះ ទាំងពួកអកុសលធម៌ ក៏នឹងកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ នឹងកើតឡើង ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកកុសល

ក្នុងភង្គក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើងទេ ឯពួកអកុសលធម៌ របស់ពួកជននោះ នឹងកើតឡើង ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ១៦៣ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងឬ ។ ពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ នឹងកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ នឹងកើតឡើង ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ១៦៤ ] ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើងឬ ។ ពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ នឹងកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ មិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ នឹងកើតឡើង ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ទាំងពួកអកុសលធម៌ ក៏កើតឡើងដែរ ។

[ ១៦៥ ] ពួកកុសលធម៌ កើតឡើង ក្នុងទីណា ។បេ។

[ ១៦៦ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកជននោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ កើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឯពួកកុសលធម៌ របស់ពួកជននោះ ទើបកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ក្រៅពីនេះ ទាំងពួកអកុសលធម៌ ក៏នឹងកើតឡើងដែរ ។ មយ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ នឹងកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកជននោះ នឹងកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ១៦៧ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។ មយ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌

របស់ពួកអសញ្ញសត្វទាំងអស់នោះ នឹងកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកកុសលធម៌របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ នឹងកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ១៦៨ ] ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើងក្នុងទីណា ពួកអព្យាកតធម៌របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌របស់ពួកអសញ្ញសត្វទាំងអស់នោះ នឹងកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអកុសលធម៌របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ នឹងកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយទាំងពួកអកុសលធម៌ ក៏កើតឡើងដែរ ។

[ ១៦៩ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងដែរឬ ។ ពួកកុសលធម៌របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក៏មិនមែន

ឯពួកកុសលធម៌ របស់ពួកព្រះអរហន្ត ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និង របស់ពួកជន ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណានោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្តនោះទេ ទាំងពួកអកុសលធម៌ ក៏នឹងមិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងទេឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តនោះទេ តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកព្រះអរហន្ត ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកជនដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងមិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្តនោះទេ ទាំងពួកកុសលធម៌ ក៏មិនកើតឡើងដែរ ។

[ ១៧០ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងដែរឬ ។ ពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជន អ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ មិនកើតឡើងទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកកុសលធម៌ របស់

បុគ្គលនោះ មិនកើតឡើងឬ ។ អើ ។

[ ១៧១ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកជនអ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ មិនកើតឡើងទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនកើតឡើងដែរ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងទេឬ ។ អើ ។

[ ១៧២ ] ពួកកុសលធម៌ មិនកើតឡើង ក្នុងទីណា ។បេ។

[ ១៧៣ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកព្រះអរហន្ត ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកជនដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា និងពួកអសញ្ញសត្វនោះ មិនកើតឡើង ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តនោះ ទាំងពួកអកុសលធម៌ ក៏នឹង

មិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ នឹងមិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកព្រះអរហន្ត ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកជនដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា និងរបស់ពួកអសញ្ញសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តនោះទេ ទាំងពួកកុសលធម៌ ក៏មិនកើតឡើងដែរ ។

[ ១៧៤ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ មិនកើតឡើងក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកសត្វអ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ មិនកើតឡើង ក្នុងទីនោះទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ១៧៥ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា

ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកសត្វអ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ មិនកើតឡើង ក្នុងទីនោះទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ១៧៦ ] ពួកកុសលធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ ពួកកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកជន ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណានោះ ធ្លាប់កើតឡើងហើយ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើងទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ ធ្លាប់កើតឡើងហើយ ទាំងពួកអកុសលធម៌ ក៏នឹងកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយឬ ។ អើ ។

[ ១៧៧ ] ពួកកុសលធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ ពួកកុសលធម៌ របស់ពួកជនអ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ ធ្លាប់កើតឡើងហើយ តែពួកអព្យា-

កតធម៌ របស់ពួកជននោះ នឹងមិនកើតឡើងទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ ធ្លាប់កើតឡើងហើយ ទាំងពួកអព្យាកតធម៌ ក៏នឹងកើតឡើងដែរ ។ មយ៉ាងទៀត ពួកអព្យាកតធម៌របស់បុគ្គលណា នឹងកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយឬ ។ អើ ។

[ ១៧៨ ] ពួកអកុសលធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ ពួកអកុសលធម៌ របស់ពួកជនអ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ ធ្លាប់កើតឡើងហើយ តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនកើតឡើងទេ ឯពួកអកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ ធ្លាប់កើតឡើងហើយ ទាំងពួកអព្យាកតធម៌ ក៏នឹងកើតឡើងដែរ ។ មយ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយឬ ។ អើ ។

[ ១៧៩ ] ពួកកុសលធម៌ ធ្លាប់កើតឡើងហើយ ក្នុងទីណា ។បេ។

[ ១៨០ ] ពួកកុសលធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកជនដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណានោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ទាំងពួក

*អកុសលធម៌ ក៏នឹងកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ កាលចិត្តទីពីររបស់ពួកសុទ្ធាវាសសត្វ កាលប្រព្រឹត្តទៅ ពួកអកុសលធម៌ របស់ពួកសត្វនោះ នឹងកើតឡើង ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកសត្វនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ នឹងកើតឡើង ក្នុងទីនោះ ទាំងពួកកុសលធម៌ ក៏ធ្លាប់កើតឡើងហើយដែរ ។*

*[ ១៨១ ] ពួកកុសលធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកជនអ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ទាំងពួកអព្យាកតធម៌ ក៏នឹងកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កាលប្រព្រឹត្តទៅ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វនោះ នឹងកើតឡើង ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនធ្លាប់កើតឡើងហើយ*

ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ នឹងកើតឡើង ក្នុងទីនោះ ទាំងពួកកុសលធម៌ក៏ធ្លាប់កើតឡើងហើយដែរ ។

[ ១៨២ ] ពួកអកុសលធម៌ របស់បុគ្គលណា ធ្លាប់កើតឡើងហើយក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកជន អ្នកព្រមព្រៀងដោយបច្ឆិមចិត្តនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ ធ្លាប់កើតឡើងហើយ ក្នុងទីនោះ ទាំងពួកអព្យាកតធម៌ ក៏នឹងកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ ធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កាលប្រព្រឹត្តទៅ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វនោះ នឹងកើតឡើង ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកជននោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ គឺពួកសត្វចតុ-វោការ នឹងកើតឡើង ក្នុងទីនោះ ទាំងពួកអកុសលធម៌ ក៏ធ្លាប់កើតឡើងហើយដែរ ។

[ ១៨៣ ] ពួកកុសលធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ មិនមានទេ ។

ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយឬ ។ ធ្លាប់កើតឡើងហើយ ។

[ ១៨៤ ] ពួកកុសលធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ មិនមានទេ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកកុសលធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយឬ ។ ធ្លាប់កើតឡើងហើយ ។

[ ១៨៥ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ មិនមានទេ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយឬ ។ ធ្លាប់កើតឡើងហើយ ។

[ ១៨៦ ] ពួកកុសលធម៌ មិនធ្លាប់កើតឡើងហើយ ក្នុងទីណា ។បេ។

[ ១៨៧ ] ពួកកុសលធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ កាលចិត្តទីពីររបស់ពួកសុទ្ធាវាសសត្វ កាលប្រព្រឹត្តទៅ ពួកកុសលធម៌ របស់ពួកសត្វនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌

របស់ពួកអសញ្ញសត្វនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះទេ ទាំងពួកអកុសលធម៌ ក៏នឹងមិនកើតឡើងដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកជន ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណានោះ នឹងមិនកើតឡើង ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកជននោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកអសញ្ញសត្វនោះ ក៏នឹងមិនកើតឡើង ក្នុងទីនោះទេ ទាំងពួកកុសលធម៌ ក៏មិនធ្លាប់កើតឡើងហើយដែរ ។

[ ១៨៨ ] ពួកកុសលធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ នឹងកើតឡើង ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនធ្លាប់កើតឡើងហើយ ក្នុងទីនោះឬ ។ ធ្លាប់កើតឡើងហើយ ។

[ ១៨៩ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនធ្លាប់កើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ នឹងកើតឡើង ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនធ្លាប់កើត

ឡើងហើយ ក្នុងទីនោះឬ ។ ធ្លាប់កើតឡើងហើយ ។

ឧប្បាទវារៈ ចប់

[ ១៩០ ] ពួកកុសលធម៌ របស់បុគ្គលណា រលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា រលត់ ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ មិនមែនទេ ។

[ ១៩១ ] ពួកកុសលធម៌ របស់បុគ្គលណា រលត់ ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ ពួកកុសលធម៌ របស់ពួកជននោះ រលត់ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ក្នុងអរូបភព តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ទេ ឯពួកកុសលធម៌ របស់ពួកជននោះ រលត់ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអព្យាកតធម៌ ក៏រលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ កាលច្យុត រលត់ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងបវត្តិកាល តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ រលត់ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកកុសលធម៌ ក៏រលត់ដែរ ។

[ ១៩២ ] ពួកអកុសលធម៌ របស់បុគ្គលណា រលត់ ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ រលត់ ក្នុងភង្គក្ខណៈនៃអកុសលទាំងឡាយ ក្នុងអរូបភព តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ទេ ឯពួកអកុសលធម៌ របស់ពួកជននោះ រលត់ ក្នុងភង្គក្ខណៈនៃអកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអព្យាកតធម៌ ក៏រលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ កាលច្យុត រលត់ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងបវត្តិកាល តែពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ រលត់ ក្នុងភង្គក្ខណៈនៃអកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអកុសលធម៌ ក៏រលត់ដែរ ។

[ ១៩៣ ] ពួកកុសលធម៌ រលត់ ក្នុងទីណា ពួកអកុសលធម៌ រលត់ ក្នុងទីនោះដែរឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ រលត់ ក្នុងទីណា ពួកកុសលធម៌ រលត់ ក្នុងទីនោះដែរឬ ។ អើ ។

[ ១៩៤ ] ពួកកុសលធម៌ រលត់ ក្នុងទីណា ពួកអព្យាកតធម៌ រលត់ ក្នុងទីនោះដែរឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ រលត់ ក្នុងទីណា ពួកកុសលធម៌ រលត់ ក្នុងទីនោះដែរឬ ។ ពួកអព្យាកតធម៌ រលត់ ក្នុងទីនោះ គឺក្នុងអសញ្ញសត្វ តែពួកកុសលធម៌ មិនរលត់ ក្នុងទីនោះទេ ឯពួកអព្យា-កតធម៌ រលត់ ក្នុងទីនោះ គឺក្នុងចតុវោការភព និងបញ្ចវោការភព ទាំងពួក

កុសលធម៌ ក៏រលត់ដែរ ។

[ ១៩៥ ] ពួកអកុសលធម៌ រលត់ ក្នុងទីណា ពួកអព្យាកតធម៌ រលត់ ក្នុងទីនោះដែរឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ រលត់ ក្នុងទីណា ពួកអកុសលធម៌ រលត់ ក្នុងទីនោះដែរឬ ។ ពួកអព្យាកតធម៌ រលត់ ក្នុងទីនោះ គឺក្នុងអសញ្ញសត្វ តែពួកអកុសលធម៌ មិនរលត់ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ រលត់ ក្នុងទីនោះ គឺក្នុងចតុវោការភព និងបញ្ចវោការភព ទាំងពួកកុសលធម៌ ក៏រលត់ដែរ ។

[ ១៩៦ ] ពួកកុសលធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។

[ ១៩៧ ] ពួកកុសលធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ ក្នុងទីនោះដែរឬ ។ ពួកកុសលធម៌ របស់ពួកជននោះ រលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ក្នុងអរូបភព តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះទេ ឯពួកកុសលធម៌ របស់ពួកជននោះ រលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអព្យាកតធម៌ ក៏រលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ ក្នុងទីនោះដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកជន

ទាំងអស់នោះ កាលច្យុត រលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាស
ចាកកុសល ក្នុងបវត្តិកាល តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់
ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ រលត់ ក្នុងទីនោះ ក្នុង
ភង្គក្ខណៈនៃកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកកុសលធម៌ ក៏
រលត់ដែរ ។

[ ១៩៨ ] ពួកអកុសលធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួក
អព្យាកតធម៌ របស់បុគ្គលនោះ រលត់ ក្នុងទីនោះដែរឬ ។ ពួកអកុសលធម៌
របស់ពួកជននោះ រលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃអកុសលទាំងឡាយ
ក្នុងអរូបភព តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះទេ
ឯពួកអកុសលធម៌ របស់ពួកជននោះ រលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃ
អកុសលទាំងឡាយ ក្នុងបញ្ចវោការភព ទាំងពួកអព្យាកតធម៌ ក៏រលត់ដែរ ។
ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួក
អកុសលធម៌ របស់បុគ្គលនោះ រលត់ ក្នុងទីនោះដែរឬ ។ ពួកអព្យាកតធម៌
របស់ពួកជនទាំងអស់នោះ កាលច្យុត រលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃ
ចិត្តដែលប្រាសចាកអកុសល ក្នុងបវត្តិកាល តែពួកអកុសលធម៌ របស់ពួក
ជននោះ មិនរលត់ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ
រលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃអកុសលទាំងឡាយ ក្នុងបញ្ចវោការភព
ទាំងពួកអកុសលធម៌ ក៏រលត់ដែរ ។

[ ១៩៩ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ ពួកអកុសលធម៌

របស់បុគ្គលនោះ មិនរលត់ដែរឬ ។ ពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងភង្គក្ខណៈនៃអកុសលទាំងឡាយទេ តែពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនរលត់ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកកុសល និងចិត្តដែលប្រាសចាកអកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត ទាំងពួកអកុសលធម៌ ក៏មិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ដែរឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយទេ តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនរលត់ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកអកុសល និងចិត្តដែលប្រាសចាកកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត ទាំងពួកកុសលធម៌ ក៏មិនរលត់ដែរ ។

[ ២០០ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ដែរឬ ។ ពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ កាលច្យុត មិនរលត់ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងបវត្តិកាល តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ កាលកើតឡើង មិនរលត់ ក្នុងភង្គក្ខណៈនៃអកុសលទាំងឡាយ ក្នុងអរូបភព ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុង

បវត្តិកាល ទាំងពួកអព្យាកតធម៌ ក៏មិនរលត់ដែរ ។ មួយវិញទៀត ពួកអព្យា-កតធម៌ របស់បុគ្គលណា មិនរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ក្នុងអរូបភពទេ តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ ក៏មិនមែន ឯពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ កាលកើតឡើង មិនរលត់ ក្នុងភង្គក្ខណៈនៃអកុសលទាំងឡាយ ក្នុងអរូបភព ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ទាំងពួកកុសលធម៌ ក៏មិនរលត់ដែរ ។

[ ២០១ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ កាលច្យុត មិនរលត់ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងបវត្តិកាល តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ កាលកើតឡើង មិនរលត់ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ក្នុងអរូបភព ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ទាំងពួកអព្យាកតធម៌ ក៏មិនរលត់ដែរ ។ មួយវិញទៀត ពួកអព្យា-កតធម៌ របស់បុគ្គលណា មិនរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ឬ ។ ពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក្នុងភង្គក្ខណៈនៃអកុសលទាំងឡាយ ក្នុងអរូបភពទេ តែពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ ក៏មិនមែន ឯពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ កាលកើតឡើង មិនរលត់ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ក្នុងអរូបភព ក្នុង

ឧប្បាទក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ទាំងពួកអកុសលធម៌ ក៏មិនរលត់ដែរ ។

[ ២០២ ] ពួកកុសលធម៌ មិនរលត់ ក្នុងទីណា ពួកអកុសលធម៌ មិនរលត់ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ មិនរលត់ ក្នុងទីណា ពួកកុសលធម៌ មិនរលត់ ក្នុងទីនោះឬ ។ អើ ។

[ ២០៣ ] ពួកកុសលធម៌ មិនរលត់ ក្នុងទីណា ពួកអព្យាកតធម៌ មិនរលត់ ក្នុងទីនោះឬ ។ រលត់ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ មិនរលត់ ក្នុងទីណា ពួកកុសលធម៌ មិនរលត់ ក្នុងទីនោះឬ ។ មិនមានទេ ។

[ ២០៤ ] ពួកអកុសលធម៌ មិនរលត់ ក្នុងទីណា ពួកអព្យាកតធម៌ មិនរលត់ ក្នុងទីនោះឬ ។ រលត់ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ មិនរលត់ ក្នុងទីណា ពួកអកុសលធម៌ មិនរលត់ ក្នុងទីនោះឬ ។ មិនមានទេ ។

[ ២០៥ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃអកុសលទាំងឡាយទេ តែពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះ ក៏មិនមែនឯពួកកុសលធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកកុសល និងចិត្តដែលប្រាសចាកអកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត ទាំងពួកអកុសលធម៌ ក៏មិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ ក្នុងទីណា ពួកកុសលធម៌របស់បុគ្គលនោះ មិនរលត់ ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ

មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយទេ តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្ត ដែលប្រាសចាកអកុសល និងចិត្តដែលប្រាសចាកកុសល ក្នុងឧប្បាទក្ខណៈ នៃចិត្ត ទាំងពួកកុសលធម៌ ក៏មិនរលត់ដែរ ។

[ ២០៦ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ កាលច្យុត មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈ នៃចិត្តដែលប្រាសចាកកុសល ក្នុងបវត្តិកាល តែពួកអព្យាកតធម៌របស់ពួកជននោះ មិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ កាលកើតឡើង មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃអកុសលទាំងឡាយ ក្នុងអរូបភព ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ទាំងពួកអព្យាកតធម៌ ក៏មិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ក្នុងអរូបភពទេ តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ កាលកើតឡើង មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃអកុសលទាំងឡាយ ក្នុងអរូបភព ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ទាំងពួក

កុសលធម៌ ក៏មិនរលត់ដែរ ។

[ ២០៧ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ កាលច្យុត មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងបវត្តិកាល តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ កាលកើតឡើង មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ក្នុងអរូបភព ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ទាំងពួកអព្យាកតធម៌ ក៏មិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃអកុសលទាំងឡាយ ក្នុងអរូបភព តែពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ កាលកើតឡើង មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ក្នុងអរូបភព ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបវត្តិកាល ទាំងពួកអកុសលធម៌ ក៏មិនរលត់ដែរ ។

[ ២០៨ ] ពួកកុសលធម៌ របស់បុគ្គលណា ធ្លាប់រលត់ហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ហើយឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា ធ្លាប់រលត់ហើយ ពួកកុសលធម៌ របស់បុគ្គល

នោះ រលត់ហើយឬ ។ អើ ។

[ ២០៩ ] ពួកកុសលធម៌ របស់បុគ្គលណា ធ្លាប់រលត់ហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ហើយឬ ។ អើ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា ធ្លាប់រលត់ហើយ ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ហើយឬ ។ អើ ។

[ ២១០ ] ពួកអកុសលធម៌ របស់បុគ្គលណា ធ្លាប់រលត់ហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ហើយឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា ធ្លាប់រលត់ហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ហើយឬ ។ អើ ។

[ ២១១ ] ពួកកុសលធម៌ រលត់ហើយ ក្នុងទីណា ពួកអកុសលធម៌ រលត់ហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ រលត់ហើយ ក្នុងទីណា ពួកកុសលធម៌ រលត់ហើយ ក្នុងទីនោះឬ ។ អើ ។

[ ២១២ ] ពួកកុសលធម៌ រលត់ហើយ ក្នុងទីណា ពួកអព្យាកតធម៌ រលត់ហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ រលត់ហើយ ក្នុងទីណា ពួកកុសលធម៌ រលត់ហើយ ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ រលត់ហើយ ក្នុងទីនោះ គឺក្នុងអសញ្ញសត្វ តែពួកកុសលធម៌ មិនរលត់ហើយ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ រលត់ហើយ ក្នុងទីនោះ គឺក្នុងចតុវោការភព និងបញ្ចវោការភព ទាំងពួកកុសលធម៌ ក៏រលត់ហើយដែរ ។

[ ២១៣ ] ពួកអកុសលធម៌ រលត់ហើយ ក្នុងទីណា ពួកអព្យាកតធម៌

រលត់ហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ រលត់ហើយ ក្នុងទីណា ពួកអកុសលធម៌ រលត់ហើយ ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ រលត់ហើយ ក្នុងទីនោះ គឺក្នុងអសញ្ញសត្វ តែពួកអកុសលធម៌ មិនរលត់ហើយ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ រលត់ហើយ ក្នុងទីនោះ គឺក្នុងចតុ-វោការភព និងបញ្ចវោការភព ទាំងពួកអកុសលធម៌ ក៏រលត់ហើយដែរ ។

[ ២១៤ ] ពួកកុសលធម៌ របស់បុគ្គលណា ធ្លាប់រលត់ហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា ធ្លាប់រលត់ហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះឬ ។ កាលអកុ-សលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកអកុសលធម៌ របស់ពួកសត្វនោះ រលត់ហើយ ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកសត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ រលត់ហើយ ក្នុងទីនោះ ទាំងពួកកុសលធម៌ ក៏រលត់ហើយដែរ ។

[ ២១៥ ] ពួកកុសលធម៌ របស់បុគ្គលណា ធ្លាប់រលត់ហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា ធ្លាប់រលត់ហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកអព្យាកតធម៌ របស់ពួក

*អសញ្ញសត្វនោះ រលត់ហើយ ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកសត្វនោះ មិនធ្លាប់រលត់ហើយ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ រលត់ហើយ ក្នុងទីនោះ ទាំងពួកកុសលធម៌ ក៏រលត់ហើយដែរ ។*

*[ ២១៦ ] ពួកអកុសលធម៌ របស់បុគ្គលណា រលត់ហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វនោះ រលត់ហើយ ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកសត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ រលត់ហើយ ក្នុងទីនោះ ទាំងពួកអកុសលធម៌ ក៏រលត់ហើយដែរ ។*

*[ ២១៧ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ហើយឬ ។ មិនមានទេ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយឬ ។ មិនមានទេ ។*

*[ ២១៨ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ហើយឬ ។ មិនមានទេ ។ ម្យ៉ាងទៀត*

ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយឬ ។ មិនមានទេ ។

[ ២១៩ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ហើយឬ ។ មិនមានទេ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយឬ ។ មិនមានទេ ។

[ ២២០ ] ពួកកុសលធម៌ មិនរលត់ហើយ ក្នុងទីណា ពួកអកុសលធម៌ មិនរលត់ហើយ ក្នុងទីនោះដែរឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ មិនរលត់ហើយ ក្នុងទីណា ពួកកុសលធម៌ មិនរលត់ហើយ ក្នុងទីនោះឬ ។ អើ ។

[ ២២១ ] ពួកកុសលធម៌ មិនរលត់ហើយ ក្នុងទីណា ពួកអព្យាកតធម៌ មិនរលត់ហើយ ក្នុងទីនោះឬ ។ រលត់ហើយ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ មិនរលត់ហើយ ក្នុងទីណា ពួកកុសលធម៌ មិនរលត់ហើយ ក្នុងទីនោះឬ ។ មិនមានទេ ។

[ ២២២ ] ពួកអកុសលធម៌ មិនរលត់ហើយ ក្នុងទីណា ពួកអព្យាកតធម៌ មិនរលត់ហើយ ក្នុងទីនោះឬ ។ រលត់ហើយ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ មិនរលត់ហើយ ក្នុងទីណា ពួកអកុសលធម៌ មិនរលត់ហើយ ក្នុងទីនោះឬ ។ មិនមានទេ ។

[ ២២៣ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា

ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ កាលអកុសលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកកុសលធម៌ របស់ពួកសត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេ តែពួកអកុសលធម៌ របស់ពួកសត្វនោះ មិនរលត់ហើយ ក្នុងទីនោះ ក៏មិនមែន កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ឯពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេ ទាំងពួកអកុសលធម៌ ក៏រលត់ហើយដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ អើ ។

[ ២២៤ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេ តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនរលត់ហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកសត្វនោះ កាលចូលទៅកាន់សុទ្ធាវាស មិនរលត់ហើយ ក្នុងទីនោះទេ ទាំងពួកអព្យាកតធម៌ ក៏មិនរលត់ហើយដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ អើ ។

[ ២២៥ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។

កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកអកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេ តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនរលត់ហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកសត្វនោះ កាលចូលទៅកាន់សុទ្ធាវាស មិនរលត់ហើយ ក្នុងទីនោះ ទេ ទាំងពួកអព្យាកតធម៌ ក៏មិនរលត់ហើយដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ អើ ។

[ ២២៦ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ដែរឬ ។ ពួកកុសលធម៌ របស់ពួកជនដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ នឹងរលត់ តែពួកកុសលធម៌របស់ពួកជននោះ នឹងមិនរលត់ទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ នឹងរលត់ ទាំងពួកអកុសលធម៌ ក៏នឹងរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ដែរឬ ។ អើ ។

[ ២២៧ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងរលត់ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ដែរឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ដែរ ឬ ។ ពួកអព្យាកតធម៌ របស់ពួកព្រះអរហន្តនោះ នឹងរលត់ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ តែពួកកុសលធម៌ របស់ពួកព្រះអរហន្តនោះ នឹងមិនរលត់ទេ

ឯពួកអព្យាកតធម៌ របស់ពួកជននោះ ក្រៅពីនេះ នឹងរលត់ ទាំងពួកកុសលធម៌ ក៏នឹងរលត់ដែរ ។

[ ២២៨ ] ពួកអកុសលធម៌ របស់បុគ្គលណា នឹងរលត់ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ដែរឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកជនដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណានោះ នឹងរលត់ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ ក្រៅពីនេះ នឹងរលត់ ទាំងពួកអកុសលធម៌ ក៏នឹងរលត់ដែរ ។

[ ២២៩ ] ពួកកុសលធម៌ នឹងរលត់ ក្នុងទីណា ។បេ។

[ ២៣០ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកជននោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ នឹងរលត់ ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ នឹងរលត់ ក្នុងទីនោះ ទាំងពួកអកុសលធម៌ ក៏នឹងរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ នឹង

វលេត់ក្នុងទីនោះ ឬ ។ អើ ។

[ ២៣១ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកព្រះអរហន្ត និងរបស់ពួកអសញ្ញសត្វនោះ នឹងរលត់ ក្នុងទីនោះ ក្នុងកង្ខណៈនៃមគ្គដ៏ប្រសើរ តែពួកកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ក្នុងទីនោះទេ ឯពួកអព្យាកតធម៌របស់ពួកសត្វនោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ នឹងរលត់ ក្នុងទីនោះ ទាំងពួកកុសលធម៌ ក៏នឹងរលត់ដែរ ។

[ ២៣២ ] ពួកអកុសលធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកអសញ្ញសត្វនោះ ដែលនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងរលត់ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ នឹងរលត់ ក្នុងទីនោះ ទាំងពួកអកុសលធម៌ ក៏នឹងរលត់ដែរ ។

[ ២៣៣ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ឬ ។ អើ ។ មួយវិញទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ នឹងមិនរលត់ទេ តែពួកកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកព្រះអរហន្តនោះ នឹងមិនរលត់ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ ទាំងពួកកុសលធម៌ ក៏នឹងមិនរលត់ដែរ ។

[ ២៣៤ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកអព្យាកតធម៌របស់បុគ្គលនោះ នឹងមិនរលត់ឬ ។ ពួកកុសលធម៌ របស់ពួកព្រះអរហន្តនោះ នឹងមិនរលត់ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ តែពួកអព្យាកតធម៌ របស់ពួកព្រះអរហន្តនោះ នឹងមិនរលត់ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកព្រះអរហន្តនោះ នឹងមិនរលត់ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្តទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនរលត់ដែរ ។ មួយវិញទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ដែរឬ ។ អើ ។

[ ២៣៥ ] ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ឬ ។ ពួកអកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកជននោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងមិនរលត់ទេ តែពួក

អព្យាកតធម៌របស់ពួកជននោះ នឹងមិនរលត់ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្តទេ ទាំងពួកអព្យា-កតធម៌ ក៏នឹងមិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ឬ ។ អើ ។

[ ២៣៦ ] ពួកកុសលធម៌ នឹងមិនរលត់ ក្នុងទីណា ។បេ។

[ ២៣៧ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកកុសលធម៌របស់បុគ្គលនោះ នឹងមិនរលត់ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ ដែលនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ នឹងមិនរលត់ ក្នុងទីនោះទេ តែពួកកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកព្រះអរហន្ត និងរបស់ពួកអសញ្ញសត្វនោះ នឹងមិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ ទាំងពួកកុសលធម៌ ក៏នឹងមិនរលត់ដែរ ។

[ ២៣៨ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកព្រះអរហន្ត និងរបស់ពួកអសញ្ញសត្វនោះ នឹងមិនរលត់ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ តែពួកអព្យាកតធម៌ របស់

ពួកជនទោះ នឹងមិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជនទោះ នឹងមិនរលត់ ក្នុងទីនោះ ក្នុងកង្ខណៈនៃបច្ឆិមចិត្តទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនរលត់ដែរ ។ មួយវិញទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះឬ ។ អើ ។

[ ២៣៩ ] ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះឬ ។ ពួកអកុ-សលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកអសញ្ញសត្វ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណានោះ នឹងមិនរលត់ ក្នុងទីនោះទេ តែពួកអព្យាកតធម៌ របស់ពួកជនទោះ នឹងមិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកជនទោះ នឹងមិនរលត់ ក្នុងទីនោះ ក្នុងកង្ខណៈនៃបច្ឆិមចិត្ត ទាំងពួកអព្យាកតធម៌ ក៏នឹងមិនរលត់ដែរ ។ មួយវិញទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះឬ ។ អើ ។

[ ២៤០ ] ពួកកុសលធម៌ របស់បុគ្គលណា រលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ហើយឬ ។ អើ ។ មួយវិញទៀត ពួកអកុសលធម៌ របស់បុគ្គលណា រលត់ហើយ ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់

និរោធ និងពួកអសញ្ញសត្វ រលត់ហើយ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាក កុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិន រលត់ទេ ឯពួកអកុសលធម៌ របស់ពួកជននោះ រលត់ហើយ ក្នុងភង្គក្ខណៈ នៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏រលត់ដែរ ។

[ ២៤១ ] ពួកកុសលធម៌ របស់បុគ្គលណា រលត់ ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ហើយឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ហើយ ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ដែរ ឬ ។ ពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់ និរោធ និងពួកអសញ្ញសត្វ រលត់ហើយ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាក កុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិន រលត់ទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ រលត់ហើយ ក្នុងភង្គក្ខណៈ នៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏រលត់ដែរ ។

[ ២៤២ ] ពួកអកុសលធម៌ របស់បុគ្គលណា រលត់ ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ហើយឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ហើយ ពួកអកុសលធម៌របស់បុគ្គលនោះ រលត់ដែរ ឬ ។ ពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់ និរោធ និងពួកអសញ្ញសត្វ រលត់ហើយ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាក អកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ រលត់ហើយ ក្នុង

កង្គក្ខណៈនៃអកុសលទាំងឡាយ ទាំងពួកអកុសលធម៌ ក៏រលត់ដែរ ។

[ ២៨៣ ] ពួកកុសលធម៌ រលត់ ក្នុងទីណា ។បេ។

[ ២៨៤ ] ពួកកុសលធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះឬ ។ អើ ។ មួយ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា រលត់ហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ រលត់ហើយ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្ត ដែលប្រាសចាកកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកកុសលធម៌របស់ពួកជននោះ មិនរលត់ ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកជននោះ រលត់ហើយ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏រលត់ដែរ ។

[ ២៨៥ ] ពួកកុសលធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះឬ ។ អើ ។ មួយ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ គឺពួកអសញ្ញសត្វ រលត់ហើយ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ រលត់ហើយ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ទាំងពួក

កុសលធម៌ ក៏រលត់ដែរ ។

[ ២៤៦ ] ពួកអកុសលធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ រលត់ហើយ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកសត្វនោះ មិនរលត់ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ រលត់ហើយ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃអកុសលទាំងឡាយ ទាំងពួកអកុសលធម៌ ក៏រលត់ដែរ ។

[ ២៤៧ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ដែរឬ ។ មិនមានទេ ។

[ ២៤៨ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ទេឬ ។ មិនមានទេ ។

[ ២៤៩ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ ពួក

អព្យាកតធម៌របស់បុគ្គលនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។ ម្យ៉ាង ទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ទេឬ ។ មិនមានទេ ។

[ ២៥០ ] ពួកកុសលធម៌ មិនរលត់ ក្នុងទីណា ។បេ។

[ ២៥១ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកសត្វទាំងអស់នោះ មិនរលត់ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកសត្វនោះ មិនរលត់ហើយ ក្នុងទីនោះ ក៏មិនមែន កាលចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ឯពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនរលត់ក្នុងទីនោះទេ ទាំងពួកអកុសលធម៌ ក៏មិនរលត់ហើយដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ ក្នុងទីនោះឬ ។ អើ ។

[ ២៥២ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វនោះ មិនរលត់ហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកសត្វនោះ កាលចូលទៅកាន់សុទ្ធាវាស មិនរលត់ ក្នុង

ទីនោះទេ ទាំងពួកអព្យាកតធម៌ ក៏មិនរលត់ហើយដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ ក្នុងទីនោះឬ ។ អើ ។

[ ២៥៣ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វនោះ មិនរលត់ហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកសត្វនោះ កាលចូលទៅកាន់សុទ្ធាវាស មិនរលត់ ក្នុងទីនោះទេ ទាំងពួកអព្យាកតធម៌ ក៏មិនរលត់ហើយដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ ក្នុងទីនោះឬ ។ អើ ។

[ ២៥៤ ] ពួកកុសលធម៌ របស់បុគ្គលណា រលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ដែរឬ ។ ពួកកុសលធម៌ របស់ពួកជននោះ ដែលនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ រលត់ក្នុងភង្គក្ខណៈនៃចិត្តនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ទេ ឯពួកកុសលធម៌ របស់ពួកជននោះ រលត់ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ក្រៅពីនេះ ទាំងពួកអកុសលធម៌ ក៏នឹងរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងរលត់ ពួកកុសលធម៌ របស់បុគ្គល

នោះ រលត់ដែរឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ នឹងរលត់ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ទេ ឯពួកអកុសលធម៌ របស់ពួកជននោះ នឹងរលត់ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏រលត់ដែរ ។

[ ២៥៥ ] ពួកកុសលធម៌ របស់បុគ្គលណា រលត់ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ឬ ។ អើ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ នឹងរលត់ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ នឹងរលត់ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏រលត់ដែរ ។

[ ២៥៦ ] ពួកអកុសលធម៌ របស់បុគ្គលណា រលត់ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ដែរឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ នឹងរលត់ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ

មិនរលត់ទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ នឹងរលត់ ក្នុងភង្គក្ខណៈ នៃអកុសលទាំងឡាយ ទាំងពួកអកុសលធម៌ ក៏រលត់ដែរ ។

[ ២៥៧ ] ពួកកុសលធម៌ រលត់ ក្នុងទីណា ។បេ។

[ ២៥៨ ] ពួកកុសលធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកជននោះ ដែលនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ រលត់ក្នុងភង្គក្ខណៈនៃចិត្តនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះទេ ពួកកុសលធម៌ របស់ពួកជននោះ រលត់ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ក្រៅពីនេះ ទាំងពួកអកុសលធម៌ ក៏នឹងរលត់ដែរ ។ មា្យ៉ងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ នឹងរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកជននោះ នឹងរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏រលត់ដែរ ។

[ ២៥៩ ] ពួកកុសលធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ក្នុងទីនោះឬ ។ អើ ។ មា្យ៉ងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកកុសលធម៌

របស់បុគ្គលនោះ រលត់ ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ នឹងរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ នឹងរលត់ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏រលត់ដែរ ។

[ ២៦០ ] ពួកអកុសលធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ នឹងរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ នឹងរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃអកុសលទាំងឡាយ ទាំងពួកអកុសលធម៌ ក៏រលត់ដែរ ។

[ ២៦១ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ដែរឬ ។ ពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនរលត់ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួក

អកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកព្រះអរហន្ត ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកជនដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា មិនរលត់ក្នុងឧប្បាទក្ខណៈនៃចិត្តនោះទេ ទាំងពួកអកុសលធម៌ ក៏នឹងមិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ដែរឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ នឹងមិនរលត់ ក្នុងភង្គក្ខណៈនៃចិត្តនោះ តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកព្រះអរហន្ត ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកជនដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណានោះ នឹងមិនរលត់ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះទេ ទាំងពួកកុសលធម៌ ក៏មិនរលត់ដែរ ។

[ ២៦២ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ដែរឬ ។ ពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនរលត់ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនរលត់ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្តទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹង

មិនរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ដែរឬ ។ អើ ។

[ ២៦៣ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ទេឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនរលត់ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ជននោះ នឹងមិនរលត់ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្តទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនរលត់ដែរ ។ មួយវិញទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ទេឬ ។ អើ ។

[ ២៦៤ ] ពួកកុសលធម៌ មិនរលត់ ក្នុងទីណា ។បេ។

[ ២៦៥ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះឬទេ ។ ពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកព្រះអរហន្ត ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកអសញ្ញសត្វ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណានោះ មិនរលត់ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះទេ ទាំងពួកអកុសលធម៌ ក៏នឹងមិនរលត់ដែរ ។

ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ ក្នុងទីនោះទេឬ ។ ពួកអកុសលធម៌ របស់ពួកជនដែលនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ នឹងមិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តនោះ តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកព្រះអរហន្ត ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកអសញ្ញសត្វ ដែលនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណានោះ នឹងមិនរលត់ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះទេ ទាំងពួកកុសលធម៌ ក៏មិនរលត់ដែរ ។

[ ២៦៦ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះទេឬ ។ ពួកកុសលធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្តទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ ក្នុងទីនោះទេឬ ។ អើ ។

[ ២៦៧ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ ក្នុងទីណា

ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ មិនរលត់ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងឧប្បាទក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្តទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនរលត់ដែរ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ ក្នុងទីនោះទេឬ ។ អើ ។

[ ២៦៨ ] ពួកកុសលធម៌ របស់បុគ្គលណា រលត់ហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ដែរឬ ។ ពួកកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកជនដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណានោះ រលត់ហើយ តែពួកអកុសលធម៌របស់ពួកជននោះ នឹងមិនរលត់ទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ រលត់ហើយ ទាំងពួកអកុសលធម៌ ក៏នឹងរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ហើយឬ ។ អើ ។

[ ២៦៩ ] ពួកកុសលធម៌ របស់បុគ្គលណា រលត់ហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ដែរឬ ។ ពួកកុសលធម៌ របស់ពួកជននោះ រលត់ហើយ ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត តែពួកអព្យាកតធម៌ របស់

ពួកជននោះ នឹងមិនរលត់ទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ រលត់ហើយ ទាំងពួកអព្យាកតធម៌ ក៏នឹងរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ហើយឬ ។ អើ ។

[ ២៧០ ] ពួកអកុសលធម៌ របស់បុគ្គលណា រលត់ហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ដែរឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ រលត់ហើយ ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនរលត់ទេ ឯពួកអកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ រលត់ហើយ ទាំងពួកអព្យាកតធម៌ ក៏នឹងរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ហើយឬ ។ អើ ។

[ ២៧១ ] ពួកកុសលធម៌ រលត់ហើយ ក្នុងទីណា ។បេ។

[ ២៧២ ] ពួកកុសលធម៌ របស់បុគ្គលណា រលត់ហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកជនដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណានោះ រលត់ហើយ ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ រលត់ហើយ ទាំងពួកអកុសលធម៌ ក៏នឹងរលត់ដែរ ។ ម្យ៉ាង

ទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកអកុសលធម៌ របស់ពួកសត្វនោះ នឹងរលត់ ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកសត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ នឹងរលត់ក្នុងទីនោះ ទាំងពួកកុសលធម៌ក៏រលត់ហើយដែរ ។

[ ២៧៣ ] ពួកកុសលធម៌ របស់បុគ្គលណា រលត់ហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកជននោះ រលត់ហើយ ក្នុងទីនោះ ក្នុងកន្ត្រណៈនៃបច្ឆិមចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ រលត់ហើយក្នុងទីនោះ ទាំងពួកអព្យាកតធម៌ ក៏នឹងរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាស-សត្វ កំពុងប្រព្រឹត្តទៅ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វនោះ នឹងរលត់ ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ហើយ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ នឹងរលត់ ក្នុងទីនោះ ទាំងពួកកុសលធម៌

ក៏រលត់ហើយដែរ ។

[ ២៧៤ ] ពួកអកុសលធម៌ របស់បុគ្គលណា រលត់ហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ រលត់ហើយ ក្នុងទីនោះ ក្នុងកង្គក្ខណៈនៃបច្ឆិមចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ រលត់ហើយ ក្នុងទីនោះ ទាំងពួកអព្យាកតធម៌ ក៏នឹងរលត់ដែរ ។ មា្យងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វនោះ នឹងរលត់ ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ហើយ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ នឹងរលត់ ក្នុងទីនោះ ទាំងពួកអកុសលធម៌ ក៏រលត់ហើយដែរ ។

[ ២៧៥ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ដែរឬ ។ មិនមានទេ ។ មា្យងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។

[ ២៧៦ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួក

អព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ឬ ។ មិនមានទេ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។

[ ២៧៧ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ឬ ។ មិនមានទេ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។

[ ២៧៨ ] ពួកកុសលធម៌ មិនរលត់ហើយ ក្នុងទីណា ។បេ។

[ ២៧៩ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកកុសលធម៌ របស់ពួកជននោះ មិនរលត់ហើយ ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេ ទាំងពួកអកុសលធម៌ ក៏នឹងមិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកជនដែលនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណានោះ នឹងមិនរលត់ ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកជននោះ

មិនរលត់ហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកអសញ្ញសត្វនោះ នឹងមិនរលត់ ក្នុងទីនោះទេ ទាំងពួកកុសលធម៌ ក៏មិនរលត់ហើយដែរ ។

[ ២៨០ ] ពួកកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះឬ ។ នឹងមិនរលត់ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ រលត់ហើយ ។

[ ២៨១ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះឬ ។ នឹងរលត់ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ រលត់ហើយ ។

**និរោធវារៈ ចប់**

[ ២៨២ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា រលត់ ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងឬ ។ មិនមែនទេ ។

[ ២៨៣ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ មិនមែនទេ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងឬ ។ មិនមែនទេ ។

[ ២៨៤ ] ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ដែរឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ ពួកអកុសលធម៌ របស់បុគ្គលនោះកើតឡើងឬ ។ មិនមែនទេ ។

[ ២៨៥ ] ពួកកុសលធម៌ កើតឡើង ក្នុងទីណា ពួកអកុសលធម៌ រលត់ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ រលត់ ក្នុងទីណា ពួកកុសលធម៌ កើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ២៨៦ ] ពួកកុសលធម៌ កើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ រលត់ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ រលត់ ក្នុងទីណា ពួកកុសលធម៌ កើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ រលត់ ក្នុងទីនោះ គឺក្នុងអសញ្ញសត្វ តែពួកកុសលធម៌ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ រលត់ ក្នុងទីនោះ គឺក្នុងចតុវោការភព និងបញ្ចវោការភព ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ២៨៧ ] ពួកអកុសលធម៌ កើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ រលត់ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ រលត់ ក្នុងទីណា

ពួកអកុសលធម៌ កើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ រលត់ ក្នុងទីនោះ គឺក្នុងអសញ្ញសត្វ តែពួកអកុសលធម៌ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ រលត់ ក្នុងទីនោះ គឺក្នុងចតុវោការភព និងបញ្ចវោការភព ទាំងពួកអកុសលធម៌ ក៏កើតឡើងដែរ ។

[ ២៨៨ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ក្នុងទីនោះឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។ មិនមែនទេ ។

[ ២៨៩ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ក្នុងទីនោះឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។ មិនមែនទេ ។

[ ២៩០ ] ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ក្នុងទីនោះឬ ។ មិនមែនទេ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះឬ ។ មិនមែនទេ ។

[ ២៩១ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ឬ ។ ពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយទេ តែពួកកុសលធម៌

របស់ពួកជននោះ មិនរលត់ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជននោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ទាំងពួកអកុសលធម៌ ក៏មិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកជននោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនរលត់ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ទាំងពួកកុសលធម៌ ក៏មិនកើតឡើងដែរ ។

[ ២៩២ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ឬ ។ ពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ កាលច្យុត មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ កាលកើតឡើង មិនកើតឡើង ក្នុងភង្គក្ខណៈនៃកុសល និងអកុសលទាំងឡាយ ក្នុងអរូបភព ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងបវត្តិកាល ទាំងពួកអព្យាកតធម៌ ក៏មិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ ពួកកុសលធម៌

របស់បុគ្គលនោះ មិនកើតឡើងឬ ។ ពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក៏មិនមែន ឯពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ កាលកើតឡើង មិនរលត់ក្នុងភង្គក្ខណៈនៃកុសល និងអកុសលទាំងឡាយ ក្នុងអរូបភព ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងបវត្តិកាល ទាំងពួកកុសលធម៌ ក៏មិនកើតឡើងដែរ ។

[ ២៩៣ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ដែរឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ កាលច្យុត មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ កាលកើតឡើង មិនកើតឡើង ក្នុងភង្គក្ខណៈនៃកុសល និងអកុសលទាំងឡាយ ក្នុងអរូបភព ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងបវត្តិកាល ទាំងពួកអព្យាកតធម៌ ក៏មិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ ពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ តែពួកអកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក៏មិនមែន ឯពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ កាលកើតឡើង មិនរលត់ ក្នុងភង្គក្ខណៈនៃកុសល និងអកុសលទាំងឡាយ ក្នុងអរូបភព ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាក

អកុសល ក្នុងបវត្តិកាល ទាំងពួកអកុសលធម៌ ក៏មិនកើតឡើងដែរ ។

[ ២៩៤ ] ពួកកុសលធម៌ មិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ មិនរលត់ ក្នុងទីនោះដែរឬ ។ អើ ។ មួយវិញទៀត ពួកអកុសលធម៌ មិនរលត់ ក្នុងទីណា ពួកកុសលធម៌ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ២៩៥ ] ពួកកុសលធម៌ មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ មិនរលត់ ក្នុងទីនោះឬ ។ រលត់ ។ មួយវិញទៀត ពួកអព្យាកតធម៌ មិនរលត់ ក្នុងទីណា ពួកកុសលធម៌ មិនកើតឡើង ក្នុងទីនោះឬ ។ មិនមានទេ ។

[ ២៩៦ ] ពួកអកុសលធម៌ មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ មិនរលត់ ក្នុងទីនោះឬ ។ រលត់ ។ មួយវិញទៀត ពួកអព្យាកតធម៌ មិនរលត់ ក្នុងទីណា ពួកអកុសលធម៌ មិនកើតឡើង ក្នុងទីនោះឬ ។ មិនមានទេ ។

[ ២៩៧ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃអកុសលទាំងឡាយទេ ឯពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ទាំងពួកអកុសលធម៌ ក៏មិនរលត់ដែរ ។ មួយវិញទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះ

ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនរលត់ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ទាំងពួកកុសលធម៌ ក៏មិនកើតឡើងដែរ ។

[ ២៩៨ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ កាលច្យុត មិនកើតឡើង ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ កាលកើតឡើង មិនកើតឡើង ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃកុសល និងអកុសលទាំងឡាយ ក្នុងអរូបភព ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងបវត្តិកាល ទាំងពួកអព្យាកតធម៌ ក៏មិនរលត់ដែរ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយទេ តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ កាលកើតឡើង មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃកុសល និងអកុសលទាំងឡាយ ក្នុងអរូបភព ក្នុង

ឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងបវត្តិកាល ទាំងពួកកុសលធម៌ក៏មិនកើតឡើងដែរ ។

[ ២៩៩ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ កាលច្យុត មិនកើតឡើង ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបវត្តិកាល តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ កាលកើតឡើង មិនកើតឡើង ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃកុសល និងអកុសលទាំងឡាយ ក្នុងអរូបភព ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងបវត្តិកាល ទាំងពួកអព្យាកតធម៌ ក៏មិនរលត់ដែរ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃកុសលទាំងឡាយទេ តែពួកអកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ កាលកើតឡើង មិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃកុសល និងអកុសលទាំងឡាយ ក្នុងអរូបភព ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងបវត្តិកាល ទាំងពួកអកុសលធម៌ ក៏មិនកើតឡើងដែរ ។

[ ៣០០ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ពួក

អកុសលធម៌ របស់បុគ្គលនោះ រលត់ហើយឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា រលត់ហើយ ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយឬ ។ អើ ។

[ ៣០១ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ហើយឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ហើយ ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយឬ ។ អើ ។

[ ៣០២ ] ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ហើយឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយឬ ។ អើ ។

[ ៣០៣ ] ពួកកុសលធម៌ កើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ រលត់ហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ រលត់ហើយ ក្នុងទីណា ពួកកុសលធម៌ កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។

[ ៣០៤ ] ពួកកុសលធម៌ កើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ រលត់ហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ រលត់ហើយ ក្នុងទីណា ពួកកុសលធម៌ កើតឡើងហើយ ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ រលត់ហើយ ក្នុងទីនោះ គឺក្នុងអសញ្ញសត្វ តែពួកកុសលធម៌ មិនកើតឡើងហើយ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ រលត់ហើយ ក្នុងទីនោះ

គឺក្នុងចតុវោការភព និងបញ្ចវោការភព ទាំងពួកកុសលធម៌ ក៏កើតឡើង ហើយដែរ ។

[ ៣០៥ ] ពួកអកុសលធម៌ កើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ រលត់ហើយ ក្នុងទីនោះឬ ។ អើ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ រលត់ហើយ ក្នុងទីណា ពួកអកុសលធម៌ កើតឡើងហើយ ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ រលត់ហើយ ក្នុងទីនោះ គឺក្នុងអសញ្ញសត្វ តែពួកអកុសលធម៌ មិនកើតឡើងហើយ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ រលត់ហើយ ក្នុងទីនោះ គឺក្នុងចតុវោការភព និងបញ្ចវោការភព ទាំងពួកអកុសលធម៌ ក៏កើតឡើងហើយដែរ ។

[ ៣០៦ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះឬ ។ អើ ។ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា រលត់ហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ កាលអកុ-សលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកអកុសលធម៌ របស់ពួកសត្វនោះ រលត់ហើយ ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ រលត់ហើយ ក្នុងទីនោះ ទាំងពួកកុសលធម៌ ក៏កើតឡើងហើយដែរ ។

[ ៣០៧ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ក្នុងទីណា

ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វនោះ រលត់ហើយ ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ រលត់ហើយ ក្នុងទីនោះ ទាំងពួកកុសលធម៌ ក៏កើតឡើងហើយដែរ ។

[ ៣០៨ ] ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វនោះ រលត់ហើយ ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកសត្វនោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ រលត់ហើយ ក្នុងទីនោះ ទាំងពួកអកុសលធម៌ ក៏កើតឡើងហើយដែរ ។

[ ៣០៩ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយឬ ។ មិនមានទេ ។ ម្យ៉ាង

ទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកកុសលធម៌ របស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយឬ ។ មិនមានទេ ។

[ ៣១០ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ហើយឬ ។ មិនមានទេ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកកុសលធម៌ របស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយឬ ។ មិនមានទេ ។

[ ៣១១ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ហើយឬ ។ មិនមានទេ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ ឈ្មោះថា មិនកើតឡើងហើយឬ ។ មិនមានទេ ។

[ ៣១២ ] ពួកកុសលធម៌ មិនកើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ មិនរលត់ហើយ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ មិនរលត់ហើយ ក្នុងទីណា ពួកកុសលធម៌ ឈ្មោះថា មិនកើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។

[ ៣១៣ ] ពួកកុសលធម៌ មិនកើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ មិនរលត់ហើយ ក្នុងទីនោះឬ ។ រលត់ហើយ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ មិនរលត់ហើយ ក្នុងទីណា ពួកកុសលធម៌ ឈ្មោះថា មិនកើតឡើងហើយ ក្នុងទីនោះឬ ។ មិនមានទេ ។

[ ៣១៤ ] ពួកអកុសលធម៌ មិនកើតឡើងហើយ ក្នុងទីណា ពួក

អព្យាកតធម៌ មិនរលត់ហើយ ក្នុងទីនោះឬ ។ រលត់ហើយ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ មិនរលត់ហើយ ក្នុងទីណា ពួកអកុសលធម៌ ឈ្មោះថា មិនកើតឡើងហើយ ក្នុងទីនោះឬ ។ មិនមានទេ ។

[ ៣១៥ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ កាលអកុសលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ តែពួកអកុសលធម៌ របស់ពួកសត្វនោះ មិនរលត់ហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ កាលចូលទៅកាន់សុទ្ធាវាស មិនកើតឡើងហើយ ក្នុងទីនោះទេ ទាំងពួកអកុសលធម៌ ក៏មិនរលត់ហើយដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។

[ ៣១៦ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនរលត់ហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកសត្វនោះ កាលចូលទៅកាន់សុទ្ធាវាស មិនកើតឡើង

ហើយ ក្នុងទីនោះទេ ទាំងពួកអព្យាកតធម៌ ក៏មិនរលត់ហើយដែរ ។ ម្យ៉ាង ទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។

[ ៣១៧ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកអកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ តែពួកអព្យាកតធម៌ របស់ពួកសត្វនោះ មិនរលត់ហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកសត្វនោះ កាលចូលទៅកាន់សុទ្ធាវាស មិនកើតឡើងហើយ ក្នុងទីនោះ ទាំងពួកអព្យាកតធម៌ ក៏មិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ អើ ។

[ ៣១៨ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ដែរឬ ។ ( ពួកជន ) ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ពួកកុសលធម៌ របស់ពួកជននោះ នឹងកើតឡើង តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ នឹងកើតឡើង ទាំងពួកអកុសលធម៌ ក៏រលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ អើ ។

[ ៣១៩ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ពួកកុសលធម៌របស់បុគ្គលនោះ នឹងកើតឡើង ឬ ។ ពួកអព្យាកតធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ នឹងរលត់ តែពួកកុសលធម៌ របស់ពួកព្រះអរហន្តនោះ នឹងមិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ ក្រៅពីនេះ នឹងរលត់ ទាំងពួកកុសលធម៌ ក៏នឹងកើតឡើងដែរ ។

[ ៣២០ ] ពួកអកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើងឬ ។ ពួកអព្យាកតធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកជននោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណានោះ នឹងរលត់ ( ក្នុងលំដាប់នៃចិត្តនោះ ) តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ ក្រៅពីនេះ នឹងរលត់ ទាំងពួកអកុសលធម៌ ក៏នឹងកើតឡើងដែរ ។

[ ៣២១ ] ពួកកុសលធម៌ នឹងកើតឡើង ក្នុងទីណា ពួកអកុសលធម៌ នឹងរលត់ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ នឹងរលត់ ក្នុងទីណា ពួកកុសលធម៌ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ៣២២ ] ពួកកុសលធម៌ នឹងកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ នឹងរលត់ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ នឹងរលត់ ក្នុងទីណា ពួកកុសលធម៌ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ នឹងរលត់ក្នុងទីនោះ គឺក្នុងអសញ្ញសត្វ តែពួកកុសលធម៌ នឹងមិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ នឹងរលត់ក្នុងទីនោះ គឺក្នុងចតុវោការភព និងបញ្ចវោការភព ទាំងពួកកុសលធម៌ នឹងកើតឡើងដែរ ។

[ ៣២៣ ] ពួកអកុសលធម៌ នឹងកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ នឹងរលត់ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ នឹងរលត់ ក្នុងទីណា ពួកអកុសលធម៌ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ នឹងរលត់ ក្នុងទីនោះ គឺក្នុងអសញ្ញសត្វ តែពួកអកុសលធម៌ នឹងមិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ នឹងរលត់ ក្នុងទីនោះ គឺក្នុងចតុ-វោការភព និងបញ្ចវោការភព ទាំងពួកអកុសលធម៌ ក៏នឹងកើតឡើងដែរ ។

[ ៣២៤ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកជននោះ ដែលនឹងបានទទួលមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តនោះ នឹងកើតឡើង ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ នឹងកើតឡើង ក្នុងទីនោះ ទាំងពួកអកុសលធម៌ ក៏នឹងរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងរលត់

ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ៣២៥ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើងក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកអសញ្ញសត្វនោះ នឹងរលត់ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ នឹងរលត់ក្នុងទីនោះ ទាំងពួកកុសលធម៌ក៏នឹងកើតឡើងដែរ ។

[ ៣២៦ ] ពួកអកុសលធម៌ របស់បុគ្គលណា នឹងកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកអព្យាកតធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកអសញ្ញសត្វ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណានោះ នឹងរលត់ ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វ

ចតុវោការ និងបញ្ចវោការ នឹងរលត់ ក្នុងទីនោះ ទាំងពួកអកុសលធម៌ក៏នឹងកើតឡើងដែរ ។

[ ៣២៧ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ដែរឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងមិនរលត់ តែពួកកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក៏មិនមែន ឯពួកអកុលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ នឹងមិនរលត់ទេ ទាំងពួកកុសលធម៌ ក៏នឹងមិនកើតឡើងដែរ ។

[ ៣២៨ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ដែរឬ ។ ពួកកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរនោះ នឹងមិនកើតឡើងទេ ពួកអព្យាកតធម៌ របស់ពួកព្រះអរហន្តនោះ នឹងមិនរលត់ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកព្រះអរហន្តនោះ នឹងមិនកើតឡើង ក្នុងកង្គក្ខណៈនៃបច្ឆិមចិត្តទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ អើ ។

[ ៣២៩ ] ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ពួក

អព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ដែរឬ ។ ពួកអកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកជននោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងមិនកើតឡើង តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនរលត់ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក្នុងកង្ខណៈនៃបច្ឆិមចិត្តទាំងពួកអព្យាកតធម៌ ក៏នឹងមិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើងឬ ។ អើ ។

[ ៣៣០ ] ពួកកុសលធម៌ នឹងមិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ នឹងមិនរលត់ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ នឹងមិនរលត់ ក្នុងទីណា ពួកកុសលធម៌ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ៣៣១ ] ពួកកុសលធម៌ នឹងមិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ នឹងមិនរលត់ក្នុងទីនោះឬ ។ នឹងរលត់ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ នឹងមិនរលត់ក្នុងទីណា ពួកកុសលធម៌នឹងមិនកើតឡើងក្នុងទីនោះឬ ។ មិនមានទេ ។

[ ៣៣២ ] ពួកអកុសលធម៌ នឹងមិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ នឹងមិនរលត់ ក្នុងទីនោះឬ ។ នឹងរលត់ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ នឹងមិនរលត់ ក្នុងទីណា ពួកអកុសលធម៌ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ មិនមានទេ ។

[ ៣៣៣ ] ពួកកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទី

ណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងមិនរលត់ ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក្នុងទីនោះ ក៏មិនមែន តែពួកកុសលធម៌ របស់ពួកព្រះអរហន្តអ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកអសញ្ញសត្វនោះ នឹងមិនរលត់ ក្នុងទីនោះទេ ទាំងពួកកុសលធម៌ ក៏នឹងមិនកើតឡើងដែរ ។

[ ៣៣៤ ] ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកអសញ្ញសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជននោះ នឹងមិនកើតឡើង ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្តទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ៣៣៥ ] ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះឬ ។ ពួក

អកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និង របស់ពួកអសញ្ញសត្វ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នោះ នឹងមិនកើតឡើង ក្នុងទីនោះ តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹង មិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកជននោះ នឹង មិនកើតឡើង ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត ទាំងពួកអព្យាកតធម៌ ក៏នឹងមិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹង មិនរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ៣៣៦ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ហើយដែរឬ ។ អើ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា រលត់ហើយ ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើង ដែរឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូល កាន់និរោធ និងពួកអសញ្ញសត្វ រលត់ហើយ ក្នុងឧប្បាទក្ខណៈនៃចិត្តដែល ប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើងទេ ឯពួកអកុសលធម៌ របស់ពួកជននោះ រលត់ហើយ ក្នុង ឧប្បាទក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ៣៣៧ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ រលត់ហើយឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ហើយ ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើង

ដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូល
កាន់និរោធ និងពួកអសញ្ញសត្វ រលត់ហើយ ក្នុងឧប្បាទក្ខណៈនៃចិត្តដែល
ប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ
មិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ រលត់ហើយ ក្នុង
ឧប្បាទក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ៣៣៨ ] ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអព្យា-
កតធម៌ របស់បុគ្គលនោះ រលត់ហើយដែរឬ ។ អើ ។ មួយវិញទៀត ពួក
អព្យាកតធម៌ របស់បុគ្គលណា រលត់ហើយ ពួកអកុសលធម៌ របស់បុគ្គល
នោះ កើតឡើងដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ គឺ
លោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ រលត់ហើយ ក្នុងឧប្បាទក្ខណៈ
នៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអកុសលធម៌
របស់ពួកជននោះ មិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ
រលត់ហើយ ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ទាំងពួកអកុសលធម៌
ក៏កើតឡើងដែរ ។

[ ៣៣៩ ] ពួកកុសលធម៌ កើតឡើង ក្នុងទីណា ។បេ។

[ ៣៤០ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា
ពួកអកុសលធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ អើ ។
មួយវិញទៀត ពួកអកុសលធម៌ របស់បុគ្គលណា រលត់ហើយ ក្នុងទីណា ពួក
កុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកអកុសលធម៌

របស់ពួកជនទាំងអស់នោះ រលត់ហើយ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាស ចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិន កើតឡើង ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកជននោះ រលត់ហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើត ឡើងដែរ ។

[ ៣៤១ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួក អព្យាកតធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ហើយ ក្នុងទីណា ពួក កុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ រលត់ហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ ពួកជននោះ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជន នោះ រលត់ហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ទាំង ពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ៣៤២ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួក អព្យាកតធម៌ របស់បុគ្គលនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ អើ ។ ម្យ៉ាង ទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា រលត់ហើយ ក្នុងទីណា ពួកអកុ-សលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ រលត់ហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈ

នៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ រលត់ហើយ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ទាំងពួកអកុសលធម៌ ក៏កើតឡើងដែរ ។

[ ៣៨៣ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងដែរឬ ។ មិនមានទេ ។

[ ៣៨៤ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ មិនមានទេ ។

[ ៣៨៥ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ មិនមានទេ ។

[ ៣៨៦ ] ពួកកុសលធម៌ មិនកើតឡើង ក្នុងទីណា ។បេ។

[ ៣៨៧ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះដែរឬ ។ ពួក

កុសលធម៌ របស់ពួកជនទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ មិនរលត់ហើយ ក្នុងទីនោះ ក៏មិនមែន កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ឯពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនកើតឡើង ក្នុងទីនោះទេ ទាំងពួកអកុសលធម៌ ក៏មិនរលត់ហើយដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ៣៤៨ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកកុសលធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជននោះ កាលចូលទៅកាន់សុទ្ធាវាស មិនកើតឡើង ក្នុងទីនោះទេ ទាំងពួកអព្យាកតធម៌ ក៏មិនរលត់ហើយដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ៣៤៩ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ មិនរលត់ហើយ ក្នុងទីនោះដែរឬ ។ ពួក

អកុសលធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ មិនរលត់ហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកជននោះ កាលចូលទៅកាន់សុទ្ធាវាស មិនកើតឡើង ក្នុងទីនោះទេ ទាំងពួកអព្យាកតធម៌ ក៏មិនរលត់ហើយដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា មិនរលត់ហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ៣៥០ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ដែរឬ ។ ពួកកុសលធម៌ របស់ពួកជននោះ ដែលនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ កើតឡើងក្នុងឧប្បាទក្ខណៈនៃចិត្តនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ទេ ឯពួកកុសលធម៌ របស់ពួកជននោះ កើតឡើងក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ក្រៅពីនេះ ទាំងពួកអកុសលធម៌ ក៏នឹងរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងដែរឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ នឹងរលត់ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើងទេ ឯពួកអកុសលធម៌ របស់ពួកជននោះ នឹងរលត់ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើត

ឡើងដែរ ។

[ ៣៥១ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ នឹងរលត់ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ នឹងរលត់ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ៣៥២ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ពួកអកុសលធម៌របស់បុគ្គលនោះ កើតឡើងដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ នឹងរលតក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ មិនកើតឡើងទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ នឹងរលត់ ក្នុងឧប្បាទក្ខណៈនៃអកុសលទាំងឡាយ ទាំងពួកអកុសលធម៌ ក៏កើតឡើងដែរ ។

[ ៣៥៣ ] ពួកកុសលធម៌ កើតឡើង ក្នុងទីណា ។បេ។

[ ៣៥៤ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួក

អកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះដែរឬ ។ ពួកកុសលធម៌ របស់ពួកជននោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ កើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះទេ ឯពួកកុសលធម៌ របស់ពួកជននោះ កើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ក្រៅពីនេះ ទាំងពួកអកុសលធម៌ ក៏នឹងរលត់ដែរ ។ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ នឹងរលត់ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកជននោះ នឹងរលត់ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ៣៥៥ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ នឹងរលត់ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកកុសលធម៌ របស់ពួកជន

នោះ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ នឹងរលត់ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ទាំងពួកកុសលធម៌ ក៏កើតឡើងដែរ ។

[ ៣៥៦ ] ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះឬ ។ អើ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ នឹងរលត់ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ នឹងរលត់ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃកុសលទាំងឡាយ ទាំងពួកអកុសលធម៌ ក៏កើតឡើងដែរ ។

[ ៣៥៧ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ដែរឬ ។ ពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកព្រះអរហន្ត ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងពួកជននោះ ដែលនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា មិនកើតឡើង ក្នុង

កង្គក្ខណៈនៃចិត្តនោះទេ ទាំងពួកអកុសលធម៌ ក៏នឹងមិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងដែរឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ នឹងមិនរលត់ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកព្រះអរហន្ត ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងពួកជននោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងមិនរលត់ ក្នុងភង្គក្ខណៈនៃចិត្តនោះទេ ទាំងពួកកុសលធម៌ ក៏មិនកើតឡើងដែរ ។

[ ៣៥៨ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ដែរឬ ។ ពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនរលត់ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្តទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ អើ ។

[ ៣៥៩ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ពួក

អព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ដែរឬ ។ ពួកអកុសលធម៌ របស់ពួកជនទាំងអស់នោះ គឺលោកដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនរលត់ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្តទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងឬ ។ អើ ។

[ ៣៦០ ] ពួកកុសលធម៌ មិនកើតឡើង ក្នុងទីណា ។បេ។

[ ៣៦១ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះឬ ។ ពួកកុសលធម៌ របស់ពួកជនទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកព្រះអរហន្ត ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងពួកអសញ្ញសត្វនោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា មិនកើតឡើង ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តនោះទេ ទាំងពួកអកុសលធម៌ ក៏នឹងមិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះដែរឬ ។ ពួកអកុ-

សលធម៌ របស់ពួកជននោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្ត ណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ នឹងមិនរលត់ ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ តែពួកអកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកព្រះអរហន្ត ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងពួកអសញ្ញសត្វនោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងមិនរលត់ ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃចិត្តនោះ ទាំងពួកកុសលធម៌ ក៏មិនកើតឡើងដែរ ។

[ ៣៦២ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះដែរឬ ។ ពួកកុសលធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើង ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្តទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ៣៦៣ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើង ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះដែរឬ ។ ពួកអកុសលធម៌ របស់ពួកអសញ្ញសត្វទាំងអស់នោះ មិនកើតឡើង ក្នុងទីនោះ

ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកអកុសល ក្នុងភង្គក្ខណៈនៃចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើង ក្នុងទីនោះ ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្តទេ ទាំងពួកអព្យាកតធម៌ ក៏នឹងមិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ៣៦៤ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ដែរឬ ។ ពួកកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកជននោះដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា កើតឡើងហើយ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ កើតឡើងហើយ ទាំងពួកអកុសលធម៌ ក៏នឹងរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយឬ ។ អើ ។

[ ៣៦៥ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ដែរឬ ។ ពួកកុសលធម៌ របស់ពួកជននោះ កើតឡើងហើយ ក្នុងភង្គក្ខណៈនៃបច្ឆិមចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនរលត់ទេ ឯពួកអកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ កើតឡើងហើយ ទាំងពួកអព្យាកតធម៌ ក៏នឹងរលត់ដែរ ។ ម្យ៉ាងទៀត

ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយឬ ។ អើ ។

[ ៣៦៦ ] ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ដែរឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ កើតឡើងហើយ ក្នុងកង្គក្ខណៈនៃបច្ឆិមចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនរលត់ទេ ឯពួកអកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ កើតឡើងហើយ ទាំងពួកអព្យាកតធម៌ ក៏នឹងរលត់ដែរ ។ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយឬ ។ អើ ។

[ ៣៦៧ ] ពួកកុសលធម៌ កើតឡើងហើយ ក្នុងទីណា ។បេ។

[ ៣៦៨ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះដែរឬ ។ ពួកកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកជននោះ ដែលនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា កើតឡើងហើយ ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងរលត់ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ កើតឡើងហើយ ក្នុងទីនោះ ទាំងពួកអកុ-សលធម៌ ក៏នឹងរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងរលត់ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយ ក្នុង

ទីនោះដែរឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកអកុសលធម៌ របស់ពួកជននោះ នឹងរលត់ ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ នឹងរលត់ ក្នុងទីនោះ ទាំងពួកកុសលធម៌ ក៏កើតឡើងហើយដែរ ។

[ ៣៦៩ ] ពួកកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះដែរឬ ។ ពួកកុសលធម៌ របស់ពួកជននោះ កើតឡើងហើយ ក្នុងទីនោះ ក្នុងកន្ទក្ខណៈនៃបច្ឆិមចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះទេ ឯពួកកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ កើតឡើងហើយ ក្នុងទីនោះ ទាំងពួកអព្យាកតធម៌ ក៏នឹងរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វនោះ នឹងរលត់ ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ឯពួកអព្យាកតធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ នឹងរលត់ ក្នុងទីនោះ ទាំងពួកកុសលធម៌ ក៏កើតឡើងហើយដែរ ។

[ ៣៧០ ] ពួកអកុសលធម៌ របស់បុគ្គលណា កើតឡើងហើយ ក្នុង

ទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងរលត់ ក្នុងទីនោះដែរឬ ។ ពួកអកុសលធម៌ របស់ពួកជននោះ កើតឡើងហើយ ក្នុងទីនោះ ក្នុងកង្គក្ខណៈនៃបច្ឆិមចិត្ត តែពួកអព្យាកតធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះទេ ឯពួកអកុសលធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការនិងបញ្ចវោការ កើតឡើងហើយ ក្នុងទីនោះ ទាំងពួកអព្យាកតធម៌ ក៏នឹងរលត់ដែរ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកអព្យាកតធម៌ របស់ពួកអសញ្ញសត្វនោះ នឹងរលត់ ក្នុងទីនោះ តែពួកអកុសលធម៌ របស់ពួកជននោះ កើតឡើងហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកអព្យាកតធម៌ របស់ពួកជននោះ ក្រៅពីនេះ គឺពួកសត្វចតុវោការ និងបញ្ចវោការ នឹងរលត់ក្នុងទីនោះ ទាំងពួកអកុសលធម៌ ក៏កើតឡើងហើយដែរ ។

[ ៣៧១ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ឬ ។ មិនមានទេ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងរលត់ ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។

[ ៣៧២ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ឬ ។ មិនមានទេ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកកុសលធម៌ របស់បុគ្គល

នោះ មិនកើតឡើងហើយឬ ។ មិនកើតឡើងហើយ ។

[ ៣៧៣ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ឬ ។ មិនមានទេ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។

[ ៣៧៤ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ក្នុងទីណា ។បេ។

[ ៣៧៥ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះដែរឬ ។ កាលចិត្តទីពីរ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើងហើយ ក្នុងទីនោះទេ តែពួកអកុសលធម៌ របស់ពួកជននោះ នឹងមិនរលត់ ក្នុងទីនោះ ក៏មិនមែន ឯពួកកុសលធម៌ របស់ពួកអសញ្ញសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ទាំងពួកអកុ-សលធម៌ ក៏មិនរលត់ដែរ ។ ម្យ៉ាងទៀត ពួកអកុសលធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយ ក្នុងទីនោះដែរឬ ។ ពួកអកុសលធម៌ របស់ពួកព្រះអរហន្ត អ្នកព្រមព្រៀងដោយមគ្គដ៏ប្រសើរ និងរបស់ពួកជននោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងមិនរលត់ ក្នុងទីនោះ តែពួកកុសលធម៌ របស់ពួកជននោះ មិនកើតឡើងហើយ ក្នុងទីនោះ ក៏មិនមែន ឯពួកអកុសលធម៌ របស់

ពួកអសញ្ញសត្វនោះ នឹងមិនរលត់ ក្នុងទីនោះទេ ទាំងពួកកុសលធម៌ ក៏មិនកើតឡើងហើយដែរ ។

[ ៣៧៦ ] ពួកកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះឬ ។ នឹងរលត់ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ កើតឡើងហើយ ។

[ ៣៧៧ ] ពួកអកុសលធម៌ របស់បុគ្គលណា មិនកើតឡើងហើយ ក្នុងទីណា ពួកអព្យាកតធម៌ របស់បុគ្គលនោះ នឹងមិនរលត់ ក្នុងទីនោះឬ ។ នឹងរលត់ ។ ម្យ៉ាងទៀត ពួកអព្យាកតធម៌ របស់បុគ្គលណា នឹងមិនរលត់ ក្នុងទីណា ពួកអកុសលធម៌ របស់បុគ្គលនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ កើតឡើងហើយ ។

ឧប្បាទនិរោធវារៈ ចប់

បវត្តិវារៈ ចប់

# ភាវនាវារៈ

[ ៣៧៨ ] បុគ្គលណា ចម្រើននូវកុសលធម៌ បុគ្គលនោះ ឈ្មោះថា លះបង់នូវអកុសលធម៌ឬ ។ អើ ។ម្យ៉ាងទៀត បុគ្គលណា លះបង់នូវអកុសលធម៌ បុគ្គលនោះ ឈ្មោះថា ចម្រើននូវកុសលធម៌ឬ ។ អើ ។ បុគ្គលណា មិនចម្រើននូវកុសលធម៌ បុគ្គលនោះ ឈ្មោះថា មិនលះបង់នូវអកុសលធម៌ឬ ។ អើ ។ ម្យ៉ាងទៀត បុគ្គលណា មិនលះបង់នូវអកុសលធម៌ បុគ្គលនោះ ឈ្មោះថា មិនចម្រើននូវកុសលធម៌ឬ ។ អើ ។ ។បេ។

ភាវនាវារៈ ចប់

ធម្មយមកៈ ចប់

# អដ្ឋកថា

# ធម្មយមកៈ

## បណ្ណត្តិឧទ្ទេសវារៈ

*[ ៧៨ ] ឥឡូវនេះ ជាកិច្ចពណ៌នាធម្មយមកៈ ដែលព្រះមានព្រះភាគទ្រង់តាំងមាតិកានៃធម៌ទាំងឡាយ មានកុសលទាំងនោះឯងជាដើម ដែលសម្តែងក្នុងមូលយមកៈ ហើយសម្តែងបន្តអំពីចិត្តយមកៈ ។*

*ក្នុងធម្មយមកៈនោះ គប្បីជ្រាបការកំណត់ព្រះបាលីតាមន័យដែលពោលក្នុងខន្ធយមកៈ ។ ក្នុងខន្ធយមកៈនោះ មាន ៣ មហាវារៈ មានបណ្ណត្តិវារៈជាដើម និងមានអន្តរវារៈដ៏សេស មានដោយប្រការណា ក្នុងធម្មយមកៈនេះក៏មានដោយប្រការនោះ ។*

*ក្នុងធម្មយមកៈនេះ គប្បីជ្រាបថា លោកហៅបរិញ្ញាវារៈថា ភាវនាវារៈ ព្រោះព្រះបាលីក្នុងអាគតដ្ឋានថា* **យោ កុសលំ ធម្មំ ភាវេតិ សោ អកុសលំ ធម្មំ បជហាតិ** *បុគ្គលណា ចម្រើននូវកុសលធម៌ បុគ្គលនោះ ឈ្មោះថាលះបង់នូវអកុសលធម៌ឬ ។*

*ក្នុងភាវនាវារៈនោះ អព្យាកតធម៌ ជាធម៌ដែលបុគ្គលមិនគួរចម្រើនផងមិនគួរលះផង ព្រោះហេតុនោះ ទើបលោកមិនលើកបទនោះឡើងសម្តែងក្នុងបណ្ណត្តិវារៈ ក្នុងធម្មយមកៈនេះ គប្បីជ្រាបការរាប់យមកៈក្នុងវារៈទាំង ៤ នេះ គឺ* **បទសោធនវារៈ ១ បទសោធនមូលចក្កវារៈ ១ សុទ្ធធម្មវារៈ ១**

**សុទ្ធធម្មមូលចក្កវារៈ** ១ *ដោយអំណាចនៃធម៌ទាំង ៣ មានកុសលធម៌ជាដើម ។*

## បណ្ណត្តិនិទ្ទេសវារៈ

[ ៨៦ ] *ចំណែកក្នុងបណ្ណត្តិវារនិទ្ទេស ទ្រង់ត្រាស់ថា* **អាមន្តា** *ព្រោះភាពនៃកុសលទាំងឡាយជាកុសលធម៌ដោយពិតប្រាកដ ក្នុងបញ្ហាថា* **កុសលា កុសលធម្មា** *ពួកកុសល ឈ្មោះថា កុសលធម៌ឬ ដូច្នេះ ។ ក្នុងពាក្យវិសជ្ជនាដ៏សេស ក៏ន័យនេះឯង ពាក្យវិសជ្ជនាថា* **អវសេសា ធម្មា ន អកុសលា ធម្មា** *ពួកធម៌ដ៏សេស ឈ្មោះថា មិនមែនអកុសលធម៌ទេ អធិប្បាយថា ធម៌ទាំងឡាយដ៏សេស មិនជាអកុសល តែជាធម៌ ។ គប្បីជ្រាបពាក្យវិសជ្ជនាទាំងអស់ ដោយន័យនេះ ។*

## បវត្តិវារៈ

[ ៩៤ ] *ក្នុងអនុលោមន័យរបស់បុគ្គលវារៈ ក្នុងបច្ចុប្បន្នកាល ក្នុងបវត្តិវារៈនេះ ៣ យមកៈ គឺយមកៈដែលមានកុសលធម៌ជាមូល ២ យ៉ាង មានអកុសលធម៌ជាមូល ១ យ៉ាង រមែងមានក្នុងបញ្ហាថា* **យស្ស កុសលា ធម្មា ឧប្បជ្ជន្តិ តស្ស អកុសលា ធម្មា ឧប្បជ្ជន្តិ យស្ស វា បន អកុសលា ធម្មា ឧប្បជ្ជន្តិ តស្ស កុសលា ធម្មា ឧប្បជ្ជន្តិ** *ពួកកុសលធម៌របស់បុគ្គលណាកើតឡើង ពួកអកុសលធម៌របស់បុគ្គលនោះ កើតឡើងឬ មួយវិញទៀត ពួកអកុសលធម៌របស់បុគ្គលណាកើតឡើង ពួកកុសលធម៌របស់បុគ្គលនោះកើតឡើងឬ ដូច្នេះ ។*

ក្នុងបដិលោមន័យក្តី ក្នុងវារៈទាំងឡាយ មានឱកាសវារៈជាដើមក្តី នៃបុគ្គលវារៈនោះ ក៏ន័យនេះឯង ។ បណ្ឌិតគប្បីជ្រាបការរាប់យមកៈ ដោយអំណាចនៃយមកៈទាំងឡាយនីមួយៗ ៣ ក្នុងវារៈទាំងពួង ក្នុងបវត្តិវារៈនេះ យ៉ាងនេះ ។

ក្នុងការវិនិច្ឆ័យអត្ថ ក្នុងបវត្តិវារៈ គប្បីជ្រាបលក្ខណៈនេះដូចតទៅ

ក្នុងបវត្តិវារៈ នៃធម្មយមកៈនេះ បទថា **ឧប្បជ្ជន្តិ** និង **និរុជ្ឈន្តិ** ក្នុងឧប្បាទវារៈ និងនិរោធវារៈទាំងនេះ រមែងបានកុសលធម៌ និងអកុសលធម៌ ក្នុងបវត្តិកាលប៉ុណ្ណោះ ដោយពិតប្រាកដ រមែងមិនបានក្នុងចុតិ និងក្នុងបដិ-សន្ធិកាល តែអព្យាកតធម៌ រមែងបានក្នុងកាលទាំង ៣ គឺបវត្តិ ចុតិ និងបដិសន្ធិ ។

លក្ខណៈណា រមែងបានក្នុងទីណា គប្បីជ្រាបពាក្យវិនិច្ឆ័យដោយអំណាចនៃលក្ខណៈនោះ ក្នុងទីនោះៗ យ៉ាងនេះ ។

គប្បីជ្រាបនយមុខ ក្នុងការវិនិច្ឆ័យដូចតទៅ ពាក្យបដិសេធថា **នោ** ទ្រង់ធ្វើហើយ ព្រោះការមិនកើតឡើងក្នុងខណៈជាមួយគ្នា របស់កុសល និងអកុសល ។

បទថា **អព្យាកតា ច** លោកពោលហើយ ដោយអំណាចនៃរូបដែលមានចិត្តជាសមុដ្ឋាន ។

[ ១០៣ ] បញ្ហាថា **យត្ថ កុសលា ធម្មា ឧប្បជ្ជន្តិ** នេះ លោកពោលសំដៅយកអសញ្ញីកព ព្រោះហេតុនោះឯង ទើបក្នុងបញ្ហានេះ លោកធ្វើពាក្យ

វិសជ្ជនាថា **អាមន្តា** ។ ក្នុងបទថា **ឧប្បជ្ជន្តិ** នេះ លោកក៏ពោលសំដៅយកអសញ្ញីភពនោះឯង តែធ្វើការហាមថា **នត្ថិ** ព្រោះការមិនមាននៃទីដែលមិនកើតឡើងនៃអព្យាកតធម៌ទាំងឡាយ ( សេចក្តីថា អព្យាកតធម៌ កើតបានគ្រប់ភូមិ ) ។

[ ១១៨ ] បទថា **ទុតិយេ អកុសលេ** បានដល់ ជវនចិត្តជួនទី ២ ក្នុងនិក្កន្តិជវន ដែលកើតឡើងហើយ ព្រោះត្រេកអរនូវភព ។

បទថា **ទុតិយេ ចិត្តេ វត្តមានេ** បានដល់ កាលភវង្គចិត្ត ដែលជាចិត្តជួនទី ២ បន្ទាប់អំពីបដិសន្ធិចិត្តប្រព្រឹត្តទៅ ។ ម្យ៉ាងទៀត បទថា **ទុតិយេ ចិត្តេ វត្តមានេ** បានដល់ កាលអាវជ្ជនចិត្ត ក្នុងភវនិក្កន្តិជវន ប្រព្រឹត្តទៅ ព្រោះធ្វើនូវភវង្គ និងបដិសន្ធិឲ្យជាបែបតែមួយ ដោយអំណាចរបស់វិបាកចិត្ត ។ ពិតហើយ អាវជ្ជនចិត្តនោះ ឈ្មោះថា ចិត្តជួនទី ២ រាប់អំពីវិបាកចិត្ត ព្រោះភាពនៃអាវជ្ជនចិត្តនោះ ជាកិរិយាចិត្ត ក្នុងអព្យាកតជាតិ ។

[ ១៣០ ] បទថា **យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ** លោកពោលសំដៅយកគោត្រភូចិត្ត ។

បទថា **កុសលា ធម្មា ឧប្បជ្ជិស្សន្តិ** លោកពោលសំដៅយកធម៌ទាំងឡាយ គឺមគ្គដ៏ប្រសើរទាំងនោះ ។

[ ១៦២ ] បញ្ហាថា **យស្ស ចិត្តស្ស អនន្តរា អគ្គមគ្គំ បដិលភិស្សន្តិ តស្ស ចិត្តស្ស ឧប្បាទក្ខណេ** លោកពោលពាក្យនេះ ដោយអំណាចនៃការកើតឡើងនៃចិត្ត ។ លក្ខណៈនេះ រមែងបានក្នុងឧប្បាទខណៈនៃឱរិមចិត្ត ( ចិត្ត

*ដូនមុន ) បន្ទាប់អំពីចិត្តនោះ ដែលកើតឡើងហើយ ដោយអាវជ្ជនចិត្តដូចគ្នា នៃការកើតរបស់ចិត្តនោះ ។*

*[ ១៩០ ] ក្នុងនិរោធវារៈ លោកពោលហើយថា* **ណោ** *ព្រោះភាពដែលកុសល និងអកុសល មិនរលត់ព្រមគ្នា ។ គប្បីជ្រាបពាក្យវិនិច្ឆ័យក្នុងទីទាំងពួង ដោយនយមុខនេះ ដោយប្រការដូច្នេះ ។*

**អដ្ឋកថាធម្មយមកៈ ចប់**

# ក្បាលទី ៧៤

# អភិធម្មបិដក បាលីប្រែ~៨៩

## សន្លឹកចង្អុលប្រាប់មាតិកា


| មាតិកា | | លេខទំព័រ |
|---|---|---|
| អភិធម្មបិដក អនុសយវារៈ | ...... ...... ...... ...... ...... | ២ |
| អភិធម្មបិដក សានុសយវារៈ | ...... ...... ...... ...... ...... | ៨២ |
| អភិធម្មបិដក បជហនវារៈ | ...... ...... ...... ...... ...... | ១៦៨ |
| អដ្ឋកថាអនុសយយមកៈ | ...... ...... ...... ...... ...... | ២៣៨ |
| អដ្ឋកថាបរិច្ឆេទបរិច្ឆិន្នុទ្ទេសវារៈ | ...... ...... ...... ...... ...... | ២៣៨ |
| អដ្ឋកថាឧប្បត្តិដ្ឋានវារៈ | ...... ...... ...... ...... ...... | ២៤៦ |

### មហាវារៈ ៧

| | | |
|---|---|---|
| អដ្ឋកថាអនុសយវារៈ | ...... ...... ...... ...... ...... | ២៥៦ |
| អដ្ឋកថាសានុសយវារៈ | ...... ...... ...... ...... ...... | ២៦០ |
| អដ្ឋកថាបជហនវារៈ | ...... ...... ...... ...... ...... | ២៦២ |


# បាលីប្រែ~៩០

### យមកៈ ចតុត្ថភាគ


| | | |
|---|---|---|
| អភិធម្មបិដក បរិញ្ញាវារៈ | ...... ...... ...... ...... ...... | ២៦៥ |
| អភិធម្មបិដក បហីនវារៈ | ...... ...... ...... ...... ...... | ៣៤២ |
| អភិធម្មបិដក ឧប្បជ្ជនវារៈ | ...... ...... ...... ...... ...... | ៤០៦ |
| អភិធម្មបិដក ធាតុវារៈ | ...... ...... ...... ...... ...... | ៤០៧ |
| អដ្ឋកថាបរិញ្ញាវារៈ | ...... ...... ...... ...... ...... | ៤៣៤ |
| អដ្ឋកថាបហីនវារៈ | ...... ...... ...... ...... ...... | ៤៣៤ |

អដ្ឋកថាឧប្បជ្ជនវារៈ ...... ...... ...... ...... ...... ៤៣៧

អដ្ឋកថាធាតុវារៈ ...... ...... ...... ...... ...... ៤៣៨

# បាលីប្រែ ~៩១

## យមកៈ បញ្ចមភាគ

### ចិត្តយមកៈ

អភិធម្មបិដក បុគ្គលវារុទ្ទេស ...... ...... ...... ...... ...... ៤៤២

អភិធម្មបិដក ធម្មវារុទ្ទេស ...... ...... ...... ...... ...... ៤៤៨

អភិធម្មបិដក បុគ្គលធម្មវារុទ្ទេស ...... ...... ...... ...... ...... ៤៥៣

អភិធម្មបិដក មិស្សកវារុទ្ទេស ...... ...... ...... ...... ...... ៤៦០

អភិធម្មបិដក បុគ្គលវារនិទ្ទេស ...... ...... ...... ...... ...... ៤៦២

អភិធម្មបិដក ធម្មវារនិទ្ទេស ...... ...... ...... ...... ...... ៤៧៤

អភិធម្មបិដក បុគ្គលធម្មវារនិទ្ទេស ...... ...... ...... ...... ...... ៤៨៣

អភិធម្មបិដក មិស្សកវារនិទ្ទេស ...... ...... ...... ...... ...... ៤៨៨

អដ្ឋកថាចិត្តយមកៈ ឧទ្ទេសវារៈ ...... ...... ...... ...... ...... ៤៩០

អដ្ឋកថានិទ្ទេស បុគ្គលវារៈ ...... ...... ...... ...... ...... ៤៩៤

### ធម្មយមកៈ

អភិធម្មបិដក បណ្ណត្តិវារៈ ឧទ្ទេសវារៈ ...... ...... ...... ...... ...... ៤៩៩

អភិធម្មបិដក និទ្ទេសវារៈ ...... ...... ...... ...... ...... ៥០១

អភិធម្មបិដក បវត្តិវារៈ ...... ...... ...... ...... ...... ៥០៧

អភិធម្មបិដក ភាវនាវារៈ ...... ...... ...... ...... ...... ៦២១

អដ្ឋកថាធម្មយមកៈ ...... ...... ...... ...... ...... ៦២២

អដ្ឋកថាបណ្ណត្តិឧទ្ទេសវារៈ ...... ...... ...... ...... ...... ៦២២

អដ្ឋកថាបណ្ណត្តិនិទ្ទេសវារៈ ...... ...... ...... ...... ...... ៦២៣

អដ្ឋកថាបវត្តិវារៈ ...... ...... ...... ...... ...... ៦២៣